Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា




## ការងើបឡើងវិញជាមធ្យមនៃសេដ្ឋកិច្ច

## អត្ថបទផ្តោតពិសេស៖
## ការសម្របទៅនឹងជំងឺកូវីដ 19 នៅក្នុងពិភពមិនប្រាកដប្រជា

ខែ វិច្ឆិកា ឆ្នាំ 2020

ក្រុមធនាគារពិភពលោក


FOR SALE

# បច្ចុប្បន្នភាព សេដ្ឋកិច្ច កម្ពុជា

ខែ វិច្ឆិកា ឆ្នាំ 2020

## ការងើបឡើងវិញ ជាមធ្យមនៃសេដ្ឋកិច្ច

ក្រុមធនាគារពិភពលោក

# មាតិកា


**សេចក្តីថ្លែងអំណរគុណ ........ 7**

**អក្សរកាត់ ........ 8**

**សេចក្តីសង្ខេប ........ 9**

**ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ ........ 14**

**ការអភិវឌ្ឍថ្មីៗ ........ 14**

សកម្មភាពសេដ្ឋកិច្ចបានងើបឡើងបន្តិច បន្ទាប់ពីទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺរាតត្បាត ........ 14

ការបន្តធ្លាក់ចុះនៃឧស្សាហកម្មផលិតទំនិញនាំចេញរបស់កម្ពុជា ........ 17

ឧស្សាហកម្មផលិតទំនិញនាំចេញទៅកាន់សហរដ្ឋអាមេរិក បានកើនឡើងទោះបីជាមានជំងឺរាតត្បាតកូវីដ 19 ........ 17

ការនាំចេញកង់ និងគ្រឿងបន្លាស់អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត បានកើនឡើង ........ 18

ចំនួនភ្ញៀវទេសចរអន្តរជាតិថយចុះយ៉ាងខ្លាំង ........ 18

ភ្ញៀវទេសចរក្នុងស្រុកជួយទ្រទ្រង់ការងើបឡើងវិញជាបណ្តើរៗនៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ ........ 19

ប្រជាពលរដ្ឋកម្ពុជាសន្សំប្រាក់រាប់ពាន់លានដុល្លារពីការធ្វើដំណើរទៅក្រៅប្រទេស ដោយសារតែការរឹតត្បិតការធ្វើដំណើរ ........ 19

ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើង និងងាកទៅគម្រោងកម្មន្តសាលក្រៅពីសម្លៀកបំពាក់ ........ 20

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) តែម្យ៉ាង មិនអាចជំរុញកំណើនពាណិជ្ជកម្មទាំងស្រុងបានឡើយ ........ 21

វិស័យសំណង់នៅតែថយចុះ ដោយសារការផ្គត់ផ្គង់លើសក្នុងពេលមានកំណើនខ្ពស់ពីមុនពេលមានវិបត្តិ ........ 22

មានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើវិស័យកសិកម្ម ដែលរងផលប៉ះពាល់តិចតួចបំផុតដោយសារជំងឺរាតត្បាត ........ 22

ការនាំចេញស្រូវ/អង្ករកើនឡើងយ៉ាងឆាប់រហ័ស ដោយសារកើនឡើងតម្រូវការ ........ 22

ផលិតកម្មស្រូវកើនឡើង ........ 24

ជំងឺកូវីដ 19 ប៉ះពាល់យ៉ាងខ្លាំងលើតម្រូវការក្នុងស្រុក និងកាត់បន្ថយការប្រើប្រាស់ ........ 24

ទុនបម្រុងជារូបិយប័ណ្ណបរទេសបានបន្តកើនឡើង ........ 24

អតិផរណានៅតែមានកម្រិតទាប ដោយសារអត្រាអតិផរណាទាបក្នុងចំណោមដៃគូនាំចូល និងស្ថិរភាពអត្រាប្តូរប្រាក់ ........ 25

ភាពក្រីក្រត្រូវបានប៉ាន់ស្មានថានឹងកើនឡើង ........ 26

ធនាគារកណ្តាលបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុ ........ 26

កំណើនរូបិយវត្ថុទូលាយថយចុះ ដោយសារការថយចុះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ........ 27

កំណើនប្រាក់បញ្ញើ និងឥណទានថយចុះ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ច ........ 27

ការផ្តល់ឥណទានក្នុងស្រុកដល់សកម្មភាពសាងសង់ថយចុះ ប៉ុន្តែការផ្តល់ឥណទានដល់សកម្មភាពកសិកម្មកើនឡើង ........ 27

រដ្ឋាភិបាលបានចាត់វិធានការឆ្លើយតបដែលមិនធ្លាប់មានទៅនឹងជំងឺកូវីដ 19 ........ 32

ឱនភាពសារពើពន្ធត្រូវបានព្យាករណ៍ថាកើនដល់ 5.6 ភាគរយ នៃ ផសស ក្នុងឆ្នាំ 2020 ........ 33

ការទ្រទ្រង់សារពើពន្ធនៅកម្ពុជាមានលំដាប់ខ្ពស់ទី 4 ក្នុងតំបន់ ........ 33

បំណុលសាធារណៈត្រូវបានរំពឹងថានឹងកើនឡើង ប៉ុន្តែហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប ........ 34

កំណើនបំណុលសាធារណៈរបស់កម្ពុជាថយចុះ ប៉ុន្តែបំណុលវិស័យឯកជនកើនឡើង ........ 35

**ទស្សនវិស័យ ........ 36**

**ហានិភ័យ និងបញ្ហាប្រឈម ........ 37**

**ជម្រើសគោលនយោបាយ ........ 38**

**អត្ថបទផ្តោតពិសេស ៖ ការសម្របទៅនឹងវិបត្តិជំងឺកូវីដ 19 នៅក្នុងពិភព មិនប្រាកដប្រជា ........ 42**

**1. សេចក្តីផ្តើម ........ 42**

**2. ក្រុមហ៊ុនកំពុងចាប់ផ្តើមបើកទ្វារឡើងវិញ ប៉ុន្តែការលក់នៅតែរងការប៉ះពាល់ ........ 42**

**3. ក្រុមហ៊ុននៅតែប្រឈមនឹងហានិភ័យលើប្រតិបត្តិការ ជាពិសេសហិរញ្ញប្បទាន ........ 47**

**4. យន្តការរបស់ក្រុមហ៊ុនក្នុងការដោះស្រាយវិបត្តិ ........ 49**

**5. គោលនយោបាយចាំបាច់ដែលក្រុមហ៊ុនបានលើកឡើង ........ 53**

**6. អនុសាសន៍គោលនយោបាយ ........ 56**

លទ្ធភាពទទួលបានហិរញ្ញវត្ថុ ........ 57

ការបញ្ចូលសាច់ប្រាក់ និងការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ........ 57

ការគាំទ្រក្រុមហ៊ុនខ្នាតមីក្រូ ........ 59

ភាពក្ស័យធន អសោធនភាព និងបរិយាកាសអាជីវកម្ម ........ 59

**ឯកសារយោង ........ 60**

**ឧបសម្ព័ន្ធ ........ 60**

**ឧបសម្ព័ន្ធ ៖ សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា ........ 61**

**គន្ថនិទ្ទេស ........ 62**

# ប្រអប់

ប្រអប់ 1 ៖ ការអភិវឌ្ឍសេដ្ឋកិច្ច ទស្សនៈវិស័យ និងហានិភ័យនៅកម្រិតសកល និងតំបន់ ..... 15
ប្រអប់ 2 ៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ..... 23
ប្រអប់ 3 ៖ ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ផ្អែកតាមលទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ ..... 28
ប្រអប់ S1៖ ការអង្កេតលើដំណើរការអាជីវកម្មរបស់ធនាគារពិភពលោក សម្រាប់ប្រទេសកម្ពុជា និងសកលលោក ..... 43
ប្រអប់ S2៖ សារៈសំខាន់នៃសហគ្រាសគ្រួសារក្រៅពីកសិកម្មនៅកម្ពុជា ..... 51
ប្រអប់ S3៖ កិច្ចការពារសង្គម/គោលនយោបាយសម្រាប់សហគ្រាសគ្រួសារក្រៅពីកសិកម្ម ..... 58

# រូប

រូប ES.1៖ ទិដ្ឋភាពរួមស្ដីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា ..... 12
រូប 1 ៖ សន្ទស្សន៍ស្ដីពីនិន្នាការចល័តភាព Apple របស់កម្ពុជា ..... 14
រូប 2 ៖ និន្នាការស្ដីពីចល័តភាព Google របស់កម្ពុជា ..... 14
រូប B1.1៖ ទិន្នន័យស្ដីពីកំណើន ផសស ចុងក្រោយនៅតាម បណ្ដាប្រទេសមួយចំនួន ..... 15
រូប B1.2៖ សន្ទស្សន៍រងនៃការបញ្ជាទិញថ្មីៗក្នុងការនាំចេញនៃសន្ទស្សន៍ស្ដីពីអ្នកគ្រប់គ្រងការបញ្ជាទិញ (PMI) ..... 15
រូប B1.3៖ កំណើនសកល ..... 16
រូប B1.4៖ កម្រិតផលសេដ្ឋកិច្ចធៀបនឹងការព្យាករនៅខែ មករា ឆ្នាំ 2020 ..... 16
រូប 3 ៖ ការរួមចំណែកតាមវិស័យដល់កំណើនពិត ..... 17
រូប 4 ៖ ឧស្សាហកម្មផលិតទំនិញនាំចេញ ..... 17
រូប 5 ៖ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ និងកង់របស់កម្ពុជា ..... 18
រូប 6 ៖ ទីផ្សារនាំចេញធំៗរបស់កម្ពុជា ..... 18
រូប 7 ៖ ចំនួនភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសកម្ពុជា ..... 19
រូប 8 ៖ ចំនួនភ្ញៀវទេសចរទៅកាន់ប្រទេសកម្ពុជា ថៃ និងវៀតណាម ..... 19
រូប 9 ៖ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត តាមវិស័យសំខាន់ៗ ..... 20
រូប 10៖ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តតាមវិស័យ ..... 20
រូប 11៖ ការនាំចេញសម្ភារសាងសង់សំខាន់ៗ ..... 21
រូប 12៖ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានអនុម័ត ..... 21
រូប 13៖ តម្លៃបន្ថែមកសិកម្មសរុបណ្ឌមីណល ..... 22
រូប 14៖ ការនាំចេញអង្ករ ការប្រៀបធៀបក្នុងតំបន់ ..... 22
រូប 15៖ ទុនបម្រុងអន្តរជាតិរបស់កម្ពុជា ..... 25
រូប 16៖ ទុនបម្រុងអន្តរជាតិ-ការប្រៀបធៀបក្នុងតំបន់ ..... 25
រូប 17៖ អតិផរណាមានអត្រាថេរ ..... 26
រូប 18៖ អត្រាប្តូរប្រាក់ណ្ឌមីណល នៅតែមានស្ថិរភាព ..... 26
រូប 19៖ កំណើនរូបិយវត្ថុទូលាយថយចុះ ..... 27
រូប 20៖ កត្តារួមចំណែកដល់កំណើនឥណទានក្នុងស្រុក ..... 27
រូប B3.1៖ អ្នកឆ្លើយតបដែលធ្វើការក្នុងរយៈពេល 7 ថ្ងៃចុងក្រោយ ..... 28
រូប B3.2៖ គ្រួសារធ្វើអាជីវកម្មមិនមែនកសិកម្ម ដែលលើកឡើងពីការប្រែប្រួលប្រាក់ចំណូលក្នុងការលក់ ..... 28
រូប B3.3៖ គ្រួសារជនទេសន្តរប្រវេសន៍ដែលលើកឡើងពីការប្រែប្រួលប្រាក់ចំណូលតាំងពីពាក់កណ្ដាលខែ មីនា ..... 29
រូប B3.4៖ គ្រួសារជនទេសន្តរប្រវេសន៍ដែលលើកឡើងពីការប្រែប្រួលប្រាក់បញ្ញើតាំងពីពាក់កណ្ដាលខែ មីនា ..... 29
រូប B3.5៖ ការប្រែប្រួលប្រាក់ចំណូលគ្រួសារនៅអំឡុងខែ ឧសភា-សីហា ឆ្នាំ 2020 ..... 30
រូប B3.6៖ គ្រួសារដែលអាចទិញថ្នាំព្យាបាលក្នុងរយៈពេល 7 ថ្ងៃចុងក្រោយ ..... 30

រូប 21៖ ប្រាក់រៀលដែលកំពុងចរាចរណ៍ និងអត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក ....... 31
រូប 22៖ ប្រាក់សន្សំរបស់រដ្ឋាភិបាល ....... 31
រូប 23៖ ចំណូលរបស់រដ្ឋាភិបាល ....... 32
រូប 24៖ ចំណាយរបស់រដ្ឋាភិបាល ....... 32
រូប 25៖ ប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល ....... 33
រូប 26៖ អតិរេក/ឱនភាពរបស់រដ្ឋាភិបាល និងហិរញ្ញប្បទាន ....... 33
រូប 27៖ ការទ្រទ្រង់សារពើពន្ធ-ការប្រៀបធៀបក្នុងតំបន់ ....... 34
រូប 28៖ បំណុលរដ្ឋាភិបាល កើនឡើង ....... 34
រូប 29៖ ការរួមចំណែកដល់កំណើនបំណុលរបស់កម្ពុជា ....... 35
រូប 30៖ ប្រទេសមួយចំនួនជំពាក់បំណុលច្រើន ប៉ុន្តែភាគច្រើនជាបំណុលក្នុងស្រុក និងឯកជន ....... 35
រូប S1៖ ទោះបីជាមានភាពប្រសើរឡើងនៃការបើកអាជីវកម្មឡើងវិញក្តី ក៏ការលក់នៅតែទទួលរងការប៉ះពាល់យ៉ាងខ្លាំង ....... 44
រូប S2៖ ស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុនមានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយការកើនការលក់ឡើងវិញនៅកម្ពុជាមាន ល្បឿនលឿនជាងនៅតំបន់អាស៊ីបូព៌ា....... 45
រូប S3៖ ការរំពឹងទុកពីភាពប្រសើរឡើងក្នុងរយៈពេល 6 ខែបន្ទាប់ ប៉ុន្តែការលក់ជាមធ្យមនៅតែថយចុះ (អវិជ្ជមាន) ....... 45
រូប S4៖ ផលប៉ះពាល់ខ្លាំងលើការលក់របស់ក្រុមហ៊ុនខ្នាតមីក្រូ តូច មធ្យម និងធំ....... 45
រូប S5៖ ការងើបឡើងវិញហាក់មានភាពដូចគ្នាក្នុងចំណោមក្រុមហ៊ុនគ្រប់ទំហំ និងគ្រប់វិស័យនៅកម្ពុជា ជាងការងើបឡើង នៅប្រទេសវៀតណាម....... 46
រូប S6៖ ខេត្តសៀមរាបដែលពឹងផ្អែកលើវិស័យទេសចរណ៍ ទទួលរងផលប៉ះពាល់ខ្លាំងជាងបណ្តាខេត្តផ្សេងទៀត ....... 47
រូប S7៖ សម្ពាធកាន់តែខ្លាំងលើលំហូរសាច់ប្រាក់ ....... 47
រូប S8៖ ការបន្តពឹងផ្អែកលើគ្រួសារ និងមិត្តភក្តិជាយន្តការដ៏សំខាន់ក្នុងការសម្រួលដល់កង្វះលំហូរសាច់ប្រាក់ ....... 48
រូប S9៖ ក្រុមហ៊ុនដែលមានការលក់ធ្លាក់ចុះខ្លាំង ច្រើនតែប្រើប្រាស់ហិរញ្ញប្បទានដើម្បីសម្រួលដល់កង្វះលំហូរសាច់ប្រាក់....... 48
រូប S10៖ លទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទាននិងហានិភ័យនៃការជំពាក់បំណុលច្រើនថយចុះទៅតាមទំហំក្រុមហ៊ុន ....... 49
រូប S11៖ ក្រុមហ៊ុននៅកម្ពុជាបានរំសាយបុគ្គលិកយ៉ាងច្រើន....... 49
រូប S12៖ ក្រុមហ៊ុនខ្នាតធំច្រើនតែកែសម្រួលការងារដោយបង្ខំល្បឿនលឿនជាងនៅតំបន់អាស៊ីបូព៌ា ....... 50
រូប S13៖ ភាពខុសគ្នានៃការកែសម្រួលការងារដោយក្រុមហ៊ុនក្នុងតំបន់អាស៊ីបូព៌ា ....... 50
រូប S14៖ ក្រុមហ៊ុនជិតពាក់កណ្តាលបង្កើនការប្រើប្រាស់បណ្តាញឌីជីថល គិតត្រឹមខែ កញ្ញា....... 52
រូប S15៖ ការប្រើប្រាស់បណ្តាញឌីជីថលក្នុងការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ 19 នៅតំបន់អាស៊ីបូព៌ា ....... 53
រូប S16៖ ការពន្យារពេលបង់ពន្ធត្រូវបានលើកឡើងជាជម្រើសគោលនយោបាយចាំបាច់បំផុតនៅខែ កញ្ញា ....... 54
រូប S17៖ ភាពមិនស៊ីសង្វាក់គ្នារវាងតម្រូវការគោលនយោបាយ និងលទ្ធភាពទទួលបាន....... 54
រូប S18៖ ក្រុមហ៊ុនខ្នាតធំច្រើនតែបានដឹង និងដាក់ពាក្យស្នើសុំវិធានការគោលនយោបាយគាំទ្រ....... 55
រូប A.S1៖ និន្នាការចល័តភាព Google ក្នុងខេត្តសៀមរាប មិនមានភាពប្រសើរឡើងវិញទេ ធៀបនឹងចល័តភាពទូទាំងប្រទេសកម្ពុជា....60

# តារាង

តារាង B2.1៖ ជំពូក1-10 នៃកាលវិភាគពន្ធគយរបស់កម្ពុជា....... 23
តារាង B2.2៖ ផលិតផលនាំចេញសំខាន់ៗទាំង 7 របស់កម្ពុជា (HS4) ទៅកាន់ប្រទេសចិន និងផលិតផលនាំចូលពីប្រទេសចិន....... 23
តារាង 1 ៖ ទស្សនវិស័យម៉ាក្រូ....... 36
តារាង S1៖ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅកម្ពុជាធៀបនឹងបណ្តាក្រុមហ៊ុនក្នុងតំបន់អាស៊ីបូព៌ា....... 48
តារាង S2៖ ចំនួនក្រុមហ៊ុននៅកម្ពុជា ដែលបានដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីជំនួយរដ្ឋាភិបាល បានថយចុះ ....... 55
តារាង A.S1៖របាយសំណាក ....... 60

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) ខែវិច្ឆិកា ឆ្នាំ 2020 ត្រូវបានរៀបចំឡើងដោយលោក លី សូដេត ដោយមានការរួមចំណែកពីលោកស្រី Claire Honore Hollweg លោកស្រី Sarah Hebous លោក Philippe de Meneval លោក Trang Thu Tran លោកស្រី Wendy Cunningham លោក Maheshwor Shrestha លោក Wendy Karamba លោក តុង គឹមស៊ុន និងលោកស្រី Ekaterine Vashakmadze។ លោកស្រី គី លីនណា និង លោកស្រី ហៀវ ចាន់កេសី គឺជាជំនួយការផ្នែកស្រាវជ្រាវ។ លោក ប៊ូ សារឿន បានជួយលើការងារផ្សព្វផ្សាយតាមសារព័ត៌មាន ការបង្ហាញតាមគេហទំព័រ និងពិធីផ្សព្វផ្សាយរបាយការណ៍នេះ។

ក្រុមការងារបានបំពេញកិច្ចការក្រោមការណែនាំរបស់ លោក Deepak Mishra។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងយោបល់របស់លោកស្រី Inguna Dobraja លោកស្រី Mariam Sherman និង លោក Hassan Zaman។ សហសេវិករបស់ធនាគារពិភពលោកមួយចំនួន គឺ លោក Aaditya Mattoo លោក Ergys Islamaj លោកស្រី Ekaterine Vashakmadze លោក Vera Kehayova និងលោក Duong Le បានផ្តល់យោបល់លើសេចក្តីព្រាងនៃរបាយការណ៍នេះ។

ក្រុមការងារសូមអរគុណចំពោះអាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហការ និងការគាំទ្រកន្លងមក។ របាយការណ៍នេះក៏ទទួលបានផលប្រយោជន៍ពីដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

ក្រុមធនាគារពិភពលោក សូមថ្លែងអំណរគុណចំពោះហិរញ្ញប្បទានពីកម្មវិធីពហុម្ចាស់ជំនួយនៃមូលនិធិពាណិជ្ជកម្ម សម្រាប់ការរៀបចំផ្នែកស្តីពីអត្ថបទផ្តោតពិសេសនៃរបាយការណ៍នេះ។

របាយការណ៍នេះ ត្រូវបានរៀបចំឡើងចំនួនពីរដងក្នុងមួយឆ្នាំ និងផ្តល់បច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើង គឺ www.worldbank.org/cambodia ។

ដើម្បីស្ថិតនៅក្នុងបញ្ជីស្ថាប័នដែលទទួលបានរបាយការណ៍នេះតាមអ៊ីមែល និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធផ្សេងទៀត សូមទាក់ទងមកលោកស្រី ហៀវ ចាន់កេសី (cheav@worldbank.org)។ បើមានសំណួរពីខ្លឹមសាររបាយការណ៍នេះ សូមទាក់ទងមកលោក ប៊ូ សារឿន (sbou@worldbank.org) ។

របកគំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋានដែលមានក្នុងរបាយការណ៍នេះ មិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។ ធនាគារពិភពលោកមិនធានាទៅលើភាពត្រឹមត្រូវនៃទិន្នន័យដែលមានក្នុងឯកសារនេះទេ។ ព្រំដែនពណ៌ ការកំណត់ឈ្មោះ និងព័ត៌មានផ្សេងទៀតដែលមានបង្ហាញលើផែនទីណាមួយក្នុងឯកសារនេះ មិនបង្ហាញពីការវិនិច្ឆ័យណាមួយរបស់ធនាគារពិភពលោកពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ដែនដីណាមួយ ឬការយល់ស្រប ឬការទទួលយកព្រំដែនទាំងនោះឡើយ។

# អក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CCFTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **CGT** | ពន្ធលើចំណេញមូលធន |
| **COVID-19** | ជំងឺកូវីដ 19 |
| **CR** | ប្រាក់រៀលខ្មែរ |
| **EAP** | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EC** | គណៈកម្មការអឺរ៉ុប |
| **EMDEs** | ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ |
| **EU** | សហភាពអឺរ៉ុប |
| **FDI** | ការវិនិយោគផ្ទាល់ពីបរទេស |
| **FTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| **GDCE** | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| **GDP** | ផលិតផលក្នុងស្រុកសរុប (ផសស) |
| **GDT** | អគ្គនាយកដ្ឋានពន្ធដារ |
| **GMAC** | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| **GVA** | តម្លៃបន្ថែមសរុប |
| **IMF** | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **LPCO** | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| **NAFTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង |
| **PMI** | សន្ទស្សន៍ស្តីពីការទិញរបស់អ្នកគ្រប់គ្រង |
| **UK** | ចក្រភពអង់គ្លេស |
| **U.S.** | សហរដ្ឋអាមេរិក |
| **US$** | ដុល្លារអាមេរិក |
| **YTD** | ឆ្នាំនេះ |
| **y/y** | ធៀបនឹងឆ្នាំមុន |

# សេចក្តីសង្ខេប

## ការអភិវឌ្ឍថ្មីៗ

**ការរាតត្បាតជំងឺកូវីដ 19 បានបង្កការរាំងស្ទះយ៉ាងលឿនដល់ដំណើរកំណើនរបស់កម្ពុជាដែលទទួលបាននូវការសាទរ។** កម្ពុជាមានអត្រាកំណើនពិតជាមធ្យម 7.7 ភាគរយក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ ផ្ទុយទៅវិញ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ 2020 អាចថយចុះ 2 ភាគរយ ដែលធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានវិបត្តិលើកដំបូងក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ។ ម៉ាស៊ីនកំណើនសំខាន់ៗ គឺ សំណង់ ទេសចរណ៍ និងការនាំចេញទំនិញ ដែលសរុបមានចំនួនជាង 70 ភាគរយនៃកំណើន និង 39 ភាគរយនៃការងារដែលទទួលបានប្រាក់កម្រៃសរុប បានទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

**ជំងឺកូវីដ 19 បានបង្អាក់កំណើននៃវិស័យសំណង់ និងអចលនទ្រព្យ ដែលពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគពីបរទេស។** ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 ការនាំចូលដែកថែបបានថយចុះ 41.4 ភាគរយ ចំណែកការនាំចូលស៊ីម៉ង់ត៍បានថយចុះ 38.1 ភាគរយ (ធៀបនឹងឆ្នាំមុន) ព្រោះថាគម្រោងអភិវឌ្ឍន៍ធំៗជាច្រើនត្រូវបានផ្អាកដំណើរការ។ សរុបទំនិញកម្មន្តសាលនាំចេញសំខាន់ៗរបស់កម្ពុជា ដែលរួមមានសម្លៀកបំពាក់ ទំនិញធ្វើដំណើរ ស្បែកជើង កង់ គ្រឿងបន្លាស់អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំ បានថយចុះ 2.5 ភាគរយ ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020។ ការរឹតត្បិតលើការធ្វើដំណើរ និងការបង្ខាំងមិនឱ្យចេញចូល បានធ្វើឱ្យវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅកម្ពុជាដួលរលំ ដោយចំនួនភ្ញៀវទេសចរអន្តរជាតិបានថយចុះ 74.1 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020។

**អតិផរណានៅតែមានកម្រិតទាប ដោយសារអត្រាអតិផរណាទាបក្នុងចំណោមដៃគូនាំចូល និងស្ថិរភាពអត្រាប្តូរប្រាក់។** អត្រាអតិផរណាគោល គឺ 2.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែកញ្ញា ឆ្នាំ 2020 ថយពី 3.1 ភាគរយនៅបំណាច់ឆ្នាំ 2019។ អត្រាប្តូរប្រាក់រៀលនិងដុល្លារអាមេរិក នៅតែមានអត្រាថេរជារួម គឺ 4,100 រៀល/ដុល្លារ នៅខែ កញ្ញា ឆ្នាំ ២០២០ ធៀបនឹងអត្រា 4,075 រៀល/ដុល្លារ នៅខែ ធ្នូ ឆ្នាំ 2019។

**ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងកើនឡើង ប៉ុន្តែទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។** ការនាំចូលបានថយចុះបន្តិច ដោយសារតែការថយចុះនូវតម្រូវការក្នុងស្រុក និងការផ្អាកកំណើនវិស័យសំណង់។ ទំនិញជាប់ធន់សំខាន់ៗដែលកម្ពុជានាំចូល យានយន្តធ្វើដំណើរបានថយចុះ 34.1 ភាគរយ ហើយម៉ូតូថយចុះ 39.5 ភាគរយ ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020។ ប្រាក់បញ្ញើរបស់កម្មករបានថយចុះ 4.6 ភាគរយ (ស្មើនឹង 550 លានដុល្លារ) ក្នុងរយៈពេល 6 ខែដំបូងក្នុងឆ្នាំ 2020។ ឱនភាពគណនីចរន្តត្រូវបានព្យាករណ៍ថានឹងកើនដល់ 12.8 ភាគរយនៃ ផសស នៅឆ្នាំ 2020 កើនពី 10 ភាគរយនៃ ផសស នៅឆ្នាំ 2019 បានដោយសារតែកំណើនឱនភាពពាណិជ្ជកម្ម។ គណនីចរន្តត្រូវបានរំពឹងថាទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។ ស្ថានភាពទុនបម្រុងអន្តរជាតិសរុប នៅតែរឹងមាំដោយកើនឡើងដល់ 19.5 ពាន់ដុល្លារ (ស្មើនឹងការនាំចូល រយៈពេល 10 ខែ) ក្នុងខែ មិថុនា ឆ្នាំ 2020 កើនឡើងពី 18.7 ពាន់លានដុល្លារនៅបំណាច់ឆ្នាំ 2019។

**កំណើនរូបិយវត្ថុទូលាយបានថយចុះ សំខាន់ដោយសារតែការថយល្បឿននៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** សេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្លាំង ដោយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានជាង 70 ភាគរយនៃរូបិយវត្ថុទូលាយ។ រូបិយវត្ថុទូលាយមានកំណើន 12.3 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពីកំណើន 18.2 ភាគរយនៅឆ្នាំ 2019។ កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានថយល្បឿន ដែលបង្ហាញពីការថមថយល្បឿននៃលំហូរមូលធន។ ទោះជាយ៉ាងណាក៏ដោយកំណើនរូបិយវត្ថុនៅខាងក្រៅធនាគារ នៅតែមានភាពរឹងមាំ ដោយកើន 28.0 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពីកំណើន 32.1 ភាគរយនៅឆ្នាំ 2019 ដោយសារតែធនាគារកណ្តាលបន្តជំរុញការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ កំណើនប្រាក់បញ្ញើក្នុងវិស័យឯកជនបានថយចុះ 10.7 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពីកំណើន 16.4 ភាគរយនៅខែ ធ្នូ ឆ្នាំ 2019 ដែលអាចបង្ហាញពីការថយចុះនៃសកម្មភាពសេដ្ឋកិច្ចដែលមានឥទ្ធិពលមិនល្អលើសន្ទនីយភាពនៃវិស័យសាជីវកម្ម (និងគ្រួសារ) ដែលប៉ះពាល់ដល់លទ្ធភាពសន្សំប្រាក់។ ទោះបីជាធនាគារកណ្តាលបានបន្ធូរបន្ថយ គោលនយោបាយរូបិយវត្ថុក្តី ប៉ុន្តែ កំណើននៃការផ្តល់ឥណទានជាប្រាក់បញ្ញើដល់វិស័យឯកជន បានថយចុះមក 18.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពី 27.0 ភាគរយនៅឆ្នាំ 2019 ដោយសារតែតម្រូវការឥណទានបានថយចុះ។

**ការអង្កេតគ្រួសារតាមទូរស័ព្ទបានបញ្ជាក់ពីផលប៉ះពាល់មិនល្អនៃជំងឺកូវីដ 19 លើការងារ។** ចំនួនអ្នកឆ្លើយតបដែលកំពុងធ្វើការ បានថយចុះពី 82 ភាគរយនៅអំឡុងពេលមុនផ្ទុះជំងឺកូវីដ 19 មកត្រឹម 71 ភាគរយនៅខែ ឧសភា ឆ្នាំ 2020 ប៉ុន្តែចំនួននេះនៅថេររហូតដល់ខែ សីហា ឆ្នាំ 2020។ ជំងឺកូវីដ 19 នៅតែបន្តប៉ះពាល់ជាអវិជ្ជមានលើសកម្មភាពអាជីវកម្មក្រៅពីផ្នែកកសិកម្ម ប៉ុន្តែការប៉ះពាល់នេះ មិនសូវធ្ងន់ធ្ងរដូចពេលផ្ទុះជំងឺនេះដំបូងឡើយ។ យ៉ាងណាក៏ដោយ ការបាត់បង់ប្រាក់ចំណូលនៅ

តែកើតមានច្រើន ទោះបីជាការថយចុះប្រាក់ចំណូលគ្រួសារត្រូវបានកាត់បន្ថយ ក្រោយពេលអនុវត្តន៍កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដើម្បីជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ។

**ការគាំទ្ររបស់រដ្ឋាភិបាលទៅដល់ប្រជាពលរដ្ឋដែលរងការប៉ះពាល់មានច្រើនដែលមិនធ្លាប់មានកន្លងមក ដោយមានចំនួនរហូតដល់ 5 ភាគរយនៃ ផសស។** កញ្ចប់គាំទ្រដ៏ធំ រួមមាន ការចំណាយពាក់ព័ន្ធនឹងសុខភាព និងជំនួយដល់ប្រាក់ចំណូល ការផ្តល់ជំនួយសមធម៌ និងការធានាលើប្រាក់កម្ចី ចំណាយលើការអភិវឌ្ឍ និងការបន្ធូរបន្ថយពន្ធ។ កម្មវិធីទ្រទ្រង់សារពើពន្ធដ៏ធំរបស់រដ្ឋាភិបាលត្រូវបានរំពឹងថានឹងប្រែក្លាយអតិរេកថវិកានៅឆ្នាំ 2019 ទៅជាឱនភាពថវិកានៅឆ្នាំ 2020។

**ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020 រដ្ឋាភិបាលប្រមូលចំណូលបាន 14.3 ទ្រីលានរៀល ដែលថយចុះចំនួន 14.2 ភាគរយ ធៀបនឹងឆ្នាំមុន។** ទោះជាយ៉ាងណា ចំណាយរបស់រដ្ឋាភិបាលកើនយ៉ាងលឿនដល់ 16.2 ទ្រីលានរៀល ឬមានកំណើន 21.5 ភាគរយធៀបនឹងឆ្នាំមុន។ ដូច្នេះ ឱនភាពសារពើពន្ធជារួមនៅឆ្នាំ2020ត្រូវបានព្យាករណ៍ថានឹងមានចំនួនខ្ពស់បំផុត 6.2 ទ្រីលានរៀល។ ចំនួននេះបង្ហាញពីឱនភាពសារពើពន្ធរួមចំនួន 5.6 ភាគរយនៃ ផសស ពីអតិរេកសារពើពន្ធ 0.8 ភាគរយនៃ ផសស នៅឆ្នាំ 2019។ ឱនភាពសារពើពន្ធប្រមាណពាក់កណ្តាលត្រូវបានរំពឹងថាទទួលបានហិរញ្ញប្បទានពីប្រាក់សន្សំរបស់រដ្ឋាភិបាល ដែលមានចំនួន 20.2 ភាគរយនៃ ផសស នៅបំណាច់ឆ្នាំ 2019 ចំណែកឱនភាពសារពើពន្ធពាក់កណ្តាលទៀតត្រូវបានរំពឹងថាទទួលបានហិរញ្ញប្បទានពីកម្ចីជាផ្លូវការ។ ការពង្រីកជំនួយសង្គមយ៉ាងច្រើនដែលមិនធ្លាប់មាន នឹងជួយសម្រាលផលប៉ះពាល់នៃជំងឺកូវីដ 19 លើប្រជាជនក្រីក្រ និងប្រជាជនដែលស្ទើរតែក្រីក្របានយ៉ាងច្រើន បើទោះជាមិនបានទាំងស្រុងក្តី។

## ទស្សនៈវិស័យ

**ដោយមានការបន្ធូរបន្ថយលើការអនុវត្តវិធានការរក្សាគម្លាតសង្គម សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនៅកម្ពុជាកំពុងវិលត្រឡប់ទៅរកភាពប្រក្រតីជាបណ្តើរៗវិញហើយ។** តម្រូវការក្នុងស្រុក រួមទាំង ការធ្វើដំណើរក្នុងស្រុក និងទេសចរណ៍កំពុងងើបឡើងវិញ។ នៅខែ តុលា ឆ្នាំ 2020 កម្ពុជា និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) ដែលរំពឹងថានឹងចូលជាធរមាននៅឆ្នាំ 2021។ លើសពីនេះទៀត ចាប់ពីឆ្នាំ 2021 ទៅ កម្ពុជានឹងទទួលបានប្រយោជន៍ពីសមាជិកភាពជាដៃគូផ្នែកសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់ (RCEP) ដែលជាតំបន់ពាណិជ្ជកម្មសេរីធំជាងគេក្នុងពិភពលោក ដែលត្រូវបានចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ 2020។ បើទោះជាការវិនិយោគផ្ទាល់ពីបរទេសត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំនេះ មានសញ្ញាវិជ្ជមានមួយចំនួនដែលថា លំហូរការវិនិយោគផ្ទាល់ពីបរទេសកំពុងងើបឡើងវិញ និងធ្វើពិពិធកម្មជាងមុន។

**ដោយសារវិបត្តិសេដ្ឋកិច្ចសកលដែលបណ្តាលមកពីជំងឺកូវីដ 19 នៅតែបន្តទៅទៀត សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ 2020 ត្រូវបានព្យាករណ៍ថានឹងថយចុះ 2.0 ភាគរយ** ដែលជាការថយចុះយ៉ាងលឿនមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជាសម័យថ្មីនេះ។ ការដកផ្នែកខ្លះនៃការអនុគ្រោះពន្ធ “អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ” របស់សហភាពអឺរ៉ុប បានចូលជាធរមាននៅថ្ងៃទី 12 ខែ សីហា ឆ្នាំ 2020 បានធ្វើឱ្យប៉ះពាល់ដល់ការនាំចេញរបស់កម្ពុជាចំនួន 20 ភាគរយ ទៅកាន់សហភាពអឺរ៉ុប។ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងងើបឡើងវិញនៅឆ្នាំ 2021 ក្នុងកំណើន 4.0 ភាគរយ។

## ហានិភ័យ និងបញ្ហាប្រឈម

**ទស្សនៈវិស័យកំណើនរបស់កម្ពុជានៅតែមានភាពមិនច្បាស់លាស់ខ្លាំង។** ហានិភ័យ រួមមាន ការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍ ការថយចុះថែមទៀត និងយូរទៅមុខនៃចំនួនភ្ញៀវទេសចរ ដោយសារអត្ថិភាពនៃជំងឺកូវីដ 19 នៅទូទាំងពិភពលោក និងល្បឿននៃការបញ្ចេញវ៉ាក់សាំងជំងឺកូវីដ 19 សម្រាប់ការប្រើប្រាស់យ៉ាងទូលំទូលាយ និងលទ្ធភាពនៃកំណើនភាពតានតឹងផ្នែកពាណិជ្ជកម្មសកល និងគោលនយោបាយគាំពារនិយម។ ក្រៅពីនេះ វិស័យធនាគារ (និងមីក្រូហិរញ្ញវត្ថុ) ដែលមានអ្នកជំពាក់បំណុលច្រើនខ្លាំង ក៏ជាហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជាដែរ។ ដោយសារតែការអន្តរាគមយ៉ាងច្រើនដែលមិនធ្លាប់មានពីមុនមករបស់ រដ្ឋាភិបាល ការពង្រីកជំនួយសង្គមហួសពីក្របខណ្ឌពេលវេលាដែលបានគ្រោងទុក នឹងដាក់សម្ពាធបន្ថែមទៀតលើថវិកា និងកាត់បន្ថយទំហំសារពើពន្ធរបស់កម្ពុជា។

## ជម្រើសគោលនយោបាយ

**គោលដៅគោលនយោបាយសំខាន់បំផុតត្រូវតែជាការស្តារឡើងវិញជាបន្ទាន់នូវការបាត់បង់ ឬការព្យួរការងារដែលបណ្តាលមកពីជំងឺកូវីដ 19។** លើចំណុចនេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកចិត្តទាំងស្រុងលើការជំរុញ ការវិនិយោគលើវិស័យដែលប្រើកម្លាំងពលកម្មច្រើនដើម្បីបង្កើតការងារ។ ការងារនេះអាចធ្វើទៅបានដោយទាញប្រយោជន៍ពីការងើបឡើងវិញយ៉ាងឆាប់រហ័សនៃតម្រូវការទំនិញប្រើប្រាស់ក្នុងប្រទេស ដូចជា អាហារ និងសេវាកម្មក្នុងប្រទេស (ជាពិសេស ការធ្វើដំណើរ បដិសណ្ឋារកិច្ច និងការថែទាំសុខភាព)។ ឧទាហរណ៍ ការធានាការបន្តអត្ថិភាពនៃក្រុមហ៊ុន និងអាជីវកម្ម ដែលអាចរីកចម្រើនក្រោយវិបត្តិជំងឺកូវីដ 19 នឹងជួយដល់កម្មករ ធ្វើឲ្យមានការងើបឡើងយ៉ាងឆាប់រហ័ស និងជំរុញកំណើន។ ទន្ទឹមនឹងនេះ ការជំរុញការវិនិយោគសាធារណៈដែលជួយដល់ប្រជាជនក្រីក្រ និងបង្កើនកំណើន រួមទាំង គម្រោងផ្តល់ការងារដែលមានប្រាក់កម្រៃ នឹងជួយបង្កើតការងារ។ កម្មវិធីវិនិយោគសាធារណៈ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក្នុងក្រុងព្រះសីហនុ និងក្រុងសៀមរាប នឹងបង្កើនការតភ្ជាប់ និងជួយដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ វិធានការទាំងនេះក៏នឹងជួយសម្រួលដល់អាជ្ញាធរកម្ពុជាក្នុងការបង្វែរការ

អន្តរាគមរបស់ពួកគាត់ពីជំនួយសង្គ្រោះបន្ទាន់ និងជំនួយសង្គម ជាទម្រង់ការផ្តល់សាច់ប្រាក់ ទៅការគាំទ្រការប្រកបរបរចិញ្ចឹមជីវិត ដោយផ្តោតសំខាន់លើការរកប្រាក់ចំណូល និងការបង្កើតការងារ។

**តទៅមុខទៀត ជាការសំខាន់ត្រូវសម្រួលដល់ការពង្រីកការវិនិយោគក្នុងស្រុក និងការវិនិយោគពីបរទេស ចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងក្នុងតំបន់នាពេលថ្មីៗនេះ។** ក្នុងគោលបំណងនេះ ជាសំខាន់ រដ្ឋាភិបាលត្រូវអនុវត្តច្បាប់ស្តីពីការវិនិយោគបែបប្រកួតប្រជែង និងរបបលើកទឹកចិត្ត និងការសម្រួលដល់ការធ្វើអាជីវកម្ម។ អត្ថប្រយោជន៍ភ្លាមៗពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន អាចមានប្រភពពីការនាំចេញផលិតផលកសិកម្ម មិនមែនស្រូវ/អង្ករ និងមានតម្លៃខ្ពស់ (វត្ថុធាតុដើម និងវត្ថុធាតុកែច្នៃ) ដូចជា ដំឡូងមី កៅស៊ូ និងសណ្តែកសៀង ព្រោះប្រទេសចិនបានផ្តល់កូតាសម្រាប់ឱ្យកម្ពុជានាំចេញអង្ករ និងស្វាយទៅប្រទេសចិនរួចទៅហើយ។ ដូច្នេះ អាចផ្តល់ការគាំទ្រផ្នែកគោលនយោបាយ បច្ចេកទេស និងហិរញ្ញវត្ថុ ដល់ការពង្រីកផលិតកម្ម និងគុណភាពរបស់ផលិតផលទាំងនេះ។ ក្នុងរយៈពេលមធ្យម ជាការសំខាន់ត្រូវសម្រួលដល់ការធ្វើសមាហរណកម្មសង្វាក់តម្លៃនៃការកែច្នៃផលិតផលកសិកម្ម និងកម្មន្តសាលរបស់កម្ពុជា ទៅក្នុងសង្វាក់តម្លៃតំបន់ ដោយចាប់ផ្តើមដំបូងពីសមាហរណកម្មទៅក្នុងសង្វាក់តម្លៃរបស់ប្រទេសចិន វៀតណាម និងថៃ។ សិង្ហបុរី សាធារណរដ្ឋកូរ៉េ ចិន និងជប៉ុន ដែលជាវិនិយោគិនឈានមុខក្នុងប្រទេសវៀតណាម (និងថៃ) ក៏ជាវិនិយោគិនសំខាន់នៅកម្ពុជាផងដែរ។ ដូច្នេះ ការទាក់ទាញឱ្យវិនិយោគិនទាំងនេះធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសង្វាក់ផលិតកម្មថ្នាក់តំបន់ (និងថ្នាក់សកល) តាមរយៈការបង្កើនការតភ្ជាប់ ការអភិវឌ្ឍកម្លាំងពលកម្មជំនាញ និងការកាត់បន្ថយតំលៃអគ្គិសនី គឺជាជំហានដ៏សំខាន់មួយ។ ដើម្បីសម្រេចបានគោលបំណងនេះ ចាំបាច់ត្រូវសម្រួលការធ្វើពាណិជ្ជកម្ម និងការវិនិយោគបន្ថែមទៀត (ធៀបនឹងចំណាត់ថ្នាក់របស់កម្ពុជាលើភាពប្រកួតប្រជែង និងការធ្វើធុរកិច្ចសកល) ក៏ដូចជា លើកកម្ពស់សហគ្រាសធុនតូច និងមធ្យម (ដែលជាចំនួនភាគច្រើនក្នុងសេដ្ឋកិច្ច និងទីផ្សារការងារនៅកម្ពុជា) តាមរយៈការជ្រៀតចូល និងការពង្រីកអាជីវកម្មផ្នែកនវានុវត្តន៍ និងតម្រង់ និងផ្សារភ្ជាប់អាជីវកម្មទាំងនោះ ទៅនឹងវិស័យវិនិយោគផ្ទាល់ពីបរទេស។

**ជាការសំខាន់ត្រូវបន្តពិនិត្យយ៉ាងហ្មត់ចត់លើភាពងាយរងគ្រោះដែលបណ្តាលមកពីកំណើនរយៈពេលយូរនៃវិស័យសំណង់ និងអចលនទ្រព្យ និងកំណើនឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យនេះ។** ចំណុចនេះជាការសំខាន់កាន់តែខ្លាំង ប្រសិនបើជំងឺកូវីដ 19 នៅតែបន្តទៅមុខទៀត ហើយការបំផ្លិចបំផ្លាញដោយសារគ្រោះទឹកជំនន់ មានភាពធ្ងន់ធ្ងរ។ ព្រឹត្តិការណ៍ទាំងនេះនឹងកាន់តែប៉ះពាល់លទ្ធភាពរបស់អាជីវកម្ម និងគ្រួសារ ក្នុងការសងបំណុល ដែលកាន់តែដាក់សម្ពាធលើវិស័យហិរញ្ញវត្ថុថែមទៀត។ បើទោះជាអាជ្ញាធរកម្ពុជាបានលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ដែលមានតម្លៃស្មើ ឬតិចជាង 70,000 ដុល្លារ ដែលនេះជាផ្នែកមួយនៃវិធានការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ 19 ក៏ដោយ ក៏ពន្ធលើចំណេញមូលធនចំនួន 20 ភាគរយ នឹងចូលជាធរមាននៅឆ្នាំ 2022។ ពន្ធនេះអនុវត្តចំពោះចំណេញមូលធន ដែលជាប្រាក់ចំណេញជាប់ពន្ធនៃចំណូលពីការលក់ ឬផ្ទេរមូលធន។ ពន្ធលើចំណេញមូលធននេះនឹងធ្វើឱ្យការទិញ/លក់អចលនទ្រព្យដើម្បីបានប្រាក់ចំណេញយ៉ាងប្រថុយប្រថាន ថយចុះ ព្រោះពន្ធនេះកាត់បន្ថយតម្រូវការនៃការទិញ/លក់ដើម្បីបានប្រាក់ចំណេញ ដែលជួយរក្សាស្ថិរភាពទីផ្សារអចលនទ្រព្យនៅកម្ពុជាដែលបានកើនឡើងយ៉ាងលឿនកាលពីមុនវិបត្តិជំងឺកូវីដ 19។ តាមរយៈលំហូរចូលយ៉ាងច្រើននៃការវិនិយោគផ្ទាល់ពីបរទេសដែលផ្តោតលើវិស័យសំណង់ និងអចលនទ្រព្យ តម្រូវការទិញ/លក់ដើម្បីបានប្រាក់ចំណេញ បានកើនឡើងយ៉ាងឆាប់រហ័ស និងធ្វើឱ្យទីផ្សារលំនៅដ្ឋាននៅកម្ពុជាបង្ហាញរូបភាពមិនត្រឹមត្រូវ។ ក្រៅពីការប្រមូលចំណូលបន្ថែមសម្រាប់រដ្ឋាភិបាល ពន្ធលើចំណេញមូលធនអាចនឹងជួយកាត់បន្ថយការប្រែប្រួលតម្លៃ។ សំខាន់ជាងនេះទៀត ពន្ធនេះគួរតែជួយបង្វែរការវិនិយោគពីការទិញ និងកាន់កាប់អចលនទ្រព្យដើម្បីយកចំណេញ ទៅជាការផ្តល់ហិរញ្ញប្បទានដល់វិស័យដែលមានផលិតភាព និងអាចជួញដូរបាន ដែលជំរុញដល់ការបង្កើតការងារ និងការនាំចេញ។

**អ្វីដែលសំខាន់បំផុតគឺត្រូវបង្កើតហេដ្ឋារចនាសម្ព័ន្ធចែកចាយវ៉ាក់សាំងជំងឺកូវីដ 19 ក៏ដូចជាកំណត់ វ៉ាក់សាំងជំងឺកូវីដ 19 ដែលអាចទិញបាន និងមានតម្លៃសមរម្យ។** នេះជាពេលវេលាដ៏សំខាន់ក្នុងការធ្វើឱ្យប្រាកដថា កម្ពុជាអាចទិញវ៉ាក់សាំងដែលនឹងមាននាពេលខាងមុខ និងចែកចាយដោយប្រសិទ្ធភាព និងយុត្តិធម៌។ កន្លងមក កម្ពុជាបានស្វែងរកកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗក្នុងតំបន់ដែលកំពុងបង្កើតវ៉ាក់សាំងជំងឺកូវីដ 19 ដូចជា ប្រទេសចិន ដើម្បីធានាថា កម្ពុជាមានលទ្ធភាពទទួលបានវ៉ាក់សាំងនេះ ក្រោយពេលមានការបញ្ចេញលក់ក្នុងទីផ្សារ។

# រូប ES.1៖ ទិដ្ឋភាពរួមស្តីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា

**កំណើនពិត ដែលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺកូវីដ 19 ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅឆ្នាំក្រោយ...**

*កំណើនពិត (ភាគរយ)*




**...ព្រោះមានកំណើនការយកចិត្តទុកដាក់លើការវិនិយោគ...។**

*គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត (ការប្រែប្រួលជាភាគរយនៅឆ្នាំនេះ ធៀបនឹងឆ្នាំមុន)*




**...ខណៈដែលសកម្មភាពក្នុងប្រទេសកំពុងងើបឡើងជាបណ្តើរៗ...**

*សន្ទស្សន៍ស្តីពីនិន្នាការចល័តភាពរបស់កម្ពុជា ដោយ Apple (ភាគរយ)*




**...ទោះបីជាផលិតទំនិញនាំចេញ មិនទាន់មានភាពប្រសើរឡើងក្តី។**

*(ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)*




**ទុនបម្រុងអន្តរជាតិនៅតែកើនឡើង...**

*ទុនបម្រុងអន្តរជាតិសរុប (ចំនួនខែនៃការនាំចូល)*




**...ទោះបីជាកំណើនរូបិយវត្ថុទូលាយ ថយចុះក្តី។**

*បំណុលជារូបិយវត្ថុទូលាយ (ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)*




*ប្រភព ៖ អាជ្ញាធរកម្ពុជា ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក*

*សម្គាល់ ៖ p=ការព្យាករ, y/y=ធៀបនឹងឆ្នាំមុន, YTD=ឆ្នាំនេះ, RHS=ខាងស្តាំ, KHM=កម្ពុជា*

## ផ្នែកទី ១

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ



# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

## ការអភិវឌ្ឍថ្មីៗ

### សកម្មភាពសេដ្ឋកិច្ចបានងើបឡើងបន្តិច បន្ទាប់ពីទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារជំងឺរាតត្បាត

**សេដ្ឋកិច្ចកម្ពុជាកំពុងងើបឡើងវិញជាបណ្តើរៗពីវិបត្តិធ្ងន់ធ្ងរផ្សេងៗដែលបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ 19 នៅពិភពលោក។** សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសកំពុងងើបឡើងវិញ បន្ទាប់ពីមានការបន្ធូរបន្ថយការបង្ខាំងមិនឱ្យចេញចូល និងការរឹតត្បិតលើការធ្វើដំណើរនៅខែ ឧសភា ឆ្នាំ 2020 ដោយសារតែអាជ្ញាធរខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍ (រូប 1 និងរូប 2)។ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ 19 ដែលធ្វើឱ្យម៉ាស៊ីនកំណើនសំខាន់ៗភាគច្រើនរបស់កម្ពុជាថយចុះយ៉ាងលឿននៅឆមាសទីមួយក្នុងឆ្នាំ 2020 លែងកើនឡើងទៅមុខទៀតមួយផ្នែកដោយសារតែការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ទោះបីជាវិបត្តិខាងក្រៅនៅតែបន្តមានក្តី។ តម្លៃនៃគម្រោងដែលត្រូវបានអនុម័តក្នុងវិស័យផលិតរបស់កម្ពុជាដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស ដែលចាប់ផ្តើមថយចុះនៅពាក់កណ្តាលឆ្នាំ 2019 ទន្ទឹមនឹងមានការហាមឃាត់ល្បែងស៊ីសងតាមប្រព័ន្ធអនឡាញ បានងើបឡើងវិញចាប់តាំងពីខែ ឧសភា ឆ្នាំ 2020។ គួរកត់សម្គាល់ថា គម្រោងការវិនិយោគផ្ទាល់ពីបរទេស (ដែលត្រូវបានអនុម័ត) កំពុងងាកចេញលើកដំបូងពីវិស័យទេសចរណ៍ឆ្ពោះទៅវិស័យកម្មន្តសាលក្រៅពីសម្លៀកបំពាក់។ ការថយចុះនៃវិស័យទេសចរណ៍ត្រូវបានដោះស្រាយបានមួយផ្នែកដោយការកើនឡើងនៃភ្ញៀវទេសចរក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពសាងសង់ និងឧស្សាហកម្មផលិតទំនិញនាំចេញរបស់កម្ពុជា នៅតែថយចុះបន្តិច។

**កន្លងមក កម្ពុជាបានចៀសផុតពីបញ្ហាវិបត្តិសុខភាពដោយសារតែអាជ្ញាធរកម្ពុជាបានចាត់វិធានការយ៉ាងរហ័សក្នុងការកំណត់រក និងទប់ស្កាត់ការផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍។** សាលារៀន និងមហាវិទ្យាល័យត្រូវបានអនុញ្ញាតឱ្យបើកទ្វារឡើងវិញតាំងពីខែ សីហា ឆ្នាំ 2020 ប៉ុន្តែ ត្រូវបានបិទទ្វារសាជាថ្មីនៅសប្តាហ៍ទីពីរ និងទីបីក្នុងខែវិច្ឆិកា ឆ្នាំ 2020។ នៅថ្ងៃទី 14 ខែ វិច្ឆិកា ឆ្នាំ 2020 មានករណីវិជ្ជមានជំងឺកូវីដ 19 ចំនួន 302 ករណី ក្នុងនោះ 289 ករណីបានជាសះស្បើយទាំងស្រុង ចំណែកអ្នកនៅសល់ កំពុងទទួលការព្យាបាល។ ករណីវិជ្ជមានទីមួយត្រូវបានរកឃើញនៅថ្ងៃទី 27 ខែ មករា ឆ្នាំ 2020[1]។

**នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ 19 បានកាត់បន្ថយសកម្មភាពសេដ្ឋកិច្ច[2]។** ការលំបាកនៅតាមប្រទេសទាំងនេះកាន់តែមានទំហំធំធេងដោយសារការថយចុះសេដ្ឋកិច្ចសកលដោយសារតែវិបត្តិជំងឺកូវីដ 19 ដែលប៉ះពាល់យ៉ាងខ្លាំងលើសេដ្ឋកិច្ចនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលពឹងផ្អែកយ៉ាងខ្លាំងលើពាណិជ្ជកម្ម និងទេសចរណ៍ (សូមមើលប្រអប់ 1)។ ជាទូទៅលទ្ធផលដែលសម្រេចបានក្នុងប្រទេសពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការទប់ស្កាត់ជំងឺកូវីដ 19 និងកម្រិតនៃការប្រឈមទៅនឹងវិបត្តិខាងក្រៅ។ ជាមធ្យម រដ្ឋាភិបាលនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានប្រើប្រាស់ថវិកាជិត 5 ភាគរយនៃ ផសស ដើម្បីកែលម្អប្រព័ន្ធសុខាភិបាល ជួយសម្រួលដល់ការប្រើប្រាស់ក្នុងគ្រួសារ និងទ្រទ្រង់ដល់ក្រុមហ៊ុនកុំឱ្យក្ស័យធន។ ការទប់ស្កាត់ជំងឺកូវីដ 19 ដោយជោគជ័យនៅតាមបណ្តាប្រទេសមួយចំនួន

**រូប 1 ៖ សន្ទស្សន៍ស្តីពីនិន្នាការចល័តភាព Apple របស់កម្ពុជា (ភាគរយ)**




*ប្រភព ៖ និន្នាការស្តីពីចល័តភាព Apple (Apple)*

*សម្គាល់ ៖ KHM=កម្ពុជា*

**រូប 2 ៖ និន្នាការស្តីពីចល័តភាព Google របស់កម្ពុជា (នៅថ្ងៃទី 18 ខែ តុលា ឆ្នាំ 2020)**




*ប្រភព ៖ និន្នាការស្តីពីចល័តភាព Google (Google)*

---

[1] សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ថ្ងៃទី 5 ខែ វិច្ឆិកា ឆ្នាំ 2020។

[2] ធនាគារពិភពលោក ឆ្នាំ 2020a។

ប្រអប់ 1 ៖

## ការអភិវឌ្ឍសេដ្ឋកិច្ច ទស្សនៈវិស័យ និងហានិភ័យនៅកម្រិតសកល និងតំបន់[1]

បន្ទាប់ពីការថយចុះនៅឆមាសទីមួយក្នុងឆ្នាំ 2020 សកម្មភាពសកលបានចាប់ផ្តើមងើបឡើងវិញបន្ទាប់ពីមានការបន្ធូរបន្ថយវិធានការបង្ខាំងការចេញចូល ដែលនាំមុខដោយប្រទេសចិន (រូប B1.1)។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃការឆ្លងរាលដាលជំងឺកូវីដ 19 ក្នុងតំបន់មួយចំនួន កំពុងប៉ះពាល់ដល់សកម្មភាពងើបឡើងបន្តិចនាពេលថ្មីៗនេះ។ សេដ្ឋកិច្ចសកលត្រូវបានរំពឹងថាថយចុះយ៉ាងខ្លាំងនៅឆ្នាំ 2020 ដែលជាការថយចុះយ៉ាងខ្លាំងដែលមិនធ្លាប់មានចាប់តាំងពីការបញ្ចប់សង្គ្រាមលោកលើកទី ២ (របាយការណ៍ធនាគារពិភពលោក ឆ្នាំ 2020)។ ពាណិជ្ជកម្មទំនិញសកលបន្តងើបឡើងបន្តិច ខណៈដែលពាណិជ្ជកម្មសេវាងើបឡើងយឺតជាង។ ការផលិតតាមការបញ្ជាទិញថ្មីៗសម្រាប់ការនាំចេញ ត្រូវបានបញ្ជាក់ថាមានចំនួន 51.7 ភាគរយនៅខែ កញ្ញា កើនពី 27.1 ភាគរយនៅខែ មេសា (រូប B1.2)។ ចំនួនភ្ញៀវទេសចរអន្តរជាតិក្នុងបណ្តាប្រទេសជាច្រើននៅតែថយចុះជាង 90 ភាគរយ ធៀបនឹងកម្រិតកាលពីឆ្នាំមុន។ ចំនួនជើងហោះហើរពាណិជ្ជកម្មប្រចាំថ្ងៃបានកើនដល់ជិតពាក់កណ្តាលនៃចំនួនជើងហោះហើរកាលពីឆ្នាំមុនគិតត្រឹមដើមខែ សីហា ប៉ុន្តែ ចំនួននេះនៅថេរកាលពីអំឡុងខែ កញ្ញា និងតុលា។

ជំងឺកូវីដ 19 បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ កំណើនក្នុងតំបន់បានថយចុះមកត្រឹមកម្រិតប៉ាន់ស្មាន 0.9 ភាគរយនៅឆ្នាំនេះ ដែលជាកំណើនទាបបំផុតចាប់តាំងពីឆ្នាំ 1967 និងបង្ហាញពីផលប៉ះពាល់នៃការអាក់ខាន ការបង្ខាំងការចេញចូល និងការរឹតត្បិតលើការធ្វើដំណើរដោយសារជំងឺកូវីដ 19។ ការប៉ះពាល់មកលើសេដ្ឋកិច្ចក្នុងតំបន់ មានកម្រិតខុសៗគ្នា និងឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរខុសៗគ្នានៃការបង្អាក់សង្វាក់ផ្គត់ផ្គង់ និងផលប៉ះពាល់ពីការថយចុះសេដ្ឋកិច្ចសកល។ នៅប្រទេសចិន និងវៀតណាម ដែលបានរក្សាអត្រាឆ្លងជំងឺកូវីដ 19 ថ្មីឱ្យនៅទាប ផសស ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងនៅឆ្នាំនេះ។ ប្រទេសផ្សេងៗទៀតក្នុងតំបន់នេះនឹងមានការបាត់បង់ផលសេដ្ឋកិច្ចយ៉ាងច្រើន ដោយ ផសស នឹងថយចុះជាមធ្យមចំនួន 4 ភាគរយ។

ធនាគារកណ្តាលនៅជុំវិញពិភពលោក បានបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុច្រើន និងផ្តល់ការគាំទ្រដល់សន្ទនីយភាព ដើម្បីបញ្ចៀសការខ្វះខាតក្នុងទីផ្សារឥណទាន។ ទុនបម្រុងកម្រិតសហព័ន្ធបានកាត់បន្ថយអត្រាគោលនយោបាយរូបិយវត្ថុរបស់ខ្លួនដល់ជិតសូន្យ។ លំហូរចេញមូលធនពីទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ ដែលលើសពីអំឡុងពេលដ៏អាក្រក់បំផុតនៃវិបត្តិហិរញ្ញវត្ថុសកលនៅពេលមានការផ្ទុះជំងឺកូវីដ 19 ជាលើកដំបូង បានថយចុះបន្តិច។ ទោះបីជាផលមានកម្រិតទាប ប៉ុន្តែ ចំណាត់ថ្នាក់ឥណទាន បានបន្តថយចុះ ដែលបង្ហាញពីបញ្ហាស្តីពីនិរន្តរភាពបំណុល។ ទីផ្សារទំនិញមាននិន្នាការផ្សេងៗគ្នា។ តម្លៃប្រេងថយចុះជិត 7 ភាគរយនៅខែ កញ្ញា មុនពេលមានតម្លៃថេរនៅខែ តុលា ដោយតម្លៃប្រេងឆៅជាមធ្យមរបស់ក្រុមហ៊ុន Brent មានចំនួន 40 ដុល្លារក្នុងមួយបារ៉ែល។ តម្លៃលោហធាតុសំខាន់ៗចាប់ផ្តើមកើនឡើងនៅខែ តុលា ហើយបច្ចុប្បន្ន មានតម្លៃខ្ពស់ជាងជិត 6 ភាគរយ នៃតម្លៃមុនពេលផ្ទុះជំងឺកូវីដ 19 នៅខែ មករា ជាពិសេសសម្រាប់ទង់ដែងដែលមានតម្លៃខ្ពស់ជាងគេ។ កំណើនតម្លៃនេះបណ្តាលមកពីការបង្កើនសកម្មភាពសេដ្ឋកិច្ចសកល ជាពិសេសសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសចិន។ តម្លៃទំនិញកសិកម្មបានកើនចំនួន 6 ភាគរយនៅខែ កញ្ញា ហើយបច្ចុប្បន្ន កើនលើសតម្លៃកាលពីខែ មករា។

**រូប B1.1៖ ទិន្នន័យស្តីពីកំណើន ផសស ចុងក្រោយនៅតាមបណ្តាប្រទេសមួយចំនួន**
(ភាគរយ)




**រូប B1.2៖ សន្ទស្សន៍រងនៃការបញ្ជាទិញថ្មីៗក្នុងការនាំចេញនៃសន្ទស្សន៍ស្តីពីអ្នកគ្រប់គ្រងការបញ្ជាទិញ (PMI)**




*ប្រភព ៖ Haver Analytics*

*សម្គាល់ ៖ តួលេខនេះបង្ហាញពីអត្រាកំណើនប្រចាំឆ្នាំតាមត្រីមាស សម្រាប់ត្រីមាសទីពីរនៃឆ្នាំ 2020 នៅតាមបណ្តាប្រទេសមួយចំនួន។ បង្គោលពណ៌ក្រហមគូសបញ្ជាក់ពីអត្រាកំណើនមិនប្រចាំឆ្នាំតាមត្រីមាស (ត្រីមាសទីបី នៃឆ្នាំ 2020) សម្រាប់ប្រទេសចិន។*

[1] ប្រអប់នេះត្រូវបានរៀបចំឡើងដោយលោកស្រី Ekaterine Vashamadze, PG

### ទស្សនវិស័យសកល[1]

សេដ្ឋកិច្ចសកលត្រូវបានព្យាករណ៍ថានឹងថយចុះចំនួន 5.2 ភាគរយនៅឆ្នាំនេះ ទោះបីជាមានការគាំទ្រផ្នែកគោលនយោបាយដែលមិនធ្លាប់មានពីមុនក្តី (រូប B1.3 ធនាគារពិភពលោក ឆ្នាំ 2020)។ នេះបណ្តាលមកពីការបង្អាក់ភ្លាមៗនូវសកម្មភាពសកលនៅឆមាសទីមួយក្នុងឆ្នាំ 2020 ដោយសារការអនុវត្តវិធានការបង្ខាំងការចេញចូលនៅទូទាំងពិភពលោកដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ 19។ ទោះបីជាមានការប៉ាន់ប្រមាណពីការងើបឡើងបន្តិចនៅឆ្នាំ 2021 ជាមួយនឹងកំណើនសកលចំនួន 4.2 ភាគរយក្តី ប៉ុន្តែផលសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងមិនត្រឡប់ទៅរកអត្រារំពឹងទុកពីមុនឡើយ (រូប B1.4)។ ភាពរឹងមាំ និងនិរន្តរភាពនៃការងើបឡើងនៃកំណើនសកលអាស្រ័យលើថាតើជំងឺកូវីដ 19 នៅមានអត្ថិភាពយូរប៉ុណ្ណា និងប្រសិទ្ធភាពនៃវិធានការគោលនយោបាយក្នុងការទប់ស្កាត់ការ ថយចុះហិរញ្ញវត្ថុ ការស្តារទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងវិនិយោគិនទូទាំងពិភពលោក និងប្រក្រតីភាពនៃការធ្វើដំណើរទូទាំងពិភពលោក។

កំណើនក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានព្យាករណ៍ថានឹងកើនចំនួន 7.4 ភាគរយនៅឆ្នាំ 2021 ដោយសារតែការងើបឡើងវិញនៃកំណើនក្នុងប្រទេសចិន។ ចំណុចនេះផ្អែកលើការចាប់ផ្តើមបញ្ចេញវ៉ាក់សាំងជំងឺកូវីដ 19 នៅដើមឆ្នាំ 2021 នៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំៗ និងរយៈពេលក្រោយមកទៀតនៅក្នុងទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍(EMDEs)។ ទោះបីជាមានការថមថយឥទ្ធិពលនៃជំងឺកូវីដ 19 និងការងើបឡើងវិញនូវតម្រូវការក្នុងប្រទេស និងតម្រូវការសកលក្តី ក៏សកម្មភាពក្នុងតំបន់ត្រូវបានព្យាករណ៍ថានៅតែស្ថិតក្រោមនិន្នាការមុនពេលផ្ទុះជំងឺកូវីដ 19 នៅត្រឹមបំណាច់ឆ្នាំ 2021 នេះ ដែលបង្ហាញពីផលប៉ះពាល់យូរអង្វែងនៃជំងឺកូវីដ 19។ ការងើបឡើងវិញក្នុងតំបន់ (មិនរាប់បញ្ចូលប្រទេសចិន) ត្រូវបានព្យាករណ៍ថានឹងកើនចំនួន 5.3 ភាគរយជាមធ្យម នៅអំឡុងឆ្នាំ 2021-2022 ដោយមានភាពខុសគ្នាខ្លាំងនៅតាមបណ្តាប្រទេសនានា។

ដូច្នេះ ការឆ្លើយតបពិសេសផ្នែកគោលនយោបាយ បានជួយទប់ស្កាត់ការថយចុះនៃសកម្មភាពមិនឲ្យវិវឌ្ឍន៍ទៅជាវិបត្តិហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពហិរញ្ញវត្ថុនឹងនៅតែមានភាពផុយស្រួយសម្រាប់បណ្តាប្រទេសជាច្រើនដែលចូលរួមក្នុងទីផ្សារ។ ការបង្អាក់សកម្មភាពសេដ្ឋកិច្ចរយៈពេលវែង អាចបង្កើនបញ្ហាហិរញ្ញវត្ថុកាន់តែខ្លាំង ដែលអាចបង្កជាវិបត្តិហិរញ្ញវត្ថុជាទូទៅ។ មានភាពមិនប្រាកដប្រជាច្រើនលើការព្យាករណ៍កំណើនសកល។ ការថយចុះជាសកលនឹងមានទំហំធំជាងការព្យាករណ៍ដើមគ្រា ប្រសិនបើពិភពលោកត្រូវចំណាយពេលយូរជាងការរំពឹងទុកក្នុងការគ្រប់គ្រងស្ថានការណ៍ជំងឺកូវីដ 19 ឬប្រសិនបើបញ្ហាហិរញ្ញវត្ថុធ្វើឲ្យមានការជាប់គាំងខ្លាំង។

ជំងឺកូវីដ 19 អាចនឹងមានផលប៉ះពាល់រយៈពេលយូរលើច្រើនផ្នែក រួមទាំង កង្វះការវិនិយោគ និងនវានុវត្តន៍ ការថយចុះធនធានមនុស្ស និងការដកខ្លួនចេញពីពាណិជ្ជកម្ម និងសង្វាក់ផ្គត់ផ្គង់សកល។ ការប៉ះពាល់រយៈពេលវែងដោយសារជំងឺកូវីដ 19 នឹងមានកម្រិតធ្ងន់ធ្ងរខ្លាំងក្នុងបណ្តាប្រទេសដែលមានវិបត្តិហិរញ្ញវត្ថុ និងបណ្តាប្រទេសនាំចេញថាមពល ដោយសារតែតម្លៃប្រេងធ្លាក់ចុះ។ ឧ. ក្នុងទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ ការថយចុះកំណើន គួបផ្សំនឹងវិបត្តិហិរញ្ញវត្ថុក្នុងរយៈពេល ៥ ឆ្នាំខាងមុខ អាចធ្វើឱ្យផលសេដ្ឋកិច្ចថយចុះជិត 8 ភាគរយ (ធនាគារពិភពលោក ឆ្នាំ 2020)។

**រូប B1.3៖ កំណើនសកល**

(ភាគរយ)




*ប្រភព ៖ ធនាគារពិភពលោក*

*សម្គាល់ ៖ ផ្នែកព្រាលៗបង្ហាញពីការព្យាករ។ អត្រាកំណើនសរុប ត្រូវបានគណនាដោយប្រើប្រាស់អត្រាប្រាក់ដុល្លារថេរក្នុង ផសស ឆ្នាំ 2010។ ទិន្នន័យសម្រាប់ឆ្នាំ 2019 គឺជាការប៉ាន់ស្មាន។ អត្រាកំណើនសរុបដែលត្រូវបានគណនាដោយប្រើប្រាស់ ផសស ធៀបនឹងតម្លៃថេរ និងអត្រាប្តូរប្រាក់ក្នុងទីផ្សារនៅឆ្នាំ 2010។*

**រូប B1.4៖ កម្រិតផលសេដ្ឋកិច្ចធៀបនឹងការព្យាករនៅខែ មករា ឆ្នាំ 2020**

(ភាគរយ)




*ប្រភព ៖ ធនាគារពិភពលោក*

*សម្គាល់ ៖ តួលេខបង្ហាញពីភាគរយខុសគ្នារវាងកម្រិតនៃផលសេដ្ឋកិច្ចក្នុងឯកសារ "ទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មករា និងខែ មិថុនា ឆ្នាំ 2020" របស់ធនាគារពិភពលោក។*

[1] ផ្អែកលើរបាយការណ៍ស្តីពីទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មិថុនា ឆ្នាំ 2020 របស់ធនាគារពិភពលោក។ ការព្យាករបច្ចុប្បន្នភាពសកល នឹងត្រូវបានបោះពុម្ពផ្សាយនៅខែ មករា ឆ្នាំ 2021។

បានជួយស្តារសកម្មភាពសេដ្ឋកិច្ចឡើងវិញ ប៉ុន្តែ សេដ្ឋកិច្ចតំបន់នៅតែពឹងផ្អែកយ៉ាងខ្លាំងលើសេដ្ឋកិច្ចរបស់បណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក។ ពាណិជ្ជកម្មនឹងងើបឡើងវិញ នៅពេលដែលសកម្មភាពសេដ្ឋកិច្ចសកលចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗ ប៉ុន្តែ វិស័យទេសចរណ៍នឹងនៅតែគ្មានភាពសកម្ម។ ទោះបីជាតំបន់នេះចាប់ផ្តើមទទួលបានមូលធនរយៈពេលខ្លីក្តី ប៉ុន្តែ ភាពមិនប្រាកដប្រជាក្នុងពិភពលោក នៅតែបង្អាក់ការវិនិយោគក្នុងស្រុក និងការវិនិយោគពីបរទេស។

**ជំងឺកូវីដ 19 បានរាំងស្ទះយ៉ាងលឿនដល់កំណើននៅកម្ពុជា។** កម្ពុជាមានអត្រាកំណើនពិតជាមធ្យមចំនួន 7.7 ភាគរយក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ កម្ពុជាសម្រេចបានកំណើនពិតចំនួន 7.1 ភាគរយនៅឆ្នាំ 2019 (រូប 3)។ ម៉ាស៊ីនកំណើនសំខាន់ៗ ដែលរួមមាន សំណង់ ទេសចរណ៍ និងការនាំចេញទំនិញ ដែលសរុបចូលគ្នាមានចំនួនជាង 70 ភាគរយនៃកំណើន និង 39 ភាគរយនៃការងារដែលទទួលបានប្រាក់កម្រៃ បានទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

### ការបន្តធ្លាក់ចុះនៃឧស្សាហកម្មផលិតទំនិញនាំចេញរបស់កម្ពុជា

**មូលដ្ឋាននៃការនាំចេញដ៏តូចរបស់កម្ពុជា នៅតែបន្តទទួលរងការប៉ះពាល់ដោយសារវិបត្តិតម្រូវការ ដែលបណ្តាលមកពីជំងឺកូវីដ 19។** នៅពេលដែលវិបត្តិកូវីដ 19 នៅបន្ត ការនាំចេញផលិតផលរបស់កម្ពុជា រួមទាំង សម្លៀកបំពាក់ ទំនិញធ្វើដំណើរ ស្បែកជើង កង់ គ្រឿងបន្លាស់អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំ បានថយចុះចំនួន 2.5 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 (រូប 4)។ ឧស្សាហកម្មផលិតទំនិញនាំចេញសរុបបានថយចុះមកត្រឹម 8.48 ពាន់លានដុល្លារ ថយពី 8.69 ពាន់លានដុល្លារ ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ដែលមានចំនួន 2/3 នៃឧស្សាហកម្មផលិតទំនិញនាំចេញ នៅតែមានស្ថានភាពមិនច្បាស់លាស់។ ព័ត៌មានថ្មីៗចុងក្រោយពីឧស្សាហកម្មនេះបង្ហាញថា ការបញ្ជាទិញរបស់អ្នកបញ្ជាទិញអន្តរជាតិជាច្រើន នៅតែមានភាពមិនច្បាស់លាស់។ ការអង្កេតមួយដែលធ្វើឡើងដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) កាលពីខែ មិថុនា ឆ្នាំ 2020 បង្ហាញថា មានរោងចក្រតែ 40 ភាគរយប៉ុណ្ណោះ ដែលនឹងទទួលបានការបញ្ជាទិញ (ទាំងស្រុង ឬដោយផ្នែក) រហូតដល់ត្រីមាសចុងក្រោយក្នុងឆ្នាំ 2020 ខណៈដែលរោងចក្រផ្សេងទៀតមិនទាន់មានការបញ្ជាទិញនៅឡើយ។ ក្រៅពីនេះ និន្នាការថ្លៃសម្រាប់ការបញ្ជាទិញថ្មីៗភាគច្រើនមានតម្លៃថោកជាងមុន។ មានរោងចក្រតែ 37 ភាគរយប៉ុណ្ណោះដែលបានលើកឡើងថា អ្នកទិញផ្តល់តម្លៃដដែល ខណៈរោងចក្រ 45 ភាគរយលើកឡើងថា អ្នកទិញផ្តល់តម្លៃទាបជាងមុន។ លក្ខខណ្ឌនៃការទូទាត់ដោយអ្នកទិញសម្រាប់ការបញ្ជាទិញថ្មីៗ ហាក់មានភាពតឹងរ៉ឹង។ មានរោងចក្រតែ 45 ភាគរយប៉ុណ្ណោះដែលលើកឡើងថាទទួលបានលក្ខខណ្ឌទូទាត់ដដែល ខណៈដែលរោងចក្រ 35 ភាគរយលើកឡើងថាមានលក្ខខណ្ឌទូទាត់យូរជាងមុន។ ក្រៅពីនេះ ការដកផ្នែកខ្លះនៃការអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប ដែលចូលជាធរមានតាំងពីថ្ងៃទី 12 ខែ សីហា ឆ្នាំ 2020 កំពុងផ្តល់ផលប៉ះពាល់លើការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបប្រមាណ 20 ភាគរយ[3]។ យោងតាមសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) នៅខែ កក្កដា ឆ្នាំ 2020 រោងចក្រចំនួន 400 បានផ្អាកប្រតិបត្តិការ និងរំសាយកម្មករចំនួន 150,000 នាក់[4]។ នៅខែ មិថុនា ឆ្នាំ 2020 រោងចក្រជាង 13,600 (ក្នុងនោះ រោងចក្រ 1,200 ជារោងចក្រកាត់ដេរ) មានក្នុងបញ្ជីរោងចក្ររួម និងផ្តល់ការងារដល់កម្មករជាង 1.37 លាននាក់ (ក្នុងនោះ កម្មករ 0.83 លាននាក់ជាកម្មករកាត់ដេរ)។

### ឧស្សាហកម្មផលិតទំនិញនាំចេញទៅកាន់សហរដ្ឋអាមេរិកបានកើនឡើងទោះបីជាមានជំងឺរាតត្បាតកូវីដ 19

**ខុសពីឧស្សាហកម្មផលិតទំនិញនាំចេញទៅកាន់ទីផ្សារធំៗផ្សេងទៀត ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានកើនឡើង។** ការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើ

**រូប 3 ៖ ការរួមចំណែកតាមវិស័យដល់កំណើនពិត**
(ភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក*
*សម្គាល់ ៖ p=ការព្យាករ*

**រូប 4 ៖ ឧស្សាហកម្មផលិតទំនិញនាំចេញ**
(លានដុល្លារ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS=ខាងស្តាំ, YTD=ឆ្នាំនេះ, y/y=ធៀបនឹងឆ្នាំមុន*

[3] សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់ ៖ https://trade.ec.europa.eu/doclib/press/index.cfm?id=2113 ។
[4] សេចក្តីថ្លែងការណ៍របស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2020។

ដំណើរ ស្បែកជើង និងផលិតផលកង់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក កើនដល់ 2.7 ពាន់លានដុល្លារ កើន 7.6 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 (រូប 5)។ ការបែងចែកទិន្នន័យទីផ្សារសហរដ្ឋអាមេរិកបង្ហាញថា ការនាំចេញសម្លៀកបំពាក់កើនឡើង 5.0 ភាគរយ ទំនិញធ្វើដំណើរកើនឡើង 8.0 ភាគរយ ស្បែកជើងកើនឡើង 4.1 ភាគរយ និងផលិតផលកង់ កើនឡើង 190.9 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ផ្ទុយទៅវិញ ការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប (មិនគិតចក្រភពអង់គ្លេស) បានថយចុះមកត្រឹម 2.1 ពាន់លានដុល្លារ ឬថយចុះ 19.8 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងនោះ ការនាំចេញសម្លៀកបំពាក់ថយចុះ 22.4 ភាគរយ ស្បែកជើងថយចុះ 14.6 ភាគរយ និងទំនិញធ្វើដំណើរថយចុះ 30.2 ភាគរយ (ធៀបនឹងឆ្នាំមុន) ប៉ុន្តែ ការនាំចេញកង់កើនបន្តិចចំនួន 3.6 ភាគរយ។ ប្រហាក់ប្រហែលគ្នាដែរ ការនាំចេញទៅកាន់គោលដៅសំខាន់ៗផ្សេងទៀត ដូចជា ចក្រភពអង់គ្លេស បានថយចុះ 19.1 ភាគរយ ហើយជប៉ុន ថយចុះ 6.7 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ទីផ្សារសហរដ្ឋអាមេរិកមានទំហំធំជាងគេនៃការនាំចេញសរុបរបស់កម្ពុជា ស្មើនឹង 36 ភាគរយនៃការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ ស្បែកជើង និងផលិតផលកង់សរុបរបស់កម្ពុជា (រូប 6)។ ទីផ្សារសហភាពអឺរ៉ុបមានលំដាប់ទីពីរ ស្មើនឹង 28 ភាគរយ។

### ការនាំចេញកង់ និងគ្រឿងបន្លាស់អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត បានកើនឡើង

**វិបត្តិតម្រូវការមិនមានឥទ្ធិពលអវិជ្ជមានលើផលិតផលនាំចេញទាំងអស់នោះទេ។** ទោះជាការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលទំនិញធ្វើដំណើរទៅកាន់ទីផ្សារធំៗទាំងអស់ (លើកលែងតែសហរដ្ឋអាមេរិក) បានថយចុះ ការនាំចេញផលិតផលកង់បានកើនយ៉ាងលឿនរហូតដល់ 369 លានដុល្លារ ឬកើន 31.6 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020។ ការនាំចេញកង់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកកើនចំនួន 190.9 ភាគរយ សហភាពអឺរ៉ុបកើនចំនួន 3.6 ភាគរយ និងចក្រភពអង់គ្លេសកើនចំនួន 32.3 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ប្រហែលគ្នានេះដែរ ការនាំចេញគ្រឿងបន្លាស់អគ្គិសនី និងគ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំ កើនដល់ 456 លានដុល្លា ឬកើន 14.4 ភាគរយ ធៀបនឹងឆ្នាំមុនក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 ក្នុងនោះ ការនាំចេញ 60 ភាគរយទៅកាន់ប្រទេសសមាជិកអាស៊ាន និងប្រទេសជប៉ុន។

### ចំនួនភ្ញៀវទេសចរអន្តរជាតិថយចុះយ៉ាងខ្លាំង

**ចំនួនភ្ញៀវទេសចរអន្តរជាតិបានថយចុះចំនួន 74.1 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ កញ្ញា ឆ្នាំ 2020 ដោយសារការរឹតត្បិតការធ្វើដំណើរអន្តរជាតិ និងការចៀសការធ្វើដំណើរ (អន្តរជាតិ) ជាសកល** (រូប 7)។ ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 ភ្ញៀវទេសចរអន្តរជាតិមានចំនួនតែ 1.25 លាននាក់ ថយពី 4.8 លាននាក់ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ ខេត្តសៀមរាប ដែលជាទីទាក់ទាញភ្ញៀវទេសចរដ៏មានប្រជាប្រិយភាពបំផុតនៅកម្ពុជា បានថយចុះភ្ញៀវទេសចរអន្តរជាតិចំនួន 74.6 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅឆមាសទីមួយក្នុងឆ្នាំ 2020។ ការថយចុះគួរឱ្យកត់សម្គាល់នូវចំនួនភ្ញៀវទេសចរអន្តរជាតិ ក៏កើតមាននៅប្រទេសថៃ និងវៀតណាមផងដែរ (រូប 8)។ នៅកម្ពុជា វិស័យទេសចរណ៍ (រួមទាំងបដិសណ្ឋារកិច្ច) គឺជាម៉ាស៊ីនកំណើនធំជាងគេទីពីរបន្ទាប់ពីវិស័យសំណង់។ យោងតាមការប៉ាន់ស្មានជាផ្លូវការនៅឆ្នាំ 2019 កម្ពុជារកចំណូលបាន 4.9 ពាន់លានដុល្លារពីវិស័យទេសចរណ៍ ហើយនៅឆ្នាំនេះ កម្ពុជាត្រូវបានព្យាករណ៍ថាខាតបង់ 3 ពាន់លានដុល្លារក្នុងវិស័យទេសចរណ៍ ដោយសារការថយចុះខ្លាំងនៃចំនួនភ្ញៀវទេសចរអន្តរជាតិ[5]។ គួរកត់សម្គាល់ថា វិស័យទេសចរណ៍នៅកម្ពុជាជួបប្រទះ "ការលិចជ្រាប[6]" ការដោះដូរបរទេសយ៉ាងច្រើន។ កត្តាលិចជ្រាបត្រូវបានប៉ាន់ស្មានថាមានប្រមាណ 40 ភាគរយសម្រាប់ប្រទេសកម្ពុជា ដែលបញ្ជាក់ថា ការចំណាយយ៉ាងច្រើននៅប្រទេសគោលដៅ

**រូប 5 ៖ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ និងកង់របស់កម្ពុជា**
(លានដុល្លារ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RoW=ប្រទេសផ្សេងទៀត*

**រូប 6 ៖ ទីផ្សារនាំចេញធំៗរបស់កម្ពុជា** [a]
(%, 2020)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ a.សំដៅលើសម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ និងផលិតផលកង់ RoW=ប្រទេសផ្សេងទៀត*

---
5 ក្រសួងទេសចរណ៍ (2019) និងសេចក្តីថ្លែងការណ៍ថ្ងៃទី 6 ខែ វិច្ឆិកា ឆ្នាំ 2020។
6 ការលិចជ្រាបកើតឡើងនៅពេលមានការនាំចូលទំនិញ សេវា និងកម្លាំងពលកម្មដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍។

ទៅការនាំចូល ឬក៏កម្ពុជាមានសមត្ថភាពផ្គត់ផ្គង់តិចតួចក្នុងការបំពេញតម្រូវការបន្ថែម និងច្រើនមុខ[7]។ ជាលទ្ធផល មេគុណចំណូលនៅតែមានទំហំតូច ហើយការលិចជ្រាបការដោះដូរបរទេសមានទំហំធំ ដែលធ្វើឱ្យមានការរួមចំណែកតិចតួចដល់សេដ្ឋកិច្ចរបស់កម្ពុជា។

### ភ្ញៀវទេសចរក្នុងស្រុកជួយទ្រទ្រង់ការងើបឡើងវិញជាបណ្តើរៗនៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍

**បន្ទាប់ពីការដកចេញនូវវិធានការបង្ខាំងការចេញចូលក្នុងប្រទេស ការធ្វើដំណើរ និងសកម្មភាពទេសចរណ៍ក្នុងប្រទេសបានកើនឡើង។** ដោយសារតែការវិលត្រឡប់របស់ភ្ញៀវទេសចរក្នុងស្រុកទៅកាន់តំបន់ទេសចរណ៍សំខាន់ៗ វិស័យទេសចរណ៍ និងធ្វើដំណើរនៅកម្ពុជា បានងើបឡើងវិញចាប់តាំងពីត្រីមាសទីពីរក្នុងឆ្នាំ 2020។ យោងតាមក្រសួងទេសចរណ៍ មានភ្ញៀវទេសចរចំនួន 0.6 លាននាក់ដែលភាគច្រើនជាភ្ញៀវទេសចរក្នុងស្រុកនៅអំឡុងថ្ងៃឈប់សម្រាកចាប់ពីថ្ងៃទី 29 ខែ តុលា ដល់ថ្ងៃទី 1 ខែ វិច្ឆិកា ឆ្នាំ 2020 និងចំនួន 1.11 លាននាក់នៅអំឡុងថ្ងៃឈប់សម្រាកថ្ងៃទី 16-18 ខែ កញ្ញា ឆ្នាំ 2020។ ទីតាំងសំខាន់ៗ 3 ដែលទាក់ទាញភ្ញៀវទេសចរច្រើនជាងគេ រួមមានតំបន់ឆ្នេរសមុទ្រ (ខេត្តព្រះសីហនុ កំពត កែប និងកោះកុង) ដែលទទួលបានភ្ញៀវទេសចរចំនួន 23.1 ភាគរយ តំបន់ភាគពាយ័ព្យ (ខេត្តបាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ និងប៉ៃលិន) ទទួលបានភ្ញៀវទេសចរចំនួន 23.0 ភាគរយ និងតំបន់វប្បធម៌ (ខេត្តសៀមរាប កំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ) ទទួលបានភ្ញៀវទេសចរចំនួន 17 ភាគរយ។ នៅអំឡុងថ្ងៃឈប់សម្រាកពិធីបុណ្យចូលឆ្នាំខ្មែរ កាលពីថ្ងៃទី 17-21 ខែ សីហា ឆ្នាំ 2020 កម្ពុជាទទួលបានភ្ញៀវទេសចរចំនួន 1.5 លាននាក់ ដែលភាគច្រើនជាភ្ញៀវទេសចរក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ ចំនួនភ្ញៀវទេសចរក្នុងស្រុកនៅឆ្នាំ 2020 នៅតែមានចំនួនតិចជាងចំនួនភ្ញៀវទេសចរនៅឆ្នាំ 2019 ដែលមានចំនួន 11.3 លាននាក់។ ខុសពីភ្ញៀវទេសចរអន្តរជាតិដែលចាប់អារម្មណ៍ខ្លាំងលើបេតិកភណ្ឌវប្បធម៌របស់កម្ពុជាក្នុង "តំបន់វប្បធម៌" ជាពិសេសប្រាង្គប្រាសាទអង្គរក្នុងខេត្តសៀមរាប ទីតាំងពេញនិយមបំផុតរបស់ភ្ញៀវទេសចរក្នុងស្រុកគឺតំបន់ឆ្នេរសមុទ្រ។ នៅឆ្នាំ 2019 តំបន់ឆ្នេរសមុទ្រទទួលបានភ្ញៀវទេសចរក្នុងស្រុកចំនួន 28.1 ភាគរយនៃចំនួនភ្ញៀវទេសចរក្នុងស្រុកសរុប ខណៈដែលរាជធានីភ្នំពេញទទួលបានភ្ញៀវទេសចរក្នុងស្រុកចំនួន 21.0 ភាគរយ។ ក្រៅពីនេះ តំបន់វប្បធម៌ទទួលបានភ្ញៀវទេសចរក្នុងស្រុកចំនួន 20.6 ភាគរយ និងតំបន់ភាគពាយ័ព្យទទួលបានភ្ញៀវទេសចរក្នុងស្រុកចំនួន 10.9 ភាគរយ ចំណែកតំបន់ផ្សេងទៀតទទួលបានភ្ញៀវទេសចរក្នុងស្រុកចំនួន 19.4 ភាគរយ។ ដោយមានការរំពឹងថា ជំងឺកូវីដ 19 នឹងបន្តប៉ះពាល់ជាអវិជ្ជមានយូរអង្វែងលើការធ្វើដំណើរអន្តរជាតិ ឧស្សាហកម្មទេសចរណ៍ (និងបដិសណ្ឋារកិច្ច) នឹងពឹងផ្អែកស្ទើរតែទាំងស្រុងលើសកម្មភាពធ្វើដំណើរ និងទេសចរណ៍ក្នុងស្រុកសម្រាប់ពេលអនាគតដែលអាចប្រមើលមើលឃើញ។ ឧស្សាហកម្មនេះកំពុងរៀបចំសម្រាប់សេវាធ្វើដំណើរ និងទេសចរណ៍របស់ភ្ញៀវទេសចរក្នុងស្រុក ក្រោយពេលអនុវត្តវិធានការបង្ខាំងការចេញចូល។

### ប្រជាពលរដ្ឋកម្ពុជាសន្សំប្រាក់រាប់ពាន់លានដុល្លារពីការធ្វើដំណើរទៅក្រៅប្រទេស ដោយសារតែការរឹតត្បិតការធ្វើដំណើរ

**បច្ចុប្បន្ន ប្រជាពលរដ្ឋកម្ពុជាដែលធ្លាប់ធ្វើដំណើរចេញទៅក្រៅប្រទេស កាលពីមុនវិបត្តិកូវីដ 19 កំពុងជក់ចិត្តនឹងសកម្មភាពធ្វើដំណើរ និងទេសចរណ៍ក្នុងប្រទេស ដោយសារការរឹតត្បិតការធ្វើដំណើរអន្តរជាតិ។** នៅឆ្នាំ 2019 ប្រជាពលរដ្ឋកម្ពុជាចំនួន 2.03 លាននាក់បានធ្វើដំណើរទៅក្រៅប្រទេស[8]។ ក្នុងចំណោមនោះមួយភាគបី បានធ្វើដំណើរតាមផ្លូវអាកាសទៅកាន់ប្រទេសនានានៅជុំវិញពិភពលោក ហើយពីរភាគបីទៀតធ្វើដំណើរតាមផ្លូវគោកទៅកាន់ប្រទេសថៃ ដែលទទួលបានភ្ញៀវទេសចរកម្ពុជាប្រមាណមួយលាននាក់ និងប្រទេសវៀតណាម

**រូប 7 ៖ ចំនួនភ្ញៀវទេសចរដែលចូលមកទស្សនាប្រទេសកម្ពុជា**
(លាននាក់ និងការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

*សម្គាល់ ៖ RHS=ខាងស្តាំ y/y=ធៀបនឹងឆ្នាំមុន*

**រូប 8 ៖ ចំនួនភ្ញៀវទេសចរទៅកាន់ប្រទេសកម្ពុជា ថៃ និងវៀតណាម**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំនេះ)




*ប្រភព ៖ ក្រសួងទេសចរណ៍នៃប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសថៃ*

---

7 សូមមើលអត្ថបទពិសេសស្តីពីការបង្កើនសក្តានុពលវិស័យទេសចរណ៍ជាអតិបរមា បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ តុលា ឆ្នាំ 2017។

8 ក្រសួងទេសចរណ៍ ឆ្នាំ 2019។

ដែលទទួលបានភ្ញៀវទេសចរកម្ពុជាចំនួន 25 ម៉ឺននាក់។ ចំណាយសរុបរបស់ភ្ញៀវទេសចរកម្ពុជាដែលទៅកាន់ប្រទេសថៃមានចំនួន 1.15 ពាន់លានដុល្លារនៅឆ្នាំ 2019[9]។

### ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើង និងងាកទៅគម្រោងកម្មន្តសាលក្រៅពីសម្លៀកបំពាក់

**ទោះជាលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសទៅក្នុងវិស័យហិរញ្ញវត្ថុ និងវិស័យពិត ត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំនេះ មានសញ្ញាវិជ្ជមានថា លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសកំពុងវិលត្រឡប់មកវិញ និងធ្វើពិពិធកម្មខ្លាំងជាងមុន។** ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 តម្លៃសរុបនៃគម្រោងដែលត្រូវបានអនុម័តទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យផលិតរបស់កម្ពុជា កើនចំនួន 1.4 ពាន់លានដុល្លារ ឬកើន 25.8 ភាគរយធៀបនឹងឆ្នាំមុន ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន[10]។ តម្លៃនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តថយចុះតាំងពីពាក់កណ្តាលឆ្នាំ 2019 នៅពេលមានការហាមឃាត់ល្បែងស៊ីសងអនឡាញ។ តម្លៃនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសថយមកត្រឹម 56.0 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2019 ថយពី 84.8 ភាគរយនៅឆ្នាំ 2018។

**ទោះជាការវិនិយោគរបស់ចិនបន្តមានចំណែកច្រើននៃតម្លៃគម្រោង (ដែលត្រូវបានអនុម័ត) ដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស មានការងាកទៅផ្តល់ហិរញ្ញប្បទានដល់វិស័យកម្មន្តសាលក្រៅពីសម្លៀកបំពាក់។** ការវិនិយោគផ្ទាល់ពីចិនមានចំនួន 56.3 ភាគរយនៃតម្លៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសសរុប (ដែលត្រូវបានអនុម័ត) ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 កើនពី 43.7 ភាគរយនៅឆ្នាំ 2019។ បើសំឡឹងមើលឱកាសក្រោយវិបត្តិជំងឺកូវីដ 19 ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 ទំហំនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ដែលផ្តោតលើវិស័យកម្មន្តសាលក្រៅពីសម្លៀកបំពាក់ មានចំនួន 60.4 ភាគរយ (878 លានដុល្លារ) (រូប 9) កើនពី 8.2 ភាគរយ (95 លានដុល្លារ) ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ 2019។ ចំណុចនេះបង្ហាញពីចំណាប់អារម្មណ៍វិនិយោគជាក់ស្តែងជាងមុន។ ទន្ទឹមនឹងនេះ ចំណែកនៃតម្លៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ដែលផ្តោតលើវិស័យកសិកម្ម មានចំនួន 6.9 ភាគរយ (100 លានដុល្លារ) កើនពី 2.9 ភាគរយ (34 លានដុល្លារ) ក្នុងរយៈពេលដូចគ្នា។ តម្លៃនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ដែលផ្តោតលើវិស័យទេសចរណ៍ មានចំនួន 1.8 ភាគរយ (26 លានដុល្លារ) ថយពី 43.3 ភាគរយ (500 លានដុល្លារ) នេះដោយសារការបាត់បង់ទំនុកចិត្តរបស់វិនិយោគិនដែលបណ្តាលមកពីការធ្លាក់ចុះខ្លាំងនៃវិស័យទេសចរណ៍នាពេលថ្មីៗនេះ។ ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 គម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តចំនួន 9.8 ភាគរយ (142 លានដុល្លារ) បានចូលទៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ កើនពី 9.0 ភាគរយ (104 លានដុល្លារ) ក្នុងរយៈពេលដូចគ្នានៅឆ្នាំ 2019។

**ចាប់ពីខែ មករា ឆ្នាំ 2014 ដល់ខែ មិថុនា ឆ្នាំ 2020 តម្លៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តច្រើនជាងគេ បានចូលទៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ ដែលមានទឹកប្រាក់ចំនួន 5.0 ពាន់លានដុល្លារ ឬស្មើនឹងមួយភាគបីនៃតម្លៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសសរុប** (រូប 10)។ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តច្រើនជាងគេទីពីរ បានចូលទៅក្នុងឧស្សាហកម្មក្រៅពីសម្លៀកបំពាក់ ដែលមានទឹកប្រាក់ 3.3 ពាន់លានដុល្លារ ឬស្មើនឹង 22 ភាគរយនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសសរុប។ ក្រៅពីនេះ តម្លៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តច្រើនជាងគេទីបី បានចូលទៅក្នុងវិស័យកាត់ដេរ មានទឹកប្រាក់ 2.5 ពាន់លានដុល្លារ ឬស្មើនឹង 17 ភាគរយនៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសសរុប។ លំហូ

**រូប 9៖ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត តាមវិស័យសំខាន់ៗ**

(% នៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 10៖ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តតាមវិស័យ**

(ពាន់លានដុល្លារ ខែ មករា ឆ្នាំ 2014-ខែ កក្កដា ឆ្នាំ 2020)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

---

[9] ក្រសួងទេសចរណ៍ និងកីឡានៃប្រទេសថៃ (https://www.mots.go.th/more_news_new.php?cid=527) ។

[10] យោងតាមធនាគារកណ្តាល លំហូរចូលការវិនិយោគផ្ទាល់ពីបរទេសចំនួន 1/3 ទៅក្នុងវិស័យហិរញ្ញវត្ថុ។

ចូលការវិនិយោគផ្ទាល់ពីបរទេសដែលផ្តោតលើវិស័យទេសចរណ៍ មាននៅឆ្នាំ 2016 ជាឆ្នាំដែលអនុញ្ញាតឱ្យបើកល្បែងស៊ីសងអនឡាញក្នុងរយៈពេលខ្លី និងជាឆ្នាំដែលវិស័យទេសចរណ៍ក្លាយជាវិស័យដែលស្រូបយកលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសច្រើនជាងគេ ដែលមានទឹកប្រាក់ 2.4 ពាន់លានដុល្លារ ឬស្មើនឹង 16 ភាគរយនៃការវិនិយោគផ្ទាល់ពីបរទេសសរុប។

**ការធ្វើពិពិធកម្មលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសគឺជាសញ្ញាល្អ។** ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម និងការកែច្នៃអាហារ ក៏មានការកើនឡើងដែរ។ ឧស្សាហកម្មទាំងនោះអាចទទួលបានប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន រួមទាំង ការផ្លាស់ទីតាំងឧស្សាហកម្មដែលគាំទ្រដល់ការពង្រីកយ៉ាងលឿននៃឧស្សាហកម្មទំនិញធ្វើដំណើរ និងស្បែកជើងរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការតភ្ជាប់បណ្តាញ កម្លាំងពលកម្មជំនាញ និងចំណាយលើថាមពល នៅតែជាចំណុចរាំងស្ទះដ៏ធំដែលប៉ះពាល់ដល់ការពង្រីក និងការបង្កើនការចូលរួមរបស់របស់កម្ពុជាក្នុងសង្វាក់តម្លៃសកល និងសង្វាក់តម្លៃក្នុងតំបន់។

### កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) តែម្យ៉ាង មិនអាចជំរុញកំណើនពាណិជ្ជកម្មទាំងស្រុងបានឡើយ

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) ត្រូវបានរំពឹងថានឹងទាក់ទាញលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមកកាន់ប្រទេសកម្ពុជា។** វិស័យមួយចំនួន ដូចជា កសិកម្ម ការកែច្នៃផលិតផលកសិកម្ម និងកម្មន្តសាល មានស្ថានភាពល្អប្រសើរសម្រាប់ការនាំចេញទៅកាន់ទីផ្សារប្រទេសចិន និងក្រៅពីនេះ (សូមមើលប្រអប់ 2 ស្តីពីការពិភាក្សាបន្ថែមអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន)។ ឧត្តមភាពប្រៀបធៀបរបស់កម្ពុជារួមមាន កម្លាំងពលកម្មដែលមិនទាន់ប្រើប្រាស់អស់លទ្ធភាព និងមានតម្លៃទាប និងធនធានដីធ្លីយ៉ាងច្រើនដែលសមស្របសម្រាប់ការផលិតទំនិញសំខាន់ និងប្រើកម្លាំងពលកម្មច្រើនសម្រាប់ការនាំចេញ ដែលផ្តល់ផលចំណេញតាមរយៈការធ្វើឯកទេសកម្ម និងវិមាត្រសេដ្ឋកិច្ច។ កត្តានេះនឹងជួយឱ្យកម្ពុជាពង្រីកខ្លួនលើសពីគំរូផលិតកម្មបច្ចុប្បន្នរបស់ខ្លួនដែលពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ក៏ដូចជា លើកកម្ពស់រចនាសម្ព័ន្ធសេដ្ឋកិច្ចឱ្យមានលក្ខណៈពិពិធកម្មកាន់តែខ្លាំង។

**ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) តែម្យ៉ាង មិនអាចជំរុញកំណើនពាណិជ្ជកម្ម និងដំណើរការសេដ្ឋកិច្ចរបស់កម្ពុជាទាំងស្រុងបានឡើយ។** លទ្ធផលរកឃើញដ៏សំខាន់មួយពីការសិក្សាការនាំចេញនាំចូលរបស់ប្រទេសម៉ិចស៊ិករបស់ Garces-Diaz (ឆ្នាំ 2001) ដែលមានចំណងជើងថា "តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) គឺជាចលករជំរុញកំណើនការនាំចេញរបស់ប្រទេសម៉ិចស៊ិក (1994-2000) ឬទេ?"[11] បង្ហាញពីការកែប្រែស្ថាប័នសំខាន់ៗ ដូចជា ការលុបចោលគោលនយោបាយពាណិជ្ជកម្មខុសប្រក្រតីជាមួយនឹងការបើកទូលាយសេដ្ឋកិច្ចក្រោយពេលដែលប្រទេសម៉ិចស៊ិកអនុលោមតាមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ដែលអនុញ្ញាតឱ្យក្រុមហ៊ុននាំចេញរបស់ម៉ិចស៊ិកទាញប្រយោជន៍ពីលក្ខខណ្ឌអនុគ្រោះពីខាងក្រៅ និងការពង្រីកសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។ ការសិក្សានេះបានក្រើនរម្លឹកថា ប្រទេសទាំងឡាយមិនគួរផ្តេកផ្តួលលើក្តីសង្ឃឹមមិនប្រាកដប្រជា នៅពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឡើយ។ ដូចគ្នានេះដែរ ការវាយតម្លៃទៅលើពាណិជ្ជកម្មសហរដ្ឋអាមេរិក-ម៉ិចស៊ិក ដោយការិយាល័យថវិកាសភាសហរដ្ឋអាមេរិក (ឆ្នាំ 2003) សន្និដ្ឋានថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង មានឥទ្ធិពលតិចតួចបំផុតលើលំហូរពាណិជ្ជកម្មទ្វេភាគី និងកំណត់ថា កំណើននៃការនាំចេញរបស់ប្រទេសម៉ិចស៊ិកទៅកាន់សហរដ្ឋអាមេរិកក្រោយឆ្នាំ 1994 បណ្តាលមកពីការធ្លាក់ថ្លៃប្រាក់ប៉េសូ និងភាពរីកចម្រើននៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក។ ការកែប្រែគោលនយោបាយនៅចុងទសវត្សរ៍ឆ្នាំ 1980 ដែលដាក់បញ្ចូលវិធានការបើកទូលាយទីផ្សារ និងកំណែទម្រង់សេដ្ឋកិច្ច បានជួយរក្សាស្ថិរភាពនៃលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសទៅក្នុងប្រទេសម៉ិច

**រូប 11៖ ការនាំចេញសម្ភារសាងសង់សំខាន់ៗ**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 12៖ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានអនុម័ត**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

11 Lederman, Maloney, and Servén 2003

ស៊ិក[12]។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (និងបទប្បញ្ញត្តិស្តីពីការវិនិយោគក្នុងកិច្ចព្រមព្រៀងនេះ) ប្រហែលជាបានជំរុញឱ្យមានការវិនិយោគផ្ទាល់ពីសហរដ្ឋអាមេរិកក្នុងប្រទេសម៉ិចស៊ិក តាមរយៈការបង្កើនទំនុកចិត្តរបស់វិនិយោគិន ប៉ុន្តែម៉ិចស៊ិកនៅតែសម្រេចបានកំណើនភាគច្រើន ដោយសារតែប្រទេសនេះចង់បន្តធ្វើសេរីភាវូបនីយកម្មច្បាប់វិនិយោគបរទេសរបស់ខ្លួន ដោយមាន ឬគ្មានកិច្ចព្រមព្រៀងនេះ។

## វិស័យសំណង់នៅតែថយចុះ ដោយសារការផ្គត់ផ្គង់លើសក្នុងពេលមានកំណើនខ្ពស់ពីមុនពេលមានវិបត្តិ

**សកម្មភាពសាងសង់នៅតែអន់ថយចាប់តាំងពីឆមាសទីមួយក្នុងឆ្នាំ 2020 មកម្លេះ។** តម្លៃនៃការនាំចូលដែកថែបថយចុះ 45.1 ភាគរយ ហើយស៊ីម៉ង់ត៍ថយចុះ 8.3 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 6 ខែដំបូងក្នុងឆ្នាំ 2020 ព្រោះគម្រោងអភិវឌ្ឍន៍ធំៗមួយចំនួន ជាពិសេសអគារពាណិជ្ជកម្ម និងអគារលំនៅដ្ឋានខ្ពស់ៗ ត្រូវបានផ្អាក។ គិតត្រឹមខែ កញ្ញា ឆ្នាំ 2020 ការនាំចូលដែកថែប និងស៊ីម៉ង់ត៍ បន្តថយចុះ។ ក្នុងនោះ ការនាំចូលដែកថែបថយចុះ 41.4 ភាគរយ ចំណែកការនាំចូលស៊ីម៉ង់ត៍ថយចុះ 38.1 ភាគរយ (ធៀបនឹងឆ្នាំមុន) (រូប 11)។ ដោយសារតែវិស័យសំណង់ (និងអចលនទ្រព្យ) គឺជាម៉ាស៊ីនកំណើនដ៏ធំជាងគេរបស់កម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការថយចុះនៃសកម្មភាពសាងសង់ និងអចលនទ្រព្យធ្វើឱ្យកំណើនពិតថយចុះក្នុងរយៈពេលខ្លី។ តម្លៃនៃអាជ្ញាប័ណ្ណអនុញ្ញាតសាងសង់ដែលត្រូវបានអនុម័តដែលមានចំនួន 98.3 ភាគរយកាលពីឆ្នាំមុន ថយចុះមកត្រឹម 9.3 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 (រូប 12) ដោយសារតែស្ថានភាពវិនិយោគមិនសូវអនុគ្រោះ ព្រោះថា ទីផ្សារអចលនទ្រព្យមានការវិនិយោគច្រើនពេក និងការផ្គត់ផ្គង់លើសតាំងពីមុនពេលមានវិបត្តិជំងឺកូវីដ 19។

## មានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើវិស័យកសិកម្ម ដែលរងផលប៉ះពាល់តិចតួចបំផុតដោយសារជំងឺរាតត្បាត

**វិស័យកសិកម្មកំពុងទទួលប្រយោជន៍ពីការកើនឡើងភាពទំនេរនៃកម្លាំងពលកម្ម ដែលត្រូវបានរំសាយពីវិស័យសេវា និងឧស្សាហកម្ម។** ដូចបានពិភាក្សាខាងលើ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ត្រូវបានរំពឹងថានឹងជំរុញកំណើនពាណិជ្ជកម្ម និងការវិនិយោគក្នុងប្រទេសកម្ពុជាសម្រាប់ការនាំចេញទៅកាន់ទីផ្សារប្រទេសចិន។ បន្ថែមបច្ចេកទេសដាំដុះទំនើប និងជម្រើសគ្រាប់ពូជថ្មីៗតាមរយៈការចែករំលែក បច្ចេកវិទ្យាពីការវិនិយោគផ្ទាល់ពីបរទេស កំពុងជួយជំរុញផលិតភាពរបស់ដំណាំសំខាន់ៗ។ នៅខែ ធ្នូ ឆ្នាំ 2019 អាជ្ញាធរកម្ពុជាបានអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម 2019-2025 ដែលមានគោលបំណងធ្វើទំនើបកម្មវិស័យកសិកម្ម ក៏ដូចជា ធ្វើយ៉ាងណាឱ្យតម្លៃបន្ថែមកសិកម្មសរុប(តម្លៃណូមីណល) កើនចំនួន 4 ភាគរយក្នុងមួយឆ្នាំ ឬស្មើនឹងទឹកប្រាក់ 25,700 ពាន់លានរៀលនៅឆ្នាំ 2023 កើនពីចំនួន 21,913 ពាន់លានរៀលនៅឆ្នាំ 2018។ ការធ្វើទំនើបកម្មវិស័យកសិកម្មគឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការពន្លឿនការប្រែក្លាយវិស័យកសិកម្មកម្ពុជា ពីកសិកម្មចិញ្ចឹមក្រពះទៅជាកសិកម្មពាណិជ្ជកម្ម។ ទោះជាយ៉ាងណាក៏ដោយ អត្រាកំណើនតម្លៃបន្ថែមកសិកម្មសរុបចំនួន 4 ភាគរយក្នុងមួយឆ្នាំគិតជាតម្លៃណូមីណល ហាក់ជាចំណុចដៅដែលមិនសូវខ្ពស់ ព្រោះថា កំណើនតម្លៃបន្ថែមកសិកម្មសរុបជាមធ្យមគឺ 3.9 ភាគរយក្នុងរយៈពេល 5 ឆ្នាំ និង 4.8 ភាគរយក្នុងរយៈពេល 10 ឆ្នាំកន្លងមក (រូប 13)។

## ការនាំចេញស្រូវ/អង្ករកើនឡើងយ៉ាងឆាប់រហ័ស ដោយសារកើនឡើងតម្រូវការ

**ក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020 ការនាំចេញអង្កររបស់កម្ពុជា (ក្នុងនោះ អង្ករក្រអូបមានប្រមាណ 80 ភាគរយ)** បានកើនឡើងចំនួន 38.3 ភាគរយធៀបនឹងឆ្នាំមុន ធ្វើឱ្យការនាំចេញអង្ករសម្រេចបាន 0.48 លានតោន (រូប 14)។ ចិនជាទីផ្សារនាំចូលអង្ករច្រើនជាងគេបំផុត ដោយបាននាំចូលអង្ករ 35.5

**រូប 13៖ តម្លៃបន្ថែមកសិកម្មសរុបណូមីណល**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 14៖ ការនាំចេញអង្ករ ការប្រៀបធៀបក្នុងតំបន់**
(គិតជាបរិមាណ ការប្រែប្រួលភាគរយនៅឆ្នាំនេះធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា និង Haver Analytics*

*សម្គាល់ ៖ សម្រាប់ប្រទេសថៃ មានតែអង្ករផ្កាម្លិះប៉ុណ្ណោះដែលត្រូវបានរាប់បញ្ចូល។*

[12] Congressional Research Service 2020

**ប្រអប់ 2 ៖**

## កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន[a]

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី 12 ខែ តុលា ឆ្នាំ 2020 ត្រូវបានរំពឹងថានឹងចូលជាធរមាននៅដើមឆ្នាំ 2021។** កិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTA) ធំដំបូងគេបង្អស់របស់កម្ពុជា ជាមួយដៃគូពាណិជ្ជកម្មដ៏សំខាន់បំផុតរបស់ខ្លួន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ក៏ជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីដំបូងគេបង្អស់របស់ចិនជាមួយប្រទេសសមាជិកអាស៊ានផងដែរ។ ទោះជាការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន គ្របដណ្តប់លើពន្ធនាំចេញនាំចូលជាង 10,800 សម្រាប់កម្ពុជា និងពន្ធនាំចេញនាំចូលចំនួន 9,530 សម្រាប់ចិន កិច្ចព្រមព្រៀងនេះផ្តោតសំខាន់លើពន្ធនាំចេញនាំចូល លើសពីអ្វីដែលត្រូវបានផ្តល់ជូនក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ខែ មករា ឆ្នាំ 2010)។ ក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន មានការព្រមព្រៀងលើពន្ធនាំចេញនាំចូលចំនួន 340 បន្ថែមទៀត (4 ភាគរយនៃចំនួនពន្ធនាំចេញនាំចូលសរុប) ដែលគ្របដណ្តប់ភាគច្រើនលើជំពូក 1-10 នៃអត្រាពន្ធនាំចូលជាប្រព័ន្ធសម្គាល់របស់អាស៊ានសម្រាប់កម្ពុជា (AHTN) មានចាប់ពីសត្វរស់/ផលិតផលសត្វរហូតដល់សាច់សត្វ ត្រី និងគ្រាប់ធុញ្ញជាតិ (តារាង B2.1)។

**បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ចូលជាធរមាន ពន្ធនាំចេញនាំចូលចំនួន 98 ភាគរយរបស់ចិន និងពន្ធនាំចេញនាំចូលជិត 90 ភាគរយរបស់កម្ពុជានឹងត្រូវបានដកចេញទាំងស្រុងភ្លាមៗ។** ក្រៅពីនេះ សមិទ្ធផលសំខាន់ៗរួមមាន ការធ្វើឱ្យនីតិវិធីនាំចេញ-នាំចូលមានភាពសាមញ្ញ យន្តការច្បាស់លាស់ និងមានតម្លាភាពសម្រាប់ការដោះស្រាយវិវាទ និងការរៀបចំពាណិជ្ជកម្មអេឡិចត្រូនិក (e-commerce)។ មានសេចក្តីរាយការណ៍ថា កម្ពុជានឹងបើកទូលាយវិស័យសេវារបស់ខ្លួនលើផ្នែកស្រាវជ្រាវ អប់រំ និងការដឹកជញ្ជូនសមុទ្រក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន លើសពីអ្វីដែលកម្ពុជាបានបើកទូលាយជាមួយចិន តាមរយៈការចូលរួមរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ចិន។ ចិននឹងបើកចំហរវិស័យធានារ៉ាប់រង អប់រំ និងទីផ្សាររបស់ខ្លួន។ល។ បច្ចុប្បន្ន ចិនគឺជាទីផ្សារនាំចេញទំនិញធំជាងគេទីបួនសម្រាប់ផលិតផលកសិកម្មធម្មតា និងផលិតផលដែលតម្លៃបន្ថែមក្នុងស្រុកមានតម្លៃទាបរបស់កម្ពុជា ដោយគ្របដណ្តប់លើការនាំចេញទំនិញចំនួន 6.8 ភាគរយនៃការនាំចេញទំនិញសរុប (ប៉ុន្តែមានចំនួនត្រឹមតែ 0.05 ភាគរយនៃការនាំចូលសរុបរបស់ចិន)។ ទីផ្សារនាំចេញធំៗសំខាន់ៗ ៣ ផ្សេងទៀតរបស់កម្ពុជា គឺ សហរដ្ឋអាមេរិក (29.8 ភាគរយ) ជប៉ុន (7.7 ភាគរយ) និងអាល្លឺម៉ង់ (7.3 ភាគរយ) ដែលសរុបគ្នាមានទំហំទឹកប្រាក់ 1.01 ពាន់លានដុល្លារ។ នៅឆ្នាំ 2019 ការនាំចូលរបស់កម្ពុជាពីប្រទេសចិនមានទំហំទឹកប្រាក់ 7.58 ពាន់លានដុល្លារ ដែលធ្វើឱ្យចិនក្លាយជាទីផ្សារនាំចូលធំជាងគេរបស់កម្ពុជា (37.4 ភាគរយនៃការនាំចូលសរុប)។

***ភាគច្រើននៃការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសចិន គឺជាផលិតផលកសិកម្មធម្មតា ឬផលិតផលដែលមានតម្លៃបន្ថែមក្នុងស្រុកទាប។*** ស្បែកសត្វធម្មជាតិ និងរោមសត្វសិប្បនិម្មិត គឺជាផលិតផលនាំចេញច្រើនជាងគេរបស់កម្ពុជា ដែលមានចំនួន 25 ភាគរយនៃការនាំចេញសរុបទៅកាន់ប្រទេសចិន (252.9 លានដុល្លារ) (តារាង B2.2)។ ទោះជាយ៉ាងណា កម្ពុជាបាននាំចូលទាំងស្រុងនូវស្បែកឆៅ រួមទាំង ក្បាល កន្ទុយ និងក្រចក/ក្រញ៉ាំពីប្រទេសដាណឺម៉ាក (202.9 លានដុល្លារ)។ ទន្ទឹមនឹងនេះ សម្លៀកបំពាក់ និងក្រណាត់ ទាំងដេរប៉ាក់ និងចាក់ (HS 61) មានចំនួន 19.5 ភាគរយ (197.4 លានដុល្លារ) នៃការនាំចេញសរុបទៅកាន់ប្រទេសចិន ប៉ុន្តែ កម្ពុជានាំចូលទាំងស្រុងនូវក្រណាត់ដេរប៉ាក់ ឬចាក់ (HS60) ដែលមានទំហំទឹកប្រាក់ 1.5 ពាន់លានដុល្លារ (នៃទឹកប្រាក់សរុប 2.68 ពាន់លានដុល្លារ) ពីប្រទេសចិនសម្រាប់ការកែច្នៃ ដែលភាគច្រើនជាប្រតិបត្តិការកាត់ដេរធម្មតា។ អង្ករជាផលិតផលច្រើនជាងគេទីបីដែលកម្ពុជានាំចេញទៅប្រទេសចិន ដែលមានចំនួន 15.4 ភាគរយ (ឬ 156.2 លានដុល្លារ)។ កម្ពុជាពឹងផ្អែកកាន់តែខ្លាំងលើលំហូរការវិនិយោគរបស់ចិន ដែលភាគច្រើនប្រមូលផ្តុំក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ ក្នុងចំណោមភ្ញៀវទេសចរអន្តរជាតិសរុបចំនួន 6.6 លាននាក់ ដែលមកទស្សនាកម្ពុជានៅឆ្នាំ 2019 ភ្ញៀវទេសចរអន្តរជាតិជាង 1/3 (35.7 ភាគរយ) ជាភ្ញៀវទេសចរចិន។ ក្នុងចំណោមភ្ញៀវទេសចរចិនទាំងនេះ ភ្ញៀវទេសចរជិតពាក់កណ្តាល (44.3 ភាគរយ) ចូលមកកម្ពុជាដើម្បីធ្វើជំនួញ។

**កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងបណ្តាប្រទេសនានា ដែលកាត់បន្ថយរបាំងពាណិជ្ជកម្មលើទំនិញនាំចូល បង្កើនសុខុមាលភាពរបស់អ្នកប្រើប្រាស់ ព្រោះអ្នកប្រើប្រាស់អាចរកទិញទំនិញច្រើនមុខ ទទួលបានទំនិញដែលមានគុណភាពកាន់តែល្អ និងតម្លៃទាបជាងមុន ហើយបង្កើតជាជំនួញ។** ដូចគ្នានឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាលើកដំបូងរបស់ចិនជាមួយរដ្ឋសមាជិកអាស៊ានផ្សេងទៀតដែរ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ក៏អាចផ្តល់ប្រយោជន៍ដល់កម្ពុជាផងដែរតាមរយៈការបង្វែរពាណិជ្ជកម្មពីបណ្តាប្រទេសអាស៊ានផ្សេងទៀត។ យោងតាមការព្យាករផ្លូវការ ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសចិននឹងកើនចំនួន 25 ភាគរយ ហើយការនាំចេញរបស់ចិននឹងកើនចំនួន 23 ភាគរយ ក្រោយពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះចូលជាធរមាន។ ក្រៅពីនេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន អាចឱ្យកម្ពុជាក្លាយជាទិសដៅដែលទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដែលផ្តោតលើទីផ្សារចិន ជាងប្រទេសជិតខាង។ ការសម្រេចបានអត្ថប្រយោជន៍ទាំងនេះអាស្រ័យលើចំណុចផ្សេងៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ដែលមិនទាន់បានផ្សព្វផ្សាយឱ្យដឹង។

**តារាង B2.1៖ ជំពូក1-10 នៃកាលវិភាគពន្ធគយរបស់កម្ពុជា**

| |
|---|
| 1. សត្វរស់ |
| 2. សាច់សត្វ និងកំទេចសាច់សត្វដែលអាចទទួលទានបាន |
| 3. ត្រី និងសត្វខ្នងជាតិ សិប្បីសត្វ និងសត្វទឹកគ្មានឆ្អឹងខ្នងផ្សេងទៀត |
| 4. ផលិតផលទឹកដោះគោ ស៊ុតបក្សី ទឹកឃ្មុំធម្មជាតិ ផលិតផលសត្វដែលអាចទទួលទានបាន ដែលមិនត្រូវបានកំណត់ ឬរាប់បញ្ចូលនៅកន្លែងផ្សេងទៀត |
| 5. ផលិតផលសត្វ ដែលមិនត្រូវបានកំណត់ ឬរាប់បញ្ចូលនៅកន្លែងផ្សេងទៀត |
| 6. ដើមឈើរស់ និងរុក្ខជាតិផ្សេងទៀត មើមរុក្ខជាតិ ឫស។ល។ ផ្កា និងស្លឹកឈើលំអរ |
| 7. បន្លែ និងឫស ឬមើមមួយចំនួនដែលអាចញ៉ាំបាន |
| 8. ផ្លែឈើ និងផ្លែឈើសំបករឹងដែលអាចទទួលទានបាន សំបកក្រូចឆ្មារ ឬត្រសក់ស្រូវ |
| 9. កាហ្វេ តែ អំបូរស្រដៀងគ្នានេះ និងគ្រឿងទេស |
| 10.គ្រាប់ធុញ្ញជាតិ |

*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**តារាង B2.2៖ ផលិតផលនាំចេញសំខាន់ៗទាំង 7 របស់កម្ពុជា (HS4) ទៅកាន់ប្រទេសចិន និងផលិតផលនាំចូលពីប្រទេសចិន**

| ផលិតផលដែលកម្ពុជានាំចេញទៅកាន់ប្រទេសចិន | | | ផលិតផលដែលកម្ពុជានាំចូលពីប្រទេសចិន | | |
|---|---|---|---|---|---|
| HS4 | ស្លាកផលិតផល | ចំណែក (%) | HS4 | ស្លាកផលិតផល | ចំណែក (%) |
| 4302 | ស្បែកសត្វធម្មជាតិ និងរោមសត្វសិប្បនិម្មិត កម្មន្តសាល | 25.0 | 6004/06 | ក្រណាត់ដេរប៉ាក់ ឬចាក់ | 20.5 |
| 6103/04/09/10/11 | សម្លៀកបំពាក់ និងក្រណាត់ (ដេរប៉ាក់ ឬចាក់) | 19.5 | 5509/10/15 | ជាតិសរសៃធ្វើដោយមនុស្ស | 10.2 |
| 1006 | គ្រាប់ធុញ្ញជាតិ | 15.4 | 8413/19/28/29/51 | គ្រឿងម៉ាស៊ីន ឧបករណ៍មេកានិក ម៉ាស៊ីនរ៉េអាក់ទ័រនុយក្លេអ៊ែរ ឆ្នាំងដាំទឹក គ្រឿងបន្លាស់ | 10.0 |
| 8501/04/17 | គ្រឿងម៉ាស៊ីន និងបរិក្ខារអេឡិចត្រូនិក និងគ្រឿងបន្លាស់ ឧបករណ៍ថត និងបញ្ចេញសំឡេង ទូរទស្សន៍... | 7.4 | 8504/17/36/39/41/44 | គ្រឿងម៉ាស៊ីន និងបរិក្ខារអេឡិចត្រូនិក និងគ្រឿងបន្លាស់ឧបករណ៍ថត និងបញ្ចេញសំឡេងទូរទស្សន៍... | 8.1 |
| 6203/04 | សម្លៀកបំពាក់ និងក្រណាត់ (មិនដេរប៉ាក់ ឬចាក់) | 6.5 | 5208/09/11 | កប្បាស | 6.8 |
| 6403/04 | ស្បែកជើង ស្រោមជើងវែង។ល។ ផ្នែកនៃផលិតផលទាំងនេះ | 5.1 | 7304/08/18/26 | ផលិតផលលោហធាតុ ឬដែកថែប | 4.8 |
| 7401/02 | ទង់ដែង និងផលិតផលពាក់ព័ន្ធ | 3.3 | 3921/23/26 | ផ្លាស្ទិក និងផលិតផលពាក់ព័ន្ធ | 4.4 |
| **សរុបទំនិញនាំចេញច្រើនជាងគេទាំង 7 មុខ** | | 82.2 | **សរុបទំនិញនាំចូលច្រើនជាងគេទាំង 7 មុខ** | | 86.3 |

*ប្រភព ៖ UN Comtrade*

*សម្គាល់ ៖ a.ត្រូវបានរៀបចំឡើងដោយក្រុមការងារផ្នែកម៉ាក្រូសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគសកល។*

ភាគរយនៃបរិមាណអង្ករសរុបដែលកម្ពុជានាំចេញ ចំណែកទីផ្សារសហភាពអឺរ៉ុបជាទីផ្សារធំទីពីររបស់កម្ពុជា ដោយបាននាំចូលអង្ករមួយភាគបីនៃការនាំចេញអង្ករសរុប។ ទោះជាមានការដាក់វិធានការធានាសុវត្ថិភាពរបស់សហភាពអឺរ៉ុបលើការនាំចេញអង្កររបស់កម្ពុជាក្តី ក៏ការនាំចេញអង្កររបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប (រាប់បញ្ចូលចក្រភពអង់គ្លេស) មានចំនួនទៅដល់ 150,000 តោន ឬកើន 25 ភាគរយធៀបនឹងឆ្នាំមុន (ក្នុងនោះអង្ករជាងមួយភាគបីត្រូវបាននាំចូលដោយប្រទេសបារាំងតែឯង) ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020។ លំហូរចូលការវិនិយោគផ្ទាល់ពីបរទេស ការវិនិយោគសាធារណៈ និងការវិនិយោគឯកជនលើវិស័យកសិកម្ម បានកើនឡើង ដោយសារមានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍ និងធ្វើពិពិធកម្មវិស័យកសិកម្ម។ ក្រៅពីផលិតស្រូវ ដំឡូងមី និងកៅស៊ូដែលជាផលិតផលប្រពៃណី ការនាំចេញផលិតផលកសិកម្មថ្មីៗរបស់កម្ពុជា ដូចជា ចេក និងស្វាយ ក៏កំពុងបង្ហាញពីសញ្ញាវិជ្ជមានផងដែរ។

### ផលិតកម្មស្រូវកើនឡើង

**ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 ផ្ទៃដីដាំដុះស្រូវវស្សាមានទំហំ 2.28 លានហិកតា ឬមានកំណើន 7.2 ភាគរយធៀបនឹងឆ្នាំមុនដោយសារតែស្ថានភាពធាតុអាកាសល្អប្រសើរ[13]។** ការប្រមូលផលស្រូវប្រាំងកើនឡើងមានចំនួនដល់ 0.26 លានតោន ឬកើន 38.8 ភាគរយធៀបនឹងឆ្នាំមុន[14]។ ទោះជាយ៉ាងណាក៏ដោយ ទិន្នផលស្រូវប្រាំងមានចំនួន 4.2 តោន/ហិកតា ថយពី 4.4 តោន/ហិកតា នៅឆ្នាំ 2019។ គួរកត់សម្គាល់ថា ដំណើរការផលិតកម្ម និងការនាំចេញទំនិញកសិកម្មផ្សេងទៀត មានលក្ខណៈចម្រុះ។ ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 ផលិតកម្មកៅស៊ូថយចុះដល់ 100,000 តោន ថយចុះ 10.9 ភាគរយ។ ក្រៅពីនេះ គ្រោះទឹកជំនន់កាលពីខែ តុលា បានធ្វើឱ្យបាត់បង់ជីវិតមនុស្ស បំផ្លិចបំផ្លាញដំណាំ ខូចខាតទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ល។

**ផលិតកម្មដំណាំ ជាពិសេសស្រូវ នៅតែរួមចំណែកច្រើនជាងគេ (60 ភាគរយ) ដល់ផលិតផលកសិកម្មក្នុងស្រុកសរុប។** កម្ពុជាទទួលបានជោគជ័យតិចតួចក្នុងការធ្វើពិពិធកម្មផលិតផលកសិកម្មទៅជាដំណាំ ផលនេសាទ និងបសុសត្វ ដែលមានតម្លៃបន្ថែមខ្ពស់ ដោយសារតែភាពយឺតយ៉ាវក្នុងការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មទំនើប ដូចជា ការប្រើប្រាស់ធាតុចូល និងធារាសាស្ត្រ[15]។

### ជំងឺកូវីដ 19 ប៉ះពាល់យ៉ាងខ្លាំងលើតម្រូវការក្នុងស្រុក និងកាត់បន្ថយការប្រើប្រាស់

**កង្វះទំនុកចិត្តរបស់អ្នកប្រើប្រាស់ធ្វើឱ្យតម្រូវការក្នុងស្រុកថយចុះ ជាហេតុនាំឱ្យការនាំចូលថយចុះ។** ការនាំចូលទំនិញអាចប្រើប្រាស់បាន និងទំនិញជាប់ធន់ ថយចុះក្នុងរយៈពេល 9 ខែដំបូងក្នុងឆ្នាំ 2020។ ទំនិញជាប់ធន់សំខាន់ៗដែលកម្ពុជានាំចូល ដូចជា យានយន្តធ្វើដំណើរថយចុះ 34.1 ភាគរយ និងម៉ូតូថយចុះ 39.5 ភាគរយ (ធៀបនឹងឆ្នាំមុន) ខណៈដែលការនាំចូលប្រេងសាំងមានចំនួន 0.3 ភាគរយ និងប្រេងម៉ាស៊ូតមានចំនួន 2.7 ភាគរយ ដែលមានកម្រិតទាប។ ការនាំចូលគ្រឿងឧបភោគបរិភោគថយចុះ 16.8 ភាគរយ និងសម្ភារៈអេឡិចត្រូនិក (ទូរស័ព្ទចល័ត និងទូរទស្សន៍) ថយចុះ 45.9 ភាគរយ។ ដោយសារតែការថយចុះការនាំចេញមិនអាចប៉ះប៉ូវការនាំចូលបាន ឱនភាពពាណិជ្ជកម្មត្រូវបានរំពឹងថានឹងកើនឡើង។ ប្រាក់បញ្ញើរបស់កម្មករ (លំហូរចូល) ថយចុះ 4.6 ភាគរយ ឬស្មើនឹង 550 លានដុល្លារក្នុងរយៈពេល 6 ខែដំបូងក្នុងឆ្នាំ 2020។ ដូច្នេះ ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងមានចំនួន 12.8 ភាគរយនៃ ផសស នៅឆ្នាំ 2020 កើនពី 10 ភាគរយនៃ ផសស នៅឆ្នាំ 2019។ ការកើនឡើងនេះត្រូវបានរំពឹងថានឹងទទួលបានហិរញ្ញប្បទានពីលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស។

### ទុនបម្រុងជារូបិយប័ណ្ណបរទេសបានបន្តកើនឡើង

**ស្ថានភាពក្រៅប្រទេសរបស់កម្ពុជានៅតែមានស្ថិរភាពជារួម ខណៈដែលទុនបម្រុងអន្តរជាតិរបស់កម្ពុជាបន្តកើនឡើង។** ទុនបម្រុងអន្តរជាតិសរុប (ដែលស្មើនឹងទុនបម្រុងអន្តរជាតិដុល ដោយសារតែកម្ពុជាមិនខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ) បានបន្តកើនឡើង មានចំនួន 19.5 ពាន់លានដុល្លារនៅខែ មិថុនា ឆ្នាំ 2020 កើន 21.7 ភាគរយ (ធៀបនឹងឆ្នាំមុន) (រូប 15) ឬស្មើនឹងការនាំចូលរយៈពេល 10 ខែ។ ប្រាក់បម្រុងជារូបិយប័ណ្ណបរទេស ដែលជាចំនួនច្រើននៅក្នុងទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជា (និងតម្លៃនៃទុនបម្រុងជាមាស) កើនឡើងនៅអំឡុងឆមាសទីមួយក្នុងឆ្នាំ 2020 ដោយសារការបន្តលំហូរចូលមូលធន (សូមមើលការពិភាក្សាលម្អិតស្តីពីរូបិយវត្ថុទូលាយនៅផ្នែកខាងក្រោម)។ ផ្អែកតាមរូប 15 ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក មានសេណារីយ៉ូពីរដែលកាត់បន្ថយកំណើនទុនបម្រុងអន្តរជាតិរបស់កម្ពុជា។ ទីមួយ កំណើនទុនបម្រុងអន្តរជាតិរបស់កម្ពុជាមានចំនួនត្រឹមតែ 2.3 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ កក្កដា ឆ្នាំ 2009 ដោយសារតែវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-2009។ ទីពីរ កំណើនទុនបម្រុងអន្តរជាតិរបស់កម្ពុជាថយចុះ 7.7 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ កញ្ញា ឆ្នាំ 2013 ដោយសារភាពមិនប្រាកដប្រជាផ្នែកនយោបាយក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ 2013។ ការប្រៀបធៀបក្នុងតំបន់បង្ហាញថា កម្ពុជានៅតែរក្សាបានកំណើនទុនបម្រុងជារូបិយប័ណ្ណអន្តរជាតិ ល្អប្រសើរជាងប្រទេសសមាជិកអាស៊ានផ្សេងទៀត។ អត្រាកំណើនធៀបនឹងឆ្នាំមុននៃទុនបម្រុងជារូបិយប័ណ្ណបរទេសរបស់កម្ពុជា កើនឡើងលឿនជាងអត្រាកំណើននៃទុនបម្រុងជារូបិយប័ណ្ណបរទេសរបស់ប្រទេសថៃ ហ្វីលីពីន និង

13 ការព្យាករធាតុអាកាសសម្រាប់ឆ្នាំ 2020 ថ្ងៃទី 14 ខែ មេសា ឆ្នាំ 2020 និងការព្យាករណ៍ធាតុអាកាសប្រចាំសប្តាហ៍ ក្រសួងធនធានទឹក និងឧតុនិយម។

14 របាយការណ៍ប្រចាំខែ កក្កដា ឆ្នាំ 2020 ស្តីពីផលិតកម្មកសិកម្ម ថ្ងៃទី 4 ខែ សីហា ឆ្នាំ 2020 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

15 សូមមើល ធនាគារពិភពលោក ឆ្នាំ 2015a។

ឥណ្ឌូណេស៊ី (រូប 16)។

**អតិផរណានៅតែមានកម្រិតទាប ដោយសារអត្រាអតិផរណាទាបក្នុងចំណោមដៃគូនាំចូល និងស្ថិរភាពអត្រាប្តូរប្រាក់**

**អតិផរណាគោលមានចំនួន 2.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ កញ្ញា ឆ្នាំ 2020 ថយពី 3.1 ភាគរយនៅបំណាច់ឆ្នាំ 2019។** ការកើនឡើងនៃសន្ទស្សន៍រងស្តីពីស្បៀងអាហារ ត្រូវបានប៉ះប៉ូវដោយការថយចុះសន្ទស្សន៍រងស្តីពីការធ្វើដំណើរ (និងទូរគមនាគមន៍) (រូប 17)។ ការឡើងថ្លៃម្ហូបអាហារ ជាពិសេស សាច់ជ្រូក សាច់គោ និងត្រី បណ្តាលមកពីការកើនឡើងនៃតម្រូវការ និងការបង្អាក់ការផ្គត់ផ្គង់ដោយសារវិបត្តិជំងឺកូវីដ 19។ យោងតាម "ទស្សនវិស័យតម្លៃស្បៀងអាហារឆ្នាំ 2020" ដែលបោះពុម្ពផ្សាយដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក តម្លៃស្បៀងអាហារថយចុះយឺតៗពីអត្រាខ្ពស់ ដោយសារវិបត្តិជំងឺកូវីដ 19។ ទោះជាយ៉ាងណា តម្លៃផលិតផលប្រេងឆៅថយចុះដោយសារការរឹតត្បិតការធ្វើដំណើរ។ គិតត្រឹមខែ កញ្ញា ឆ្នាំ 2020 សន្ទស្សន៍រងស្តីពីស្បៀងអាហារ និងភេសជ្ជៈមិនមែនគ្រឿងស្រវឹង ក្នុងកន្ត្រកអតិផរណារបស់កម្ពុជា បានកើនឡើងថែមទៀតទៅ 4.6 ភាគរយ (ធៀបនឹងឆ្នាំមុន) កើនពី 3.4 ភាគរយនៅខែ ធ្នូ ឆ្នាំ 2019។ ក្នុងអំឡុងពេលដូចគ្នានេះ សន្ទស្សន៍រងស្តីពីលំនៅដ្ឋាន និងទឹក-ភ្លើង ថយចុះ 1.2 ភាគរយ ថយពី 1.6 ភាគរយ ខណៈដែលសន្ទស្សន៍រងស្តីពីការធ្វើដំណើរ និងទូរគមនាគមន៍ធ្លាក់មកចំនួនអវិជ្ជមាន 4.5 ភាគរយ ថយពី 1.7 ភាគរយ។

**ការថយចុះអតិផរណាក្នុងចំណោមដៃគូនាំចូលរបស់កម្ពុជា និងស្ថិរភាពអត្រាប្តូរប្រាក់បានជួយទប់សម្ពាធតម្លៃក្នុងស្រុក។** មានកត្តាសំខាន់ៗពីរដែលមានឥទ្ធិពលលើថ្លៃទំនិញក្នុងស្រុកនៅកម្ពុជា។ ទីមួយ កម្ពុជាជាប្រទេសនាំចូលទំនិញ ជាពិសេស ទំនិញប្រើប្រាស់ ដូចជា គ្រឿងឧបភោគបរិភោគពីប្រទេសជិតខាង ជាអាទិ៍ វៀតណាម ថៃ និងចិន។ ដូច្នេះ ជាញឹកញាប់ ការកើនឡើងនៃអត្រាអតិផរណាក្នុងប្រទេសដៃគូនាំចូលសំខាន់ៗទាំងនោះ ធ្វើឱ្យអតិផរណានៅកម្ពុជាកើនឡើង (អតិផរណាដោយសារការនាំចូល)។ ការថយចុះនៃអតិផរណាក្នុងចំណោមដៃគូនាំចូលសំខាន់របស់កម្ពុជា ជួយទប់សម្ពាធថ្លៃនៅកម្ពុជា។ ទីពីរ តម្លៃលួមីណលនៃប្រាក់រៀលខ្មែរធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ ប្រាក់ដុងវៀតណាម និងប្រាក់យន់ចិន ធ្វើឱ្យប៉ះពាល់ដល់អតិផរណានៅកម្ពុជា ព្រោះក្រុមហ៊ុនផ្គត់ផ្គង់ និងពាណិជ្ជករក្នុងស្រុកគណនាដោយផ្អែកលើការធ្លាក់ថ្លៃប្រាក់រៀលខ្មែរ។ អតិផរណាកើនឡើងនៅពេលប្រាក់រៀលធ្លាក់ថ្លៃ។ ដូច្នេះ ស្ថិរភាពអត្រាប្តូរប្រាក់រៀលខ្មែរធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់ដុងវៀតណាម ប្រាក់បាតថៃ និងប្រាក់យន់ចិន ជួយទប់អតិផរណាក្នុងស្រុក។ អតិផរណានៅប្រទេសវៀតណាមថយចុះចំនួន 3.2 ភាគរយធៀបនឹងឆ្នាំមុន នៅខែ សីហា ឆ្នាំ 2020 ដោយសារការធ្លាក់ថ្លៃម្ហូបអាហារ និងការថយចុះតម្រូវការ[16]។ នៅប្រទេសថៃ អតិផរណាបានស្រកចុះបែបអវិជ្ជមានចំនួន 0.5 ភាគរយនៅខែ សីហា ឆ្នាំ 2020 ដោយសារការបញ្ចុះថ្លៃទឹក-ភ្លើងសាធារណៈ និងតម្លៃថាមពល។ នៅប្រទេសចិន អតិផរណាគោលមានចំនួន 2.4 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ សីហា ឆ្នាំ 2020 ថយពី 4.0 ភាគរយនៅខែ មីនា ឆ្នាំ 2020 ព្រោះអតិផរណាស្បៀងអាហារថយចុះ។ សេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្លាំង។ ដូច្នេះ ការទម្លាក់ថ្លៃរូបិយវត្ថុក្នុងស្រុកដែលជាញឹកញាប់ ធ្វើឱ្យអតិផរណាកើនឡើង មិនអាចធ្វើទៅរួចឡើយ ទោះក្នុងកាលៈទេសៈណាក៏ដោយ ព្រោះវានឹងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មទាំងស្រុង។

**ប្រាក់រៀលឡើងថ្លៃបន្តិចធៀបនឹងប្រាក់បាតថៃ ប៉ុន្តែធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ប្រាក់យន់ចិន និងប្រាក់ដុងវៀតណាម។** អត្រាប្តូរប្រាក់រៀលក្នុងមួយបាត គឺ 130.5 រៀលនៅបំណាច់ខែ កញ្ញា ឆ្នាំ 2020 ថយពី 136.0 រៀលនៅខែ ធ្នូ ឆ្នាំ 2019។ ទោះជាយ៉ាងណាក៏ដោយ អត្រាប្តូរប្រាក់រៀលក្នុងមួយដុល្លារអាមេរិក គឺ 4,095 រៀល (កើនពី 4,075

**រូប 15៖ ទុនបម្រុងអន្តរជាតិរបស់កម្ពុជា (ពាន់លានដុល្លារ)**




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

*សម្គាល់ ៖ NIR=ទុនបម្រុងអន្តរជាតិសរុប, RHS=ខាងស្តាំ*

**រូប 16៖ ទុនបម្រុងអន្តរជាតិ-ការប្រៀបធៀបក្នុងតំបន់ (ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)**




*ប្រភព ៖ អាជ្ញាធរកម្ពុជា និង Haver Analytics*

16 ធនាគារពិភពលោក ឆ្នាំ 2020a។

រៀលក្នុងមួយដុល្លារ) ចំណែកអត្រាប្តូរប្រាក់រៀលក្នុងមួយយន់ គឺ 602 រៀល (កើនពី 583 រៀលក្នុងមួយយន់) ហើយអត្រាប្តូរប្រាក់រៀលក្នុងមួយដុង គឺ 0.117 រៀល (កើនពី 0.176 រៀលក្នុងមួយដុង) (រូប 18)។

## ភាពក្រីក្រត្រូវបានប៉ាន់ស្មានថានឹងកើនឡើង

**បច្ចុប្បន្ន ការខាតបង់ផ្នែកសេដ្ឋកិច្ច និងសង្គមដោយសារជំងឺកូវីដ 19 ត្រូវបានបង្ហាញច្រើនផ្នែក។** ការអង្កេតគ្រួសារតាមទូរស័ព្ទបង្ហាញពីផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ 19 លើការងារ។ ចំនួនអ្នកឆ្លើយតបដែលកំពុងធ្វើការ ថយពី 82 ភាគរយនៅមុនពេលផ្ទុះជំងឺកូវីដ 19 មកត្រឹមចំនួន 71 ភាគរយនៅខែ ឧសភា ឆ្នាំ 2020 ហើយមានអត្រាថេររហូតដល់ខែ សីហា ឆ្នាំ 2020។ ជំងឺកូវីដ 19 នៅតែមានឥទ្ធិពលអវិជ្ជមានលើសកម្មភាពអាជីវកម្មមិនមែនកសិកម្ម ប៉ុន្តែ មិនសូវមានភាពធ្ងន់ធ្ងរដូចមុនពេលផ្ទុះជំងឺនេះឡើយ។ ទោះជាយ៉ាងណា នៅតែមានការបាត់បង់ប្រាក់ចំណូល ទោះបីជាការថយចុះប្រាក់ចំណូលគ្រួសារមានកម្រិតទាបជាងមុន បន្ទាប់ពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្តី (សូមមើលប្រអប់ 3)។ ក្រុមហ៊ុនក៏ប្រឈមនឹងបញ្ហាសេដ្ឋកិច្ចផងដែរ (សូមមើលអត្ថបទផ្តោតពិសេសខាងក្រោម)។ នៅដើមខែ មិថុនា ក្រសួងផែនការ បានប្រកាសថា ប្រជាជនចំនួន 560,000 គ្រួសារ (2.3 លាននាក់) មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងវិបត្តិជំងឺកូវីដ 19។ គិតត្រឹមខែ តុលា ប្រជាជនជាង 640,000 គ្រួសារ (2.6 លាននាក់) បានទទួលការឧបត្ថម្ភសាច់ប្រាក់។ មានន័យថា ប្រជាជនយ៉ាងតិច 80,000 គ្រួសារបន្ថែមទៀត ត្រូវបានកំណត់ថាជាគ្រួសារក្រីក្រនៅអំឡុងខែ មិថុនា-តុលា[17]។

## ធនាគារកណ្តាលបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុ

**ដើម្បីទ្រទ្រង់សន្ទនីយភាពទីផ្សារក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 ធនាគារកណ្តាលបានកាត់បន្ថយលក្ខខណ្ឌស្តីពីអត្រាទុនបម្រុង។** អត្រាបច្ចុប្បន្ន បានថយមក 7 ភាគរយទាំងសម្រាប់ប្រាក់បញ្ញើជារូបិយវត្ថុក្នុងស្រុក និងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ថយពី 8 ភាគរយសម្រាប់ប្រាក់បញ្ញើជារូបិយវត្ថុក្នុងស្រុក និងថយពី 12.5 ភាគរយសម្រាប់ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក្នុងរយៈពេល 6 ខែចាប់តាំងពីខែ មេសា ឆ្នាំ 2020។ ធនាគារកណ្តាលបានកាត់បន្ថយអត្រាការប្រាក់ចំនួន 0.5 ភាគរយសម្រាប់កាលកំណត់នៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ទាំងអស់តាំងពីខែ មីនា ឆ្នាំ 2020។ តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ធនាគារកណ្តាលមានឥទ្ធិពលលើអត្រាការប្រាក់នៃប្រាក់រៀល ប៉ុន្តែ មិនអាចមានឥទ្ធិពលលើអត្រាការប្រាក់នៃប្រាក់ដុល្លារអាមេរិកបានឡើយ ព្រោះសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈដុល្លារូបនីយកម្មខ្ពស់។ ដូច្នេះ អត្រាការប្រាក់មធ្យមជាក់ស្តែងនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ថយមក 2.66 ភាគរយ (ថយពី 2.94 ភាគរយ) សម្រាប់រយៈពេល 91 ថ្ងៃ 3.08 ភាគរយ (ថយពី 3.2 ភាគរយ) សម្រាប់រយៈពេល 182 ថ្ងៃ និង 3.25 ភាគរយ (ថយពី 3.43 ភាគរយ) សម្រាប់រយៈពេល 364 ថ្ងៃ ធៀបនឹងឆ្នាំ 2019[18]។ ក្រៅពីនេះ ធនាគារកណ្តាលបានពន្យារពេលអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិន ដើម្បីរក្សាលក្ខខណ្ឌតម្រូវបច្ចុប្បន្ន 50 ភាគរយ[19]។ កាលពីខែ មីនា ឆ្នាំ 2020 ធនាគារកណ្តាលបានចេញសេចក្តីណែនាំដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ឱ្យកែសម្រួលរចនាសម្ព័ន្ធប្រាក់កម្ចី ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ក៏ដូចជាសម្រាលបន្ទុករបស់

**រូប 17៖ អតិផរណាមានអត្រាថេរ**

កត្តារួមចំណែកដល់អតិផរណាក្នុងរយៈពេល 12 ខែ (ភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 18៖ អត្រាប្តូរប្រាក់ណូមីណល នៅតែមានស្ថិរភាព**




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

*សម្គាល់ ៖ RHS=ខាងស្តាំ*

17 បទបង្ហាញរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្ងៃទី 22 ខែ តុលា ឆ្នាំ 2020។

18 របាយការណ៍ប្រចាំឆមាស ធនាគារជាតិនៃកម្ពុជា ខែ មិថុនា ឆ្នាំ 2020។

19 ទ្រនាប់ដើមទុនខនស៊ើវេសិនត្រូវបានរៀបចំឡើងដើម្បីធានាថា គ្រឹះស្ថានហិរញ្ញវត្ថុបង្កើតទ្រនាប់ដើមទុននៅក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា ដែលអាចដកមូលធនបាន នៅពេលមានការខាតបង់។ សូមមើលប្រកាសចុះថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំ 2018 និងរបាយការណ៍ប្រចាំឆមាស ឆ្នាំ 2020 របស់ធនាគារជាតិនៃកម្ពុជា។

អ្នកជាប់បំណុលដែលកំពុងប្រឈមនឹងការថយចុះប្រាក់ចំណូល ដោយសារវិបត្តិជំងឺកូវីដ 19[20]។ យោងតាមសមាគមមីក្រូហិរញ្ញវត្ថុ នៅខែ កក្កដា ឆ្នាំ 2020 វិស័យមីក្រូហិរញ្ញវត្ថុបានកែសម្រួលកម្ចីចំនួន 1.2 ពាន់លានដុល្លារជាមួយអ្នកខ្ចីចំនួន 250,000 នាក់ ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ 19[21]។ នៅខែ មិថុនា ឆ្នាំ 2020 វិស័យមីក្រូហិរញ្ញវត្ថុមានអ្នកខ្ចី 2.1 លាននាក់ ស្មើនឹងទឹកប្រាក់ 7.3 ពាន់លានដុល្លារ[22]។

### កំណើនរូបិយវត្ថុទូលាយថយចុះ ដោយសារការថយចុះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស

**ដោយសារការថយចុះលំហូរចូលមូលធន កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសថយចុះ ដែលនាំឱ្យកំណើនរូបិយវត្ថុទូលាយថយចុះ។** កំណើនរូបិយវត្ថុទូលាយមានចំនួន 12.3 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពី 18.2 ភាគរយគិតត្រឹមបំណាច់ឆ្នាំ 2019 (និងថយពី 24.0 ភាគរយនៅឆ្នាំ 2018) (រូប 19)។ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (ចាត់ទុកជាប្រភេទ "ប្រាក់បញ្ញើផ្សេងទៀត") ដល់កំណើនរូបិយវត្ថុទូលាយ ថយមក 9.0 ភាគរយពិន្ទុ ដែលជាអត្រាទាបក្នុងរយៈពេល 8.5 ឆ្នាំ ថយពី 11.0 ភាគរយពិន្ទុនៅឆ្នាំ 2019 (និងថយពី 20.0 ភាគរយពិន្ទុនៅឆ្នាំ 2018)។ ទោះជាយ៉ាងណា ការរួមចំណែកនៃប្រាក់រៀលដែលកំពុងចរាចរណ៍ដល់កំណើនរូបិយវត្ថុទូលាយមានចំនួន 2.5 ភាគរយពិន្ទុថយចុះបន្តិចពី 2.8 ភាគរយ ដោយសារគោលនយោបាយរបស់ធនាគារកណ្តាលក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។

### កំណើនប្រាក់បញ្ញើ និងឥណទានថយចុះ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ច

**កំណើនប្រាក់បញ្ញើនៅសាជីវកម្មប្រាក់បញ្ញើ (ធនាគារ និងគ្រឹះស្ថានទទួលប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុ) ថយចុះ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ច។** ប្រាក់បញ្ញើកើនមក 10.7 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ថយពី 16.4 ភាគរយនៅឆ្នាំ 2019 (និងថយពី 28.9 ភាគរយនៅឆ្នាំ 2018)។ ដោយសារតែស្ថិរភាពនៃអត្រាការប្រាក់នៃប្រាក់បញ្ញើ ការថយចុះកំណើនប្រាក់បញ្ញើបង្ហាញពីការថយចុះនៃសកម្មភាពសេដ្ឋកិច្ច ដែលមានឥទ្ធិពលអវិជ្ជមានលើសន្ទនីយភាពនៃវិស័យសាជីវកម្ម (និងគ្រួសារ) ជាធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពសន្សំប្រាក់ (សូមមើលប្រអប់ 3 និងអត្ថបទផ្តោតពិសេស)។ ការថយចុះនៃតម្រូវការឥណទាន បានកាត់បន្ថយលំហូរនៃការផ្តល់ឥណទានពីសាជីវកម្មប្រាក់បញ្ញើដល់អាជីវកម្ម។ កំណើនឥណទានថយមក 18.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2020 ដែលជាអត្រាទាបក្នុងរយៈពេលពីរឆ្នាំកន្លះ ដែលអត្រានេះបានថយពី 27.0 ភាគរយនៅឆ្នាំ 2019។

### ការផ្តល់ឥណទានក្នុងស្រុកដល់សកម្មភាពសាងសង់ថយចុះ ប៉ុន្តែការផ្តល់ឥណទានដល់សកម្មភាពកសិកម្មកើនឡើង

**ហិរញ្ញប្បទានឥណទានក្នុងស្រុកដល់វិស័យសំណង់ និងអចលនទ្រព្យ ថយចុះ ដោយសារតែការថយចុះនៃសកម្មភាពសាងសង់។** យោងតាមទិន្នន័យរបស់ធនាគារកណ្តាលស្តីពីឥណទានធនាគារដែលត្រូវបានធ្វើចំណាត់ថ្នាក់តាមគ្រឹះស្ថានអាជីវកម្ម នៅខែ មិថុនា ឆ្នាំ 2020 ការរួមចំណែកនៃការផ្តល់កម្ចីដល់វិស័យសំណង់ អចលនទ្រព្យ និងបញ្ចាំដល់កំណើនឥណទាន ថយចុះមក 8 ភាគរយ (ឥណទានមិនទាន់សង 8.1 ពាន់លានដុល្លារ) ដែលជាអត្រាទាបក្នុងរយៈពេល 2.5 ឆ្នាំ ថយពី 11.0 ភាគរយនៅឆ្នាំ 2019 (រូប 20)។ ដោយសារតែការថយចុះនៃសកម្មភាពអាជីវកម្ម និងការលក់ក្នុងស្រុក ការរួមចំណែកនៃវិស័យលក់រាយ និងលក់ដុំ និងវិស័យកម្មន្តសាលដល់កំណើនឥណទានក្នុងស្រុកនៅខែ មិថុនា ឆ្នាំ 2020

**រូប 19៖ កំណើនរូបិយវត្ថុទូលាយថយចុះ**

កត្តារួមចំណែកដល់កំណើនរូបិយវត្ថុទូលាយ (ភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 20៖ កត្តារួមចំណែកដល់កំណើនឥណទានក្នុងស្រុក**

(ភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

---

20 សូមមើលសារាចរណែនាំ ចុះថ្ងៃទី 27 ខែ មីនា ឆ្នាំ 2020 របស់ធនាគារជាតិនៃកម្ពុជា។ "កម្ចីចរចាឡើងវិញ" ឬ "កម្ចីកែសម្រួលឡើងវិញ" សំដៅលើកម្ចីដែលត្រូវបានកែប្រែកាលវិភាគសង ឬផ្តល់ហិរញ្ញប្បទានឡើងវិញ ដោយផ្អែកតាមការព្រមព្រៀងដែលបានកំណត់កាលវិភាគសងប្រាក់ថ្មីជាដំណាក់កាល ដោយសារការថយចុះស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី និង/ឬអសមត្ថភាពក្នុងការសងប្រាក់ ដូចការព្រមព្រៀងពីដំបូង។

21 កិច្ចសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយជាមួយប្រធានសមាគមមីក្រូហិរញ្ញវត្ថុ ថ្ងៃទី 31 ខែ សីហា ឆ្នាំ 2020។

22 របាយការណ៍ប្រចាំឆមាសរបស់ធនាគារជាតិនៃកម្ពុជា ខែ មិថុនា ឆ្នាំ 2020។

**ប្រអប់ 3 ៖**

## ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ផ្អែកតាមលទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ[a]

**ជំងឺកូវីដ 19 ដែលជាជំងឺផ្លូវដង្ហើមដែលបង្កឡើងដោយវីរុសក្លូណា ដែលត្រូវបានរកឃើញជាលើកដំបូងនៅឆ្នាំ 2019 បានក្លាយជាជំងឺឆ្លងរាតត្បាតនៅដើមខែ មីនា ឆ្នាំ 2020។** កម្ពុជារកឃើញករណីវិជ្ជមានដំបូងនៃជំងឺកូវីដ 19 នៅថ្ងៃទី 27 ខែ មករា ឆ្នាំ 2020 និងបានទប់ស្កាត់ការឆ្លងរាលដាលវីរុសនេះ។ យោងតាមអង្គការសុខភាពពិភពលោក គិតត្រឹមថ្ងៃទី 25 ខែ តុលា ឆ្នាំ 2020 កម្ពុជាមានករណីវិជ្ជមានចំនួន 287 ករណី និងគ្មានករណីស្លាប់ទេ។ កម្ពុជាបានចាត់វិធានការផ្សេងៗដើម្បីទប់ស្កាត់ការឆ្លងរាលដាលវីរុសក្លូណាដែលបង្កជាជំងឺកូវីដ 19[b]។ វិធានការរួមមាន ការណែនាំឱ្យប្រជាពលរដ្ឋនៅក្នុងផ្ទះ ការរក្សាគម្លាតពីគ្នា និងការកាត់បន្ថយការធ្វើដំណើរដែលមិនចាំបាច់ ការបិទសាលារៀន ការហាមឃាត់ការជួបជុំទ្រង់ទ្រាយធំ ការរឹតត្បិតការធ្វើដំណើរអន្តរជាតិ ការពិនិត្យសុខភាពបឋមនៅព្រលានយន្តហោះ និងការបិទព្រំដែន។

**ជំងឺកូវីដ 19 មិនត្រឹមតែជាស្ថានភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុទៀតផង។** ជំងឺកូវីដ 19 បានបង្កការប៉ះទង្គិចយ៉ាងខ្លាំងដល់សេដ្ឋកិច្ចក្នុងស្រុក។ ទោះជាកម្ពុជាបានចៀសផុតពីវិបត្តិសុខភាព ការខាតបង់ផ្នែកសេដ្ឋកិច្ចមានទំហំធំធេង។ ធនាគារពិភពលោកព្យាករណ៍ថា កម្ពុជានឹងមានកំណើនកម្រិតអវិជ្ជមាន -2.0 ភាគរយនៅឆ្នាំ 2020 ដោយសារជំងឺកូវីដ 19 ហើយភាពក្រីក្រក្នុងតំបន់ត្រូវបានព្យាករណ៍ថានឹងកើនឡើងជាលើកដំបូងក្នុងរយៈពេល 20 ឆ្នាំកន្លងមកនេះ។

**រដ្ឋាភិបាលត្រូវការទិន្នន័យទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ជាងពេលណាៗទាំងអស់ ដើម្បីពិនិត្យតាមដាន និងកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចនៃវិបត្តិជំងឺកូវីដ 19 លើប្រជាជនក្រីក្រ និងងាយរងគ្រោះ។** ដើម្បីពិនិត្យតាមដានផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចនៃជំងឺកូវីដ 19 និងផ្តល់មូលដ្ឋានព័ត៌មានដល់ការឆ្លើយតបផ្នែកគោលនយោបាយ ធនាគារពិភពលោកបានរៀបចំ និងធ្វើការអង្កេតគ្រួសារតាមទូរស័ព្ទ នៅទូទាំងប្រទេសកម្ពុជា។ ការអង្កេតនេះគ្របដណ្តប់លើប្រធានបទសំខាន់ៗ និងពាក់ព័ន្ធមួយចំនួន រួមទាំង ចំណេះដឹងស្តីពីជំងឺកូវីដ 19 និងការអនុវត្តឥរិយាបថទប់ស្កាត់ សកម្មភាពសេដ្ឋកិច្ច និងប្រភពប្រាក់ចំណូល លទ្ធភាពទទួលបានទំនិញ និងសេវាសំខាន់ៗ ការប្រឈមនឹងវិបត្តិ និងយន្តការដោះស្រាយ និងលទ្ធភាពទទួលបានជំនួយសង្គម។

**ការងារមានស្ថិរភាពនៅអំឡុងខែ មីនា-សីហា ក្រោយការផ្ទុះវិបត្តិដំបូងដោយសារជំងឺកូវីដ 19។** ទោះជាចំនួនអ្នកឆ្លើយតបដែលកំពុងធ្វើការថយពី 82 ភាគរយនៅមុនពេលផ្ទុះជំងឺកូវីដ 19 មកត្រឹម 71 ភាគរយនៅខែ ឧសភា ក្នុងការសម្ភាសន៍លើកទីមួយ (រូប B3.1) អត្រានេះនៅថេររហូតដល់ខែ សីហា ក្នុងការសម្ភាសន៍លើកទីពីរ (ត្រឹម 70 ភាគរយ)។ អ្នកឆ្លើយតបភាគច្រើនបន្តធ្វើការក្នុងវិស័យដដែល។ មានអ្នកឆ្លើយតបតែ 5 ភាគរយប៉ុណ្ណោះដែលប្តូរការងារ ដែលភាគច្រើនជាការប្តូរការងារពីវិស័យឧស្សាហកម្មទៅវិស័យកសិកម្ម។ ចំនួនអ្នកឆ្លើយតបដែលឈប់ធ្វើការមានចំនួន 10 ភាគរយ នៅចន្លោះការសម្ភាសន៍ទាំងពីរលើក។ ក្នុងចំណោមអ្នកឆ្លើយតបដែលឈប់ធ្វើការ អ្នកឆ្លើយតបចំនួន 32 ភាគរយលើកឡើងថាឈប់ធ្វើការដោយសារការងារមានតាមរដូវ និង 21 ភាគរយលើកឡើងថាឈប់ធ្វើការដោយសារមានជំងឺ[b]។ ភាគច្រើននៃមូលហេតុពាក់ព័ន្ធនឹងជំងឺកូវីដ 19 ដែលត្រូវបានដកស្រង់កាលពីខែ ឧសភា ដូចជា ការបិទអាជីវកម្ម ឬការរំសាយបណ្តោះអាសន្ន មិនត្រូវបានលើកឡើងទៀតទេ។

**ជំងឺកូវីដ 19 នៅតែមានផលប៉ះពាល់អវិជ្ជមានលើសកម្មភាពអាជីវកម្មក្រៅពីកសិកម្ម ទោះបីជាផលប៉ះពាល់មិនសូវធ្ងន់ធ្ងរដូចពេលផ្ទុះជំងឺនេះកាលពីដំបូងក្តី** (រូប B3.2)។ ចំនួនអាជីវកម្មគ្រួសារក្រៅពីកសិកម្មដែលលើកឡើងថាគ្មានប្រាក់ចំណូល ឬរកប្រាក់ចំណូលបានតិចជាងមុន ថយចុះ។ ក្នុងចំណោម 5 គ្រួសារ មាន 4 គ្រួសារលើកឡើងថា គ្មានប្រាក់ចំណូល ឬរកប្រាក់ចំណូលបានតិចនៅខែ មេសា ជាងខែ មីនា ខណៈដែលក្នុងចំណោម 5 គ្រួសារ មាន 3 គ្រួសារលើកឡើងថា គ្មានប្រាក់ចំណូល ឬរកប្រាក់ចំណូលបានតិចនៅខែ កក្កដា ជាងខែ មិថុនា។ អាជីវកម្មគ្រួសារដែលលើកឡើងថារកប្រាក់ចំណូលបានដដែល កើនទ្វេដង មានចំនួន 31 ភាគរយនៅខែ កក្កដា។ និន្នាការដូចគ្នានេះក៏លេចឡើងក្នុងចំណោមគ្រួសារក្រីក្រផងដែរ ទោះបីជាមានកម្រិតខុសគ្នាក្តី។ ចំនួនគ្រួសារដែលធ្វើអាជីវកម្មគ្រួសារក្រៅពីកសិកម្ម នៅដដែល។ គ្រួសារប្រមាណ 1/3 (32-34 ភាគរយ) ក្នុងសំណាកនៃការសិក្សារង្វាស់ស្តង់ដារជីវភាព ធ្វើអាជីវកម្មគ្រួសារក្រៅពីកសិកម្មនៅអំឡុងខែ ឧសភា-សីហា ខណៈដែលគ្រួសារចន្លោះពី 16 ភាគរយ ទៅ 19 ភាគរយក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ធ្វើអាជីវកម្មគ្រួសារក្រៅពីកសិកម្ម នៅអំឡុងខែ មិថុនា-សីហា។ អាជីវកម្មភាគច្រើនជាការលក់រាយ។ ក្នុងនោះ អាជីវកម្មជិត 80 ភាគរយដែលធ្វើប្រតិបត្តិការនៅខែ សីហា (67 ភាគរយនៅខែ ឧសភា) គឺជាការលក់រាយ។

**រូប B3.1៖ អ្នកឆ្លើយតបដែលធ្វើការក្នុងរយៈពេល 7 ថ្ងៃចុងក្រោយ**




**រូប B3.2៖ គ្រួសារធ្វើអាជីវកម្មមិនមែនកសិកម្ម ដែលលើកឡើងពីការប្រែប្រួលប្រាក់ចំណូលក្នុងការលក់**




*សម្គាល់ ៖ ID Poor =កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ LSMS=ការសិក្សារង្វាស់ស្តង់ដារជីវភាព R1=ការសម្ភាសន៍លើកទីមួយ R2=ការសម្ភាសន៍លើកទីពីរ*

*សម្គាល់ ៖ a.ប្រអប់នេះត្រូវបានរៀបរៀងឡើងដោយលោក Wendy Karamba និងលោក តុង គឹមស៊ុន។ b.សម្គាល់ ៖ កម្ពុជាបានទប់ស្កាត់ជំងឺកូវីដ 19 ដោយជោគជ័យ។ កាលពីថ្ងៃទី 18 ខែ តុលា ឆ្នាំ 2020 អង្គការសុខភាពពិភពលោករាយការណ៍ថា ករណីសរុបនៃជំងឺកូវីដ 19 នៅកម្ពុជា គឺ 283 ករណី (https://www.who.int/countries/khm/)។*

## ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ផ្អែកតាមលទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ (ត)

**ការថយចុះតម្រូវការរបស់អ្នកប្រើប្រាស់ ធ្វើឱ្យអាជីវកម្មគ្រួសារក្រៅពីកសិកម្ម បាត់បង់ប្រាក់ចំណូល ឬរកប្រាក់ចំណូលបានតិចជាងមុន។** ក្នុងចំណោមអាជីវកម្មគ្រួសារដែលលើកឡើងថាគ្មានប្រាក់ចំណូល ឬរកប្រាក់ចំណូលបានតិចជាងមុន អាជីវកម្មគ្រួសារចំនួន 88 ភាគរយលើកឡើងថាគ្មាន ឬមានអតិថិជន តិច។ ការថយចុះនៃតម្រូវការកំពុងបង្កផលប៉ះពាល់ដូចគ្នាលើអាជីវកម្មគ្រួសារទាំងអស់ ទាំងនៅទីក្រុង និងជនបទ និងក្នុងចំណោមគ្រួសារចំនួន 40 ភាគរយនៅផ្នែកខាងក្រោម និងគ្រួសារចំនួន 60 ភាគរយនៅផ្នែកខាងលើ។

**ជនទេសន្តរប្រវេសន៍ភាគច្រើនបាត់បង់ការងារ ឬប្រាក់ឈ្នួលដោយសារវិបត្តិជំងឺកូវីដ 19** (រូប B3.3)។ កាលពីមុនវិបត្តិជំងឺកូវីដ 19 ក្នុងចំណោមប្រជាជន 10 គ្រួសារ មាន 3 គ្រួសារ មានសមាជិកម្នាក់ជាជនទេសន្តរប្រវេសន៍។ ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19 ក្នុងចំណោមប្រជាជន 10 គ្រួសារ មាន 2 គ្រួសារដែលសមាជិកជាជនទេសន្តរប្រវេសន៍បន្តស្នាក់នៅក្នុងប្រទេសគោលដៅ ខណៈដែលក្នុងចំណោមប្រជាជន 10 គ្រួសារ មាន 1 គ្រួសារដែលសមាជិកជាជនទេសន្តរប្រវេសន៍វិលត្រលប់មកស្រុកកំណើតវិញ។ ក្នុងចំណោមគ្រួសារដែលមានសមាជិកធ្វើការឆ្ងាយពីផ្ទះ គ្រួសារចំនួន 80 ភាគរយ មានសមាជិកធ្វើការជាពលករទេសន្តរប្រវេសន៍ដែលទទួលបានប្រាក់កម្រៃ។ គ្រួសារដែលមានសមាជិកជាជនទេសន្តរប្រវេសន៍ជាង 60 ភាគរយលើកឡើងពីការថយចុះប្រាក់ចំណូលរបស់សមាជិកជាជនទេសន្តរប្រវេសន៍។ ក្នុងនោះ គ្រួសារដែលមានសមាជិកជាជនទេសន្តរប្រវេសន៍ចំនួន 60 ភាគរយ លើកឡើងថា ប្រាក់ចំណូលរបស់សមាជិកគ្រួសារដែលជាជនទេសន្តរប្រវេសន៍ ថយចុះចំនួន 47 ភាគរយ ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19 ដោយបានកាត់បន្ថយចំនួនប្រាក់បញ្ញើដែលផ្ញើមកស្រុក។ គ្រួសារក្រីក្រលើកឡើងថា ប្រាក់ចំណូលរបស់សមាជិកគ្រួសារដែលជាជនទេសន្តរប្រវេសន៍ ថយចុះ 42 ភាគរយធៀបនឹងអំឡុងពេលមុនការផ្ទុះជំងឺកូវីដ 19។

**ក្នុងចំណោម 1 គ្រួសារនៃ 10 គ្រួសារដែលមានសមាជិកជាជនទេសន្តរប្រវេសន៍វិលត្រលប់មកវិញ គ្រួសារភាគច្រើនមានជនទេសន្តរប្រវេសន៍ម្នាក់វិលត្រលប់មកវិញដោយសារការបិទរោងចក្រ (36 ភាគរយ) និងកង្វះការងារ (24 ភាគរយ)។** គ្រួសារដែលមានសមាជិកជាជនទេសន្តរប្រវេសន៍វិលត្រលប់មកវិញចំនួន 1/3 (34 ភាគរយ) មានជនទេសន្តរប្រវេសន៍ដែលវិលត្រលប់មកវិញម្នាក់គ្មានការងារធ្វើ ប៉ុន្តែការប៉ាន់ស្មានសម្រាប់គ្រួសារក្រីក្រ ចំនួននេះមានរហូតដល់ពាក់កណ្តាល។ ជនទេសន្តរប្រវេសន៍ដែលវិលត្រលប់មកវិញចំនួន 1/3 (29 ភាគរយ) ចូលរួមក្នុងសកម្មភាពកសិកម្មគ្រួសារ ខណៈដែលជនទេសន្តរប្រវេសន៍ដែលវិលត្រលប់មកវិញចំនួន 16 ភាគរយធ្វើការងារទទួលបានប្រាក់កម្រៃ។ ផ្ទុយទៅវិញ ក្នុងចំណោមគ្រួសារក្រីក្រ ដែលមានសមាជិកជាជនទេសន្តរប្រវេសន៍វិលត្រលប់មកវិញ មានជនទេសន្តរប្រវេសន៍ដែលវិលត្រលប់មកវិញតែ 16 ភាគរយប៉ុណ្ណោះដែលចូលរួមក្នុងសកម្មភាពកសិកម្មគ្រួសារ ខណៈដែលជនទេសន្តរប្រវេសន៍ដែលវិលត្រលប់មកវិញចំនួន 58 ភាគរយធ្វើការងារទទួលបានប្រាក់កម្រៃ (អាចដោយសារតែគ្រួសារក្រីក្រមានដីស្រែតិចតួច)។

**ការបាត់បង់ប្រាក់ឈ្នួល និងការងារក្នុងចំណោមជនទេសន្តរប្រវេសន៍ បង្កផលប៉ះពាល់អវិជ្ជមានលើលំហូរប្រាក់បញ្ញើ ដែលជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារនៅជនបទ** (រូប B3.4)។ គ្រួសារជនទេសន្តរប្រវេសន៍ជាង 70 ភាគរយ បានទទួលប្រាក់បញ្ញើតាំងពីខែ មីនា។ ទោះជាយ៉ាងណាគ្រួសារជនទេសន្តរប្រវេសន៍បានទទួលប្រាក់បញ្ញើជាមធ្យម 50 ដុល្លារក្នុងមួយខែ ជាចំនួនតិចជាងប្រាក់បញ្ញើដែលទទួលបានកាលពីមុនពេលផ្ទុះជំងឺកូវីដ 19។ គ្រួសារក្រីក្របានទទួលប្រាក់បញ្ញើជាមធ្យម 30 ដុល្លារក្នុងមួយខែ ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19។ ការអង្កេតនេះមិនបានសាកសួរពីទំហំនៃការប្រែប្រួលប្រាក់បញ្ញើឡើយ។

**រូប B3.3៖ គ្រួសារជនទេសន្តរប្រវេសន៍ដែលលើកឡើងពីការប្រែប្រួលប្រាក់ចំណូលតាំងពីពាក់កណ្តាលខែ មីនា** (% នៃគ្រួសារ)




*សម្គាល់ ៖ LSMS=ការសិក្សារង្វាស់ស្តង់ដារជីវភាព*




*សម្គាល់ ៖ IDPoor=កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ*

**រូប B3.4៖ គ្រួសារជនទេសន្តរប្រវេសន៍ដែលលើកឡើងពីការប្រែប្រួលប្រាក់បញ្ញើតាំងពីពាក់កណ្តាលខែ មីនា** (% នៃគ្រួសារ)




*សម្គាល់ ៖ LSMS=ការសិក្សារង្វាស់ស្តង់ដារជីវភាព*




*សម្គាល់ ៖ IDPoor=កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ*

## ផលប៉ះពាល់នៃជំងឺកូវីដ 19 លើគ្រួសារ ផ្អែកតាមលទ្ធផលពីការអង្កេតគ្រួសារតាមទូរស័ព្ទ (ត)

**ប្រជាជននៅតែបាត់បង់ប្រាក់ចំណូល ទោះបីជាការថយចុះប្រាក់ចំណូលគ្រួសារបានថយចុះតាំងពីខែ ឧសភា ដោយសារមិនសូវមានការបង្អាក់សកម្មភាពការងារ និងកំណើនជំនួយរបស់រដ្ឋាភិបាល** (រូប B3.5)។ ក្នុងចំណោម 5 គ្រួសារ មាន 3 គ្រួសារ លើកឡើងពីការថយចុះប្រាក់ចំណូលគ្រួសារក្នុងការសម្ភាសន៍លើកទីមួយ ប៉ុន្តែ ក្នុងការសម្ភាសន៍លើកទីពីរ ក្នុងចំណោម 5 គ្រួសារ មាន 4 គ្រួសារ លើកឡើងពីការថយចុះប្រាក់ចំណូលគ្រួសារ។ ការថយចុះប្រាក់ចំណូលត្រូវបានកាត់បន្ថយសម្រាប់ប្រាក់ចំណូលពីប្រភពទាំងអស់ ប៉ុន្តែ ភាគច្រើនគឺប្រាក់ចំណូលពីកសិកម្ម។ គ្រួសារដែលប្រកបរបរចិញ្ចឹមជីវិតដោយធ្វើកសិកម្ម ចិញ្ចឹមសត្វ ឬនេសាទ ចំនួន 32 ភាគរយ លើកឡើងថា ប្រាក់ចំណូលរបស់ពួកគេថយចុះក្នុងការសម្ភាសន៍លើកទីពីរ ស្មើនឹងការថយចុះចំនួន 30 ភាគរយតាំងពីការសម្ភាសន៍លើកទីមួយ។ ចំនួនគ្រួសារដែលលើកឡើងពីការថយចុះប្រាក់ចំណូលពីការងារទទួលបានប្រាក់ឈ្នួល និងអាជីវកម្មគ្រួសារក្រៅពីកសិកម្ម ថយចុះចំនួន 13-14 ភាគរយ។ ប្រាក់បញ្ញើ និងជំនួយពីគ្រួសារ មានភាពប្រសើរឡើង ព្រោះចំនួនគ្រួសារដែលលើកឡើងពីការថយចុះប្រាក់ប្រាក់បញ្ញើ ថយមក 17 ភាគរយ (ថយពីប្រមាណ 75 ភាគរយ) ហើយចំនួនគ្រួសារដែលលើកឡើងពីការថយចុះជំនួយពីគ្រួសារ មាន 44 ភាគរយ (ថយពី ប្រមាណ 75 ភាគរយ)។ ចំនួនគ្រួសារដែលលើកឡើងពីការទទួលជំនួយកាន់តែច្រើនពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល កើនឡើង 10 ដងនៅអំឡុងខែ ឧសភា-សីហា ដោយកើនចន្លោះពី 4 ភាគរយ ទៅ 42 ភាគរយ។

**ទីផ្សារនៅតែដំណើរការ និងអាចផ្គត់ផ្គង់ទំនិញ/សេវាចាំបាច់ ទោះបីជាមានវិបត្តិជំងឺកូវីដ 19 ក្តី។** ជាក់ស្តែង គ្រួសារទាំងអស់ (មិនគិតពីស្ថានភាពក្រីក្រ និងតំបន់រស់នៅ) អាចទិញអង្ករ ត្រី ឬសាច់ និងបន្លែ ឬផ្លែឈើទាំងនៅអំឡុងខែ ឧសភា និងខែ សីហា នៅពេលដែលពួកគេរកទិញទំនិញសំខាន់ៗទាំងនេះ។ ដូចគ្នានេះដែរ គ្រួសារចំនួន 99 ភាគរយ ដែលរកទិញថ្នាំព្យាបាល អាចទិញបានថ្នាំព្យាបាលក្នុងអំឡុងពេលទាំងពីរខែនេះ (រូប B3.6)។ ក្នុងចំណោមគ្រួសារដែលត្រូវការការព្យាបាលវេជ្ជសាស្រ្ត គ្រួសារទាំងអស់អាចទទួលបានសេវាវេជ្ជសាស្រ្ត។ អ្នកឆ្លើយតបជាស្រ្តីច្រើនតែលើកឡើងថា ពួកគាត់ត្រូវការការព្យាបាលវេជ្ជសាស្រ្តសម្រាប់ខ្លួនឯង ឬសមាជិកគ្រួសារផ្សេងទៀត ជាងអ្នកឆ្លើយតបជាបុរស។

**ការចូលរួមរបស់កុមារក្នុងសកម្មភាពរៀនសូត្រ កើនឡើងបន្ទាប់ពីការរអាក់ខានពីដំបូងដោយសារការផ្ទុះជំងឺកូវីដ 19។** នៅថ្ងៃទី 16 ខែ មីនា ឆ្នាំ 2020 ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំឱ្យបិទសាលារដ្ឋ និងសាលាឯកជនទាំងអស់ និងតម្រូវឱ្យសិស្សានុសិស្សសិក្សាតាមប្រព័ន្ធអនឡាញ។ គ្រួសារពឹងផ្អែកខ្លាំងលើកម្មវិធីទូរទស្សន៍ ឬវិទ្យុ ដើម្បីបំពេញបន្ថែមលើសកម្មភាពរៀនសូត្រនៅផ្ទះ។ ចាប់តាំងពីថ្ងៃទី 7 ខែ កញ្ញា ឆ្នាំ 2020 មក សាលារៀនបានបើកទ្វារឡើងវិញដោយផ្នែក និងត្រូវអនុវត្តតាមបទដ្ឋានដែលកំណត់ដោយក្រសួង ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ 19 ដូចជា ការរក្សាអនាម័យ ការរក្សាគម្លាតសង្គម ការវាស់កម្តៅ និងការពាក់ម៉ាស់។ ក្នុងពេលធ្វើការអង្កេតនេះ ការបើកសាលារៀនឡើងវិញដោយផ្នែកមិនទាន់ត្រូវបានអនុវត្តឡើយ។ ផ្ទុយទៅវិញ ការសម្របខ្លួនក្នុងគ្រួសារ និងការផ្តល់ជម្រើសយ៉ាងច្រើនពីសាលារៀន បានផ្តល់ឱកាសកាន់តែច្រើនដល់ការរៀនសូត្រនៅផ្ទះ។ ចំនួនគ្រួសារដែលមានកូនអាយុ 6-17 ឆ្នាំកំពុងសិក្សា កើនចន្លោះពី 63 ភាគរយ ទៅ 75 ភាគរយ។ ទោះបីជាមានភាពប្រសើរឡើងដូច្នេះក្តី ក៏គ្រួសារ 1 ក្នុងចំណោមគ្រួសារ 4 ដែលមានកូន នៅតែមានឱកាសរៀនសូត្រតិចតួច ក្នុងអំឡុងពេលបិទសាលារៀន។

**រូប B3.5៖ ការប្រែប្រួលប្រាក់ចំណូលគ្រួសារនៅអំឡុងខែ ឧសភា-សីហា ឆ្នាំ 2020**




*សម្គាល់ ៖ R1=ការសម្ភាសន៍លើកទីមួយ*
*R2=ការសម្ភាសន៍លើកទីពីរ*

**រូប B3.6៖ គ្រួសារដែលអាចទិញថ្នាំព្យាបាលក្នុងរយៈពេល 7 ថ្ងៃចុងក្រោយ**




*សម្គាល់ ៖ ID Poor=កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ*
*LSMS=ការសិក្សារង្វាស់ស្តង់ដារជីវភាព R1=ការសម្ភាសន៍លើកទីមួយ*
*R2=ការសម្ភាសន៍លើកទីពីរ*

មានចំនួន 3.9 ភាគរយពិន្ទុ (ឥណទានមិនទាន់សង 7.0 ពាន់លានដុល្លារ) ថយពី 6.6 ភាគរយ និងមានចំនួន -0.3 ភាគរយពិន្ទុ (ឥណទានមិនទាន់សង 1.1 ពាន់លានដុល្លារ) ថយពី 0.2 ភាគរយនៅខែ ធ្នូ ឆ្នាំ 2019។

**ការផ្តល់កម្ចីដល់វិស័យកសិកម្មកើនឡើង ដោយសារការកំណើនតម្រូវការផលិតផលកសិកម្មក្នុងអំឡុងវិបត្តិជំងឺកូវីដ 19។** ការរួមចំណែកនៃការផ្តល់កម្ចីដល់វិស័យកសិកម្មក្នុងកំណើនឥណទាន បានកើន 1.0 ភាគរយពិន្ទុ (ឥណទានមិនទាន់សង 2.0 ពាន់លានដុល្លារ) នៅខែ មិថុនា ឆ្នាំ 2020 កើនពី 0.5 ភាគរយពិន្ទុ នៅខែ ធ្នូ ឆ្នាំ 2019 ទោះបីជាមានការថយចុះនៃកំណើនឥណទានក្នុងស្រុកក្តី។ ការរួមចំណែកនៃវិស័យសណ្ឋាគារ និងភោជនីយដ្ឋានដល់កំណើនឥណទានក្នុងស្រុក កើនបន្តិចចំនួន 0.6 ភាគរយពិន្ទុ (ឥណទានមិនទាន់សង 1.2 ពាន់លានដុល្លារ) ពី 0.4 ភាគរយក្នុងអំឡុងពេលដូចគ្នានេះ។ នៅខែ មិថុនា ឆ្នាំ 2020 សេចក្តីរាយការណ៍បង្ហាញថា ផលធៀបកម្ចីមិនដំណើរការមានចំនួន 2.2 ភាគរយសម្រាប់វិស័យធនាគារ និង 0.9 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ[23]។ នៅខែ កក្កដា ឆ្នាំ 2020 សមាគមមីក្រូហិរញ្ញវត្ថុលើកឡើងថា កម្ចីមិនដំណើរការមានចំនួន 2.5 ភាគរយ។ នៅឆ្នាំ 2019 សេចក្តីរាយការណ៍បង្ហាញថា ផលធៀបកម្ចីមិនដំណើរការ មានចំនួន 2.2 ភាគរយសម្រាប់វិស័យធនាគារ និងចំនួន 1.1 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ។

**ដោយសារតែធនាគារកណ្តាលបន្តបញ្ចូលប្រាក់រៀលទៅក្នុងសេដ្ឋកិច្ច រូបិយប័ណ្ណមូលដ្ឋានដែលកំពុងចរាចរណ៍ កើនឡើងបន្ថែមទៀត** (រូប 21)។ ជាលទ្ធផល សម្ពាធលើអត្រាប្តូរប្រាក់បានកើនឡើង ដែលបង្ហាញពីការថយចុះនៃលំហូរចូលមូលធន និងការថយចុះការទទួលបានចំណូលជារូបិយប័ណ្ណ បរទេសដែលបណ្តាលមកពីការធ្លាក់ចុះនៃវិស័យទេសចរណ៍ និងការនាំចេញ។ បញ្ហានេះធ្វើឱ្យធនាគារកណ្តាលមិនសូវមានលទ្ធភាពកៀរគរទុនបម្រុងជារូបិយប័ណ្ណបរទេសឡើយ។

**នៅឆមាសទីមួយក្នុងឆ្នាំ 2020 ធនាគារកណ្តាលបានទិញប្រាក់ដុល្លារចំនួន 17 លានដុល្លារតាមរយៈការបញ្ចូលប្រាក់រៀលចំនួន 69 ពាន់លានរៀលក្នុងទីផ្សារដោះដូរប្រាក់បរទេស។** ប្រាក់ដុល្លារដែលបានទិញ ថយចុះ 99 ភាគរយ (ធៀបនឹងឆ្នាំមុន) អាចដោយសារតែការថយចុះនៃការផ្គត់ផ្គង់ប្រាក់ដុល្លារក្នុងទីផ្សារដោះដូរប្រាក់បរទេស។ ក្នុងអំឡុងពេលដូចគ្នានេះ ការទិញប្រាក់ដុល្លារអាមេរិកដោយធនាគារកណ្តាលពីទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ កើនឡើង ដោយមានចំនួន 192.3 លានដុល្លារ ឬកើន 25 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ធនាគារកណ្តាលបានធ្វើអន្តរាគមន៍ក្នុងទីផ្សារដោះដូរប្រាក់បរទេសដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក ដែលជាផ្នែកមួយនៃឧបករណ៍គោលនយោបាយដ៏សំខាន់របស់ខ្លួន ដើម្បីធានាស្ថិរភាពតម្លៃ[24]។

**ដោយសារធនាគារកណ្តាលមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់នៃប្រាក់កម្ចី និងប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក[25] អត្រាការប្រាក់ទាំងនេះមានតម្លៃថេរ ទោះបីជាមានការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុក្តី។** អត្រាជាមធ្យមនៃវិញ្ញាបនប័ត្រប្រាក់បញ្ញើជាប្រាក់ដុល្លារក្នុងរយៈពេល 12 ខែ គឺ 4.39 ភាគរយក្នុងមួយឆ្នាំ នៅខែ មិថុនា ឆ្នាំ 2020 កើនពី 4.34 ភាគរយក្នុងមួយឆ្នាំនៅខែ ធ្នូ ឆ្នាំ 2019។ ទន្ទឹមនឹងនេះ អត្រាជាមធ្យមនៃប្រាក់កម្ចីជាប្រាក់ដុល្លារក្នុងរយៈពេល 12 ខែ គឺ 9.44 ភាគរយក្នុងមួយឆ្នាំនៅខែ មិថុនា ឆ្នាំ 2020 ថយពី 9.51 ភាគរយនៅខែ ធ្នូ ឆ្នាំ 2019។

**រូប 21៖ ប្រាក់រៀលដែលកំពុងចរាចរណ៍ និងអត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក**
(ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

*សម្គាល់ ៖ RHS=ខាងស្តាំ*

**រូប 22៖ ប្រាក់សន្សំរបស់រដ្ឋាភិបាល**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

*សម្គាល់ ៖ RHS=ខាងស្តាំ*

23 របាយការណ៍ប្រចាំឆមាស ធនាគារជាតិនៃកម្ពុជា ខែ មិថុនា ឆ្នាំ 2020។

24 សូមមើល https://www.nbc.org.kh/english/monetary_policy/exchange_rate_policy.php ។

25 ទោះជាយ៉ាងណា ធនាគារកណ្តាលបានកំណត់អត្រាការប្រាក់សម្រាប់ប្រាក់កម្ចីក្នុងអត្រា 18 ភាគរយក្នុងមួយឆ្នាំ កាលពីខែ មីនា ឆ្នាំ 2017។ សូមមើលប្រកាសលេខ ប7-017-109 ផក ចុះថ្ងៃទី 13 ខែ មីនា ឆ្នាំ 2017។

### រដ្ឋាភិបាលបានចាត់វិធានការឆ្លើយតបដែលមិនធ្លាប់មានទៅនឹងជំងឺកូវីដ 19

**រដ្ឋាភិបាលបានផ្តល់ការគាំទ្រយ៉ាងច្រើនមិនធ្លាប់មាន រហូតដល់ 5 ភាគរយនៃ ផសស ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ 19។** កញ្ចប់គាំទ្រដ៏ធំ រួមមាន ចំណាយពាក់ព័ន្ធនឹងសុខភាព និងជំនួយប្រាក់ចំណូល ការផ្តល់ប្រាក់សមធម៌ និងការធានាប្រាក់កម្ចី ចំណាយលើការអភិវឌ្ឍ និងការបន្ធូរបន្ថយពន្ធ។ កម្មវិធីទ្រទ្រង់សារពើពន្ធដ៏ធំរបស់រដ្ឋាភិបាលត្រូវបានព្យាករណ៍ថានឹងប្រែក្លាយអតិរេកថវិកានៅឆ្នាំ 2019 (និងឆ្នាំ 2018) ទៅជាឱនភាពថវិកានៅឆ្នាំ 2020។ ដើម្បីលុបបំបាត់គម្លាតរវាងការប្រមូលប្រាក់ចំណូល និងលក្ខខណ្ឌតម្រូវផ្នែកហិរញ្ញប្បទាន អាជ្ញាធរកម្ពុជាបានប្រើប្រាស់ប្រាក់សន្សំរបស់រដ្ឋាភិបាលដែលបានដាក់បញ្ញើក្នុងប្រព័ន្ធធនាគារ។ បើទោះជាកំណើនប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅតែមានភាពល្អប្រសើរ នៅខែ មិថុនា ឆ្នាំ 2020 កំណើននេះមានចំនួនតែ 14.5 ភាគរយប៉ុណ្ណោះ (ធៀបនឹងឆ្នាំមុន) ថយពី 48.4 ភាគរយនៅខែ ធ្នូ ឆ្នាំ 2019 (រូប 22) ដោយសារការថយចុះនៃការប្រមូលប្រាក់ចំណូល។ ក្រៅពីនេះ ផ្នែកជាច្រើននៃអន្តរាគមន៍របស់រដ្ឋាភិបាលទើបតែចាប់ផ្តើមនៅបំណាច់ខែ មិថុនា ឆ្នាំ 2020 ប៉ុណ្ណោះ។

**ដោយសារការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយជោគជ័យតាំងពីឆ្នាំ 2005 កម្ពុជានៅតែអាចបង្កើនការប្រមូលប្រាក់ចំណូលរបស់ខ្លួន។** ជាលទ្ធផល កម្ពុជាបានបង្កើនទំហំសារពើពន្ធជាច្រើនក្នុងទម្រង់ជាប្រាក់សន្សំរបស់រដ្ឋាភិបាល ហើយកម្ពុជានៅតែគ្រប់គ្រងសារពើពន្ធយ៉ាងប្រុងប្រយ័ត្ន និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ នៅបំណាច់ខែ មិថុនា ឆ្នាំ 2020 ប្រាក់បញ្ញើរបស់រដ្ឋាភិបាលមានចំនួន 17.3 ភាគរយនៃ ផសស (ស្មើនឹង 19.3 ទ្រីលានរៀល)។

**ការប្រមូលប្រាក់ចំណូលនៅឆ្នាំ 2020 ថយចុះ ដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ច និងការថយចុះការនាំចូលដែលបណ្តាលមកពីជំងឺកូវីដ 19។** ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020 ប្រាក់ចំណូលរបស់រដ្ឋាភិបាលមានចំនួន 14.3 ទ្រីលានរៀល ថយចុះ 14.2 ភាគរយធៀបនឹងឆ្នាំមុន (រូប 23)[26]។ នៅក្នុងការថយចុះចំនួន 14.2 ភាគរយពិន្ទុនេះ ចំណូលពន្ធថយចុះ 7.9 ភាគរយពិន្ទុ ចំណូលផ្សេងទៀត (ជាពិសេសចំណូលមិនមែនពន្ធ) ថយចុះ 2.9 ភាគរយពិន្ទុ ហើយជំនួយឥតសំណងថយចុះ 3.5 ភាគរយពិន្ទុ។ ចំណូលពន្ធដែលរួមទាំងពន្ធលើទំនិញ និងសេវា ពន្ធលើប្រាក់ចំណេញ ប្រាក់ចំណូល និងចំណេញមូលធន និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ មានចំនួន 85.4 ភាគរយនៃចំណូលសរុប ខណៈដែលចំណូលផ្សេងទៀតមានចំនួន 4.6 ភាគរយ និងជំនួយឥតសំណងមានចំនួន 10.0 ភាគរយ។

**ការថយចុះចំណូលពន្ធបណ្តាលមកពីការថយចុះចំណូលពន្ធលើទំនិញ និងសេវា (60 ភាគរយនៃចំណូលពន្ធសរុប) ដែលថយចុះ 18.0 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020។** នៅពេលការនាំចូលថយចុះ ចំណូលពីពន្ធលើតម្លៃបន្ថែម អាករ និងពន្ធនាំចូល ដែលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលជាស្ថាប័នប្រមូលចំណូលធំជាងគេ ថយចុះ 23.1 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020។ ផ្ទុយទៅវិញ ដោយសារការកើនឡើងនៃពន្ធប្រាក់ចំណេញនៅខែ មេសា ឆ្នាំ 2020 ការប្រមូលចំណូលដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាស្ថាប័នប្រមូលចំណូលធំជាងគេទីពីរ កើន 10.8 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងអំឡុងពេលដូចគ្នា។ ទោះជាយ៉ាងណា ការប្រមូលចំណូលក្នុងស្រុកបន្តថយចុះរហូតដល់បំណាច់ឆ្នាំ។ ចំណូលសរុបដែលប្រមូលបានដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ មានចំនួន 90 ភាគរយនៃចំណូលក្នុងស្រុកសរុប។

**រូប 23៖ ចំណូលរបស់រដ្ឋាភិបាល (ពាន់លានរៀល)**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS=ខាងស្តាំ*

**រូប 24៖ ចំណាយរបស់រដ្ឋាភិបាល**
(ពាន់លានរៀល)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ RHS=ខាងស្តាំ*

[26] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ខែ សីហា ឆ្នាំ 2020។

**ផ្ទុយទៅវិញ ចំណាយរបស់រដ្ឋាភិបាលកើនរហូតដល់ 16.2 ទ្រីលានរៀល ឬស្មើ 21.5 ភាគរយ (ធៀបនឹងឆ្នាំមុន) (រូប 24) ក្នុងអំឡុងពេលដូចគ្នា ដោយសារការអន្តរាគមជាច្រើនរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបនឹងជំងឺកូវីដ 19។** ក្នុងចំណាយកំណើន 21.5 ភាគរយនេះ ការកើនឡើងនៃចំណាយលើអចលនទ្រព្យ (ចំណាយមូលធន) មានចំនួនច្រើនជាងគេ ស្មើនឹងពាក់កណ្ដាលនៃកំណើនចំណាយសរុបនេះ (ឬ 10.5 ភាគរយពិន្ទុ)។ ចំណាយលើអត្ថប្រយោជន៍សង្គម ឧបត្ថម្ភធន និងជំនួយឥតសំណង (ដល់ថ្នាក់ក្រោមជាតិ) សរុបរួម មានចំនួន 8.7 ភាគរយពិន្ទុនៃកំណើនចំណាយសរុបនេះ។ ការផ្ដល់សំណងដល់កម្មករនិយោជិត ដែលកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានថយចុះ និងមានចំណែកត្រឹមតែ 0.8 ភាគរយនៃកំណើនចំណាយសរុបនេះ។ អាជ្ញាធរកម្ពុជាសម្រេចបាន ឬសម្រេចលើសចំណុចដៅនៃការដំឡើងប្រាក់បៀវត្សរ៍អប្បបរមាប្រចាំខែរបស់មន្ត្រីរាជការ ឱ្យបានយ៉ាងតិច 1 លានរៀល។ ក្រៅពីនេះ ការឆ្លើយតបទៅនឹងជំងឺកូវីដ 19 តម្រូវឱ្យមានការបង្កើនចំណាយសាធារណៈយ៉ាងច្រើន ដែលធ្វើឱ្យថយចុះទំហំសារពើពន្ធរបស់អាជ្ញាធរកម្ពុជាសម្រាប់ការដំឡើងប្រាក់បៀវត្សរ៍មន្ត្រីរាជការបន្ថែមទៀត។

**ចំណាយលើអត្ថប្រយោជន៍សង្គមកើនឡើងយ៉ាងឆាប់រហ័សដោយសារអន្តរាគមន៍គោលនយោបាយថ្មីៗរបស់រដ្ឋាភិបាល។** ដោយសារអន្តរាគមន៍ជាច្រើនរបស់រដ្ឋាភិបាល ចំណាយរបស់រដ្ឋាភិបាលលើអត្ថប្រយោជន៍សង្គមមានចំនួន 1,737.8 ពាន់លានរៀល (ស្មើនឹង 424.3 លានដុល្លារ) ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020 កើន 70 ភាគរយធៀបនឹងឆ្នាំមុន។ ចំណាយលើអត្ថប្រយោជន៍សង្គម ដែលរួមមានសន្តិសុខសង្គម និងជំនួយសង្គមមានចំនួនមួយភាគបួន (ឬ 5.4 ភាគរយពិន្ទុ) នៃកំណើនចំណាយសរុបក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020។

### ឱនភាពសារពើពន្ធត្រូវបានព្យាករណ៍ថាកើនដល់ 5.6 ភាគរយនៃ ផសស ក្នុងឆ្នាំ 2020

**ការប្រមូលចំណូលនៅឆ្នាំ 2020 ត្រូវបានរំពឹងថាមានចំនួនតែ 18.8 ភាគរយនៃ ផសស ថយពី 26.3 ភាគរយនៃ ផសស នៅឆ្នាំ 2019។** ដោយសារអន្តរាគមន៍ជាច្រើនរបស់រដ្ឋាភិបាល ចំណាយត្រូវបានរំពឹងថាមានចំនួនដល់ 24.4 ភាគរយនៃផសស នៅឆ្នាំ 2020 តិចជាងចំនួនប៉ាន់ស្មាន 25.5 ភាគរយនៃ ផសស ដែលបានចំណាយនៅឆ្នាំ 2019។ ជាលទ្ធផល ឱនភាពសារពើពន្ធជារួម (រួមទាំងជំនួយឥតសំណង) ត្រូវបានព្យាករណ៍ថានឹងកើនដល់ 5.6 ភាគរយនៃ ផសស នៅឆ្នាំ 2020 (រូប 25)។ ដោយទទួលបានហិរញ្ញប្បទានពីបរទេសយ៉ាងច្រើនពីដៃគូអភិវឌ្ឍន៍ ហិរញ្ញប្បទានក្នុងស្រុកត្រូវបានរំពឹងថានឹងមានចំនួនស្មើពាក់កណ្ដាលនៃតម្រូវការហិរញ្ញប្បទានសរុបដែលបានព្យាករណ៍ ដែលជួយកាត់បន្ថយតម្រូវការដកយកប្រាក់បញ្ញើរបស់រដ្ឋាភិបាលមកប្រើប្រាស់។ ក្នុងចំណោមតម្រូវការហិរញ្ញប្បទានដែលមានចំនួន 5.6 ភាគរយនៃ ផសស ហិរញ្ញប្បទានបរទេស (កម្ចីផ្លូវការ) ត្រូវបានព្យាករណ៍ថាមានចំនួន 3.0 ភាគរយនៃ ផសស ខណៈហិរញ្ញប្បទានក្នុងស្រុក (និងការរំលោះបំណុល) ដែលជាការដកយកប្រាក់បញ្ញើរបស់រដ្ឋាភិបាលមកប្រើប្រាស់មានចំនួន 2.6 ភាគរយនៃ ផសស (រូប 26)។

### ការទ្រទ្រង់សារពើពន្ធនៅកម្ពុជាមានលំដាប់ខ្ពស់ទី 4 ក្នុងតំបន់

**ការទ្រទ្រង់សារពើពន្ធសរុបរបស់កម្ពុជាដែលមានចំនួន 5 ភាគរយនៃ ផសស មានលំដាប់ទី 4 ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ចំណែកប្រទេស 3 ទៀតដែលមានការទ្រទ្រង់សារពើពន្ធច្រើនជាងកម្ពុជា រួមមាន ថៃ ម៉ុងហ្គោលី និងម៉ាឡេស៊ី** (រូប 27)។ ទោះបីកម្ពុជាជាប្រទេសក្រីក្រជាងគេក្នុងតំបន់ក្ដី ប៉ុន្តែ កម្រិតនៃការទ្រទ្រង់ផ្នែកគោលនយោបាយសរុបរបស់កម្ពុជា ដែលមានទំហំធំជាងប្រទេសជិត

**រូប 25៖ ប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល**
(% នៃ ផសស)




*ប្រភព ៖ ច្បាប់ស្ដីពីការទូទាត់ថវិកា ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក*

*សម្គាល់ ៖ e=ការប៉ាន់ស្មាន; p/proj.=ការព្យាករណ៍*

**រូប 26៖ អតិរេក/ឱនភាពរបស់រដ្ឋាភិបាល និងហិរញ្ញប្បទាន**
(% នៃ ផសស នៅឆ្នាំ 2020)




*ប្រភព ៖ ច្បាប់ស្ដីពីការទូទាត់ថវិកា ការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក*

*សម្គាល់ ៖ e=ការប៉ាន់ស្មាន; proj.=ការព្យាករណ៍*

ខាងដែលមានសេដ្ឋកិច្ចរីកចម្រើនជាង ដូចជា ឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម គឺជាសញ្ញាល្អ។ ក្នុងចំណោមអន្តរាគមន៍របស់រដ្ឋាភិបាលដែលមានចំនួន 5 ភាគរយនៃ ផសស ការទ្រទ្រង់សារពើពន្ធផ្ទាល់ (ការគាំទ្រប្រាក់ចំណូល និងចំណូលដល់គ្រួសារ និងក្រុមហ៊ុនរងផលប៉ះពាល់ និងការទ្រទ្រង់សុខភាពសាធារណៈ) មានចំនួន 2.8 ភាគរយនៃ ផសស។ ក្រៅពីនេះជាការគាំទ្រដល់កម្ចី សមធម៌ និងការធានា។ អន្តរាគមន៍របស់រដ្ឋាភិបាលបានជួយកាត់សម្រាលវិបត្តិសេដ្ឋកិច្ច និងសង្គម ដែលបណ្តាលមកពីជំងឺកូវីដ 19។

**កម្ពុជាអាចពង្រីក និងពង្រឹងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលទើបតែត្រូវបានរៀបចំឡើងតាំងពីមុនវិបត្តិជំងឺកូវីដ 19។** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដ៏ច្រើនជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ត្រូវបានអនុវត្ត។ ចាប់តាំងពីការអនុវត្តដំបូងនៅថ្ងៃទី 24 ខែ មិថុនា ឆ្នាំ 2020 កម្មវិធីដែលមានទំហំទឹកប្រាក់ចន្លោះពី 25 លានដុល្លារ ទៅ 30 លានដុល្លារនេះ បានគ្របដណ្តប់លើប្រជាជនជាច្រើនគ្រួសារ (580,838 គ្រួសារនៅខែទីមួយ, 598,512 គ្រួសារនៅខែទីបី និង 644,655 គ្រួសារនៅខែទីបី)[27]។ សម្រាប់អន្តរាគមន៍នៅខែទីបួនដែលចាប់ផ្តើមនៅថ្ងៃទី 25 ខែ កញ្ញា ឆ្នាំ 2020 អាជ្ញាធរកម្ពុជាបានរៀបចំកញ្ចប់ថវិកាចំនួន 125.1 ទ្រីលានរៀល ស្មើនឹង 30.53 លានដុល្លារ សម្រាប់ឧបត្ថម្ភជូនប្រជាជនចំនួន 689,973 គ្រួសារ។ ទោះជាយ៉ាងណា ការពង្រីកគម្រោងជំនួយសង្គមលើសពីក្របខណ្ឌពេលវេលាដែលបានគ្រោងទុក នឹងធ្វើឱ្យមានការចំណាយថវិកាកាន់តែច្រើន។

### បំណុលសាធារណៈត្រូវបានរំពឹងថានឹងកើនឡើង ប៉ុន្តែហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប

**ផលធៀបបំណុល-ផសស របស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនទៅប្រមាណ 31.6 ភាគរយនៃ ផសស នៅឆ្នាំ 2020 (រូប 28)។** ការកើនឡើងនេះបណ្តាលមកពីការផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធដែលកើនឡើងរបស់កម្ពុជាក្នុងរយៈពេលខ្លី (សូមមើលឧបសម្ព័ន្ធ)។ ទោះបីជាការវិភាគពីនិរន្តរភាពបំណុលកាលពីឆ្នាំ 2019 ដោយប្រើប្រាស់ក្របខណ្ឌនិរន្តរភាពបំណុលរួមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ/ធនាគារពិភពលោកសម្រាប់ប្រទេសមានប្រាក់ចំណូលទាប បង្ហាញថា កម្ពុជានៅតែមានហានិភ័យទាបក្នុងការមានវិបត្តិបំណុលខាងក្រៅក្តី[28] ប៉ុន្តែទិន្នន័យដើមគ្រាមានការប្រែប្រួល។ តាមការប៉ាន់ស្មានថា ឱនភាពសារពើពន្ធនឹងមានចំនួន 5.6 ភាគរយនៃ ផសស នៅឆ្នាំ 2020 និង 6.1 ភាគរយនៃ ផសស នៅឆ្នាំ 2021 តម្រូវការហិរញ្ញប្បទានពីបរទេសនឹងកើនឡើង ខណៈដែលអត្រាប្តូរប្រាក់នឹងរងសម្ពាធ។

**ការផ្តល់ឥណទានដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំ កើនឡើងលឿន ជាមធ្យមចំនួន 32.1 ភាគរយក្នុងមួយឆ្នាំ នៅអំឡុងឆ្នាំ 2009-2019។** ទំហំនៃការផ្តល់ឥណទានដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំក្នុងឥណទានក្នុងស្រុកសរុប កើន 31.1 ភាគរយនៅឆ្នាំ 2019 កើនពី 18.8 ភាគរយនៅឆ្នាំ 2009។ ខណៈដែលការផ្តល់ឥណទាននេះមានកំណើនត្រឹមតែ 23.1 ភាគរយធៀបនឹងឆ្នាំមុន កាលពីខែ សីហា ឆ្នាំ 2020 ថយពី 39.4 ភាគរយនៅបំណាច់ឆ្នាំ 2019 ឥណទានក្នុងស្រុកមិនទាន់សង ដែលផ្តល់ហិរញ្ញប្បទានដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំ មានចំនួន 34.6 ពាន់លានដុល្លារ (ស្មើនឹង 8.17 ពាន់លានដុល្លារ)។ ទិន្នន័យលម្អិតស្តីពីឥណទានមិនទាន់សងបង្ហាញថា ការផ្តល់ហិរញ្ញប្បទានដល់ការបញ្ចាំមានចំនួនច្រើនជាងគេ ចំនួន 14.2 ពាន់លានរៀល (3.5 ពាន់លានដុល្លារ)។ បន្ទាប់មកគឺការផ្តល់ហិរញ្ញប្បទាន

**រូប 27៖ ការទ្រទ្រង់សារពើពន្ធ-ការប្រៀបធៀបក្នុងតំបន់**
(ភាគរយនៃ ផសស)




*ប្រភព ៖ ធនាគារពិភពលោក 2020a*

**រូប 28៖ បំណុលរដ្ឋាភិបាល កើនឡើង**
(ភាគរយនៃ ផសស)




*ប្រភព ៖ ធនាគារពិភពលោក 2020a និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក*

27 ការប្រកាសតាមបណ្តាញផ្សព្វផ្សាយ ថ្ងៃទី 29 ខែ កញ្ញា ឆ្នាំ 2020 អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

28 របាយការណ៍របស់បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិសម្រាប់ការពិគ្រោះមាត្រា IV ឆ្នាំ 2019 -ការវិភាគពីនិរន្តរភាពបំណុល។ https://www.imf.org/en/Publications/CR/Issues/2019/12/23/Cambodia-2019-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-48912។

ដល់វិស័យសំណង់ ដែលមានចំនួន 10.5 ពាន់លានរៀល (2.6 ពាន់លានដុល្លារ) និងការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ដែលមានចំនួន 9.8 ពាន់លានរៀល (2.4 ពាន់លានដុល្លារ) នៅខែ សីហា ឆ្នាំ 2020។ មានការយល់ឃើញជារួមថា ការកើនឡើងនៃតម្លៃទ្រព្យ អាចរួមចំណែកជាវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ និងអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច[29]។ ជំងឺកូវីដ 19 បានរឹតត្បិតលទ្ធភាពរបស់គ្រួសារក្នុងការសងប្រាក់ ជាពិសេសកម្ចីក្នុងការបញ្ចាំ ដែលភាគច្រើនជាកម្ចីជាប្រាក់ដុល្លារ។ កន្លងមក កម្ពុជារក្សាបានស្ថិរភាពហិរញ្ញវត្ថុ មួយផ្នែកដោយសារតែការទប់ស្កាត់ហានិភ័យដែលបណ្តាល មកពីអ្នកខ្ចីមានការលំបាកក្នុងការសងប្រាក់។ អត្រាការប្រាក់នៅតែមិនប្រែប្រួល។ បើទោះជាប្រាក់រៀលរងសម្ពាធ ប៉ុន្តែ តម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក នៅតែមានស្ថិរភាព។ បច្ចុប្បន្ន កម្ពុជានៅតែអាចកៀរគរទុនបម្រុងជារូបិយប័ណ្ណបរទេស ហើយទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជាមានចំនួនស្មើនឹងការនាំចូលរយៈពេល 10 ខែ។ កត្តានេះបានជួយរក្សាទំនុកចិត្តទីផ្សារលើរូបិយវត្ថុក្នុងស្រុក និងសេដ្ឋកិច្ចជាតិ។

**គិតត្រឹមខែ មិថុនា ឆ្នាំ 2020 កម្ពុជាមានបំណុលសាធារណៈដែលមិនទាន់សងសរុបចំនួន 7.9 ពាន់លានដុល្លារ[30] ដែលសុទ្ធសឹងជាបំណុលខាងក្រៅ (និងគិតជារូបិយប័ណ្ណបរទេស)។** កម្ចីភាគច្រើនគឺសម្រាប់ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលមានចំនួន 87.0 ភាគរយនៃកម្ចីសរុប។ ទំហំមធ្យមនៃជំនួយឥតសំណងក្នុងបំណុលសាធារណៈរបស់កម្ពុជាមានភាពប្រសើរឡើង ដោយមានចំនួន 55.8 ភាគរយនៅឆមាសទីមួយក្នុងឆ្នាំ 2020 កើនពី 51.6 ភាគរយនៅឆ្នាំ 2019 និងកើនពី 43.7 ភាគរយនៅឆ្នាំ 2018។ បំណុលមិនទាន់សងជាប្រាក់ដុល្លារអាមេរិកមានចំនួនច្រើនជាងគេ ស្មើនឹង 43.5 ភាគរយនៃបំណុលសរុប។ បន្ទាប់មកគឺបំណុលមិនទាន់សងជាសិទ្ធិដកប្រាក់ពិសេស (SDR) ដែលមានចំនួន 25.7 ភាគរយនៃបំណុលសរុប។ ទោះជាចិនជាប្រទេសផ្តល់ឥណទានច្រើនជាងគេ ចំនួន 3.7 ពាន់លានដុល្លារ (ស្មើនឹង 46.8 ភាគរយនៃបំណុលសរុប) បំណុលជាប្រាក់យ័នចិនមានចំនួនតិចជាង 15 ភាគរយនៃបំណុលសរុប។ កម្ពុជាក៏ជំពាក់ធនាគារអភិវឌ្ឍន៍អាស៊ី (18.6 ភាគរយ) និងធនាគារពិភពលោក (7.9 ភាគរយ) ផងដែរ។ ក្រៅពីនេះ កម្ពុជាជំពាក់បំណុលប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ និងបារាំង។ នៅខែ មិថុនា ឆ្នាំ 2020 ប្រទេសទាំង 6 ដែលផ្តល់ឥណទានច្រើនជាងគេ មានចំនួន 89 ភាគរយនៃបំណុលសរុបរបស់កម្ពុជា។

### កំណើនបំណុលសាធារណៈរបស់កម្ពុជាថយចុះ ប៉ុន្តែបំណុលវិស័យឯកជនកើនឡើង

**កំណើនបំណុលរបស់កម្ពុជាថយចុះនៅឆ្នាំ 2019 ព្រោះថាបំណុលដែលមិនទាន់សងចិន ធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋកូរ៉េ ថយចុះបន្តិច។** កំណើនបំណុលសាធារណៈរបស់កម្ពុជាកើនចំនួន 13.8 ភាគរយនៅឆ្នាំ 2017 មួយផ្នែកធំដោយសារតែការកើនឡើងនៃកម្ចីពីចិន (រូប 29)។ កម្ចីពីចិនមានចំណែកច្រើនជាងគេ ស្មើនឹង 6.7 ភាគរយពិន្ទុនៃបំណុលមិនទាន់សងសរុបនៅឆ្នាំ 2017។ កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានចំនួន 2.9 ភាគរយពិន្ទុ ខណៈដែលកម្ចីពីបារាំងមានចំនួន 1.4 ភាគរយពិន្ទុ និងកម្ចីពីសាធារណរដ្ឋកូរ៉េមានចំនួន 1.2 ភាគរយពិន្ទុ។ កំណើនបំណុលបន្តថយចុះ ដោយមានចំនួន 8.2 ភាគរយនៅឆ្នាំ 2019។ ក្នុងនោះ កម្ចីមិនទាន់សងដែលជំពាក់ចិនមានចំនួន 2.7 ភាគរយពិន្ទុ កម្ចីមិនទាន់សងដែលជំពាក់ធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួន 1.5 ភាគរយពិន្ទុ និងកម្ចីមិនទាន់សងដែលជំពាក់សាធារណរដ្ឋកូរ៉េមានចំនួន 0.3 ភាគរយពិន្ទុ។ ទោះជា

**រូប 29៖ ការរួមចំណែកដល់កំណើនបំណុលរបស់កម្ពុជា**
(គិតជាភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*
*សម្គាល់ ៖ ADB=ធនាគារអភិវឌ្ឍន៍អាស៊ី, WB=ធនាគារពិភពលោក, ROW=ប្រទេសផ្សេងទៀត*

**រូប 30៖ ប្រទេសមួយចំនួនជំពាក់បំណុលច្រើន ប៉ុន្តែភាគច្រើនជាបំណុលក្នុងស្រុក និងឯកជន**
(ភាគរយនៃ ផសសស)




*ប្រភព ៖ វិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ ធនាគារពិភពលោក*

29 មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ 2001។
30 ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈរបស់កម្ពុជា លេខ 10 ខែ កញ្ញា ឆ្នាំ 2020 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

យ៉ាងណា បំណុលសាធារណៈត្រូវបានព្យាករណ៍ថានឹងកើនឡើងជាថ្មី ដើម្បីផ្តល់ហិរញ្ញប្បទានដល់កំណើនឱនភាពសារពើពន្ធដែលបណ្តាលមកពីជំងឺកូវីដ 19។

**បំណុលឯកជនរបស់កម្ពុជាកើនឡើង។** បំណុលឯកជនរបស់កម្ពុជាកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ បំណុលសរុបរបស់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន 148.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពី 58.3 ភាគរយនៃ ផសស នៅឆ្នាំ 1997។ បំណុលខាងក្រៅរបស់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន 62.7 ភាគរយនៃ ផសស កើនពី 51.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 ចំណែកបំណុលក្នុងស្រុករបស់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន 85.7 ភាគរយនៃ ផសស នៅឆ្នាំ 2018 កើនពី 6.9 ភាគរយនៃ ផសស[31]។ ក្នុងចំណោមប្រទេសទាំង 6 ដែលមានបំណុលសរុបច្រើនជាងគេនៅតំបន់អាស៊ីបូព៌ា កម្ពុជាឈរនៅលំដាប់ទី 6 បន្ទាប់ពីប្រទេសម៉ុងហ្គោលី ចិន ម៉ាឡេស៊ី វៀតណាម និងថៃ (រូប 30)។

## ទស្សនៈវិស័យ

**សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងថយចុះចំនួន 2.0 ភាគរយនៅឆ្នាំ 2020 និងងើបឡើងវិញក្នុងអត្រាកំណើន 4.0 ភាគរយនៅឆ្នាំ 2021** (តារាង 1)។ ការព្យាករនេះស៊ីសង្វាក់គ្នានឹងសក្តានុពលកំណើនក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលត្រូវបានរំពឹងថានឹងថយចុះជិត 2 ភាគរយនៅរយៈពេលមួយទសវត្សរ៍ក្រោយ ដោយថយពី 7.6 ភាគរយក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ (2010-2019) មកត្រឹម 5.7 ភាគរយនៅអំឡុងឆ្នាំ 2020-2030 ដោយមិនគិតពីផលប៉ះពាល់នៃជំងឺកូវីដ 19 ដោយសន្មតថា សមាសភាគសំខាន់ៗនីមួយៗនៃសក្តានុពលកំណើន (ការវិនិយោគ មូលធនមនុស្ស និងអត្រាចូលរួមក្នុងកម្លាំងពលកម្ម) រក្សានិន្នាការដដែល[32]។ ដោយមានការបន្ធូរបន្ថយវិធានការរក្សាគម្លាតសង្គម សកម្មភាពសេដ្ឋកិច្ចក្នុងស្រុករបស់កម្ពុជាបាន និងកំពុងវិលត្រឡប់ជាបណ្តើរៗទៅរកស្ថានភាពប្រក្រតី។ តម្រូវការក្នុងស្រុក ដូចជា ការធ្វើដំណើរក្នុងស្រុក និងទេសចរណ៍ មានការកើនឡើង។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន (CCFTA) នាពេលថ្មីៗនេះ និងលទ្ធភាពដែលកិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅឆ្នាំ 2021 នឹងជួយជំរុញការវិនិយោគក្នុងស្រុក និងពាណិជ្ជកម្មក្នុងតំបន់។ បន្ថែមលើនេះ ចាប់ពីឆ្នាំ 2021 តទៅកម្ពុជានឹងទទួលបានប្រយោជន៍ពីការចូលជាសមាជិក ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ដែលជាតំបន់ពាណិជ្ជកម្មសេរីធំជាងគេក្នុងពិភពលោក ដែលត្រូវបានចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ 2020។

**នៅក្នុងប្រទេស ការព្យាកររំពឹងថានឹងគ្មានផលប៉ះពាល់អវិជ្ជមានខ្លាំងយូរអង្វែងនៃជំងឺកូវីដ 19 លើវិស័យសាជីវកម្ម ឬវិស័យធនាគារ ឬសមតុល្យនៃការទូទាត់ទេ។** តាមការសន្មតទំនុកចិត្តទីផ្សារនឹងត្រូវបានស្តារឡើងវិញបន្តិចម្តងៗ ខណៈដែលកម្ពុជាអាចគ្រប់គ្រងស្ថានភាពជំងឺកូវីដ 19 បាន ហើយលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសនឹងងើបឡើងវិញ។ ការប្រើប្រាស់ក្នុងវិស័យឯកជនត្រូវបានសន្មតថានឹងថយចុះបន្តិច ដោយសារការទ្រទ្រង់ផ្ទាល់របស់រដ្ឋាភិបាលលើសារពើពន្ធ ដែលមានចំនួន 2.8 ភាគរយនៃ ផសស។ ការវិនិយោគថេរសរុប នៅតែមានភាពរឹងមាំក្នុងសេណារីយ៉ូនេះ ព្រោះថា គម្រោងសាងសង់បច្ចុប្បន្នត្រូវបានបញ្ចប់ដោយមានការវិលត្រលប់មកវិញនូវលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស ខណៈដែលការវិនិយោគសាធារណៈកើនឡើង។ ការនាំចេញត្រូវបានព្យាករណ៍ថានឹងថយចុះខ្លាំង ប៉ុន្តែនឹងងើបឡើងវិញយ៉ាងឆាប់រហ័សនៅឆ្នាំ 2021 (និងឆ្នាំ 2022)។ ការនាំចូលថយចុះបន្តិច ព្រោះថា ការប្រើប្រាស់នៅតែមានកំណើនមួយផ្នែកធំដោយសារអន្តរាគមន៍ជាច្រើនរបស់រដ្ឋាភិបាល។ កំណើនកសិកម្មត្រូវបានសន្មតថានឹងកើនឡើងលឿងគ្រាន់បើ ព្រោះថាផលិតកម្មស្រូវកើនឡើង ខណៈដែលការធ្វើពិពិធកម្មដំណាំផ្សេងទៀត បសុសត្វ និងជលផលសម្រាប់ការនាំចេញ កំពុងមានការរីកចម្រើន។ វិស័យឧស្សាហកម្មត្រូវបានរំពឹងថានឹងថយចុះបន្តិច។ ការថយចុះនៃឧស្សាហកម្មផលិតសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ត្រូវបានរំពឹងថានឹងត្រូវបានប៉ះប៉ូវមួយផ្នែកដោយការពង្រីកឧស្សាហកម្មផលិតផ្សេងទៀត។

**ចំពោះប្រទេសខាងក្រៅ ការព្យាករគឺថា ពាណិជ្ជកម្មអន្តរជាតិ និងពាណិជ្ជកម្មក្នុងតំបន់នឹងងើបឡើងវិញបន្តិចម្តងៗ ដោយមានកំណើននៃការជ្រៀតចូលទីផ្សារក្រៅប្រទេស ដូចជា ទីផ្សារចិន។** កម្លាំងពលកម្មដែលមិនទាន់ប្រើប្រាស់អស់លទ្ធភាព និងមានតម្លៃទាបនៅកម្ពុជា រួមនឹងធនធានដីធ្លីយ៉ាងច្រើន អាចត្រូវបានប្រើប្រាស់ក្នុងការផលិតទំនិញចាំបាច់ និងប្រើកម្លាំងពលកម្មច្រើន សម្រាប់ការនាំចេញ។

**តារាង 1 ៖ ទស្សនៈវិស័យម៉ាក្រូ**

| | 2020 | 2021 | 2022 |
|---|---|---|---|
| កំណើន ផសស | -2.0 | 4.0 | 5.2 |
| បែងចែកតាមចំណាយ | | | |
| ការប្រើប្រាស់ដោយឯកជន | -1.4 | 3.4 | 4.7 |
| ការប្រើប្រាស់ដោយរដ្ឋាភិបាល | 6.7 | 8.6 | 5.8 |
| ការវិនិយោគមូលធនថេរសរុប | 6.3 | 6.1 | 7.1 |
| ការនាំចេញទំនិញ និងសេវា | -12.6 | 5.4 | 5.4 |
| ការនាំចូលទំនិញ និងសេវា | -8.9 | 5.5 | 5.4 |
| បែងចែកតាមផលិតកម្ម | | | |
| កសិកម្ម | 1.5 | 0.9 | 1.0 |
| ឧស្សាហកម្ម | -1.2 | 6.9 | 7.1 |
| សេវា | -4.3 | 2.6 | 5.1 |

*ប្រភព ៖ ការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក*

[31] បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ តុលា ឆ្នាំ 2020 ធនាគារពិភពលោក។

[32] បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ តុលា ឆ្នាំ 2020 ធនាគារពិភពលោក។

### ការធ្វើពិពិធកម្មការវិនិយោគផ្ទាល់ពីបរទេសគឺជាសញ្ញាល្អ

**ការកើនឡើងនៃតម្លៃគម្រោងការវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានអនុម័តក្នុងឧស្សាហកម្មក្រៅពីសម្លៀកបំពាក់ និងកសិកម្ម គឺជាសញ្ញាល្អ។** ក្នុងរយៈពេល 7 ខែដំបូងក្នុងឆ្នាំ 2020 គម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក្នុងវិស័យឧស្សាហកម្មផលិតក្រៅពីសម្លៀកបំពាក់ មានចំនួន 878 លានដុល្លារ កើនពី 95 លានដុល្លារក្នុងអំឡុងពេលដូចគ្នានៅឆ្នាំ 2019 ខណៈដែលការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកសិកម្ម (រួមទាំង ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម) មានចំនួន 100 លានដុល្លារ កើនពី 34 លានដុល្លារក្នុងអំឡុងពេលដូចគ្នា។ វិស័យក្រៅពីសម្លៀកបំពាក់ដែលទើបតែងើបឡើង រួមមាន ថាមពល ទំនិញធ្វើដំណើរ ស្បែកជើង គ្រឿងសង្ហារឹម សម្ភារៈសាងសង់ លោហធាតុ ផ្លាស្ទិក ការកែច្នៃស្បែក ការវេចខ្ចប់ផលិតផលតុបតែងលម្អ ទូរគមនាគមន៍ ការផ្គុំដំឡើងគ្រឿងមេកានិក សម្ភារៈអេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត និងភេសជ្ជៈ។ ប្រសិនបើមានការទ្រទ្រង់បានល្អ វិស័យទាំងនេះនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជា ក្នុងការធ្វើពិពិធកម្មវិស័យឧស្សាហកម្មផលិតរបស់កម្ពុជា។

## ហានិភ័យ និងបញ្ហាប្រឈម

**ទស្សនៈវិស័យកំណើនរបស់កម្ពុជានៅតែមានភាពមិនប្រាកដប្រជាយ៉ាងខ្លាំង។** សេដ្ឋកិច្ចកម្ពុជាជាសេដ្ឋកិច្ចតូច បើកចំហរ មានមូលដ្ឋានតូច និងពឹងផ្អែកខ្លាំងលើលំហូរចូលមូលធន ជាពិសេសការវិនិយោគពីបរទេស និងពាណិជ្ជកម្មពីក្រៅប្រទេស។ ការកើនឡើងនៃភាពតានតឹងរវាងមហាអំណាចសេដ្ឋកិច្ច និងការថយចុះនៃកិច្ចសហប្រតិបត្តិការពហុភាគីនៅជុំវិញពិភពលោក កំពុងធ្វើឲ្យមានភាពមិនប្រាកដប្រជា ដែលធ្វើឱ្យប៉ះពាល់ដល់លំហូរពាណិជ្ជកម្ម និងការវិនិយោគ។ ការបន្តពេលអនុវត្តគម្រោងជំនួយសង្គមនៅកម្ពុជាលើសពីក្របខណ្ឌពេលវេលាដែលបានគ្រោងទុក នឹងធ្វើឱ្យមានការចំណាយថវិកាយ៉ាងច្រើន ខណៈដែលការមិនបន្តពេលអនុវត្តគម្រោងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់គ្រួសារក្រីក្រ និងកាត់បន្ថយតម្រូវការក្នុងស្រុក។ ហានិភ័យទាបបំផុតរួមមានរលកទីពីរនៃការផ្ទុះជំងឺកូវីដ 19 និងការថយចុះបន្ថែមទៀត និងយូរអង្វែងនៃចំនួនភ្ញៀវទេសចរ ដោយសារអត្ថិភាពនៃជំងឺកូវីដ 19 ទូទាំងពិភពលោក និងល្បឿននៃការបញ្ចេញវ៉ាក់សាំងជំងឺកូវីដ 19 ឱ្យប្រើប្រាស់ជាសកល។ ការដកផ្នែកខ្លះនៃការអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប ដែលចូលជាធរមាននៅថ្ងៃទី 12 ខែ សីហា ឆ្នាំ 2020 បានធ្វើឱ្យប៉ះពាល់ដល់ការនាំចេញរបស់កម្ពុជា ទៅកាន់សហភាពអឺរ៉ុបចំនួន 20 ភាគរយ។

**បើទោះជាការទប់ហានិភ័យហិរញ្ញវត្ថុដែលបណ្តាលមកពីជំងឺកូវីដ 19 ជួយរក្សាស្ថិរភាពក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុមានហានិភ័យកាន់តែច្រើនដោយសារវិបត្តិបំណុលក្នុងវិស័យហិរញ្ញវត្ថុ។** ដូចបាន ពិភាក្សាខាងលើ បំណុលឯកជនកើនឡើងខ្លាំង ហើយនៅតែមានភាពទន់ខ្សោយដែលរួមមាន ការប្រមូលផ្តុំឥណទានយ៉ាងច្រើន ដែលពាក់ព័ន្ធមួយផ្នែកទៅនឹងហានិភ័យនៃការផ្តល់កម្ចី កង្វះការត្រួតពិនិត្យហ្មត់ចត់នៅតាមច្រកព្រំដែន និងការអនុវត្តការត្រួតពិនិត្យផ្អែកតាមហានិភ័យមិនបានពេញលេញ[33]។

**ទោះបីជាលំបាកក្នុងការបញ្ជាក់ពីផលវិបាកទាំងនេះ ដោយសារតែពេលវេលា ប៉ុន្តែ គ្រោះទឹកជំនន់ដែលកើតឡើងនៅខែតុលា ឆ្នាំ 2020 បានធ្វើឱ្យបាត់បង់អាយុជីវិតមនុស្ស បំផ្លិចបំផ្លាញដំណាំ និងខូចខាតទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។** យោងតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្ងៃទី 22 ខែ តុលា ឆ្នាំ 2020 គ្រោះទឹកជំនន់បានសម្លាប់មនុស្ស 39 នាក់ និងបង្កផលប៉ះពាល់លើប្រជាជន 120,785 គ្រួសារ (483,140 នាក់) ផ្ទះ 115,354 ខ្នង (ផ្ទះ 63 ខ្នងរងការខូចខាត) ដីស្រែ 232,551 ហិកតា និងផ្ទៃដីដាំដំណាំផ្សេងទៀតចំនួន 83,918 ហិកតា។ ទោះជាយ៉ាងណាក៏ដោយ គេមិនទាន់ដឹងថាតើផ្ទៃដីស្រែ និងផ្ទៃដីដាំដំណាំផ្សេងទៀតទទួលរងការខូចខាតជាអចិន្ត្រៃយ៍កម្រិតណានោះទេ។

### យុទ្ធសាស្ត្ររយៈពេលមធ្យមសម្រាប់វិស័យសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ កំពុងត្រូវបានរៀបចំឡើង

**យុទ្ធសាស្ត្រវិស័យសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ឆ្នាំ 2020-2025 ដែលជាផែនទីចង្អុលផ្លូវ និងមានគោលបំណងបង្កើនតម្លៃបន្ថែម និងភាពប្រកួតប្រជែងរបស់វិស័យនេះ កំពុងត្រូវបានរៀបចំឡើង[34]។** យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដើម្បីបង្កើនជំនាញ និងអាជីពសម្រាប់កម្មកររោងចក្រ លើកកម្ពស់ការវិនិយោគពីបរទេស និងការវិនិយោគក្នុងស្រុកលើតម្លៃបន្ថែមខ្ពស់ ទាក់ទាញឧស្សាហកម្មគាំទ្រវិស័យនេះ និងធ្វើពិពិធកម្មទីផ្សារនាំចេញ។ យុទ្ធសាស្ត្រនេះកើតចេញពីការផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់អាជ្ញាធរកម្ពុជាលើការជំរុញវិស័យដ៏សំខាន់នេះ ទៅក្នុងសង្វាក់តម្លៃសកល និងសង្វាក់តម្លៃតំបន់នៃផលិតកម្មសម្លៀកបំពាក់ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ 2015-2025។ គេមិនទាន់ដឹងច្បាស់ថាតើអន្តរាគមន៍របស់រដ្ឋាភិបាល ដូចជា ការកាត់បន្ថយថ្លៃអគ្គិសនី ការធ្វើទំនើបកម្មបច្ចេកវិទ្យា និងការលើកកម្ពស់ឧស្សាហកម្មវាយនភណ្ឌ នឹងធ្វើឡើងនៅពេលឆាប់ៗនេះ ឬយ៉ាងណានោះទេ។ វិស័យកាត់ដេរដែលមានមូលដ្ឋានរឹងមាំនៅកម្ពុជា មានការប្រើប្រាស់កម្លាំងពលកម្មច្រើន និងផ្តោតលើការនាំចេញ។ ទោះជាយ៉ាងណាក៏ដោយ វិស័យឧស្សាហកម្មផលិតនេះភាគច្រើននៅតែជាប្រតិបត្តិការកាត់ដេរធម្មតា ដែលជាផ្នែកមានតម្លៃបន្ថែមតិចជាងគេក្នុងសង្វាក់

33 របាយការណ៍របស់បុគ្គលិកសម្រាប់ការពិគ្រោះមាត្រា IV ឆ្នាំ 2019 មូលនិធិរូបិយវត្ថុអន្តរជាតិ។ (https://wxteww.imf.org/en/Publications/CR/Issues/2019/12/23/Cambodia-2019-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-48912)។

34 សេចក្តីប្រកាស ថ្ងៃទី 28 ខែ កក្កដា ឆ្នាំ 2020 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តម្លៃទាំងមូលនៃវិស័យនេះក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ[35]។

**ក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាភាពប្រកួតប្រជែងក្រៅប្រទេស អាជ្ញាធរកម្ពុជាបានសម្រេចថា គ្មានការដំឡើងប្រាក់ឈ្នួលប្រចាំខែ និងកាត់បន្ថយចំនួនថ្ងៃឈប់សម្រាកដែលទទួលបានប្រាក់ឈ្នួលនៅឆ្នាំ 2021។** ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មសម្លៀកបំពាក់ និងស្បែកជើងត្រូវបានកំណត់ត្រឹម 192 ដុល្លារក្នុងមួយខែសម្រាប់ឆ្នាំ 2021[36]។ ការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ 2021 នឹងមានចំនួនតែ 2 ដុល្លារប៉ុណ្ណោះ ឬស្មើនឹងកំណើន 1.1 ភាគរយធៀបនឹងឆ្នាំ 2020។ មុនឆ្នាំ 2020 ប្រាក់ឈ្នួលអប្បបរមាកើនឡើងជាមធ្យម 13.2 ភាគរយក្នុងមួយឆ្នាំ (2013-2020)។ ទន្ទឹមនឹងនេះ ចំនួនថ្ងៃឈប់សម្រាក (ផ្លូវការ) ដែលទទួលបានប្រាក់ឈ្នួលនៅឆ្នាំ 2021 ត្រូវបានបន្ថយមកត្រឹម 21 ថ្ងៃ ថយពី 23 ថ្ងៃនៅឆ្នាំ 2020។ មុនឆ្នាំ 2020 ចំនួនថ្ងៃឈប់សម្រាកបុណ្យដែលទទួលបានប្រាក់ឈ្នួលគឺ 28 ថ្ងៃក្នុងមួយឆ្នាំ។

### ផែនទីចង្អុលផ្លូវវិស័យទេសចរណ៍ 2020-2025 និងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តសៀមរាប 2020-2035 កំពុងត្រូវបានរៀបចំឡើង

**ផែនទីចង្អុលផ្លូវឆ្នាំ 2020-2025 ដើម្បីស្តារ និងអភិវឌ្ឍវិស័យទេសចរណ៍ កំពុងស្ថិតក្នុងដំណាក់កាលបញ្ចប់ចុងក្រោយ និងចែកចេញពីបីដំណាក់កាល ជាអាទិ៍ ភាពធន់ និងការចាប់ផ្តើមឡើងវិញ (2020-2021) ការស្តារឡើងវិញ (2021-2022) និងការអភិវឌ្ឍឡើងវិញ (2023-2025)[37]។** ផែនទីចង្អុលផ្លូវឆ្នាំ 2020-2025 ដែលមានគោលដៅស្រូបយកភ្ញៀវទេសចរអន្តរជាតិឱ្យបាន 7 លាននាក់ គាំទ្រដោយឧត្តមភាពប្រៀបធៀបរបស់កម្ពុជាក្នុងវិស័យទេសចរណ៍។ ទោះជាយ៉ាងណា ត្រូវមានធនធានចាំបាច់ដើម្បីអនុវត្តផែនទីចង្អុលផ្លូវនេះឲ្យជោគជ័យ ។ នាពេលអនាគត ការផ្តល់ហិរញ្ញប្បទានដោយវិស័យឯកជនជាពិសេសការវិនិយោគផ្ទាល់ពីបរទេស ទំនងជាមិនអាចទៅរួចនោះទេ ដោយសារការដួលរលំនៃវិស័យទេសចរណ៍ (សូមមើលការពិភាក្សាស្តីពីគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ក្នុងផ្នែកខាងក្រោម)។ ប្រសិនបើវិស័យសាធារណៈមិនបង្កើនការវិនិយោគសាធារណៈ ក្នុងវិស័យទេសចរណ៍ទេនោះ ផែនទីចង្អុលផ្លូវដើម្បីស្តារវិស័យទេសចរណ៍នេះ ប្រាកដជាប្រឈមនឹងការខ្វះខាតធនធាន។

**ពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងខេត្តសៀមរាប ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តសៀមរាប មានគោលបំណងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍខេត្តសៀមរាបឱ្យក្លាយទៅជាគោលដៅទេសចរណ៍អាទិភាព។** ផែនការមេនេះរួមបញ្ចូលយុទ្ធសាស្ត្រវិនិយោគលើវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ដែលគ្របដណ្តប់លើការអភិវឌ្ឍ និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើទីផ្សារ ការការពារបរិស្ថាន និងការអភិវឌ្ឍធនធានមនុស្ស។ ក្រៅពីនេះ មានការបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍នៅតាមតំបន់ទេសចរណ៍សំខាន់ៗ ចំនួន 6 ក្នុងខេត្តសៀមរាប។ នៅខែ កញ្ញា ឆ្នាំ 2020 រដ្ឋាភិបាលកម្ពុជាបានអនុម័តកញ្ចប់ថវិកាចំនួន 150 លានដុល្លារដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន 38 ខ្សែក្នុងខេត្តសៀមរាប សម្រាប់ដាក់ឱ្យប្រើប្រាស់នៅបំណាច់ឆ្នាំ 2021[38]។ គម្រោងវិនិយោគសាធារណៈស្រដៀងគ្នានេះដែរក្រោមទំហំទឹកប្រាក់ 300 លានដុល្លារសម្រាប់កសាងផ្លូវចំនួន 34 ខ្សែដែលមានប្រវែងសរុប 82.5 គីឡូម៉ែត្រ ត្រូវបានអនុម័តនៅឆ្នាំ 2019 ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងខេត្តព្រះសីហនុ។ គម្រោងនេះជិតបញ្ចប់ជាស្ថាពរហើយ[39]។

## ជម្រើសគោលនយោបាយ

**គោលដៅគោលនយោបាយដ៏សំខាន់មួយគឺត្រូវស្តារឡើងវិញជាបន្ទាន់នូវការបាត់បង់ ឬការព្យួរការងារដែលបណ្តាលមកពីជំងឺកូវីដ 19។** ក្នុងគោលបំណងនេះ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកចិត្តទាំងស្រុងលើការជំរុញការវិនិយោគលើវិស័យដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ដើម្បីបង្កើតការងារ ដោយទាញប្រយោជន៍ពីការងើបឡើងវិញយ៉ាងឆាប់រហ័សនៃតម្រូវការទំនិញប្រើប្រាស់ក្នុងប្រទេស ដូចជា អាហារ និងសេវាក្នុងប្រទេស (ការធ្វើដំណើរបដិសណ្ឋារកិច្ច និងការថែទាំសុខភាព)។ ឧទាហរណ៍ ការធានាអត្ថិភាពរបស់ក្រុមហ៊ុន និងអាជីវកម្មដែលអាចបន្តប្រតិបត្តិការក្រោយវិបត្តិកូវីដ 19 នឹងជួយសម្រាលបន្ទុករបស់កម្មករ សម្រួលការស្តារឡើងវិញយ៉ាងឆាប់រហ័ស និងជំរុញកំណើន។ ទន្ទឹមនឹងនេះ ការជំរុញការវិនិយោគសាធារណៈដែលទ្រទ្រង់ប្រជាជនក្រីក្រ និងបង្កើនកំណើន ដូចជា គម្រោងផ្តល់ការងារដោយផ្តល់ប្រាក់កម្រៃ នឹងជួយបង្កើតការងារបន្ថែមទៀត។ កម្មវិធីវិនិយោគសាធារណៈ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងក្រុងព្រះសីហនុ និងក្រុងសៀមរាប នឹងបង្កើនការតភ្ជាប់ និងទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍។ វិធានការទាំងនេះនឹងជួយសម្រួលដល់អាជ្ញាធរកម្ពុជាក្នុងការបង្វែរអន្តរាគមន៍ពីជំនួយសង្គ្រោះបន្ទាន់ទៅរកការគាំទ្រការចិញ្ចឹមជីវិត ដោយផ្តោតសំខាន់លើការរកប្រាក់ចំណូល និងការបង្កើតការងារ។

35 ផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជាដោយសារការព្យួរការអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុប Research Intelligence ខែ មិថុនា ឆ្នាំ 2019។ ក្នុងឧស្សាហកម្មផលិតដែលមានប្រតិបត្តិការកាត់ដេរធម្មតា អ្នកបញ្ជាទិញសម្លៀកបំពាក់ទូទាត់ថ្លៃកាត់ដេរសម្លៀកបំពាក់ដល់ក្រុមហ៊ុនផលិត។ ដំណើរការមុនផលិតកម្ម ដូចជាការដំណើរការការបញ្ជាទិញ ការអភិវឌ្ឍផលិតផល ការបង្កើតគំរូ និងការចាត់កម្រិតគំរូ និងដំណើរការក្រោយផលិតកម្ម ដូចជា ការដឹកជញ្ជូនទំនិញ ជាបន្ទុករបស់អ្នកបញ្ជាទិញ។

36 សេចក្តីប្រកាស ថ្ងៃទី 10 ខែ កញ្ញា ឆ្នាំ 2020 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

37 សេចក្តីថ្លែងការណ៍ ថ្ងៃទី 6 ខែ កញ្ញា ឆ្នាំ 2020 ក្រសួងទេសចរណ៍។

38 សូមមើល លិខិតចុះថ្ងៃទី 4 ខែ កញ្ញា ឆ្នាំ 2020 របស់អភិបាលខេត្តសៀមធ្វើជូននាយករដ្ឋមន្ត្រី។

39 សូមមើលសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី 17 ខែ កក្កដា ឆ្នាំ 2020 ដោយគណៈកម្មាធិការជាតិកម្ពុជាគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**តទៅមុខ ជាការសំខាន់ត្រូវសម្រួលដល់ការពង្រីកការវិនិយោគក្នុងស្រុក និងការវិនិយោគពីបរទេស ដែលមួយផ្នែកធំកើតចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់នាពេលថ្មីៗនេះ។** ក្នុងគោលបំណងនេះ រដ្ឋាភិបាលត្រូវអនុវត្តច្បាប់ស្តីពីការវិនិយោគបែបប្រកួតប្រជែង និងរបបលើកទឹកចិត្ត រួមនឹងការសម្រួលការធ្វើអាជីវកម្ម។ អត្ថប្រយោជន៍ភ្លាមៗពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន អាចរួមមាន ការនាំចេញផលិតផលកសិកម្មក្រៅពីស្រូវ/អង្ករ និងមានតម្លៃខ្ពស់ (វត្ថុធាតុដើម និងវត្ថុធាតុកែច្នៃ) ដូចជា ដំឡូងមី កៅស៊ូ និងសណ្តែកសៀង ព្រោះចិនបានផ្តល់កូតាសម្រាប់ឱ្យកម្ពុជានាំចេញអង្ករ និងស្វាយទៅប្រទេសចិន។ ដូច្នេះ អាចមានការផ្តល់ការគាំទ្រផ្នែកគោលនយោបាយ បច្ចេកទេស និងហិរញ្ញវត្ថុដល់ការពង្រីកផលិតកម្ម និងគុណភាពរបស់ផលិតផលទាំងនេះ។ ក្នុងរយៈពេលមធ្យម ការជំរុញការធ្វើសមាហរណកម្មការកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មផលិតរបស់កម្ពុជាទៅក្នុងសង្វាក់តម្លៃតំបន់ ដោយចាប់ផ្តើមពីសមាហរណកម្មទៅក្នុងសង្វាក់តម្លៃរបស់ប្រទេសចិន វៀតណាម និងថៃ គឺជាវិធានការដ៏សំខាន់។ ដំណើរការនេះអាចអនុវត្តតាម “គំរូសមាហរណកម្មសេដ្ឋកិច្ចតាមបែបក្ងានហោះ”[40]។ សិង្ហបុរី សាធារណរដ្ឋកូរ៉េ ចិន និងជប៉ុន ដែលជាវិនិយោគិនឈានមុខក្នុងប្រទេសវៀតណាម (និងថៃ) ក៏ជាវិនិយោគិនសំខាន់ៗនៅកម្ពុជាផងដែរ។ ដូច្នេះ ការទាក់ទាញឱ្យវិនិយោគិនទាំងនេះធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសង្វាក់ផលិតកម្មថ្នាក់តំបន់ (និងថ្នាក់សកល) តាមរយៈការបង្កើនការតភ្ជាប់ ការអភិវឌ្ឍកម្លាំងពលកម្មជំនាញ និងការកាត់បន្ថយតំលៃអគ្គិសនី គឺជាជំហានដ៏សំខាន់មួយ។ ជារួម ចាំបាច់ត្រូវសម្រួលការធ្វើពាណិជ្ជកម្ម និងការវិនិយោគបន្ថែមទៀត (ធៀបនឹងចំណាត់ថ្នាក់របស់កម្ពុជាលើភាពប្រកួតប្រជែង និងការធ្វើធុរកិច្ចក្នុងពិភពលោក) ក៏ដូចជា លើកកម្ពស់សហគ្រាសធុនតូច និងមធ្យម (ដែលមានចំនួនយ៉ាងច្រើនក្នុងសេដ្ឋកិច្ច និងទីផ្សារការងារនៅកម្ពុជា) តាមរយៈការជ្រៀតចូល និងការពង្រីកអាជីវកម្មនវានុវត្តន៍ និងត្រូវសម្របសម្រួល និងភ្ជាប់ទំនាក់ទំនងអាជីវកម្មទាំងនោះទៅនឹងវិស័យក្នុងការវិនិយោគផ្ទាល់ពីបរទេស។

**ជាការសំខាន់ត្រូវបន្តត្រួតពិនិត្យយ៉ាងហ្មត់ចត់លើភាពងាយរងគ្រោះដែលបណ្តាលមកពីកំណើនរយៈពេលយូរនៃវិស័យសំណង់ និងអចលនទ្រព្យ និងកំណើនឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យ។** នេះជាចំណុចសំខាន់ខ្លាំងណាស់ ប្រសិនបើជំងឺកូវីដ 19 នៅតែមិនទាន់ចប់ ហើយគ្រោះទឹកជំនន់នាពេលថ្មីៗនេះបង្កការបំផ្លិចបំផ្លាញខ្លាំង។ ស្ថានភាពទាំងនេះនឹងប៉ះពាល់ថែមទៀតលើលទ្ធភាពសងបំណុលរបស់អាជីវកម្ម និងគ្រួសារ ដែលបង្កើនសម្ពាធក្នុងវិស័យហិរញ្ញវត្ថុ។ បើទោះជាអាជ្ញាធរកម្ពុជាបានលើកលែងពន្ធផ្ទេរកម្មសិទ្ធិសម្រាប់ទ្រព្យសម្បត្តិដែលមានតម្លៃមិនលើសពី 70,000 ដុល្លារអាមេរិក[41] ដែលជាផ្នែកមួយនៃវិធានការឆ្លើយតបនឹងវិបត្តិកូវីដ 19 ពន្ធលើចំណេញមូលធនចំនួន 20 ភាគរយនឹងចូលជាធរមាននៅឆ្នាំ 2022[42]។ ពន្ធនេះត្រូវអនុវត្តចំពោះចំណេញមូលធន ដែលជាចំណូលជាប់បានមកពីការលក់ ឬផ្ទេរមូលធន (ដកចំណាយមិនជាប់ពន្ធ។ ពន្ធលើចំណេញមូលធននឹងធ្វើឱ្យការទិញ/លក់អចលនទ្រព្យដើម្បីបានប្រាក់ចំណេញ ថយចុះ ព្រោះពន្ធនេះកាត់បន្ថយតម្រូវការនៃការទិញ/លក់ដើម្បីបានប្រាក់ចំណេញយ៉ាងប្រថុយប្រថានដែលជួយរក្សាស្ថិរភាពទីផ្សារអចលនទ្រព្យនៅកម្ពុជា ដែលបានកើនឡើងខ្លាំងនៅពេលមុនមានវិបត្តិកូវីដ 19។ ដោយសារមានលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ដែលផ្តោតលើវិស័យសំណង់ និងអចលនទ្រព្យ តម្រូវការទិញ/លក់ដើម្បីបានប្រាក់ចំណេញ បានកើនឡើងយ៉ាងឆាប់រហ័ស ហើយបានប៉ះពាល់ដល់ទីផ្សារលំនៅដ្ឋាននៅកម្ពុជា។ ក្រៅពីការប្រមូលចំណូលបន្ថែមសម្រាប់រដ្ឋាភិបាល ពន្ធលើចំណេញមូលធននឹងជួយទប់ស្កាត់ការប្រែប្រួលថ្លៃនៃទីផ្សារអចលនទ្រព្យកម្ពុជាក្នុងអំឡុងក្រោយពេលមានកូវីដ19។ សំខាន់ជាងនេះទៀត ពន្ធនេះអាចជួយបង្វែរការវិនិយោគពីការទិញ និងកាន់កាប់អចលនទ្រព្យ ដើម្បីទទួលបានចំណេញមូលធនទៅជាការផ្តល់ហិរញ្ញប្បទានដល់វិស័យដែលមានផលិតភាព និងអាចជួញដូរបាន ដែលជួយដល់ការបង្កើតការងារ និងជំរុញការនាំចេញ។

**ជាការសំខាន់បំផុតនោះគឺត្រូវបង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ចែកចាយវ៉ាក់សាំងជំងឺកូវីដ 19 ក៏ដូចជាកំណត់វ៉ាក់សាំងជំងឺកូវីដ 19 ដែលអាចទិញបាន និងមានតម្លៃសមរម្យ។** នេះគឺជាពេលវេលាដ៏សំខាន់មួយក្នុងការធ្វើឱ្យប្រាកដថា វ៉ាក់សាំងដែលនឹងចែកចាយនាពេលខាងមុខមានវត្តមាននៅកម្ពុជា ហើយនឹងមានការចែកចាយយ៉ាងមានប្រសិទ្ធភាព និងយុត្តិធម៌។ កន្លងមក មានការស្វែងរកការសហការជាមួយប្រទេសផ្សេងៗក្នុងតំបន់ដែលកំពុងបង្កើតវ៉ាក់សាំងជំងឺកូវីដ 19 ដូចជា ប្រទេសចិន ដើម្បីធានាថា កម្ពុជាមានលទ្ធភាពទទួលបានវ៉ាក់សាំងនេះក្រោយពេលផលិតរួច។

---

40 ការបែងចែកកម្លាំងពលកម្មក្នុងតំបន់ប៉ាស៊ីហ្វិក ត្រូវបានចាត់ទុកជា “គំរូអភិវឌ្ឍន៍តាមបែបក្ងានហោះ”។

41 លិខិតលេខ 1313 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2020។

42 ប្រកាសលេខ 346 ចុះហត្ថលេខានៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2020 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ យោងតាមលិខិតរបស់អគ្គនាយកដ្ឋានពន្ធដារ ចុះថ្ងៃទី 22 ខែ តុលា ឆ្នាំ 2020 ការអនុវត្តពន្ធលើចំណេញមូលធន ត្រូវបានពន្យារពេលរហូតដល់ឆ្នាំ 2022។


SIEM REAP INTERNATIONAL A




អត្ថបទផ្តោតពិសេស

# ការសម្របទៅនឹងវិបត្តិជំងឺកូវីដ 19 នៅក្នុងពិភព មិនប្រាកដប្រជា

# អត្ថបទផ្ដោតពិសេស ៖ ការសម្របទៅនឹងវិបត្តិជំងឺកូវីដ 19 នៅក្នុងពិភព មិនប្រាកដប្រជា[43]

## 1. សេចក្ដីផ្ដើម

**ជំងឺកូវីដ 19 អាចធ្វើឱ្យមានការធ្លាក់ចុះខ្លាំងបំផុតនៃសេដ្ឋកិច្ចសកល ចាប់តាំងពីពេលមានវិបត្តិសេដ្ឋកិច្ចសកលធំបំផុតមក[44]។** ជំងឺកូវីដ 19 និងការខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺនេះ បានធ្វើឱ្យមានការបន្ថយសកម្មភាពសេដ្ឋកិច្ចនៅជុំវិញពិភពលោក។ ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន កំពុងមានការឆ្លងរាលដាលជំងឺកូវីដ 19 និងរងគ្រោះដោយសារផលប៉ះពាល់អន្តរជាតិតាមរយៈពាណិជ្ជកម្ម និងការវិនិយោគ។ នៅកម្ពុជា ជារួម អាជ្ញាធរអាចគ្រប់គ្រងការឆ្លងជំងឺកូវីដ 19 បាន ដែលធ្វើឲ្យមានការបិទអាជីវកម្មក្នុងរយៈពេលខ្លី ក្នុងវិស័យមួយចំនួនតូចដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ 19 នេះ ក្រោយមក មានចល័តភាពកាន់តែច្រើននៅខែ កក្កដា និងមានការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ចទៅជាប្រក្រតីឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែមានភាពទន់ខ្សោយនៅឡើយ ដោយសារតែវិបត្តិតម្រូវការជាសកលបានក្លាយជាបញ្ហាសំខាន់ ជាមួយនឹងកំណើនភាពមិនប្រាកដប្រជានោះ។

**កម្ពុជាទទួលរងផលប៉ះពាល់យ៉ាងច្រើនដោយសារជំងឺកូវីដ 19 ហើយតាមការវាយតម្លៃ នឹងមានផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចយ៉ាងខ្លាំង។** ផលប៉ះពាល់នៃជំងឺកូវីដ 19 លើសេដ្ឋកិច្ចផ្នែកផលិតរួមមាន ការបង្អាក់ការផ្គត់ផ្គង់កម្លាំងពលកម្ម តម្រូវការអ្នកប្រើប្រាស់ ពាណិជ្ជកម្មសកលតាមរយៈសង្វាក់ផ្គត់ផ្គង់សកល និងសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ការធ្វើដំណើរ និងទេសចរណ៍ ក៏ដូចជា ការរាំងស្ទះលទ្ធភាពទទួលបានមូលធន និងហិរញ្ញវត្ថុដែលបណ្ដាលមកពីការថយចុះនៃទំនុកចិត្តរបស់វិនិយោគិន។ ក្បាលម៉ាស៊ីនជំរុញកំណើនសំខាន់ៗរបស់កម្ពុជា ដែលជា ការនាំចេញទំនិញ វិស័យទេសចរណ៍ និងវិស័យសំណង់ ទទួលរងការប៉ះទង្គិចខ្លាំងជាងគេ។ ជំងឺកូវីដ 19 បានធ្វើឱ្យវិស័យសំណង់ និងអចលនទ្រព្យចុះថយ ព្រោះថាវិស័យទាំងនេះពឹងផ្អែកយ៉ាងខ្លាំងលើការវិនិយោគពីបរទេស។ ការរឹតត្បិតលើការធ្វើដំណើរ និងការហាមឃាត់ការចេញចូល ធ្វើឱ្យវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចអន្តរជាតិរបស់កម្ពុជាដួលរលំ។ វិបត្តិផ្គត់ផ្គង់ និងវិបត្តិតម្រូវការសកល ធ្វើឱ្យការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ដែលជាវិស័យនាំចេញទំនិញដ៏សំខាន់របស់កម្ពុជា ថយចុះ។ វិស័យទេសចរណ៍ សម្លៀកបំពាក់ និងស្បែកជើង និងវិស័យសំណង់រួមចំណែកជាង 1/3 ដល់ការងារទទួលបានប្រាក់ឈ្នួលសរុបនៅកម្ពុជា[45]។

**រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការគោលនយោបាយជាច្រើន ដើម្បីឆ្លើយតបទៅនឹងវិបត្តិជំងឺកូវីដ 19។** ដើម្បីជួយពិនិត្យតាមដានផលប៉ះពាល់នៃជំងឺកូវីដ 19 និងផ្ដល់មូលដ្ឋានដល់ការឆ្លើយតបផ្នែកគោលនយោបាយ ធនាគារពិភពលោកបានរៀបចំ និងអនុវត្តការអង្កេតលើដំណើរការអាជីវកម្មរបស់ក្រុមហ៊ុននៅកម្ពុជា (សូមមើលប្រអប់ S1)។ ផ្អែកលើរបកគំហើញពីការអង្កេតនេះដែលបានធ្វើឡើងចាប់ពីខែ មិថុនា រហូតដល់ខែ កញ្ញា អត្ថបទផ្ដោតពិសេសនេះពិនិត្យទៅលើផលប៉ះពាល់នៃជំងឺកូវីដ 19 លើក្រុមហ៊ុននៅកម្ពុជា ធៀបនឹងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងផ្ដល់អនុសាសន៍គោលនយោបាយ ដើម្បីជួយឱ្យក្រុមហ៊ុនរួចផុត និងងើបឡើងវិញពីវិបត្តិនេះ។ បើទោះជារបកគំហើញនៃការអង្កេតបង្ហាញពីសញ្ញានៃភាពប្រសើរឡើងពាក់ព័ន្ធនឹងការបិទអាជីវកម្ម និងការលក់របស់ក្រុមហ៊ុន ប៉ុន្តែជំងឺកូវីដ 19 នៅតែបង្កផលប៉ះពាល់យ៉ាងច្រើនលើវិស័យជាច្រើន។ ក្រុមហ៊ុននៅតែជួបការលំបាកយ៉ាងខ្លាំងច្រើនមុខ និងត្រូវឆ្លងរយៈពេលវែងរហូតដល់ពេលមានការងើបឡើងវិញ។

## 2. ក្រុមហ៊ុនកំពុងចាប់ផ្ដើមបើកទ្វារឡើងវិញ ប៉ុន្តែការលក់នៅតែរងការប៉ះពាល់

**ជំងឺកូវីដ 19 បានជំរុញឱ្យរដ្ឋាភិបាលនៅជុំវិញពិភពលោកចាត់វិធានការកាត់បន្ថយការឆ្លងរាលដាលជំងឺនេះ។** ការហាមឃាត់ការចេញចូល តម្រូវឱ្យអាជីវកម្មដែលមិនចាំបាច់ បិទទ្វារ ឬកាត់បន្ថយប្រតិបត្តិការដែលមានទំនាក់ទំនងរវាងមនុស្សផ្ទាល់ ប៉ុន្តែ ទោះបីជាគ្មានការតម្រូវឱ្យបិទទ្វារក៏ដោយ ក៏ប្រាក់ចំណូល និងប្រតិបត្តិការរបស់អាជីវកម្ម បានជួបប្រទះបញ្ហាយ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិកម្លាំងពលកម្មច្រើន និងវិបត្តិតម្រូវការអ្នកប្រើប្រាស់។ ដូចបណ្ដាប្រទេសផ្សេងទៀតក្នុងតំបន់ដែរ កម្ពុជាបានបញ្ជាឱ្យបិទអាជីវកម្មជាច្រើនដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺកូវីដ 19 ដូចជា ក្លឹបហាត់ប្រាណ កន្លែងស្ប៉ាសុខភាព រោងភាពយន្ត កាស៊ីណូ ខារ៉ាអូខេ និងក្លឹបកំសាន្តនៅដើមខែ មេសា។ ដោយសារមិនសូវមានករណីផ្ទុះជំងឺកូវីដ 19 ក្នុងសហគមន៍ ការរឹតត្បិតជាច្រើនត្រូវបានដកចេញវិញនៅខែ កក្កដា និង សីហា ប៉ុន្តែតម្រូវឱ្យមានការចាត់វិធានការប្រុងប្រយ័ត្ននៅនឹងកន្លែង។

---

43 អត្ថបទផ្ដោតពិសេសនេះត្រូវបានរៀបចំឡើងដោយ Sarah Hebous, Claire H. Hollweg, Philippe de Meneval និង Trang Thu Tran ដោយទទួលបានមតិយោបល់ដ៏សំខាន់ពី Wendy Cunningham និង Maheshwor Shrestha។ អ្នកនិពន្ធសូមអរគុណ Deepak Mishra ដែលបានផ្ដល់យោបល់ល្អៗ។

44 ធនាគារពិភពលោក (2020b)។

45 ធនាគារពិភពលោក (2020a)។

ប្រអប់ ទ1៖

## ការអង្កេតលើដំណើរការអាជីវកម្មរបស់ធនាគារពិភពលោក សម្រាប់ប្រទេសកម្ពុជា និងសកលលោក

ធនាគារពិភពលោកបានធ្វើការអង្កេតក្រុមហ៊ុនដើម្បីស្វែងយល់ពីផលប៉ះពាល់នៃជំងឺកូវីដ 19 លើអាជីវកម្មក្នុងបណ្ដាប្រទេសនៅជុំវិញពិភពលោក។ កម្រងសំណួរក្នុងការអង្កេតមានសំណួរស្ដីពីស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ប្រភពផ្ដល់ផលប៉ះពាល់លើប្រតិបត្តិការ លទ្ធភាពទទួលបានហិរញ្ញវត្ថុ លទ្ធភាពទទួលបានការគាំទ្រផ្នែកគោលនយោបាយ និងយន្តការកែសម្រួលរបស់ក្រុមហ៊ុន។

ការអង្កេតដំណើរការអាជីវកម្មត្រូវបានធ្វើឡើងក្នុងប្រទេសជាង 40 នៅជុំវិញពិភពលោក ដោយមានការបន្តប្រមូលទិន្នន័យដើម្បីពិនិត្យមើលការការវិវឌ្ឍ។ ក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ការអង្កេតត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា ម៉ាឡេស៊ី ហ្វីលីពីន និងវៀតណាម។ ការអង្កេតនេះមានទម្រង់ជាការសម្ភាសន៍ខ្លីតាមទូរស័ព្ទ រួមទាំងនៅប្រទេសកម្ពុជាដែរ។

នៅកម្ពុជា ការប្រមូលទិន្នន័យពីការសម្ភាសន៍លើកទីមួយត្រូវបានធ្វើឡើងនៅចន្លោះថ្ងៃទី 18 ខែ មិថុនា និងថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2020 ចំណែកការប្រមូលទិន្នន័យពីការសម្ភាសន៍លើកទីពីរ ត្រូវបានធ្វើឡើងនៅចន្លោះថ្ងៃទី 3 ខែ កញ្ញា និងថ្ងៃទី 29 ខែ កញ្ញា ឆ្នាំ 2020។ ការសម្ភាសន៍បន្ថែមទៀតសម្រាប់ការអង្កេតបន្ត គ្រោងនឹងធ្វើឡើងនៅរយៈពេល 6 ខែទៀត។ ក្នុងអត្ថបទនេះ លទ្ធផលពីការសម្ភាសន៍លើកទីមួយត្រូវបានហៅថា លទ្ធផលខែ មិថុនា ចំណែកលទ្ធផលពីការសម្ភាសន៍លើកទីពីរត្រូវបានហៅថាលទ្ធផលខែ កញ្ញា។

សំណាកក្រុមហ៊ុនដែលត្រូវបានសម្ភាសន៍ រួមមាន ក្រុមហ៊ុនចំនួន 537 នៅខែ មិថុនា និង 518 ក្រុមហ៊ុន នៅខែ កញ្ញា និងបណ្ដុំក្រុមហ៊ុនចំនួន 419 ទៀត ដែលមានក្រុមហ៊ុនគ្រប់កម្រិត[1] ក្នុងវិស័យឧស្សាហកម្មផលិត ឬសេវា[2] និងស្ថិតនៅខេត្ត/ក្រុង 5 ក្នុងប្រទេសកម្ពុជា (បាត់ដំបង កំពង់ចាម កណ្ដាល ក្រុងភ្នំពេញ និងខេត្តសៀមរាប)។ ការអង្កេតនេះមិនអាចកំណត់មូលហេតុនៃការបាត់បង់នៅចន្លោះការសម្ភាសន៍កាលពីខែ មិថុនា និងខែ កញ្ញា បានឡើយ (ឧទាហរណ៍ ក្រុមហ៊ុនបានបិទទ្វារជាអចិន្ត្រៃយ៍ ឬមិនអាចទាក់ទងបានដោយសារមូលហេតុផ្សេងៗទៀត)។ ក្រុមហ៊ុនភាគច្រើនលើសលប់ក្នុងសំណាកនៃការអង្កេត (94 ភាគរយ) បានចុះបញ្ជីជាមួយអាជ្ញាធររដ្ឋាភិបាលមានសមត្ថកិច្ចយ៉ាងតិចមួយស្ថាប័ន[3]។ ក្នុងនោះ ក្រុមហ៊ុនខ្នាតមីក្រូចំនួន 90 ភាគរយបានចុះបញ្ជីជាមួយអាជ្ញាធរមួយចំនួន។ ក្រុមហ៊ុនចំនួន 28 ភាគរយក្នុងការអង្កេតនេះ ស្ថិតក្រោមការកាន់កាប់របស់ស្ត្រី។




1 ការបែងចែកប្រភេទក្រុមហ៊ុននៅកម្ពុជា ៖ ក្រុមហ៊ុនដែលមាននិយោជិតតិចជាង 10 នាក់ ត្រូវបានចាត់ចូលជាក្រុមហ៊ុនខ្នាតមីក្រូ។ ក្រុមហ៊ុនដែលមាននិយោជិតពី 10 ទៅ 50 នាក់ត្រូវបានចាត់ចូលជាក្រុមហ៊ុនខ្នាតតូច។ ក្រុមហ៊ុនដែលមាននិយោជិតពី 51 ទៅ 100 នាក់ត្រូវបានចាត់ចូលជាក្រុមហ៊ុនខ្នាតមធ្យម ហើយក្រុមហ៊ុនដែលមាននិយោជិតចាប់ពី 100 នាក់ឡើងទៅ ត្រូវបានចាត់ចូលជាក្រុមហ៊ុនខ្នាតធំ។ ការអង្កេតផ្ទៀងផ្ទាត់ត្រូវបានធ្វើឡើងចំពោះអាជីវកម្មខ្នាតតូចបំផុត ដែលមាននិយោជិតមិនលើស 3 នាក់ និងអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី ធៀបនឹងអាជីវកម្មដែលគ្រប់គ្រងដោយបុរស ហើយលទ្ធផលបង្ហាញថាមានភាពដូចគ្នា។

2 វិស័យរួមមាន កសិឧស្សាហកម្ម/ការកែច្នៃអាហារ វាយនភណ្ឌ សម្លៀកបំពាក់ ក្រណាត់ ផលិតផលអេឡិចត្រូនិក ឧស្សាហកម្មផលិតផ្សេងទៀត សំណង់ ឬទឹក/ភ្លើង ការលក់រាយ ឬលក់ដុំ ការដឹកជញ្ជូន និងស្តុកទុក សេវាស្នាក់នៅ ឬម្ហូបអាហារ ព័ត៌មាន និងទំនាក់ទំនង សកម្មភាពហិរញ្ញវត្ថុ ឬអចលនទ្រព្យ ការអប់រំ សុខភាព និងសេវាផ្សេងទៀត។ ការអង្កេតនេះមិនតំណាងឱ្យកម្រិតវិស័យឡើយ។

3 កម្រងសំណួរសួរថាតើក្រុមហ៊ុនបានចុះបញ្ជីផ្លូវការជាមួយអាជ្ញាធររដ្ឋាភិបាលណាមួយ ឬទេ ៖ ការចុះបញ្ជីអាជីវកម្មថ្នាក់ជាតិ អាជ្ញាប័ណ្ណតាមវិស័យ ការចុះបញ្ជីក្នុងមូលដ្ឋាន ការចុះបញ្ជីពន្ធដារ ការចុះបញ្ជីជាមួយរបបសន្តិសុខសង្គម។ល។

**ស្របនឹងការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក របកគំហើញនៃការអង្កេតដំណើរការអាជីវកម្មនេះបង្ហាញថា ក្រុមហ៊ុនបានបន្តបើកទ្វារឡើងវិញតាំងពីខែ មិថុនា។** ចំនួនក្រុមហ៊ុនដែលបើកទ្វារឡើងវិញ កើនពី 81 ភាគរយនៅខែ មិថុនា ដល់ចំនួន 89 ភាគរយនៅខែ កញ្ញា (រូប S1, ផ្នែក a)។ នៅខែ កញ្ញា ក្រុមហ៊ុន 8 ភាគរយបន្តបិទទ្វារជាបណ្តោះអាសន្ន ដោយសារជំងឺកូវីដ 19 ថយពី 16 ភាគរយនៅខែ មិថុនា។ ការសម្រេចបិទទ្វារបន្តទៀតគឺជាឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុន ព្រោះបច្ចុប្បន្ន គ្មានលក្ខខណ្ឌតម្រូវដែលរឹតត្បិតការបិទអាជីវកម្មឡើយ[46]។ ទន្ទឹមនឹងនេះ ចំនួនក្រុមហ៊ុនដែលបិទទ្វារជារៀងរហូតដោយសារជំងឺកូវីដ 19 មានចំនួន 2 ភាគរយដដែល[47]។

**វឌ្ឍនភាពនៃការបើកអាជីវកម្មឡើងវិញ មិនមានលក្ខណៈដូចគ្នាក្នុងវិស័យនានាទេ។** ទោះជាអាជីវកម្មជាង 90 ភាគរយបានបើកទ្វារក្នុងវិស័យមួយចំនួន ដូចជា ឧស្សាហកម្មផលិត សំណង់ ទឹក/ភ្លើង ពាណិជ្ជកម្មលក់ដុំ និងលក់រាយ សកម្មភាពហិរញ្ញវត្ថុ និងសុខភាព នៅខែ មិថុនាក្តី អាជីវកម្មក្នុងវិស័យផ្សេងទៀត មិនសូវមានលទ្ធភាពធ្វើប្រតិបត្តិការឡើយ។ ឧទាហរណ៍ នៅខែ មិថុនា មានក្រុមហ៊ុនចំនួន 55 ភាគរយក្នុងវិស័យសេវាស្នាក់នៅ និងម្ហូបអាហារ និងក្រុមហ៊ុនចំនួន 60 ភាគរយក្នុងវិស័យដឹកជញ្ជូន និងស្តុកទុក បានបើកអាជីវកម្ម ខណៈដែលនៅខែ កញ្ញា មានក្រុមហ៊ុនចំនួន 80 ភាគរយក្នុងវិស័យសេវាស្នាក់នៅ និងម្ហូបអាហារ និងក្រុមហ៊ុនចំនួន 83 ភាគរយក្នុងវិស័យដឹកជញ្ជូន និងស្តុកទុក បានបើកអាជីវកម្ម។ នេះជាចំនួនច្រើន ប៉ុន្តែស្ថិតនៅក្រោមមធ្យមភាគនៅឡើយទេ[48]។ វិស័យអប់រំមានចំនួនគ្រឹះស្ថានដែលបើកទ្វារឡើងវិញតិចជាងគេ ដោយមានចំនួន 64 ភាគរយនៅខែ កញ្ញាប៉ុណ្ណោះ។

**ប្រាក់ចំណូលបានកើនឡើង ប៉ុន្តែនៅតែរងការប៉ះពាល់ខ្លាំងដោយសារវិបត្តិជំងឺកូវីដ 19។** ទោះបីជាអាជីវកម្មភាគច្រើនបានបើកទ្វារ ប៉ុន្តែ អាជីវកម្មភាគច្រើននៅតែមានការលក់ដែលទទួលរងការប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំង។ ចំនួនក្រុមហ៊ុនដែលលើកឡើងពីការថយចុះការលក់ក្នុងរយៈពេល 30 ថ្ងៃកន្លងមក ថយពី 87 ភាគរយនៅខែ មិថុនា មកត្រឹម 71 ភាគរយនៅខែ កញ្ញា (រូប S1, ផ្នែក b)។ នៅខែ មិថុនា ក្រុមហ៊ុនបានរាយការណ៍ថា ការលក់ថយចុះ 49 ភាគរយ។ នៅខែ កញ្ញា ការប្រែប្រួលលើការលក់ជាមធ្យមមានភាពធូរស្រាល ប៉ុន្តែនៅតែមានអត្រាអវិជ្ជមាន -30 ភាគរយ។

**ដោយមានការបើកអាជីវកម្មឡើងវិញថែមទៀត អត្រានៃការស្តារការលក់នៅកម្ពុជាមានភាពល្អប្រសើរជាងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីបូព៌ា និងអាចមានភាពប្រសើរឡើងលឿនជាងនេះ ប្រសិនបើអាជ្ញាធរកម្ពុជានៅតែអាចគ្រប់គ្រងជំងឺកូវីដ 19 បាន ដោយគ្មានការហាមឃាត់ការចេញចូលបន្ថែមទៀត។** នៅកម្ពុជា អាជីវកម្មចំនួន 8 ភាគរយបន្ថែមទៀតបាន បានបើកទ្វារនៅអំឡុងខែ មិថុនា-កញ្ញា ខណៈដែលនៅប្រទេសមីយ៉ាន់ម៉ា អាជីវកម្មចំនួន 9 ភាគរយបន្ថែមទៀត បានបើកទ្វារនៅអំឡុងខែ ឧសភា-សីហា (រូប S2)។ គួរកត់សម្គាល់ថា បើទោះជាប្រាក់ចំណូលដំបូងនៅខែ មិថុនា មានកម្រិតខ្ពស់ជាងមុន ហើយចំនួនអាជីវកម្មដែលបិទទ្វារនៅខែ កញ្ញា នៅតែមានអត្រាខ្ពស់ខ្លាំងជាងចំនួនអាជីវកម្មដែលបិទទ្វារនៅប្រទេសវៀតណាម ប្រាក់ចំណូលរបស់ក្រុមហ៊ុននៅកម្ពុជាក្នុងខែ កញ្ញា មានភាពប្រសើរឡើងយ៉ាងឆាប់រហ័ស។ នៅខែ កញ្ញា ការលក់ថយចុះជាមធ្យមចំនួន 30 ភាគរយសម្រាប់ក្រុមហ៊ុននៅកម្ពុជា

**រូប S1៖ ទោះបីជាមានភាពប្រសើរឡើងនៃការបើកអាជីវកម្មឡើងវិញក្តី ក៏ការលក់នៅតែទទួលរងការប៉ះពាល់យ៉ាងខ្លាំង**

*a. ស្ថានភាពប្រតិបត្តិការនៅខែ មិថុនា និងខែ កញ្ញា*




*b. ផលប៉ះពាល់លើការលក់នៅខែ មិថុនា និង កញ្ញា*




*សម្គាល់ ៖ អាជីវកម្មត្រូវបានស្នើឱ្យបញ្ជាក់ពីដំណើរការលក់របស់ខ្លួនក្នុងរយៈពេល 30 ថ្ងៃមុនការសម្ភាសន៍*

46 ខារ៉ាអូខេត្រូវបានអនុញ្ញាតឱ្យបើកទ្វារឡើងវិញដោយប្រែក្លាយទៅជាភោជនីយដ្ឋាន។ សូមមើល ៖https://www.thestar.com.my /aseanplus/aseanplus-news/2020/07/07/phnom-penh-karaoke-bars-to-reopen-ascambodia-controls-covid-19។

47 ចំនួនអាចច្រើនជាងនេះ ព្រោះថា ការអង្កេតនេះមិនអាចកំណត់កម្លាំងមូលហេតុនៃការបាត់បង់នៅចន្លោះការសម្ភាសន៍កាលពីខែ មិថុនា និងខែ កញ្ញា បានឡើយ (ឧ. ក្រុមហ៊ុនអាចបិទទ្វារជារៀងរហូត ឬមិនអាចទាក់ទងបានដោយសារមូលហេតុផ្សេងទៀត)។

48 សម្រាប់ជាជម្រើសនៃការបែងចែកប្រភេទអាជីវកម្មទៅក្នុងវិស័យ 13 គេអាចប្រើប្រាស់ព័ត៌មានស្តីពីផលិតផល ឬសេវាសំខាន់ៗ ដើម្បីបែងចែកប្រភេទអាជីវកម្ម។ ឧស្សាហកម្មទេសចរណ៍អាចពាក់ព័ន្ធនឹងផលិតផល និងសេវាចំនួន 12 (ការលក់វត្ថុអនុស្សាវរីយ៍ ការកំសាន្ត សេវាទេសចរណ៍ តាក់ស៊ី សេវាភេសជ្ជៈ ម៉ាស្សា ការដឹកជញ្ជូន សេវាស្នាក់នៅ សេវាម្ហូបអាហារ ការលក់សំបុត្រ ទីតាំងរៀបអាពាហ៍ពិពាហ៍)។ ចំនួនក្រុមហ៊ុនដែលបើកទ្វារក្នុងឧស្សាហកម្មនេះមានចំនួន 51 ភាគរយនៅខែ មិថុនា និង 74 ភាគរយនៅខែ កញ្ញា។

ហើយក្រុមហ៊ុននៅប្រទេសវៀតណាម ថយចុះ 36 ភាគរយ។ នេះអាចបណ្តាលមកពីសំណាកក្រុមហ៊ុនក្នុងប្រទេសវៀតណាម ពឹងផ្អែកខ្លាំងជាងទៅលើតម្រូវការខាងក្រៅ ដែលមិនអាចមានភាពប្រសើរឡើងដោយសារតែការបើកអាជីវកម្មក្នុងប្រទេសតែមួយមុខនោះ។

**ក្រុមហ៊ុនក្នុងប្រទេសកម្ពុជារំពឹងថា ផលប៉ះពាល់នៃជំងឺកូវីដ 19 នឹងបន្តថយចុះក្នុងរយៈពេល 6 ខែខាងមុខ។** យោងតាមលទ្ធផលនៅខែ កញ្ញា ការរំពឹងទុករបស់ក្រុមហ៊ុនចំពោះការលក់នាពេលអនាគតគឺជាមធ្យមតិចជាងមុន -10 ភាគរយ ទោះបីជាអ្នកឆ្លើយតបជាច្រើនរំពឹងថា ការលក់នឹងស្ទើរតែគ្មានការប្រែប្រួល (រូប S3)។ បើធៀបនឹងខែ មិថុនា ក្រុមហ៊ុនរំពឹងថា ការលក់នឹងថយចុះជាមធ្យម -28 ភាគរយក្នុងរយៈពេល 6 ខែខាងមុខ។ តាមពិត ការរំពឹងទុករបស់ក្រុមហ៊ុនចំពោះការប្រែប្រួលការលក់នាពេលអនាគតនៅខែ មិថុនា ស្ទើរតែប្រហាក់ប្រហែលគ្នានឹងការថយចុះការលក់ជាមធ្យមចំនួន -30 ភាគរយនៅខែ កញ្ញា។

**ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម នៅកម្ពុជា និងទូទាំងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ទទួលផលប៉ះពាល់កាន់តែខ្លាំងដោយសារជំងឺ រាតត្បាតកូវីដ 19។** ជំងឺកូវីដ 19 បង្កផលប៉ះពាល់លើការលក់របស់ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម ខ្លាំងជាងការលក់របស់ក្រុមហ៊ុនខ្នាតធំ (រូប S4)។ នៅខែ មិថុនា ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមរាយការណ៍ថា ការលក់ថយចុះចំនួន 47-56 ភាគរយ ចំណែកក្រុមហ៊ុនខ្នាតធំរាយការណ៍ថា ការលក់ថយចុះចំនួន 35 ភាគរយ។ នៅអំឡុងខែ កញ្ញា ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមរាយការណ៍ថា ការលក់ថយចុះចំនួន 30-37 ភាគរយ ចំណែកក្រុមហ៊ុនខ្នាតធំរាយការណ៍ថា ការលក់ថយចុះក្រោម 15 ភាគរយ។ របកគំហើញនេះមានភាពស៊ីសង្វាក់គ្នានៅទូទាំងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលការលក់ប្រចាំខែរបស់ក្រុមហ៊ុនខ្នាតតូច និងមធ្យមថយចុះចំនួន 24 ភាគរយក្នុងប្រទេសឥណ្ឌូណេស៊ី, 9 ភាគរយក្នុងប្រទេសហ្វីលីពីន និង 7 ភាគរយក្នុងប្រទេសមីយ៉ាន់ម៉ា[49]។ នេះអាចបណ្តាលមកពីមានយន្តការដោះស្រាយសម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម តិចជាងយន្តការដោះស្រាយសម្រាប់ក្រុមហ៊ុនខ្នាតធំ (ពិភាក្សាក្នុងផ្នែកខាងក្រោម)។

**រូប S2៖ ស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុនមានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយការកើនការលក់ឡើងវិញនៅកម្ពុជាមានល្បឿនលឿនជាងនៅតំបន់អាស៊ីបូព៌ា**

*a. ស្ថានភាពប្រតិបត្តិការ*




*b. ផលប៉ះពាល់លើការលក់*




*សម្គាល់ ៖ ការអង្កេតនេះត្រូវបានធ្វើឡើងនៅខែ មិថុនា សម្រាប់ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី វៀតណាម និងធ្វើឡើងនៅខែ កក្កដា សម្រាប់ប្រទេសហ្វីលីពីន។ ការលក់ប្រចាំខែសំដៅលើការលក់របស់ក្រុមហ៊ុនក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ មុនការអង្កេត (កម្ពុជា ឥណ្ឌូណេស៊ី និងវៀតណាម)។ សម្រាប់ប្រទេសហ្វីលីពីន ការប្រែប្រួលការលក់គឺនៅចន្លោះខែ កក្កដា-មេសា ដោយមានការបង្កើនការធ្វើចត្តាឡីស័កក្នុងសហគមន៍។*

**រូប S3៖ ការរំពឹងទុកពីភាពប្រសើរឡើងក្នុងរយៈពេល 6 ខែបន្ទាប់ ប៉ុន្តែការលក់ជាមធ្យមនៅតែថយចុះ (អវិជ្ជមាន)**




*សម្គាល់ ៖ អាជីវកម្មត្រូវបានស្នើឱ្យបញ្ជាក់ពីការរំពឹងទុកលើការលក់របស់ខ្លួនក្នុងរយៈពេល 6 ខែបន្ទាប់។ អត្រាឆ្លើយតបសម្រាប់សំណួរនេះ គឺ 56 ភាគរយនៅខែ មិថុនា និង 63 ភាគរយនៅខែ កញ្ញា។*

**រូប S4៖ ផលប៉ះពាល់ខ្លាំងលើការលក់របស់ក្រុមហ៊ុនខ្នាតមីក្រូ តូច មធ្យម និងធំ**




49 ធនាគារពិភពលោក (2020)។

**ទោះជាជំងឺកូវីដ 19 បង្កផលប៉ះពាល់យ៉ាងខ្លាំងលើការលក់របស់ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមនៅកម្ពុជា គួរកត់សម្គាល់ថា ក្រុមហ៊ុនគ្រប់ទំហំ និងគ្រប់វិស័យសុទ្ធតែមានភាពប្រសើរឡើង។** ខុសពីកម្ពុជា ការងើបឡើងវិញនៃការលក់នៅវៀតណាម ភាគច្រើនមាននៅក្រុមហ៊ុនធំៗក្នុងវិស័យលក់ដុំ និងលក់រាយ។ លទ្ធផលនៃការអង្កេតនៅចន្លោះខែ មិថុនា និងខែ កញ្ញា នៅកម្ពុជាបង្ហាញថា ក្រុមហ៊ុនធំៗងើបឡើងវិញលឿនជាងក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម។ ក្នុងអំឡុងពេលនេះ ការលក់របស់ក្រុមហ៊ុនខ្នាតធំកើនចំនួន 45 ភាគរយ ចំណែកការលក់របស់ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម កើនចំនួន 40 ភាគរយ (រូប S5, ផ្នែក a)។ កំណើននេះមាននិន្នាការខុសពីកំណើនក្នុងប្រទេសវៀតណាម ដែលនៅចន្លោះខែ កញ្ញា និងខែ តុលា ការលក់របស់ក្រុមហ៊ុនខ្នាតតូចកើនតិចតួចធៀបនឹងខែ មិថុនា (កើន 11 ភាគរយ) ប៉ុន្តែការលក់របស់ក្រុមហ៊ុនខ្នាតធំកើនឡើងខ្លាំង (កើន 41 ភាគរយ) (រូប S5, ផ្នែក b)។ ប្រហាក់ប្រហែលគ្នានេះ ជាមធ្យមនៅវៀតណាម មានតែសកម្មភាពលក់ដុំ និងលក់រាយប៉ុណ្ណោះដែលកើនឡើង (រូប S5, ផ្នែក d) ខណៈដែលការបាត់បង់ប្រាក់ចំណូលសម្រាប់ក្រុមហ៊ុនក្នុងវិស័យធំៗ 4 នៅកម្ពុជា កើនឡើងចន្លោះពី 15 ភាគរយ ទៅ 23 ភាគរយ (រូប S5, ផ្នែក c)។

**ជំងឺកូវីដ 19 កំពុងបង្កផលប៉ះពាល់ខុសៗពីគ្នានៅទូទាំងប្រទេសកម្ពុជា។** ក្រុមហ៊ុនក្នុងខេត្តសៀមរាបទទួលរងផលប៉ះពាល់ខ្លាំងជាងបណ្តាខេត្តផ្សេងទៀត ហើយការងើបឡើងវិញក៏យឺតជាបណ្តាខេត្តផ្សេងទៀតដែរ។ នៅខែ មិថុនា អាជីវកម្មក្នុងខេត្តសៀមរាបចំនួន 57 ភាគរយ បានបើកទ្វារឡើងវិញ ខណៈដែលនៅក្រុងភ្នំពេញ អាជីវកម្មចំនួន 88 ភាគរយបានបើកទ្វារឡើងវិញ ប៉ុន្តែសម្រាប់តំបន់ទាំងមូល អាជីវកម្មភាគច្រើនបើកទ្វារឡើងវិញនៅខែ កញ្ញា (អាជីវកម្មចំនួន 80 ភាគរយរាយការណ៍ពីការបើកទ្វារឡើងវិញ)។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់លើការលក់នៅតែមានទំហំធំ។ បើពិនិត្យតាមតំបន់ ការថយចុះការលក់ជាមធ្យមនៅខែ កញ្ញា ខ្ពស់ជាងគេនៅខេត្តសៀមរាប (ជាង 40 ភាគរយ) ខណៈដែលការថយចុះការលក់ជាមធ្យមក្នុងតំបន់ផ្សេងទៀតមានចំនួន 20-30 ភាគរយ (រូប S6)។ ការលក់ក្នុងខេត្តសៀមរាប (28 ភាគរយ) កើនយឺតជាងការលក់ក្នុងទីក្រុងភ្នំពេញ (41 ភាគរយ)។ នេះបណ្តាលមកពីភាពធ្ងន់ធ្ងរនៃវិបត្តិតម្រូវការសកលក្នុងវិស័យទេសចរណ៍ ក្នុងនោះចំនួនភ្ញៀវទេសចរអន្តរជាតិដែលមក ទស្សនាប្រទេសកម្ពុជាថយចុះ 71.9 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេល 8 ខែដំបូងក្នុងឆ្នាំ 2020 ហើយខេត្តសៀមរាបដែលមានប្រាង្គប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ពឹងផ្អែកខ្លាំងលើវិស័យទេសចរណ៍។

**រូប S5៖ ការងើបឡើងវិញហាក់មានភាពដូចគ្នាក្នុងចំណោមក្រុមហ៊ុនគ្រប់ទំហំ និងគ្រប់វិស័យនៅកម្ពុជា ជាងការងើបឡើងនៅប្រទេសវៀតណាម**

*a. ប្រទេសកម្ពុជា បែងចែកតាមទំហំក្រុមហ៊ុន*




*b. ប្រទេសវៀតណាម បែងចែកតាមទំហំក្រុមហ៊ុន*




*c. ប្រទេសកម្ពុជា បែងចែកតាមវិស័យ*




*d. ប្រទេសវៀតណាម បែងចែកតាមវិស័យ*



## 3. ក្រុមហ៊ុននៅតែប្រឈមនឹងហានិភ័យលើប្រតិបត្តិការ ជាពិសេសហិរញ្ញប្បទាន

**ក្រៅពីការបិទទ្វារ ប្រតិបត្តិការរបស់ក្រុមហ៊ុនអាចរងផលប៉ះពាល់ដោយសារកត្តាផ្សេងទៀត ដូចជាការរកបានបុគ្គលិកដោយសារតែការប្រែប្រួលកាលៈទេសៈ វត្ថុធាតុដើមមានថ្លៃជាងមុន ឬមានគុណភាពទាបជាងមុន ដោយសារតែការពន្យារពេលដែលពាក់ព័ន្ធនឹងវិបត្តិនៃការផ្គត់ផ្គង់ និងលទ្ធភាពទទួលបានហិរញ្ញប្បទាន។** នៅពេលក្រុមហ៊ុនមានកង្វះលំហូរសាច់ប្រាក់យ៉ាងច្រើន ការពន្យារពេលលើការទូទាត់សេវាហិរញ្ញវត្ថុ ការទូទាត់ទាន់ពេលវេលា និងការផ្តល់ឥណទានដល់ក្រុមហ៊ុនផ្គត់ផ្គង់ ជាកត្តាដ៏សំខាន់ដែលអាចគាំទ្រដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន។

**ជំងឺកូវីដ 19 នៅតែបង្កផលប៉ះពាល់លើក្រុមហ៊ុននៅកម្ពុជាតាមប្រភពផ្សេងៗ។** ផ្អែកតាមរបកគំហើញនៃការអង្កេត នៅខែ កញ្ញា ក្រុមហ៊ុនជាច្រើនបានរាយការណ៍ថា i) មិនសូវមានការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុដែលធ្លាប់រកបានជាធម្មតាពីមុន (43 ភាគរយ) ii) ពិបាករកបានវត្ថុធាតុដើម (27 ភាគរយ) និង iii) មិនសូវមានការផ្តល់ឥណទានដល់ក្រុមហ៊ុនផ្គត់ផ្គង់ និងការពន្យារពេលទូទាត់ (22 ភាគរយ) ទោះបីជាសូចនាករទាំងនេះមានភាពប្រសើរឡើងបន្តិចជាងខែ មិថុនា ក្តី (រូប S7)។ ឧទាហរណ៍ នៅខែ មិថុនា ក្រុមហ៊ុនចំនួន 34 ភាគរយរាយការណ៍ថា ពិបាករកបានវត្ថុធាតុដើម ខណៈដែលនៅខែ កញ្ញា ក្រុមហ៊ុនចំនួន 27 ភាគរយរាយការណ៍ពីចំណុចនេះ។

**ការថយចុះលំហូរសាច់ប្រាក់កំពុងប៉ះពាល់យ៉ាងខ្លាំងលើក្រុមហ៊ុន ហើយរំពឹងថានឹងប៉ះពាល់កាន់តែខ្លាំងក្នុងរយៈពេលប៉ុន្មានខែខាងមុខ។** បន្ទាប់ពីការលក់បានថយចុះក្នុងរយៈពេលជាច្រើនខែ ចំនួនក្រុមហ៊ុនដែលរាយការណ៍ពីកង្វះលំហូរសាច់ប្រាក់រហូតមិនអាចធ្វើប្រតិបត្តិការជាប្រក្រតីបាន កើនពី 61 ភាគរយនៅខែ មិថុនា ដល់ 77 ភាគរយនៅខែ កញ្ញា។ ចំនួនកើនឡើងនេះប្រហាក់ប្រហែលគ្នាសម្រាប់ក្រុមហ៊ុនគ្រប់ទំហំ ក៏ដូចជាក្រុមហ៊ុនដែលកាន់កាប់ដោយបុរស និងក្រុមហ៊ុនដែលកាន់កាប់ដោយស្ត្រី។ ចំនួនក្រុមហ៊ុនដែលរំពឹងថាមានកង្វះលំហូរសាច់ប្រាក់ក្នុងរយៈពេល 6 ខែខាងមុខ កើនពី 56 ភាគរយនៅខែ មិថុនា រហូតដល់ 71 ភាគរយនៅខែ កញ្ញា។

**ហានិភ័យរបស់ក្រុមហ៊ុនក្នុងការជំពាក់បំណុលច្រើន ពោលគឺ ក្រុមហ៊ុនមិនអាចបំពេញកាតព្វកិច្ចក្នុងការទូទាត់ទាន់ពេលវេលា នៅតែមានអត្រាខ្ពស់។** ទោះជាយ៉ាងណាក៏ដោយ ចំនួនក្រុមហ៊ុននៅកម្ពុជាដែលប្រឈមនឹងហានិភ័យនៃការជំពាក់បំណុលច្រើននៅអំឡុងខែ កញ្ញា បានថយចុះ។ ក្រុមហ៊ុនចំនួន 34 ភាគរយ (ខែ មិថុនា) និងក្រុមហ៊ុនចំនួន 25 ភាគរយ (នៅខែ កញ្ញា) រំពឹងថានឹងជំពាក់បំណុលច្រើនក្នុងរយៈពេល 6 ខែបន្ទាប់។ ភាពប្រសើរឡើងនេះស្របទៅនឹងការចាប់ផ្តើមសកម្មភាពអាជីវកម្មឡើងវិញ និងកំណើនប្រាក់ចំណូលដែលបានលើកឡើងខាងលើ។ ទោះបីជាមានភាពហាក់ប្រសើរឡើងជាងអំឡុងខែ មិថុនា ប៉ុន្តែ ក្រុមហ៊ុនខ្នាតមីក្រូ និងក្រុមហ៊ុនខ្នាតតូចហានិភ័យនៃការជំពាក់បំណុលច្រើន មានកម្រិតខ្ពស់ជាង។ ឧទាហរណ៍ ក្រុមហ៊ុនខ្នាតមីក្រូ និងក្រុមហ៊ុនខ្នាតតូច ចំនួន 29 ភាគរយ បានរាយការណ៍ពីហានិភ័យនៃការជំពាក់បំណុលច្រើននៅខែ កញ្ញា ខណៈដែលក្នុងអំឡុងពេលដូចគ្នានេះ មានក្រុមហ៊ុនខ្នាតធំចំនួន 20 ភាគរយ បានរាយការណ៍ពីហានិភ័យនេះ។

**ក្រុមហ៊ុននៅកម្ពុជា មានស្ថានភាពប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ពាក់ព័ន្ធនឹងហានិភ័យនៃការមិនមានលទ្ធភាពសងបំណុល។** ក្រុមហ៊ុននៅកម្ពុជាដែលរំពឹងថានឹងជំពាក់បំណុលច្រើន (34 ភាគរយនៅខែ មិថុនា) មានចំនួនច្រើនជាងក្រុមហ៊ុននៅឥណ្ឌូណេស៊ីដែលរំពឹងថានឹងជំពាក់បំណុលច្រើន (16 ភាគរយនៅខែ មិថុនា) ប៉ុន្តែ មានចំនួនប្រហាក់ប្រហែលគ្នានឹងចំនួនក្រុមហ៊ុននៅមីយ៉ាន់ម៉ាដែលរំពឹងថានឹងជំពាក់បំណុលច្រើន (36 ភាគរយនៅខែ ឧសភា) និងតិចជាងចំនួនក្រុមហ៊ុននៅវៀតណាមដែលរំពឹងថា នឹងជំពាក់បំណុលច្រើន (48 ភាគរយនៅខែ មិថុនា) (តារាង S1)។

**រូប S6៖ ខេត្តសៀមរាបដែលពឹងផ្អែកលើវិស័យទេសចរណ៍ទទួលរងផលប៉ះពាល់ខ្លាំងជាងបណ្តាខេត្តផ្សេងទៀត**




**រូប S7៖ សម្ពាធកាន់តែខ្លាំងលើលំហូរសាច់ប្រាក់**



**តារាង S1៖ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅកម្ពុជា ធៀបនឹងបណ្តាក្រុមហ៊ុនក្នុងតំបន់អាស៊ីបូព៌ា**

| ប្រទេស | កំពុងជំពាក់បំណុលច្រើន ឬ រំពឹងថានឹងជំពាក់បំណុលច្រើន ក្នុងរយៈពេល 6 ខែបន្ទាប់ |
|---|---|
| វៀតណាម (ខែ មិថុនា) | 48% |
| វៀតណាម (ខែ កញ្ញា/តុលា) | 43% |
| ឥណ្ឌូណេស៊ី (ខែ មិថុនា) | 16% |
| **កម្ពុជា (ខែ មិថុនា)** | **34%** |
| **កម្ពុជា (ខែ កញ្ញា)** | **25%** |
| មីយ៉ាន់ម៉ា (ខែ ឧសភា) | 36% |
| មីយ៉ាន់ម៉ា (ខែ សីហា) | 40% |

**កន្លងមក គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការបានដើរតួនាទីតិចតួចក្នុងការសម្រួលដល់កង្វះលំហូរសាច់ប្រាក់របស់ក្រុមហ៊ុននៅកម្ពុជា។** ហិរញ្ញប្បទានចាំបាច់បន្ថែមទៀតដើម្បីដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ 19 មានប្រភពពីឥណទានរបស់ក្រុមហ៊ុនផ្គត់ផ្គង់ និងការពន្យារពេលទូទាត់នៅខែ មិថុនា ជាអំឡុងពេលដែលក្រុមហ៊ុនពឹងផ្អែកលើទំនាក់ទំនងពាណិជ្ជកម្មទាំងនេះ លើសពីទម្រង់ហិរញ្ញប្បទានផ្សេងទៀត (ក្រុមហ៊ុនចំនួន 18 ភាគរយរាយការណ៍ថា ទំនាក់ទំនងនេះជាយន្តការដ៏សំខាន់សម្រាប់ដោះស្រាយកង្វះលំហូរសាច់ប្រាក់)។ ក្រោយមកទៀត និន្នាការនេះបានថយចុះនៅខែ កញ្ញា ជាអំឡុងពេលដែលមានក្រុមហ៊ុនតែ 10 ភាគរយប៉ុណ្ណោះបានលើកឡើងពីយន្តការនេះ។

នៅចំពោះមុខស្ថានការណ៍នេះ ក្រុមហ៊ុនបានខ្ចីប្រាក់ពីគ្រួសារ និងមិត្តភក្តិ ដើម្បីបំពេញកង្វះលំហូរសាច់ប្រាក់ (11 ភាគរយ)។ គ្រួសារ និងមិត្តភក្តិនៅតែជាប្រភពផ្តល់ហិរញ្ញវត្ថុក្នុងគ្រាអាសន្ន។

**លើសពីនេះទៀត ចំនួនក្រុមហ៊ុនដែលប្រើប្រាស់ហិរញ្ញប្បទានមួយចំនួនដើម្បីដោះស្រាយបញ្ហា កង្វះលំហូរសាច់ប្រាក់ បានថយចុះ។** ចំនួនក្រុមហ៊ុនទាំងនេះបានថយចុះពី 34 ភាគរយនៅខែ មិថុនា មកត្រឹម 26 ភាគរយនៅខែ កញ្ញា ដោយសារក្រុមហ៊ុនលែងសូវពឹងផ្អែកលើទំនាក់ទំនងពាណិជ្ជកម្ម (ឥណទានដល់ក្រុមហ៊ុនផ្គត់ផ្គង់ ឬការពន្យារពេលទូទាត់)។ ខណៈដែលការអង្កេតនេះមិនអាចផ្តល់ចម្លើយជាក់លាក់ថាតើការថយចុះខាងលើបណ្តាលមកពីការប្រែប្រួលតម្រូវការ ឬលទ្ធភាពទទួលបានហិរញ្ញប្បទាន ឬយ៉ាងណានោះ លទ្ធផលនៃការអង្កេតបង្ហាញពីទំនាក់ទំនងអវិជ្ជមានរវាងការប្រើប្រាស់ហិរញ្ញប្បទានដោយក្រុមហ៊ុនដើម្បីឆ្លើយតបនឹងជំងឺកូវីដ 19 និងលើកឡើងពីការប្រែប្រួលការលក់ (រូប S9)[50]។ អាចនិយាយបានថា ក្រុមហ៊ុនដែលមានការលក់ធ្លាក់ចុះខ្លាំង ច្រើនតែប្រើប្រាស់ហិរញ្ញប្បទានដើម្បីសម្រួលដល់កង្វះលំហូរសាច់ប្រាក់របស់ខ្លួន។

**ជារួម ក្រុមហ៊ុនធំៗនៅកម្ពុជាមិនសូវប្រើប្រាស់ហិរញ្ញប្បទាន និងមិនសូវប្រឈមនឹងការជំពាក់បំណុលច្រើន ដែលថយចុះទៅតាមទំហំក្រុមហ៊ុន។** ក្រុមហ៊ុនខ្នាតមីក្រូជាងពាក់កណ្តាលកំពុងប្រើប្រាស់ហិរញ្ញប្បទានប្រភេទណាមួយ (54 ភាគរយ) ខណៈដែលមានក្រុមហ៊ុនខ្នាតធំតែ 27 ភាគរយប៉ុណ្ណោះកំពុងប្រើប្រាស់ហិរញ្ញប្បទាន (រូប S10)។ សម្រាប់ក្រុមហ៊ុនគ្រប់ទំហំ ការប្រើប្រាស់ហិរញ្ញប្បទាន និងហានិភ័យនៃការជំពាក់បំណុល

**រូប S8៖ ការបន្តពឹងផ្អែកលើគ្រួសារ និងមិត្តភក្តិជាយន្តការដ៏សំខាន់ក្នុងការសម្រួលដល់កង្វះលំហូរសាច់ប្រាក់**




*សម្គាល់ ៖ ក្រុមហ៊ុនត្រូវបានស្នើឱ្យគូសបញ្ជាក់ពីយន្តការចម្បងក្នុងការដោះស្រាយបញ្ហាកង្វះលំហូរសាច់ប្រាក់ ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19។ អាចមានចម្លើយច្រើន។ ទំនាក់ទំនងពាណិជ្ជកម្មរួមបញ្ចូលការផ្តល់ឥណទានដល់ក្រុមហ៊ុនផ្គត់ផ្គង់ និងការពន្យារពេលទូទាត់។*

**រូប S9៖ ក្រុមហ៊ុនដែលមានការលក់ធ្លាក់ចុះខ្លាំង ច្រើនតែប្រើប្រាស់ហិរញ្ញប្បទានដើម្បីសម្រួលដល់កង្វះលំហូរសាច់ប្រាក់**




*សម្គាល់ ៖ រូបនេះគឺជាក្រាហ្វិកអថេរពីរចូលគ្នា ៖ ការបែងចែកការប្រែប្រួលការលក់ជា 12 ប្រភេទ និងការបែងចែកមធ្យមភាគនៃការប្រែប្រួលការលក់ជាចំណែកៗ និងលទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានដើម្បីឆ្លើយតបនឹងជំងឺកូវីដ 19 ក្នុងប្រភេទនៃការប្រែប្រួលនីមួយៗ ដោយសន្មតថា ក្រុមហ៊ុនទទួលរងផលប៉ះពាល់ថេរ។ រូបនេះប្រើប្រាស់បណ្តុំក្រុមហ៊ុន ដែលបានផ្តល់ចម្លើយក្នុងកិច្ចសម្ភាសន៍លើកទីមួយ និងលើកទីពីរ។*

50 ទោះជាការបញ្ជាក់របស់ក្រុមហ៊ុនពីកង្វះការផ្តល់ឥណទានដល់ក្រុមហ៊ុនផ្គត់ផ្គង់ និងការពន្យារពេលទូទាត់ អាចជួយពន្យល់ពីការថយចុះការប្រើប្រាស់ហិរញ្ញប្បទានប្រភេទនេះ គួរកត់សម្គាល់ថា ក្រុមហ៊ុនដែលប្រើប្រាស់ទំនាក់ទំនងពាណិជ្ជកម្មទាំងនេះក៏ច្រើនលើកឡើងពីកង្វះលំហូរសាច់ប្រាក់ផងដែរ ដែលអាចបង្ហាញពីការលំបាកក្នុងដំណើរការនេះ។

ច្រើន ថយចុះបន្តិចនៅចន្លោះខែ មិថុនា និងខែ កញ្ញា ប៉ុន្តែ នៅតែមានកម្រិតខ្ពស់សម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ។ ចំនួនក្រុមហ៊ុនដែលប្រឈមនឹងហានិភ័យនៃការជំពាក់បំណុលច្រើននៅខែមិថុនា មានចំនួន 27 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតមធ្យម និង 38 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតតូច។ ចំនួនក្រុមហ៊ុនដែលប្រឈមនឹងហានិភ័យនៃការជំពាក់បំណុលច្រើននៅខែកញ្ញា មានចំនួន 16 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតមធ្យម និង 29 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ និងក្រុមហ៊ុនខ្នាតតូច។

## 4. យន្តការរបស់ក្រុមហ៊ុនក្នុងការដោះស្រាយវិបត្តិ

**នៅលើពិភពលោក នៅកាលៈទេសៈដែលមានលទ្ធភាពតិចតួចក្នុងការប្រតិបត្តិ និងបង្កើតចំណូលក្រុមហ៊ុនត្រូវបង្ខំចិត្តកាត់បន្ថយចំណាយ ដោយកែសម្រួលការងារ។** ក្រុមហ៊ុនអាចធ្វើការកែសម្រួលការចំណាយ តាមរយៈការអនុញ្ញាតឱ្យឈប់សម្រាកពីការងារ ឬកាត់បន្ថយប្រាក់ឈ្នួល ឬចំនួនម៉ោងធ្វើការ ឬតាមរយៈការរំសាយបុគ្គលិក។

**រូប S10៖ លទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទាននិងហានិភ័យនៃការជំពាក់បំណុលច្រើនថយចុះទៅតាមទំហំក្រុមហ៊ុន**




**រូប S11៖ ក្រុមហ៊ុននៅកម្ពុជាបានរំសាយបុគ្គលិកយ៉ាងច្រើន**

*a.ការកែសម្រួលលក្ខខណ្ឌការងារ*




*សម្គាល់ ៖ ក្រុមហ៊ុនត្រូវបានស្នើឱ្យរាយការណ៍ពីស្ថានភាពការងារក្នុងក្រុមហ៊ុនក្នុងរយៈពេល 30 ថ្ងៃមុនការសម្ភាសន៍*

**នៅកម្ពុជា ក្រុមហ៊ុនកែសម្រួលលើចំណុចនេះដោយរំសាយបុគ្គលិក និងកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួល។** ក្រុមហ៊ុនជាច្រើនបានរំសាយបុគ្គលិក។ ក្នុងនោះ ក្រុមហ៊ុនចំនួន 30 ភាគរយ បានរាយការណ៍ថាបានកាត់បន្ថយចំនួនបុគ្គលិកក្នុងរយៈពេល 30 ថ្ងៃមុន នៅខែ មិថុនា ហើយក្រុមហ៊ុនចំនួន 31 ភាគរយបានរាយការណ៍ថា បានកាត់បន្ថយចំនួនបុគ្គលិកក្នុងរយៈពេល 30 ថ្ងៃមុន នៅខែ កញ្ញា (រូប S11, ផ្នែក a)។ តាមការប្រៀបធៀប ចំនួនក្រុមហ៊ុនដែលកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួលនៅខែ កញ្ញា តិចជាងចំនួនក្រុមហ៊ុនដែលកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួលនៅខែ មិថុនា ចំនួន 8-14 ភាគរយ។

**ការសម្រេចចិត្តអនុវត្តវិធានការអចិន្ត្រៃយ៍ ដូចជា ការរំសាយបុគ្គលិក ធៀបនឹងវិធានការបណ្តោះអាសន្ន ដូចជា ការកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួល ឬការអនុញ្ញាតឱ្យសុំច្បាប់ឈប់សម្រាក អាចបណ្តាលមកពីកត្តាផ្សេងៗ។** វិធានការទាំងនេះអាចបង្ហាញពីការយល់ឃើញរបស់ក្រុមហ៊ុនចំពោះរយៈពេលនៃវត្តមានជំងឺកូវីដ 19 និងការប្រែប្រួលកាលៈទេសៈ ឬភាពធ្ងន់ធ្ងរនៃឧបសគ្គសន្ទនីយភាព។ ឧបសគ្គសន្ទនីយភាពកើតចេញពីទំនាក់ទំនងអវិជ្ជមានខ្លាំងរវាងលទ្ធភាពនៃការរំសាយបុគ្គលិក និងការប្រែប្រួលការលក់ (រូប S11, ផ្នែក b)។ ចំណុចនេះអាចបង្ហាញពីភាពបត់បែននៃច្បាប់ស្តីពីការងារ និងភាពងាយស្រួលក្នុងការជួល ឬបណ្តេញបុគ្គលិកចេញពីការងារនៅតាមបណ្តាប្រទេសនានា។

**លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការរក្សាបុគ្គលិក ក៏អាចឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រដ្ឋាភិបាលដែរ ដោយកម្ពុជាផ្តោតលើការផ្តល់អត្ថប្រយោជន៍លើនិកម្មភាពដល់កម្មករដែលត្រូវបានព្យួរពីការងារ។** ក្រៅពីវិស័យទេសចរណ៍ វិស័យសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ក៏ទទួលការប៉ះទង្គិចធ្ងន់ធ្ងរដោយសារវិបត្តិជំងឺកូវីដ 19 ផងដែរ។ ក្នុងនោះ ការនាំចេញថយចុះចំនួន 11.5 ភាគរយនៅខែ សីហា ឆ្នាំ 2020 (ធៀបនឹងឆ្នាំមុន)។ វិស័យសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង

*b.ទំនាក់ទំនងរវាងការប្រែប្រួលការលក់ និងការរំសាយបុគ្គលិក*




*សម្គាល់ ៖ តួលេខនេះគឺជាការបែងចែកជារួម ៖ ការបែងចែកការប្រែប្រួលការលក់ជា 12 ប្រភេទ និងការបែងចែកមធ្យមភាគនៃការប្រែប្រួលការលក់ជាចំណែកៗ និងលទ្ធភាពនៃការរំសាយបុគ្គលិកក្នុងប្រភេទនៃការប្រែប្រួលនីមួយៗ ដោយសន្មតថា ក្រុមហ៊ុនទទួលរងផលប៉ះពាល់ថេរ។ រូបនេះប្រើប្រាស់បណ្តុំក្រុមហ៊ុនដែលបានផ្តល់ចម្លើយក្នុងកិច្ចសម្ភាសន៍លើកទីមួយ និងលើកទីពីរ។*

ផ្តល់ការងារដល់កម្មករជិត 1 លាននាក់នៅកម្ពុជា។ នៅខែ កក្កដា ឆ្នាំ 2020 រោងចក្រសម្លៀកបំពាក់ ស្បែកជើង និង ទំនិញធ្វើដំណើរជិត 400 រោងចក្របានផ្អាកប្រតិបត្តិការ និងធ្វើឱ្យប៉ះពាល់ដល់កម្មករ 150,000 នាក់[51]។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អត្ថប្រយោជន៍លើនិកម្មភាពដល់កម្មករដែលត្រូវបានព្យួរពីការងារក្នុងវិស័យសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និង ស្បែកជើង (70 ដុល្លារក្នុងមួយខែដែល 40 ដុល្លារផ្តល់ដោយរដ្ឋាភិបាល និង 30 ដុល្លារទៀតផ្តល់ដោយរោងចក្រផ្ទាល់)។

**របកគំហើញស្តីពីផលប៉ះពាល់នៃជំងឺកូវីដ 19 លើក្រុមហ៊ុន ស៊ីសង្វាក់គ្នានឹងរបកគំហើញពីការអង្កេតគ្រួសារតាមទូរស័ព្ទដែលត្រូវបានធ្វើឡើងក្នុងទិសដៅតែមួយ ដោយធនាគារពិភពលោក។** ការអង្កេតគ្រួសារនៅកម្ពុជាកាលពីខែ ឧសភា និង ខែ សីហា ឆ្នាំ 2020 បង្ហាញថា ចំនួនអ្នកឆ្លើយតបដែលកំពុងធ្វើការថយចុះពី 82 ភាគរយកាលពីមុនពេលផ្ទុះជំងឺកូវីដ 19 មកត្រឹម 71 ភាគរយនៅខែ ឧសភា និងមានចំនួន 70% នៅខែ សីហា (សូមមើលប្រអប់ 3 ខាងលើ)។ ការអង្កេតគ្រួសារបង្ហាញផងដែរថា ជំងឺកូវីដ 19 នៅតែបង្កផលប៉ះពាល់អវិជ្ជមានលើសកម្មភាពអាជីវកម្មក្រៅពីកសិកម្មក្រៅផ្លូវការ ដែលជាផ្នែកដ៏សំខាន់មួយនៃសេដ្ឋកិច្ចកម្ពុជា (សូមមើលប្រអប់ S2) ទោះបីជាផលប៉ះពាល់នៅពេលនេះមិនសូវធ្ងន់ធ្ងរដូចផលប៉ះពាល់នៅពេលផ្ទុះជំងឺនេះដំបូងក្តី។ ក្នុងចំណោមប្រជាជន 5 គ្រួសារ មាន 4 គ្រួសារលើកឡើងពីការរកប្រាក់ចំណូលបានតិចជាងមុន ឬគ្មានប្រាក់ចំណូលនៅខែ មេសា ធៀបនឹងខែ មីនា ខណៈដែលក្នុងចំណោម 5 គ្រួសារ មាន 3 គ្រួសារលើកឡើងពីការរកបានប្រាក់ចំណូលតិចជាងមុន ឬគ្មានប្រាក់ចំណូលនៅខែ កក្កដា ធៀបនឹងខែ មិថុនា។

**មានភាពខុសគ្នាខ្លាំងលើការកែសម្រួលការងារក្នុងចំណោមក្រុមហ៊ុនគ្រប់ទំហំ ដោយក្រុមហ៊ុនខ្នាតធំច្រើនតែរំសាយបុគ្គលិក ចំណែកក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម ច្រើនតែកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួល ឬអនុញ្ញាតឱ្យសុំច្បាប់ឈប់សម្រាក។** នៅខែ មិថុនា ក្រុមហ៊ុនខ្នាតចំនួន 39 ភាគរយរាយការណ៍ពីការរំសាយបុគ្គលិក ធៀបនឹងក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមចំនួន 26-29 ភាគរយដែលរាយការណ៍ពីការរំសាយបុគ្គលិក (រូប S12, ផ្នែក a)។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមចំនួន 25-28 ភាគរយ បានធ្វើការកែសម្រួលការងារ តាមរយៈការកាត់បន្ថយចំនួនម៉ោងធ្វើការ ឬប្រាក់ឈ្នួល ឬការអនុញ្ញាតឱ្យសុំច្បាប់ឈប់សម្រាក ធៀបនឹងក្រុមហ៊ុនខ្នាតធំចំនួន 15 ភាគរយដែលអនុវត្តដូច្នេះ (រូប S12, ផ្នែក b)។ ទោះជាយ៉ាងណា គិតត្រឹមខែ កញ្ញា មិនសូវមានភាពខុសគ្នាទាំងនេះឡើយ។

**រូប S12៖ ក្រុមហ៊ុនខ្នាតធំច្រើនតែកែសម្រួលការងារដោយបង្ខំល្បឿនលឿនជាងនៅតំបន់អាស៊ីបូព៌ា**

*a. ការកែសម្រួលការងារដោយបង្ខំ*




*b. ការកែសម្រួលការងារដោយប្រយោល*




*សម្គាល់ ៖ សូចនាកររួមនៃក្រុមហ៊ុនដែលប្រើប្រាស់យន្តការកែសម្រួលការងារយ៉ាងតិចមួយក្នុងចំណោមយន្តការដូចតទៅ ការកើនឡើងនៃការអនុញ្ញាតឱ្យសុំច្បាប់ឈប់សម្រាក ការកើនឡើងនៃការកាត់បន្ថយប្រាក់ឈ្នួល ការកើនឡើងនៃការកាត់បន្ថយចំនួនម៉ោងធ្វើការ។*

**រូប S13៖ ភាពខុសគ្នានៃការកែសម្រួលការងារដោយក្រុមហ៊ុនក្នុងតំបន់អាស៊ីបូព៌ា**




*សម្គាល់ ៖ ការកែសម្រួលការងារសំដៅលើរយៈពេល 30 ថ្ងៃចុងក្រោយ មុនការអង្កេត (ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី និងវៀតណាម)។ សម្រាប់ប្រទេសហ្វីលីពីន ការប្រែប្រួលគឺនៅចន្លោះខែ កក្កដា-មេសា ដោយសារការបង្កើនការធ្វើចត្តាឡីស័កក្នុងសហគមន៍។*

51 http://www.xinhuanet.com/english/2020-07/01/c_139180683.htm។

## សារៈសំខាន់នៃសហគ្រាសគ្រួសារក្រៅពីកសិកម្មនៅកម្ពុជា

ក្នុងចំណោមពលរដ្ឋខ្មែរ 5 នាក់ មានម្នាក់ធ្វើការក្នុងសហគ្រាសគ្រួសារក្រៅពីកសិកម្ម។ សហគ្រាសទាំងនោះរួមមាន ហាងលក់ចាប់ហួយដែលគ្រប់គ្រងដោយមនុស្សម្នាក់ ហាងកាត់ដេរ ស្ត្រីលក់សាច់អាំងនៅផ្សារតាមដងផ្លូវ និងហាងជួសជុលម៉ូតូតាមចិញ្ចើមផ្លូវ។ អ្នកធ្វើការទាំងនេះមិនមែនជានិយោជិតទេ ព្រោះថា ពួកគេធ្វើការដោយខ្លួនឯង ឬជាសមាជិកគ្រួសារ និងមិនមែនជាក្រុមហ៊ុនផ្តោតលើកំណើនដែលរំពឹងថានឹងក្លាយជាម៉ាស៊ីនកំណើនរបស់កម្ពុជាទេ។

សហគ្រាសគ្រួសារក្រៅពីកសិកម្ម ជាផ្នែកដ៏សំខាន់នៃសេដ្ឋកិច្ច និងទីផ្សារការងារនៅកម្ពុជា។ អាជីវកម្មគ្រួសារក្រៅពីកសិកម្មខ្នាតមីក្រូចំនួន 1.4 លាន ផ្តល់ទំនិញ និងសេវាជាច្រើនដែលរក្សាចរន្តសេដ្ឋកិច្ចក្នុងស្រុក និងជាប្រភពសំខាន់ដែលផ្តល់ប្រាក់ចំណូលដល់កម្លាំងពលកម្មចំនួន 17 ភាគរយក្នុងសេដ្ឋកិច្ចមួយដែលកំពុងប្រែក្លាយទៅជាសេដ្ឋកិច្ចទំនើប។

សហគ្រាសគ្រួសារក្រៅពីកសិកម្មស្ថិតនៅរាយប៉ាយទូទាំងប្រទេស។ គ្រួសារនៅទីក្រុងជាងពាក់កណ្តាលកាន់កាប់សហគ្រាសគ្រួសារក្រៅពីកសិកម្ម ធៀបនឹងគ្រួសារនៅជនបទចំនួន 23 ភាគរយដែលកាន់កាប់សហគ្រាសប្រភេទនេះ។ សហគ្រាសគ្រួសារក្រៅពីកសិកម្មជាង 60 ភាគរយស្ថិតនៅទីជនបទ ព្រោះប្រជាជនកម្ពុជាភាគច្រើនរស់នៅទីជនបទ។ សហគ្រាសទាំងនោះច្រើនតែប្រមូលផ្តុំក្នុងច្រករបៀងសេដ្ឋកិច្ច និងក្នុងសហគមន៍ធ្វូរធារ ដែលពោរពេញដោយសកម្មភាពពាណិជ្ជកម្ម និងសេវាកម្មតូចៗ។

សហគ្រាសគ្រួសារក្រៅពីកសិកម្ម មានទំហំតូច ទើបតែដំណើរការ និងប្រមូលផ្តុំក្នុងវិស័យលក់រាយ។ សហគ្រាសគ្រួសារក្រៅពីកសិកម្មចំនួនពាក់កណ្តាល គ្រប់គ្រងដោយមនុស្សតែម្នាក់ ខណៈដែលសហគ្រាសគ្រួសារក្រៅពីកសិកម្ម ចំនួន 51 ភាគរយទៀត ចូលរួមដោយសមាជិកគ្រួសារយ៉ាងតិចម្នាក់។ មានសហគ្រាសគ្រួសារក្រៅពីកសិកម្មតែ 6 ភាគរយប៉ុណ្ណោះ ដែលជួលកម្មករមិនមែនជាសមាជិកគ្រួសារ។ សហគ្រាសគ្រួសារក្រៅពីកសិកម្មជិតពាក់កណ្តាល (47 ភាគរយ) គឺជាពាណិជ្ជកម្មលក់រាយ ហើយ 2/3 នៃអាជីវកម្មខ្នាតតូចទាំងនេះគ្រប់គ្រងដោយស្ត្រី[1]។ ក្រៅពីនេះ សហគ្រាសគ្រួសារក្រៅពីកសិកម្មចំនួន 14 ភាគរយ ស្ថិតក្នុងវិស័យដឹកជញ្ជូន (20 ភាគរយក្នុងតំបន់ទីក្រុង) និងគ្របដណ្តប់ដោយបុរស ចំណែកសហគ្រាសគ្រួសារក្រៅពីកសិកម្មចំនួន 14 ភាគរយទៀត ស្ថិតក្នុងឧស្សាហកម្មផលិត ដែលមានចំនួនច្រើននៅតំបន់ជនបទ និងច្រើនតែពាក់ព័ន្ធនឹងបុរស។ សហគ្រាសគ្រួសារក្រៅពីកសិកម្មភាគច្រើន (96 ភាគរយ) ត្រូវបានបង្កើតឡើងដោយម្ចាស់បច្ចុប្បន្ន និងទើបតែចាប់ផ្តើមប្រតិបត្តិការ (រយៈពេលមធ្យម 6.9 ឆ្នាំ និងរយៈពេលមេដ្យាន 4 ឆ្នាំ)។ ក្នុងនោះ សហគ្រាសចំនួន 30 ភាគរយទើបតែដំណើរការមិនលើស 1 ឆ្នាំ។ ទោះជាយ៉ាងណា សហគ្រាសគ្រួសារក្រៅពីកសិកម្មក្នុងវិស័យឧស្សាហកម្មផលិត ដំណើរការជាង 1 ទសវត្សរ៍មកហើយ។

វិបត្តិជំងឺកូវីដ 19 បានបង្កើនស្ថានភាពមិនទៀងទាត់របស់ម្ចាស់សហគ្រាសគ្រួសារក្រៅពីកសិកម្ម និងការផាត់ម្ចាស់សហគ្រាសទាំងនេះចេញពីក្របខណ្ឌគោលនយោបាយទូលំទូលាយ[2]។ នៅខែ ឧសភា ឆ្នាំ 2020 ម្ចាស់សហគ្រាសគ្រួសារក្រៅពីកសិកម្មចំនួន 81 ភាគរយ លើកឡើងពីការថយចុះ ឬការគ្មានប្រាក់ចំណូលក្នុងរយៈពេលប៉ុន្មានខែកន្លងមក ធៀបនឹងការលើកឡើងដូច្នេះដោយគ្រួសារកសិករចំនួន 62 ភាគរយ និងនិយោជិតចំនួន 63 ភាគរយ។ ការបាត់បង់ប្រាក់ចំណូលមានច្រើនក្នុងចំណោមម្ចាស់សហគ្រាសគ្រួសារក្រៅពីកសិកម្មនៅទីក្រុង (89 ភាគរយ) ប៉ុន្តែសហគ្រាសគ្រួសារក្រៅពីកសិកម្មនៅជនបទក៏បង្ហាញពីការបាត់បង់ប្រាក់ចំណូលច្រើនផងដែរ (79 ភាគរយ)។ របកគំហើញ នេះមានភាពស៊ីសង្វាក់គ្នា បើគិតពីយេនឌ័ររបស់អ្នកឆ្លើយតប កម្រិតអប់រំរបស់មេគ្រួសារ និងស្ថានភាពសង្គមសេដ្ឋកិច្ចរបស់មេគ្រួសារ។ ការបាត់បង់ប្រាក់ចំណូលបណ្តាលមកពីការបាត់បង់អតិថិជន (70 ភាគរយ) និងការបិទអាជីវកម្ម ( 14 ភាគរយ) និងមានភាពធ្ងន់ធ្ងរជាងនេះនៅក្នុងវិស័យសេវា និងឧស្សាហកម្ម។

**សហគ្រាសគ្រួសារក្រៅពីកសិកម្មទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការផ្ទុះជំងឺកូវីដ 19។**

*a. ការប្រែប្រួលប្រាក់ចំណូលពីការលក់ក្នុងអាជីវកម្មធៀបនឹងខែចុងក្រោយ*




*b. មូលហេតុនៃការថយចុះ ឬការគ្មានប្រាក់ចំណូល*




*ប្រភព ៖ Cunningham and Shrestha (2020)*

---

[1] សហគ្រាសដែលពាក់ព័ន្ធនឹងការងារប្រើកម្លាំង ដូចជា ការដឹកជញ្ជូន ការសាងសង់ ការកិនស្រូវ ការងារជួសជុល ភាគច្រើនគ្រប់គ្រង ឬកាន់កាប់ដោយបុរស។ ចំនួនសហគ្រាសដែលកាន់កាប់ដោយស្ត្រីគឺ សហគ្រាសដែលពាក់ព័ន្ធនឹងការដឹកជញ្ជូន 38.3 ភាគរយ សហគ្រាសដែលពាក់ព័ន្ធនឹងការងារជួសជុល និងមេកានិក 28.9 ភាគរយ សហគ្រាសដែលពាក់ព័ន្ធនឹងការសាងសង់ 41.9 ភាគរយ និងរោងម៉ាស៊ីនកិនស្រូវ 48.8 ភាគរយ (ប្រភព ៖ Mahesh paper)។

[2] ការអង្កេតគ្រួសារស្តីពីជំងឺកូវីដ 19 បានប្រមូលព័ត៌មានសំខាន់ៗស្តីពីបទពិសោធន៍គ្រួសារក្នុងអំឡុងវិបត្តិជំងឺកូវីដ 19។ ការអង្កេតលើកទីមួយ (5 លើក) បានធ្វើឡើងនៅថ្ងៃទី 11-26 ខែ ឧសភា ឆ្នាំ 2020 ដោយមានអ្នកឆ្លើយតប 700 នាក់។ សំណាកនេះមានអ្នកចូលរួមជាប្រជាជនរស់នៅជនបទ (85 ភាគរយ) ច្រើនជាងចំនួនក្នុងស្ថិតិសកលទូទៅ ( ចំនួន 74 ភាគរយក្នុងការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា) ប៉ុន្តែតំណាងឱ្យយេនឌ័រ និងកម្រិតភាពក្រីក្រទូទាំងប្រទេស (បញ្ជាក់ដោយស្ថានភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។

**ធៀបនឹងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ការកែសម្រួលការងារនៅកម្ពុជាភាគច្រើនមានលក្ខណៈបង្ខំ (ការរំសាយបុគ្គលិក) ទោះបីជាមានភាពប្រសើរឡើងនៃវិបត្តិប្រាក់ចំណូលជាក់ស្តែង និងការរំពឹងទុកក្តី។** នៅអំឡុងខែ មិថុនា និងខែ កញ្ញា ចំនួនក្រុមហ៊ុននៅកម្ពុជាដែលរំសាយបុគ្គលិក មានតិចជាងចំនួនក្រុមហ៊ុននៅហ្វីលីពីនដែលរំសាយបុគ្គលិក (រូប S13 )។ នៅហ្វីលីពីន ការលក់របស់ក្រុមហ៊ុនថយចុះជិត 60 ភាគរយនៅអំឡុងខែ មេសា-កក្កដា ដែលជាអត្រាបាត់បង់ប្រាក់ចំណូលដ៏ខ្ពស់មួយក្នុងតំបន់។ និន្នាការនៅកម្ពុជាក៏ផ្ទុយស្រឡះពីនិន្នាការនៅវៀតណាមផងដែរ។ នៅអំឡុងខែ កញ្ញា/តុលា ក្រុមហ៊ុននៅវៀតណាមរំសាយបុគ្គលិក អនុញ្ញាតឱ្យសុំច្បាប់ឈប់សម្រាក ឬកាត់បន្ថយប្រាក់ឈ្នួល និងចំនួនម៉ោងធ្វើការ តិចជាងនៅអំឡុងខែ មិថុនា។ ដូច្នេះ ចាំបាច់ត្រូវសិក្សាពីមូលហេតុដែលជំរុញឱ្យក្រុមហ៊ុនជាច្រើននៅកម្ពុជាបញ្ឈប់បុគ្គលិកពីការងារ ព្រោះកត្តានេះអាចបណ្តាលមកពីមូលហេតុជាច្រើន ដូចជា ក្រុមហ៊ុនយល់ថា វិបត្តិនេះនឹងបន្តជារៀងរហូត ក្រុមហ៊ុនមិនសូវមានមូលដ្ឋានហិរញ្ញវត្ថុដើម្បីរក្សាទុកបុគ្គលិក បទប្បញ្ញត្តិការងារដែលមិនសូវតឹងរ៉ឹង ឬអំណាចចរចាដ៏ខ្លាំងក្លាធៀបនឹងចំនួនកម្លាំងពលកម្មយ៉ាងច្រើនក្នុងទីផ្សារ។

**ក្នុងចំណោមកត្តាផ្សេងទៀត ប្រសិទ្ធភាពនៃយន្តការរបស់ក្រុមហ៊ុនក្នុងការដោះស្រាយវិបត្តិជំងឺកូវីដ 19 អាស្រ័យលើលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការធ្វើការកែសម្រួលផ្សេងទៀតលើគំរូអាជីវកម្មរបស់ខ្លួន។** ក្រុមហ៊ុនអាចងាកទៅរកផលិតផល ឬសេវាផ្សេងដែលមានតម្រូវការខ្ពស់ (ឧ. ការចាប់ផ្តើមផលិតផលិតផលឱសថ) ឬវិនិយោគលើដំណោះស្រាយឌីជីថល ដើម្បីសម្រួលដល់ទំនាក់ទំនងច្រើនរវាងនិយោជិត និងអតិថិជន (ឧ. ការប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិក)។

**ក្រុមហ៊ុននៅកម្ពុជាកំពុងប្រើប្រាស់បណ្តាញឌីជីថលកាន់តែច្រើនក្នុងការធ្វើអាជីវកម្ម ដើម្បីឆ្លើយតបនឹងជំងឺកូវីដ 19។** ចំនួនក្រុមហ៊ុនដែលងាកទៅរកផលិតផល ឬសេវាថ្មី ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19 មានចំនួន 10 ភាគរយនៅខែ មិថុនា និង 15 ភាគរយនៅខែ កញ្ញា (រូប S14, ផ្នែក a)[52]។ គិតត្រឹមខែ កញ្ញា ក្រុមហ៊ុនចំនួន 23 ភាគរយរាយការណ៍ថា បានវិនិយោគលើដំណោះស្រាយឌីជីថល ហើយក្រុមហ៊ុនជិតពាក់កណ្តាល (47 ភាគរយ) លើកឡើងថា បានបង្កើនការប្រើប្រាស់បណ្តាញឌីជីថល។ នៅពេលចាប់ផ្តើមដំបូង ការប្រើប្រាស់ដំណោះស្រាយឌីជីថលមានកម្រិតខ្ពស់ (38 ភាគរយ) ប៉ុន្តែ ការប្រើប្រាស់នេះ

**រូប S14៖ ក្រុមហ៊ុនជិតពាក់កណ្តាលបង្កើនការប្រើប្រាស់បណ្តាញឌីជីថល គិតត្រឹមខែ កញ្ញា**

*a. យន្តការកែសម្រួល*




*សម្គាល់ ៖ ទិន្នន័យពីសំណាកតាមផ្នែក។ ក្រុមហ៊ុនត្រូវបានស្នើឱ្យបញ្ជាក់ពីការកែសម្រួលចាប់តាំងពីការផ្ទុះជំងឺកូវីដ 19។ ក្រុមហ៊ុនដែលធ្វើការកែសម្រួលនៅនៅខែ កញ្ញា បញ្ជាក់ពីការកែសម្រួលបន្ថែមទៀតបន្ទាប់ពីខែ មិថុនា។ កម្ពស់របាសរុបគឺជាការបូកសរុបពីលទ្ធផលពីការអង្កេតលើកទីមួយ និងលើកទីពីរ។*

*b. ការប្រើប្រាស់បណ្តាញឌីជីថល បែងចែកតាមមុខងារអាជីវកម្ម (ខែ កញ្ញា)*




*សម្គាល់ ៖ របាតំណាងឱ្យចំនួនក្រុមហ៊ុនដែលបង្កើនការប្រើប្រាស់ដំណោះស្រាយឌីជីថល។*

*c. ការលក់តាមបណ្តាញឌីជីថល*




*d. ការធ្វើការពីចម្ងាយ*




52 ចំនួនក្រុមហ៊ុននៅកម្ពុជាដែលរាយការណ៍ថាបានងាកទៅរកផលិតផល/សេវាថ្មី នៅខែ មិថុនា គឺដូចគ្នានឹងចំនួនក្រុមហ៊ុននៅឥណ្ឌូណេស៊ី និងវៀតណាមដែលរាយការណ៍ដូច្នេះ ប៉ុន្តែចំនួននេះទាបជាងចំនួនក្រុមហ៊ុននៅមីយ៉ាន់ម៉ា (26 ភាគរយ) នៅខែ ឧសភា និងចំនួនក្រុមហ៊ុននៅហ្វីលីពីន (26 ភាគរយ) នៅខែ កក្កដា។

បានថយចុះនៅអំឡុងខែ មិថុនា-កញ្ញា។ ក្នុងចំណោមក្រុមហ៊ុនដែលបង្កើនការប្រើប្រាស់បណ្តាញឌីជីថលទាំងនេះ ក្រុមហ៊ុនភាគច្រើនប្រើប្រាស់បណ្តាញឌីជីថលសម្រាប់ការធ្វើទីផ្សារ និងការលក់ (រូប S14, ផ្នែក b)។

**ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ដំណោះស្រាយឌីជីថល មិនធ្វើឱ្យមានការកែប្រែគំរូអាជីវកម្មរបស់ក្រុមហ៊ុនខ្លាំងនោះទេ។** ទោះជាការប្រើប្រាស់បណ្តាញឌីជីថលកាន់តែច្រើន គឺជាយន្តការដ៏សំខាន់មួយសម្រាប់ការធ្វើទំនាក់ទំនងដោយជោគជ័យក្នុងលក្ខខណ្ឌនៃការរក្សាគម្លាតសង្គម ជាការសំខាន់ត្រូវស្វែងយល់ថា តើកំណើនការប្រើប្រាស់នេះធ្វើឱ្យមានការផ្លាស់ប្តូរប្រតិបត្តិការរបស់ក្រុមហ៊ុនដោយប្រសិទ្ធភាពកម្រិតណា។ ក្រុមហ៊ុនចំនួនពីរភាគបី រាយការណ៍ថា គ្មានការលក់តាមបណ្តាញឌីជីថល ហើយក្នុងចំណោមក្រុមហ៊ុនដែលរាយការណ៍ពីការលក់ តាមបណ្តាញឌីជីថល ក្រុមហ៊ុនភាគច្រើនមិនកត់សម្គាល់ពីកំណើននៃការលក់តាមបណ្តាញឌីជីថលឡើយ (រូប S14, ផ្នែក c)។ មានក្រុមហ៊ុនតែ 12 ភាគរយប៉ុណ្ណោះដែលរាយការណ៍ថាបានតម្រូវឱ្យនិយោជិតមួយចំនួនធ្វើការនៅផ្ទះ ហើយក្រុមហ៊ុនភាគច្រើនក្នុងចំណោមក្រុមហ៊ុនទាំងនេះ មិនបង្កើនចំនួននិយោជិតដែលធ្វើការនៅផ្ទះឡើយ (រូប S14, ផ្នែក d)។

**កម្រិតនៃការប្រើប្រាស់បណ្តាញឌីជីថលដើម្បីឆ្លើយតបនឹងវិបត្តិជំងឺកូវីដ 19 របស់ក្រុមហ៊ុននៅកម្ពុជា ហាក់មានកម្រិតទាបជាងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់។** ទោះបីជាមានការប្រើប្រាស់បណ្តាញឌីជីថលកាន់តែច្រើនក្នុងចន្លោះខែ មិថុនា និងខែ កញ្ញា នៅទូទាំងតំបន់ក្តី ក៏កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្នុងតំបន់ដែលមានចំនួនក្រុមហ៊ុនប្រើប្រាស់ ឬបង្កើនការប្រើប្រាស់បណ្តាញឌីជីថល តិចជាងគេ ប៉ុន្តែប្រសើរជាងមីយ៉ាន់ម៉ា (រូប S15)។ ទោះជាយ៉ាងណា ក្រុមហ៊ុននៅកម្ពុជាច្រើនតែធ្វើការវិនិយោគថ្មីលើដំណោះស្រាយឌីជីថល ជាពិសេស ក្រុមហ៊ុនសេវាកម្មក្នុងពាណិជ្ជកម្មលក់ដុំ និងលក់រាយ ជាងប្រទេសភាគច្រើនផ្សេងទៀតដែលមានទិន្នន័យនេះ[53]។ នេះអាចបណ្តាលមកពីក្រុមហ៊ុននៅកម្ពុជាមិនសូវបានត្រៀមខ្លួនប្រើប្រាស់បច្ចេកវិទ្យានេះតាំងពីដំបូង ហើយក្រុមហ៊ុនជាច្រើនត្រូវធ្វើការវិនិយោគថ្មីដើម្បីចាប់ផ្តើមប្រើប្រាស់ដំណោះស្រាយឌីជីថល។ ចំណុចនេះបញ្ជាក់ពីភ័ស្តុតាងពីមុនថា ក្រុមហ៊ុននៅកម្ពុជាទើបតែចាប់ផ្តើមប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ឧទាហរណ៍ ក្នុងឆ្នាំ 2017 ក្រុមហ៊ុននៅកម្ពុជាតែ 24 ភាគរយប៉ុណ្ណោះដែលរាយការណ៍ថាមានគេហទំព័រ ខណៈដែលមេដ្យានក្រុមហ៊ុនក្នុងពិភពលោកចំនួន 47 ភាគរយមានគេហទំព័រនេះ[54]។

## 5. គោលនយោបាយចាំបាច់ដែលក្រុមហ៊ុនបានលើកឡើង

**រដ្ឋាភិបាលកំពុងប្រើប្រាស់ជម្រើសគោលនយោបាយផ្សេងៗ ដើម្បីបន្ធូរបន្ថយសម្ពាធហិរញ្ញវត្ថុលើក្រុមហ៊ុន និងគាំទ្រឱ្យក្រុមហ៊ុនមានលទ្ធភាពធ្វើអាជីវកម្មក្នុងបរិយាកាសបច្ចុប្បន្ន។** ជម្រើសគោលនយោបាយជួយគាំទ្រ រួមមាន ឧបត្ថម្ភធន (សម្រាប់ប្រាក់បៀវត្សរ៍ ឬចំណាយថេរ) ការពន្យារពេលទូទាត់ ឬការលើកលែង (ថ្លៃជួល ពន្ធ សន្តិសុខសង្គម)លទ្ធភាពទទួលបានហិរញ្ញវត្ថុ (ជំនួយឥតសំណងសម្រាប់ការវិនិយោគ កម្ចីឧបត្ថម្ភធន ការធានាឥណទាន)ការទិញដោយរដ្ឋាភិបាល ឬកំណែទម្រង់ពាណិជ្ជកម្ម។

**ក្រៅពីជួយដល់គ្រួសារ និងកម្មករនិយោជិត រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយជាច្រើនដើម្បីជួយដល់ក្រុមហ៊ុនដែលរងផលប៉ះពាល់ដោយសារវិបត្តិជំងឺកូវីដ 19។** គោលនយោបាយទាំងនោះរួមមាន ការបន្ធូរបន្ថយពន្ធសម្រាប់ក្រុមហ៊ុនក្នុងវិស័យទេសចរណ៍ និងវិស័យឧស្សាហកម្មផលិតសម្លៀកបំពាក់/ស្បែកជើង/ទំនិញធ្វើដំណើរ (រួមទាំងការលើកលែងការបង់ភាគទានថែទាំសុខភាពដល់បេឡាសន្តិសុខសង្គម ក្នុងពេលផ្អាកប្រតិបត្តិការ) ការដាក់បញ្ចូលមូលធនបន្ថែមទៅក្នុងធនាគារអភិវឌ្ឍន៍ជនបទដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃផលិតផលកសិកម្ម ការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជាដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈសហហិរញ្ញប្បទាន និងការចែករំលែកហានិភ័យជាមួយធនាគារពាណិជ្ជ ការពន្លឿនការអនុវត្តមូលនិធិអភិវឌ្ឍន៍សហគ្រិនភាពតាមរយៈ

**រូប S15៖ ការប្រើប្រាស់បណ្តាញឌីជីថលក្នុងការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ 19 នៅតំបន់អាស៊ីបូព៌ា**




*សម្គាល់ ៖ ចំនួនក្រុមហ៊ុនដែលបង្កើនការប្រើប្រាស់បណ្តាញឌីជីថល ឬធ្វើការវិនិយោគថ្មីលើបណ្តាញឌីជីថលក្នុងការអង្កេតលើកទីពីរ នៅប្រទេសកម្ពុជា និងវៀតណាម ជាការបូកសរុបចំនួនក្រុមហ៊ុនពីការអង្កេតលើកទីមួយ និងការអង្កេតលើកទីពីរ។*

53 ក្រុមហ៊ុននៅកម្ពុជាចំនួន 7 ភាគរយក្នុងវិស័យកសិឧស្សាហកម្ម ក្រុមហ៊ុន 15 ភាគរយក្នុងឧស្សាហកម្មផលិត ក្រុមហ៊ុន 31 ភាគរយក្នុងពាណិជ្ជកម្មលក់ដុំ និងលក់រាយ និងក្រុមហ៊ុន 27 ភាគរយក្នុងវិស័យសេវាផ្សេងទៀត រាយការណ៍ថាបានធ្វើការវិនិយោគថ្មីលើដំណោះស្រាយឌីជីថលនៅខែ កញ្ញា។ ក្រុមហ៊ុនសេវាកម្ម និងក្រុមហ៊ុនកសិឧស្សាហកម្ម ច្រើនតែបង្កើនការប្រើប្រាស់បណ្តាញឌីជីថល ៖ 55 ភាគរយសម្រាប់ពាណិជ្ជកម្មលក់ដុំ និងលក់រាយ, 57 ភាគរយសម្រាប់សេវាផ្សេងទៀត និង 54 ភាគរយសម្រាប់កសិឧស្សាហកម្ម និង 25 ភាគរយសម្រាប់ឧស្សាហកម្មផលិត។

54 ធនាគារពិភពលោក (ឆ្នាំ 2018)។

ការបង្កើតសហគ្រាសខ្មែរដែលជាសាខាប្រតិបត្តិរបស់មូលនិធិនេះ និងការផ្តល់ជំនួយឥតសំណងសម្រាប់គ្រាអាសន្ន ដល់សហគ្រាសធុនតូច និងមធ្យមដែលអាចដំណើរការមួយចំនួន វិធានការបញ្ចូលសន្ទនីយភាពក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការកាត់បន្ថយមូលធន និងទុនបម្រុងចាំបាច់ជាបណ្តោះអាសន្ន និងការបន្ធូរបន្ថយផ្នែកនិយ័តកម្ម និងវិធានការបង្កើនភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម និងការសម្រួលពាណិជ្ជកម្ម។

**ការពន្យារពេលបង់ពន្ធ នៅតែជាគោលនយោបាយដែលក្រុមហ៊ុននៅកម្ពុជាភាគច្រើនត្រូវការជាចាំបាច់ រួមនឹងលទ្ធភាពទទួលបានកម្ចី និងឧបត្ថម្ភធន។** ក្រុមហ៊ុនចំនួន 54 ភាគរយ ចាត់ទុកការពន្យារពេលបង់ពន្ធជាជម្រើសគោលនយោបាយមួយក្នុងចំណោមជម្រើសគោលនយោបាយ 3 ដែលត្រូវការជាចាំបាច់នៅខែ កញ្ញា (រូប S16)។ ក្រៅពីនេះ ជម្រើសគោលនយោបាយចាំបាច់រួមមាន លទ្ធភាពទទួលបានកម្ចី (លើកឡើងដោយក្រុមហ៊ុន 45 ភាគរយ) ជំនួយឥតសំណងសម្រាប់ការវិនិយោគ (លើកឡើងដោយក្រុមហ៊ុន 28 ភាគរយ) ឧបត្ថម្ភធនសម្រាប់ចំណាយថេរ (លើកឡើងដោយក្រុមហ៊ុន 16 ភាគរយ) និងឧបត្ថម្ភធនប្រាក់បៀវត្សរ៍ (លើកឡើងដោយក្រុមហ៊ុន 13 ភាគរយ)។ គួរកត់សម្គាល់ថា ខណៈដែលក្រុមហ៊ុនគ្រប់ទំហំលើកឡើងកាន់តែច្រើនពីតម្រូវការជំនួយឥតសំណងសម្រាប់ការវិនិយោគ មិនទាន់មានការផ្តល់ជំនួយឥតសំណងសម្រាប់ការវិនិយោគជាវិធានការឆ្លើយតបនឹងវិបត្តិជំងឺកូវីដ 19 នៅឡើយទេ[55]។ ក្រៅពីនេះ ក្រុមហ៊ុនមិនសូវលើកឡើងពីវិធានការគោលនយោបាយផ្សេងទៀត ដូចជា កំណែទម្រង់ពាណិជ្ជកម្ម និងការទិញដោយរដ្ឋាភិបាលនោះទេ។

**មានភាពមិនស៊ីសង្វាក់គ្នាគួរឲ្យកត់សម្គាល់រវាងតម្រូវការគោលនយោបាយ និងលទ្ធភាពទទួលបានវិធានការគោលនយោបាយទាំងនេះ។** ការពន្យារពេលបង់ពន្ធជាជម្រើសគោលនយោបាយដែលត្រូវការជាចាំបាច់ និងស្នើសុំច្រើនជាងគេ (ក្រុមហ៊ុនចំនួន 21 ភាគរយ ដាក់ពាក្យស្នើសុំពន្យារពេលបង់ពន្ធ)។ តម្រូវការកម្ចី ថយចុះបន្តិចដោយសារមានការផ្តល់ឧបត្ថម្ភធន

**រូប S16៖ ការពន្យារពេលបង់ពន្ធត្រូវបានលើកឡើងជាជម្រើសគោលនយោបាយចាំបាច់បំផុតនៅខែ កញ្ញា**




*សម្គាល់ ៖ ការអង្កេតផ្តល់ជម្រើស 10 ដល់ក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវគូសបញ្ជាក់ពីជម្រើសគោលនយោបាយ 3 ដែលត្រូវការជាចាំបាច់។*

**រូប S17៖ ភាពមិនស៊ីសង្វាក់គ្នារវាងតម្រូវការគោលនយោបាយ និងលទ្ធភាពទទួលបាន**

*a. ការពន្យារពេលបង់ពន្ធ*




*b. ឧបត្ថម្ភធន ឬជំនួយឥតសំណង*




*c. កម្ចី*




*សម្គាល់ ៖ រូបនេះបង្ហាញពីចំនួនក្រុមហ៊ុនសរុបដែលបានដឹង ឬបានដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយគាំទ្រតាំងពីពេលមានវិបត្តិជំងឺកូវីដ 19 ដំបូង រហូតដល់ខែ កញ្ញា។ រូបនេះប្រើប្រាស់បណ្តុំក្រុមហ៊ុនដែលបានឆ្លើយតបក្នុងការសម្ភាសន៍លើកទីមួយ និងលើកទីពីរ។ ប្រាក់បៀវត្សរ៍ និងជំនួយឥតសំណង រួមទាំងឧបត្ថម្ភធនសម្រាប់ចំណាយថេរ ឧបត្ថម្ភធនប្រាក់បៀវត្សរ៍ និងជំនួយឥតសំណងសម្រាប់ការវិនិយោគ។*

55 មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងសហគ្រាសខ្មែរដែលជាសាខាប្រតិបត្តិរបស់មូលនិធិនេះ បានអនុវត្តសាកល្បងការផ្តល់ជំនួយឥតសំណងខ្នាតតូចពីរលើកដល់សហគ្រាសធុនតូច និងមធ្យមចំនួន 20 ដោយផ្អែកលើផែនការអាជីវកម្មដែលអាចអនុវត្តបាន ដែលរួមទាំងមូលធនដំណើរការ និងការវិនិយោគ។

និងជំនួយឥតសំណង ប៉ុន្តែ មានគម្លាតគួរជាទីកត់សម្គាល់រវាងតម្រូវការរបស់ក្រុមហ៊ុន និងការផ្ដល់ផ្គង់ដោយរដ្ឋាភិបាល។ នៅខែ កញ្ញា មានក្រុមហ៊ុនតែ 3 ភាគរយប៉ុណ្ណោះដែលបានដាក់ពាក្យស្នើសុំកម្ចី ប៉ុន្តែ គ្មានក្រុមហ៊ុនណាមួយបានដាក់ពាក្យស្នើសុំជំនួយឥតសំណងសម្រាប់ការវិនិយោគឡើយ (ផ្ទុះបញ្ចាំងពីគោលនយោបាយរបស់រដ្ឋាភិបាលចំពោះវិធានការទាំងនេះ)។

**គម្លាតនេះមានកាន់តែច្រើនសម្រាប់ក្រុមហ៊ុនខ្នាតតូច (រូប S17)។** ការពន្យារពេលបង់ពន្ធត្រូវបានលើកឡើងច្រើនជាងគេដោយក្រុមហ៊ុនគ្រប់ទំហំ (ក្រុមហ៊ុនចំនួន 50-60 ភាគរយលើកឡើងថាចង់ឱ្យមានការពន្យារពេលបង់ពន្ធ) ប៉ុន្តែ អត្រាដាក់ពាក្យស្នើសុំពន្យារពេលបង់ពន្ធ មានកម្រិតទាបសម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ (17 ភាគរយ) និងក្រុមហ៊ុនខ្នាតតូច (13 ភាគរយ) ជាងអត្រាសម្រាប់ក្រុមហ៊ុនខ្នាតមធ្យម (30 ភាគរយ) និងក្រុមហ៊ុនខ្នាតធំ (29 ភាគរយ)។ ក្រុមហ៊ុនធំៗ (61 ភាគរយ) ត្រូវការឧបត្ថម្ភធន ឬជំនួយឥតសំណង ក្នុងទម្រង់ជាឧបត្ថម្ភធនសម្រាប់ចំណាយថេរ ឧបត្ថម្ភធនប្រាក់បៀវត្សរ៍ ឬជំនួយឥតសំណងសម្រាប់ការវិនិយោគ ជាងក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម (39-47 ភាគរយ) ប៉ុន្តែលទ្ធភាពទទួលបាន មានកម្រិតកាន់តែខ្ពស់ ដោយក្រុមហ៊ុនខ្នាតធំចំនួន 34 ភាគរយបានដាក់ពាក្យស្នើសុំឧបត្ថម្ភធន ឬជំនួយឥតសំណង ប៉ុន្តែ មានក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមតែ 2-11 ភាគរយប៉ុណ្ណោះដែលបានដាក់ពាក្យស្នើសុំឧបត្ថម្ភធន ឬជំនួយឥតសំណង។ អត្រាដាក់ពាក្យស្នើសុំកម្ចី មានកម្រិតទាបក្នុងចំណោមក្រុមហ៊ុនគ្រប់ទំហំ (ទាបជាង 10 ភាគរយ) ប៉ុន្តែ មានតម្រូវការខ្ពស់សម្រាប់ក្រុមហ៊ុនខ្នាតតូច។ ក្រុមហ៊ុនខ្នាតមីក្រូជាងពាក់កណ្ដាល ចាត់ទុកកម្ចីជាជម្រើសគោលនយោបាយដែលត្រូវការចាំបាច់បំផុត ប៉ុន្តែមានក្រុមហ៊ុនខ្នាតធំតែមួយភាគបី ប៉ុណ្ណោះដែលលើកឡើងពីតម្រូវការកម្ចី។

**ក្រុមហ៊ុនគ្រប់ប្រភេទមានលទ្ធភាពទទួលបានគោលនយោបាយគាំទ្រខុសពីគ្នា។** លទ្ធភាពនៃការយល់ដឹង និងបានដាក់ពាក្យស្នើសុំវិធានការគាំទ្រ ថយចុះទៅតាមទំហំក្រុមហ៊ុន (រូប S18)។

**រូប S18៖ ក្រុមហ៊ុនខ្នាតធំច្រើនតែបានដឹង និងដាក់ពាក្យស្នើសុំវិធានការគោលនយោបាយគាំទ្រ**




*សម្គាល់ ៖ រូបនេះបង្ហាញពីចំនួនក្រុមហ៊ុនសរុបដែលបានដឹង ឬបានដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយគាំទ្រចាប់តាំងពីពេលមានវិបត្តិជំងឺកូវីដ 19 ដំបូង រហូតដល់ខែ កញ្ញា។ រូបនេះប្រើប្រាស់បណ្ដុំក្រុមហ៊ុនដែលបានឆ្លើយតបក្នុងការសម្ភាសន៍លើកទីមួយ និងលើកទីពីរ។*

ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម មិនត្រឹមតែទទួលរងផលប៉ះពាល់ខ្លាំងជាងគេលើការលក់ប៉ុណ្ណោះទេ ប៉ុន្តែក្រុមហ៊ុនទាំងនេះថែមទាំងមិនសូវបានដឹង និងទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាលដូចក្រុមហ៊ុនខ្នាតធំទៀតផង។ គិតត្រឹមខែ កញ្ញា ខណៈដែលក្រុមហ៊ុនខ្នាតធំចំនួន 97 ភាគរយ បានដឹងពីវិធានការរបស់រដ្ឋាភិបាល ហើយក្រុមហ៊ុនខ្នាតធំចំនួន 60 ភាគរយ បានដាក់ពាក្យស្នើសុំវិធានការរដ្ឋាភិបាលយ៉ាងតិចមួយ មានក្រុមហ៊ុនខ្នាតមីក្រូចំនួន 74 ភាគរយ បានដឹងពីវិធានការរបស់រដ្ឋាភិបាល និងក្រុមហ៊ុនខ្នាតមីក្រូចំនួន 30 ភាគរយបានដាក់ពាក្យស្នើសុំវិធានការរដ្ឋាភិបាលយ៉ាងតិចមួយ។ ចំណុចនេះបង្ហាញថា ក្រុមហ៊ុនខ្នាតធំចំនួនពីរភាគបី ដែលបានដឹងពីវិធានការគាំទ្រ បានដាក់ពាក្យស្នើសុំវិធានការទាំងនោះ ប៉ុន្តែមានក្រុមហ៊ុនខ្នាតមីក្រូតែ 40 ភាគរយប៉ុណ្ណោះដែលបានដាក់ពាក្យស្នើសុំ។

**របកគំហើញដែលថា លទ្ធភាពទទួលបានការគាំទ្ររបស់រដ្ឋាភិបាលថយចុះទៅតាមទំហំក្រុមហ៊ុន មិនមែនជាករណីដោយឡែកនៅកម្ពុជានោះទេ។** ខុសពីបណ្ដាប្រទេសផ្សេងទៀតក្នុងតំបន់ កម្ពុជាមិនបានធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យមក្នុងរយៈពេល 3 ខែនៅចន្លោះខែ មិថុនា និងខែ កញ្ញា ឡើយ (តារាង S2)។ សម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ និងខ្នាតតូច ចំនួនក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីជំនួយរដ្ឋាភិបាលថយចុះនៅចន្លោះខែ មិថុនា និងខែ កញ្ញា ដោយថយពីចំនួន 21 ភាគរយ មកត្រឹម 9 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតមីក្រូ និង

**តារាង S2៖ ចំនួនក្រុមហ៊ុននៅកម្ពុជា ដែលបានដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីជំនួយរដ្ឋាភិបាល បានថយចុះ**

| ប្រទេស | ក្រុមហ៊ុនខ្នាតធំ | ក្រុមហ៊ុនខ្នាតមធ្យម | ក្រុមហ៊ុនខ្នាតតូច | ក្រុមហ៊ុនខ្នាតមីក្រូ | ក្រុមហ៊ុនទាំងអស់ |
|---|---|---|---|---|---|
| កម្ពុជា (ខែ មិថុនា) | 40% | 29% | 17% | 21% | 25% |
| កម្ពុជា (ខែ កញ្ញា) | 20% | 12% | 13% | 9% | 13% |
| មីយ៉ាន់ម៉ា (ខែ ឧសភា) | 30% | 23% | 20% | 3% | 10% |
| មីយ៉ាន់ម៉ា (ខែ កញ្ញា) | 34% | 18% | 24% | 14% | 17% |

*សម្គាល់ ៖ តួលេខនេះបង្ហាញពីចំនួនក្រុមហ៊ុនថ្មីទាំងអស់ដែលបានដឹង ឬដាក់ពាក្យស្នើសុំ ឬទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយគាំទ្រចាប់តាំងពីមានការផ្ទុះជំងឺកូវីដ 19 ដំបូង រហូតដល់ខែ កញ្ញា។ តារាងនេះប្រើប្រាស់បណ្ដុំក្រុមហ៊ុនដែលបានផ្ដល់ចម្លើយក្នុងការសម្ភាសន៍លើកទីមួយ និងលើកទីពីរ។ នៅមីយ៉ាន់ម៉ា ក្រុមហ៊ុនខ្នាតមីក្រូ ជាក្រុមហ៊ុនដែលមាននិយោជិត 1-4 នាក់, ក្រុមហ៊ុនខ្នាតតូចជាក្រុមហ៊ុនដែលមាននិយោជិត 5-9 នាក់, ក្រុមហ៊ុនខ្នាតមធ្យមជាក្រុមហ៊ុនដែលមាននិយោជិត 20-99 នាក់ និងក្រុមហ៊ុនខ្នាតធំជាក្រុមហ៊ុនដែលមាននិយោជិត 100 នាក់ឡើងទៅ។*

ថយពី 17 ភាគរយ មកត្រឹម 13 ភាគរយសម្រាប់ក្រុមហ៊ុនខ្នាតតូច។ និន្នាការនេះផ្ទុយពីនិន្នាការនៅមីយ៉ាន់ម៉ា ដែលលទ្ធភាពជារួមក្នុងការទទួលបានការគាំទ្រពីរដ្ឋាភិបាល កើនជិតទ្វេដងនៅចន្លោះខែ ឧសភា និងខែ សីហា ដោយសារការកើនឡើងនៃចំនួនក្រុមហ៊ុនខ្នាតមីក្រូ និងខ្នាតតូចគួរឲ្យកត់សម្គាល់។ នេះជាចំណុចគួរឱ្យព្រួយបារម្ភ ព្រោះក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម កាន់តែងាយប្រឈមនឹងការជំពាក់បំណុលច្រើន នៅពេលដែលក្រុមហ៊ុនទាំងនោះ មិនសូវមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ (ដូចបានលើកឡើងខាងលើ)។

**តាមការសង្កេត គម្លាតយេនឌ័រក្នុងលទ្ធភាពទទួលបានវិធានការគោលនយោបាយនៅខែ មិថុនា ហាក់ថយចុះ។** នៅខែ មិថុនា ក្រុមហ៊ុនដែលគ្រប់គ្រងដោយស្ត្រី (21 ភាគរយ) បានដឹង ឬដាក់ពាក្យស្នើសុំវិធានការរបស់រដ្ឋាភិបាល តិចជាងក្រុមហ៊ុនដែលគ្រប់គ្រងដោយបុរស (27 ភាគរយ)។ ទោះជាយ៉ាងណា ភាពខុសគ្នានេះបានបាត់ទៅវិញនៅខែ កញ្ញា។

## 6. អនុសាសន៍គោលនយោបាយ

**ជារួម ការអង្កេតលើដំណើរការអាជីវកម្មបង្ហាញថា ក្រុមហ៊ុនជាពិសេសក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម សុទ្ធតែទទួលរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមដោយសារជំងឺកូវីដ 19។** គួរកត់សម្គាល់ថា ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម ទទួលរងផលប៉ះពាល់ខ្លាំងជាងគេ និងអាចងាយរងគ្រោះកាន់តែខ្លាំងទៅមុខទៀត ព្រោះក្រុមហ៊ុនទាំងនេះមិនសូវមានសមត្ថភាពដោះស្រាយវិបត្តិផ្គត់ផ្គង់ទេ (ឧ. ធនធានសម្រាប់ការធ្វើការពីចម្ងាយ និងកែសម្រួលការរៀបចំផែនការផលិតកម្ម) និងវិបត្តិតម្រូវការ (ឧ. មិនសូវមានសាច់ប្រាក់សម្រាប់ទប់វិបត្តិ)។ ទោះជាការអង្កេតនេះមិនបង្ហាញថា ក្រុមហ៊ុនដែលគ្រប់គ្រងដោយស្ត្រីទទួលរងផលប៉ះពាល់ខ្លាំងជាងក្រុមហ៊ុនដែលគ្រប់គ្រងដោយបុរស បុគ្គលិកជាស្ត្រីទទួលរងផលប៉ះពាល់ខ្លាំងជាងបុគ្គលិកជាបុរស ព្រោះថាបុគ្គលិកជាស្ត្រីមានចំនួនច្រើនលើសលប់ក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងវិស័យកាត់ដេរ និងក្នុងឧស្សាហកម្មទេសចរណ៍។

**អ្នកតាក់តែងគោលនយោបាយត្រូវកែសម្រួលការកំណត់គោលដៅ និងការរៀបចំវិធានការ និងខិតខំធ្វើយ៉ាងណាបំពេញតម្រូវការរបស់ក្រុមហ៊ុនខ្នាតតូច និងខ្នាតមីក្រូឱ្យបានគ្រប់គ្រាន់។** វិធានការគោលនយោបាយត្រូវតែមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីអាចគ្របដណ្តប់លើក្រុមហ៊ុនផ្សេងៗ និងកែសម្រួលការកំណត់គោលដៅទៅតាមរបាយសហគ្រាសនៅកម្ពុជា។ វិធានការនេះមានសារៈសំខាន់ណាស់ ព្រោះកម្ពុជាមាន “ផ្នែកកណ្តាល” ដោយសហគ្រាសធុនមធ្យមមានចំនួនតែ 1.3 ភាគរយនៃចំនួនសហគ្រាសសរុប 500,000 សហគ្រាស (ជំរឿនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ 2011)។ សហគ្រាសដែលគ្រប់គ្រងដោយជនជាតិខ្មែរ មិនអាចអភិវឌ្ឍន៍ខ្លួនពីសហគ្រាសធុនមីក្រូ និងតូច ទៅជាសហគ្រាសធុនមធ្យម និងធំ ដែលមានភាពប្រកួតប្រជែងបានឡើយ ដោយសារតែគម្លាតផលិតភាពខ្ពស់។ ជំងឺកូវីដ 19 នឹងបង្កើនគម្លាតនេះបន្ថែមទៀត ប្រសិនបើរដ្ឋាភិបាលមិនផ្តោតការយកចិត្តទុកដាក់លើការកែលម្អផលិតភាពរបស់សហគ្រិន និងក្រុមហ៊ុនខ្នាតតូចទេនោះ។

**ក្រៅពីនេះ ការអង្កេតក៏បង្ហាញថា ស្ថានភាពនេះអាចវិវឌ្ឍន៍យ៉ាងលឿន (ប្រសើរ ឬមិនប្រសើរ) ដែលជាបញ្ហាប្រឈមមួយទៀតសម្រាប់អ្នកតាក់តែងគោលនយោបាយ ក្នុងការរៀបចំកម្មវិធីដោះស្រាយគ្រាអាសន្ន និងកម្មវិធីស្តារឡើងវិញ។** ចម្លើយតបក្នុងការអង្កេតលើដំណើរការអាជីវកម្ម មានភាពខុសគ្នាយ៉ាងខ្លាំងនៅចន្លោះខែ កក្កដា និងខែ កញ្ញា ដោយសារស្ថានភាពជំងឺកូវីដ 19 មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ បទពិសោធន៍ក្នុងប្រទេសជិតខាងបង្ហាញថា វីរុសក្លាយណាអាចឆ្លងរាលដាលជាថ្មី និងឈានដល់ការហាមឃាត់ការចេញចូលបន្ថែមទៀត ដែលបង្កផលប៉ះពាល់យ៉ាងខ្លាំងលើអាជីវកម្ម។ ក្រៅពីនេះ ប្រសិនបើមានការបញ្ជាក់ពីការឆ្លងផុតពីវិបត្តិឆ្ពោះទៅរកការស្តារឡើងវិញ គោលនយោបាយរដ្ឋាភិបាលត្រូវបង្វែរការយកចិត្តទុកដាក់ផ្តោតលើការគាំទ្រដល់ការកែសម្រួលចាំបាច់ ដើម្បីធានាវឌ្ឍនភាពក្នុងពិភពដែលមានការផ្លាស់ប្តូរ គាំទ្រការបង្កើតការងារ និងរក្សាសហគ្រាសដែលជួយដល់កំណើន។ ចំណុចនេះអាចពាក់ព័ន្ធនឹងការគ្រប់គ្រងការកំណត់រចនាសម្ព័ន្ធហិរញ្ញវត្ថុឡើងវិញ ការដោះស្រាយបំណុល និងភាពក្ស័យធន។ ដោយសារតែអាចមានការប្រែប្រួលឥរិយាបថរបស់អ្នកប្រើប្រាស់ ក្រុមហ៊ុនខ្នាតមីក្រូ តូច និងមធ្យម ត្រូវការការគាំទ្រដើម្បីកែសម្រួលគំរូអាជីវកម្មទៅតាមបរិយាកាសសេដ្ឋកិច្ចក្រោយវិបត្តិ ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាពាណិជ្ជកម្ម fintech និងពាណិជ្ជកម្មអេឡិចត្រូនិកកាន់តែប្រសើរ។

**ទោះជានិន្នាការមួយចំនួន ហាក់លេចឡើងច្បាស់នាពេលបច្ចុប្បន្ន នៅតែមានភាពមិនប្រាកដប្រជាចំពោះស្ថានភាពរបស់ពិភពលោកក្រោយវិបត្តិជំងឺកូវីដ 19។** ទោះជាជំងឺកូវីដ 19 បានពន្លឿននិន្នាការមួយចំនួនដែលមានពីមុន (ឧ. កំណើនឌីជីថលនីយកម្ម) ភាពមិនច្បាស់លាស់គឺថាតើផលប៉ះពាល់មួយចំនួននឹងមានរយៈពេលយូរប៉ុណ្ណា (ឧ. ការថយចុះតម្រូវការនៃការធ្វើដំណើរការតាមផ្លូវអាកាស បដិសណ្ឋារកិច្ច និងវិស័យទេសចរណ៍)។ ការរកឃើញឆាប់ៗ និងការចែកចាយថ្នាំព្យាបាល និង/ឬវ៉ាក់សាំងជំងឺកូវីដ 19 យ៉ាងទូលំទូលាយ នឹងជួយពន្លឿនការស្តារឡើងវិញនៅទូទាំងពិភពលោក។ ម៉្យាងវិញទៀត ប្រសិនបើការស្តារឡើងវិញជាសកលអាស្រ័យលើនិរន្តរភាពនៃការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នៅតាមប្រទេសទាំងឡាយ ផលប៉ះពាល់អាចកាន់តែយូរអង្វែង និងមានរបាយមិនស្មើគ្នា ដែលជាកង្វល់ចំពោះភស្តុភារអន្តរជាតិ និងសង្វាក់ផ្គត់ផ្គង់។

**ក្នុងបរិយាកាសមិនប្រាកដប្រជានេះ ជាការសំខាន់ រដ្ឋាភិបាលត្រូវបង្កើតក្របខណ្ឌគ្រប់គ្រាន់ និងសមត្ថភាពអនុវត្តន៍គោលនយោបាយរបស់ខ្លួន។** ឧបករណ៍គោលនយោបាយដែលមានស្រាប់មិនត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិបត្តិខាងក្រៅ ដូចជាការរាតត្បាតនៃ ជំងឺកូវីដ 19 នោះទេ។ អ្នកតាក់តែងគោលនយោបាយគួរបង្កើតឧបករណ៍ថ្មី និងកែសម្រួលសមត្ថភាពអនុវត្តន៍គោលនយោបាយ និងកម្មវិធីគាំទ្រក្រុមហ៊ុន ដើម្បី

បង្កើនលទ្ធភាពឱ្យក្រុមហ៊ុនអាចបន្តប្រតិបត្តិការបាន និងបង្កើនការសម្របក្រុមហ៊ុន និងវិស័យដែលមានសក្តានុពលកំណើនទៅនឹងបរិយាកាសសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ 19។ ចំណុចនេះទាមទារឲ្យមានការបង្កើតស្ថាប័នដែលមានដំណើរការប្រកបដោយតម្លាភាព អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពប្រតិបត្តិការ។

**កម្ពុជាបានចាប់ផ្តើមបង្កើត និងពង្រឹងស្ថាប័ន និងកម្មវិធីសំខាន់ៗជាច្រើនដែលអាចទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យឯកជន។** គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងពន្លឿនការដាក់ឱ្យដំណើរការនូវគម្រោងគាំទ្រជាច្រើនទៀតសម្រាប់សហគ្រាស ដែលសម្រួលលទ្ធភាពទទួលបានកម្ចី និងជំនួយឥតសំណងសម្រាប់គ្រាអាសន្ន ដូចជា សាជីវកម្មធានាឥណទានកម្ពុជា គម្រោងសហហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម ដែលគ្រប់គ្រងដោយធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងការផ្តល់ការគាំទ្រដល់ការបង្កើតអាជីវកម្មថ្មី និងសហគ្រាសធុនតូច និងមធ្យម តាមរយៈមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងសហគ្រិនខ្មែរដែលជាសាខាប្រតិបត្តិរបស់មូលនិធិនេះ។

### លទ្ធភាពទទួលបានហិរញ្ញវត្ថុ

**រដ្ឋាភិបាលកម្ពុជាបានតាក់តែងគោលនយោបាយថ្មីដោយផ្តោតការយកចិត្តទុកដាក់លើការសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនខ្នាតធំ និងក្រុមហ៊ុនខ្នាតតូច និងមធ្យម។** រាជរដ្ឋាភិបាលកម្ពុជា បានបើកគម្រោងសហហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម ដែលគ្រប់គ្រងដោយធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ដែលទើបតែបានបង្កើតឡើង។ កម្មវិធីនេះមានគោលបំណងផ្តល់ឥណទានដែលមានអត្រាការប្រាក់ទាប តាមរយៈសហហិរញ្ញប្បទានស្មើគ្នាដោយធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ដោយសារតែធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ទើបតែត្រូវបានបង្កើតឡើង ធនាគារនេះត្រូវធ្វើការកសាងផ្នែកស្ថាប័នជាច្រើន ដើម្បីអាចប្រតិបត្តិការពេញលេញ។ ធនាគារនេះមានគោលបំណងកាត់បន្ថយបញ្ហា លើលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលជាបញ្ហាប្រឈមកើតមានតាំងពីមុនពេលមានវិបត្តិជំងឺកូវីដ 19 ដោយសារតែហានិភ័យខ្ពស់ ការតម្រូវឱ្យមានទ្រព្យបញ្ចាំ និងគ្មានកំណត់ត្រាសមស្រប។

**រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតសាជីវកម្មធានាឥណទានកម្ពុជា។** សាជីវកម្មធានាឥណទានកម្ពុជាមានគោលដៅបង្កើនឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈការកាត់បន្ថយហានិភ័យឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុជាពិសេស ក្នុងបរិបទនៃវិបត្តិជំងឺកូវីដ 19។ សាជីវកម្មធានាឥណទានកម្ពុជាមានគោលបំណងបង្កើនការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈគ្រឹះស្ថានហិរញ្ញវត្ថុដោយកាត់បន្ថយការបង្វែរហានិភ័យខ្ពស់ ការតម្រូវឱ្យមានទ្រព្យបញ្ចាំ និងព័ត៌មាន ដែលជាបញ្ហាប្រឈមរបស់គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាក្នុងការផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម។ ជាផ្នែកមួយនៃកម្មវិធីស្តារសេដ្ឋកិច្ចរបស់រដ្ឋាភិបាល សាជីវកម្មធានាឥណទានកម្ពុជាផ្តោតការយកចិត្តទុកដាក់លើការគាំទ្រឱ្យសហគ្រាសធុនតូច និងមធ្យមបន្តប្រតិបត្តិការក្នុងអំឡុងវិបត្តិជំងឺកូវីដ 19 ក៏ដូចជាស្តារឡើងវិញ និងធ្វើពិពិធកម្មនៅដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ 19។

**ទោះជាវិធានការគោលនយោបាយដែលសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ក្តី រដ្ឋាភិបាលក៏ត្រូវកត់សម្គាល់ថា ជាក់ស្តែង វិធានការទាំងនេះ អាចផ្តល់អត្ថប្រយោជន៍ភាគច្រើនដល់តែក្រុមហ៊ុនខ្នាតធំ និងវិស័យផ្លូវការ។** ឧទាហរណ៍ ការពង្រីកការគាំទ្ររបស់រដ្ឋាភិបាលក្នុងទម្រង់ជាការបញ្ចូលឥណទានតាមរយៈកម្ចីសម្បទាន អាចធ្វើឱ្យមានការផ្តល់ជំនួយមិនសមាមាត្រគ្នាដល់ក្រុមហ៊ុនខ្នាតធំ ឬក្រុមហ៊ុនខ្នាតមធ្យមដែលរឹងមាំ ព្រោះថា ក្រុមហ៊ុនទាំងនេះអាចទទួលបានឥណទានពីប្រព័ន្ធធនាគារ លើកលែងតែរដ្ឋាភិបាលអនុវត្តលក្ខណវិនិច្ឆ័យតឹងរ៉ឹងសម្រាប់ជួយដល់សហគ្រាសធុនតូច និងមធ្យម ជាពិសេសសហគ្រាសធនតូច និងមធ្យមដែលមិនប្រើប្រាស់ប្រព័ន្ធធនាគារ។ ក្រុមហ៊ុនខ្នាតធំក៏មានតួនាទីសំខាន់ក្នុងការបង្កើតការងារដែលមានផលិតភាពខ្ពស់ រួមទាំង ការងារក្នុងវិស័យសំខាន់ៗដែលផ្តោតលើការនាំចេញ។ ទោះជាយ៉ាងណាក៏ដោយ ការគាំទ្ររបស់រដ្ឋាភិបាលក្នុងការសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យម នៅតែមានតួនាទីសំខាន់ ព្រោះថាការថយចុះនៃតារាងតុល្យការរបស់ក្រុមហ៊ុន នឹងបង្កើនការបញ្ចៀសហានិភ័យក្នុងវិស័យហិរញ្ញវត្ថុនៅពេលពង្រីកការផ្តល់ឥណទានថ្មី។

### ការបញ្ចូលសាច់ប្រាក់ និងការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម

**ក្រុមហ៊ុនខ្នាតតូចដែលមិនមានលទ្ធភាពទទួលបានសេវាក្នុងវិស័យហិរញ្ញវត្ថុធម្មតា (សហគ្រាសធុនតូច និងមធ្យមដែលមិនប្រើប្រាស់ប្រព័ន្ធធនាគារ) អាចទទួលបានអត្ថប្រយោជន៍ពីជំនួយឥតសំណង និងការកាត់បន្ថយចំណាយ។** ផ្អែកតាមបរិបទប្រទេស អត្ថប្រយោជន៍ទាំងនេះអាចមានទម្រង់ជាការបញ្ចូលសាច់ប្រាក់មួយចំនួនតូច ឬការកែសម្រួលលក្ខខណ្ឌជំនួយឥតសំណង។ សហគ្រាសធុនតូច និងមធ្យមដែលមានលទ្ធភាពទទួលបានសេវាក្នុងវិស័យហិរញ្ញវត្ថុ និង/ឬត្រូវបានបញ្ចូលទៅក្នុងសេដ្ឋកិច្ច តាមរយៈ សង្វាក់តម្លៃ អាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍ការនាំចេញ ឬកម្មវិធីអភិវឌ្ឍន៍ក្រុមហ៊ុនផ្គត់ផ្គង់។ ក្រុមហ៊ុនធំៗអាចត្រូវបានជំរុញឱ្យជួយគាំទ្រក្រុមហ៊ុនខ្នាតមីក្រូតូច និងមធ្យមក្នុងសង្វាក់ផ្គត់ផ្គង់របស់ខ្លួន ដូចជា តាមរយៈការជួយដល់ដៃគូជាមួយក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុក តាមរយៈកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច កម្មវិធីផ្តល់ឥណទាន (credit line) ការធានាឥណទាន និងការកាត់បន្ថយ ឬពន្យារពេលបង់ពន្ធនាំចូល។

**ទៅមុខទៀត ក្នុងបរិយាកាសស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ 19 ចាំបាច់ត្រូវមានការកំណត់គោលបំណងនៃផលិតកម្ម និងមធ្យោបាយផ្តល់ផលិតផល/សេវាឡើងវិញ ការសម្របទៅនឹងទីផ្សារថ្មី និងការវិនិយោគលើនវានុវត្តន៍ ប៉ុន្តែ វិធានការ**

**ប្រអប់ ៦៣៖**

## កិច្ចការពារសង្គម/គោលនយោបាយសម្រាប់សហគ្រាសគ្រួសារក្រៅពីកសិកម្ម

សហគ្រាសគ្រួសារក្រៅពីកសិកម្មភាគច្រើនជាកម្លាំងពលកម្មដែលមិនសូវទទួលបានការគាំទ្រនៅក្នុងគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាល ហើយជាក់ស្តែង វិបត្តិជំងឺកូវីដ 19 កាន់តែធ្វើឲ្យសហគ្រាសគ្រួសារក្រៅពីកសិកម្មត្រូវបានផាត់ចេញពីក្របខណ្ឌគោលនយោបាយរួម។ សសរស្តម្ភ 3 នៃគោលនយោបាយជាការចាំបាច់ដើម្បីជួយអភិវឌ្ឍ និងការពារសហគ្រាសគ្រួសារ។

**ជួយ ៖** គោលនយោបាយ និងអន្តរាគមន៍ដើម្បីបង្កើនផលិតភាពរបស់សហគ្រាសគ្រួសារយ៉ាងច្រើនលើសលប់។

មិនមែនអាជីវកម្មទាំងអស់សុទ្ធតែមានបំណង ឬមានសមត្ថភាពក្លាយជាប្រភពផ្តល់ការងារឡើយ។ ទោះជាយ៉ាងណាក៏ដោយ អន្តរាគមន៍អាចមានទិសដៅបង្កើនផលិតភាពរបស់អាជីវកម្មទាំងនោះ។ ការវិភាគបង្ហាញថា អន្តរាគមន៍ដែលអាចទទួលបានជោគជ័យរួមមាន ការបង្រៀនចិត្តសង្គមកម្រិតខ្ពស់ ផ្តត់គំនិតសហគ្រិនភាព ការធ្វើអាជីវកម្មកាន់តែប្រសើរ បច្ចេកវិទ្យាចល័ត និងឌីជីថលសម្រាប់ការប្រើប្រាស់ ដើម្បីឲ្យមានផលិតភាព និងអន្តរាគមន៍ដែលជួយភ្ជាប់ទៅនឹងទីផ្សារ និងសង្វាក់តម្លៃកម្រិតខ្ពស់។

ការអនុវត្តអន្តរាគមន៍នេះត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន តាមរបៀប និងក្នុងទម្រង់ដែលសមស្របសម្រាប់សហគ្រិន។ ឧទាហរណ៍ ការបណ្តុះបណ្តាលក្នុងថ្នាក់ជាច្រើនសប្តាហ៍ប្រហែលជាមិនអាចធ្វើទៅបានឡើយ ព្រោះសកម្មភាពនេះធ្វើឱ្យខាតបង់ប្រាក់ចំណូល និងពេលវេលាសម្រាប់កិច្ចការថែទាំ និងកិច្ចក្នុងគ្រួសារ ដោយជាញឹកញាប់ ម្ចាស់អាជីវកម្មត្រូវធ្វើកិច្ចការជាច្រើន។ ក្រៅពីនេះ ប្រហែលជាត្រូវមានគ្រឿងលើកទឹកចិត្តបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យវគ្គបណ្តុះបណ្តាលមានភាពទាក់ទាញចំពោះពួកគេ។

**អភិវឌ្ឍ ៖** កំណត់រកសហគ្រិនដែលមានសក្តានុពលកំណើនខ្ពស់ និងជួយឱ្យពួកគេមានភាពរីកចម្រើន។

អាចមានសហគ្រិនមួយចំនួន ដែលមានសក្តានុពលអភិវឌ្ឍខ្លួនយ៉ាងឆាប់រហ័ស ប្រសិនបើទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងក្រៅពីហិរញ្ញវត្ថុសមស្រប។ ការវាយតម្លៃជាច្រើនលើមីក្រូឥណទាន និងកម្មវិធីគាំទ្រពាក់ព័ន្ធ រកឃើញថា ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងក្រៅពីហិរញ្ញវត្ថុ ពិតជាអាចជំរុញសហគ្រិន “ដែលមានចំណាប់អារម្មណ៍ខ្លាំង” នៅគ្រប់ដំណាក់កាលរីកលូតលាស់។ ទោះជាយ៉ាងណាក៏ដោយ គេពិបាកនឹងកំណត់សហគ្រិន “ដែលមានចំណាប់អារម្មណ៍ខ្លាំង” ទាំងនេះជាមុនណាស់។ វិធីដ៏ល្អមួយគឺត្រូវមានប្រព័ន្ធសមស្របមួយ ដែលសហគ្រិនខ្នាតមីក្រូអាចចូលរួមប្រជែងយកជំនួយសាច់ប្រាក់ឥតសំណងជាច្រើន និងការគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

**ការពារ ៖** គោលនយោបាយត្រូវផ្តល់ការការពារគ្រប់គ្រាន់ដល់សហគ្រិនខ្នាតមីក្រូ។

ជំងឺកូវីដ 19 ធ្វើឱ្យម្ចាស់សហគ្រាសគ្រួសារក្រៅពីកសិកម្មងាយរងគ្រោះ ព្រោះពួកគេជាអនុក្រុមមួយដែលទទួលរងផលប៉ះពាល់ខ្លាំងជាងគេដោយសារការថយចុះប្រាក់ចំណូលក្នុងអំឡុងពេលមានវិបត្តិជំងឺកូវីដ 19។ សហគ្រាសទាំងនេះគ្មានការធានារ៉ាប់រងសង្គមដើម្បីការពារខ្លួនក្នុងគ្រាលំបាកឡើយ។ ជាទូទៅ សហគ្រាសទាំងនេះគ្មានលក្ខណៈសម្បត្តិទទួលបានជំនួយសង្គមទេ ព្រោះថាសហគ្រាសទាំងនេះមានដំណើរការល្អក្នុងស្ថានភាពធម្មតា។ ជម្រើសគោលនយោបាយអាចរួមមាន ៖

**ការការពារពីវិបត្តិផ្សេងៗ ៖** ការពង្រីកការធានារ៉ាប់រងសង្គមឱ្យគ្របដណ្តប់លើវិស័យក្រៅប្រព័ន្ធ ការផ្តល់ការលើកទឹកចិត្តឱ្យសហគ្រាសគ្រួសារក្រៅពីកសិកម្មចូលរួមក្នុងគម្រោងធានារ៉ាប់រងសង្គម។

**ការការពារពីបណ្តុំវិបត្តិដែលពាក់ព័ន្ធគ្នា ៖** ការពង្រីកការចុះបញ្ជីសង្គម (ការចុះបញ្ជី IDP) ឱ្យគ្របដណ្តប់លើប្រជាជនជាច្រើនដោយមានព័ត៌មានលម្អិតស្តីពីប្រភពប្រាក់ចំណូល និងការងារ ការអនុវត្តកម្មវិធីការពារសង្គមដែលមានភាពបត់បែន ដែលផ្តល់ជំនួយសង្គមដល់អ្នកដែលរងផលប៉ះពាល់ដោយសារវិបត្តិធំៗ (ឧទាហរណ៍ សហគ្រាសកសិករក្រៅពីកសិកម្មក្នុងអំឡុងវិបត្តិជំងឺកូវីដ 19)។

*ប្រភព ៖ Cunningham និង Shreshta (ឆ្នាំ 2020)*

**ទាំងនេះមានហានិភ័យ និងត្រូវមានការវិនិយោគយ៉ាងច្រើន។** ដើម្បីផលិត និងនាំចេញផលិតផលថ្មី សម្របទៅនឹងទីផ្សារថ្មី ឬដើម្បីសម្រេចគោលបំណងទាំងពីរនេះ ក្រុមហ៊ុនត្រូវកំណត់រកទីផ្សារគោលដៅសមស្រប ចំណែកផលិតផល និងបណ្តាញលក់ កែសម្រួលផលិតផលរបស់ខ្លួន ធ្វើយុទ្ធនាការទីផ្សារ និងលក់ ជួលបុគ្គលិកថ្មី ដើម្បីត្រៀមខ្លួនធ្វើកិច្ចការទាំងនេះ និងទទួលបានការបញ្ជាក់គុណភាព និងស្តង់ដារចាំបាច់។ សកម្មភាពទាំងនេះតម្រូវឲ្យមានការវិនិយោគយ៉ាងច្រើន ដោយមានលទ្ធផលមិនច្បាស់លាស់ ដូច្នេះ ជាញឹកញាប់ មិនទទួលបានហិរញ្ញប្បទានពីប្រភពផ្តល់ហិរញ្ញប្បទានធម្មតា ដូចជា ធនាគារពាណិជ្ជទេ។

**ដោយមើលឃើញបញ្ហាប្រឈមនេះ ប្រទេសជាច្រើនកំពុងអនុវត្តកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូចសម្រាប់ក្រុមហ៊ុន ដើម្បីបង្កើនសមត្ថភាពផលិតភាពរបស់ក្រុមហ៊ុនទាំងនោះ និងពន្លឿនដំណើរការស្តារសេដ្ឋកិច្ចឡើងវិញ។** នៅក្នុងកម្មវិធីប្រភេទនេះ ក្រុមហ៊ុនដែលត្រូវបានកំណត់ថាមានផែនការវិនិយោគដែលអាចអនុវត្តបាន អាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូចដើម្បីរ៉ាប់រងការចំណាយពាក់ព័ន្ធនឹងការវិនិយោគ។ កម្មវិធីនេះរួមមានអនុសាសន៍លើការវិភាគធុរកិច្ច ផ្នែកទន់ (ជំនួយបច្ចេកទេសលើការបណ្តុះបណ្តាលជំនាញបច្ចេកទេស ជំនាញគ្រប់គ្រង ការអនុលោមតាមបទដ្ឋានអន្តរជាតិ។ល។) និងអនុសាសន៍ផ្នែករឹង (លទ្ធកម្មគ្រឿងម៉ាស៊ីន បរិក្ខារ។ល។)។ ដំណាក់កាលនៃកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច អាចត្រូវបានបំពេញបន្ថែមដោយកម្មវិធីផ្គូរផ្គងដែលក្រុមហ៊ុនអាចទំនាក់ទំនងទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងការរ៉ាប់រងការរួមចំណែករបស់គ្រឹះស្ថានទាំងនោះ។

### ការគាំទ្រក្រុមហ៊ុនខ្នាតមីក្រូ

**ជាទូទៅ រដ្ឋាភិបាលគួរកំណត់គោលដៅលើក្រុមហ៊ុនតូចៗ និងគ្រប់គ្រងដោយម្ចាស់តែម្នាក់ (ឧទាហរណ៍ មាននិយោជិតតិចជាង 5 នាក់) ដែលភាគច្រើនផ្តល់ការងារ តាមរយៈកិច្ចការពារសង្គម ជំនួយឥតសំណង ដំណោះស្រាយមីក្រូហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ Fintech [56]។** ការងារក្រៅពីសិកម្មមានចំនួនយ៉ាងច្រើនក្នុងវិស័យក្រៅប្រព័ន្ធ។អាជីវកម្មក្រៅផ្លូវការយ៉ាងច្រើនលើសលប់គ្មាន ឬមាននិយោជិតតិចដែលទទួលបានប្រាក់ឈ្នួល មានផលិតភាពទាប មិនភ្ជាប់នឹងសេដ្ឋកិច្ចក្នុងប្រព័ន្ធ លើកលែងតែតាមរយៈការទូទាត់ថ្លៃទឹក/ភ្លើង និងថ្លៃជួល និងពឹងផ្អែកខ្លាំងលើបណ្តាញសង្គម និងការផ្តល់ហិរញ្ញប្បទានតាមសហគមន៍។ អាចប្រើប្រាស់ជំនួយឥតសំណងមួយលើក ប៉ុន្តែ មិនគួរធ្វើឱ្យមានលក្ខណៈផ្លូវការសម្រាប់ការបង់ពន្ធនោះទេ ព្រោះអាចមានការប្រើប្រាស់តិចតួច។ ការទាញប្រយោជន៍ពីឧបករណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុ fintech ឬទីផ្សារថ្មីៗដើម្បីផ្តល់សន្ទនីយភាពដល់តួអង្គក្រៅផ្លូវការ និងក្រុមហ៊ុនខ្នាតមីក្រូ អាចផ្តល់លទ្ធភាពថ្មីក្នុងការទទួលបានហិរញ្ញវត្ថុ(សូមមើលប្រអប់ S3 ស្តីពីការពិភាក្សាពីគោលនយោបាយដែលគាំទ្រការអភិវឌ្ឍវិស័យ សហគ្រាសគ្រួសារក្រៅពីកសិកម្ម)។

### ភាពក្ស័យធន អសោធនភាព និងបរិយាកាសអាជីវកម្ម

**ចុងក្រោយ រដ្ឋាភិបាលអាចពន្លឿនការធ្វើកំណែទម្រង់បរិយាកាសធុរកិច្ចនៅកម្ពុជា។** សម្រាប់ភាពងាយស្រួលក្នុងការធ្វើធុរកិច្ច កម្ពុជាសម្រេចបានវឌ្ឍនភាពតិចជាងប្រទេសផ្សេងៗ។ ផ្នែកដែលត្រូវកែលម្អរួមមាន ការពង្រឹងការអនុវត្តតាមកិច្ចសន្យា ការដោះស្រាយអសោធនភាព ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងលិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីទ្រព្យសម្បត្តិ និងការការពារវិនិយោគិនភាគតិច។ ក្រៅពីនេះ កម្ពុជាអាចពង្រឹងបរិយាកាសវិនិយោគបន្ថែមទៀត តាមរយៈការធានាការពារវិនិយោគិន។ ការរៀបចំការលើកទឹកចិត្តសមស្របអាចជួយឱ្យកម្ពុជាទាញប្រយោជន៍ពីចំណេះដឹងពីបរទេស និងសម្របសម្រួលការផ្ទេរផលិតភាព។ ដើម្បីអនុវត្តបរិយាកាសធុរកិច្ចពហុវិស័យ និងរបៀបវារៈកំណែទម្រង់បរិយាកាសវិនិយោគដែលពាក់ព័ន្ធនឹងអាជ្ញាធរ និងក្រសួងចម្រុះ ចាំបាច់ត្រូវមានយន្តការសម្របសម្រួលដើម្បីធានាថា ស្ថាប័នទាំងអស់សហការគ្នាដើម្បីសម្រេចគោលដៅរួម។ ក្នុងស្ថានភាពបន្ទាន់នេះ ត្រូវមានគម្រោង ឬតួអង្គកំណែទម្រង់ច្បាស់លាស់មួយដែលមានអំណាចនយោបាយដើម្បីធានាឲ្យមានការអនុវត្តកំណែទម្រង់ទាំងនោះ។

**ការកែសម្រួលនីតិវិធីពាក់ព័ន្ធនឹងភាពក្ស័យធន និងអសោធនភាព អាចក្លាយជាចំណុចអាទិភាព។** ការថយចុះតម្លៃទ្រព្យសកម្មនឹងបង្កើនហានិភ័យអសោធនភាពសម្រាប់ក្រុមហ៊ុនជាច្រើន និងបង្កផលប៉ះពាល់អវិជ្ជមានលើទីផ្សារឥណទានសង្វាក់ផ្គត់ផ្គង់ និងផលិតភាពរបស់កម្មករដែលនឹងបាត់បន្តិចម្តងៗ។ រដ្ឋាភិបាលអាចត្រៀមខ្លួនសម្រាប់ការស្តារឡើងវិញដោយបង្កើតបរិយាកាសអំណោយផលដើម្បីកែសម្រួលរចនាសម្ព័ន្ធបំណុល និងក្រុមហ៊ុន រួមទាំង តាមរយៈការពង្រឹងក្របខណ្ឌស្តីពីអសោធនភាព និងដំណោះស្រាយ និងក្របខណ្ឌច្បាប់សម្រាប់ការកែសម្រួលរចនាសម្ព័ន្ធបំណុលសាជីវកម្ម និងបំណុលរបស់អ្នកប្រើប្រាស់ និងការផ្សះផ្សារក្រៅប្រព័ន្ធតុលាការ និងវិធានការដោះស្រាយ។ វិធានការដោះស្រាយនេះមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការកើនឡើងនៃអសោធនភាព ការជម្រះបញ្ជីដែលបំផ្លាញតម្លៃ និងការលក់ឡៃឡុងទ្រព្យសម្បត្តិ ដើម្បីជួយរក្សាការងារ។

**ជារួម គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ក្រុមហ៊ុន អាចមានជម្រើសជាច្រើនដែលពាក់ព័ន្ធគ្នាទៅវិញទៅមក និងអាចអនុវត្តជាជំហានៗ។** ជម្រើសគោលនយោបាយខាងលើគ្របដណ្តប់លើឧបករណ៍ហិរញ្ញប្បទានជាច្រើន ដូចជា បទប្បញ្ញត្តិស្តីពីកម្ចីសម្បទាន ការធានាឥណទាន ជំនួយឥតសំណងខ្នាតតូច ឬកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច ដើម្បីលើកទឹកចិត្តឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម បន្តប្រតិបត្តិការ និងធ្វើការវិនិយោគ ដើម្បីសម្របទៅនឹងស្ថានភាពក្រោយវិបត្តិជំងឺកូវីដ 19។ ជម្រើសគោលនយោបាយទាំងនេះ ផ្អែកតាមទំហំសារពើពន្ធរបស់កម្ពុជា ក្នុងការដោះស្រាយផលប៉ះពាល់នៃវិបត្តិនេះលើវិស័យឯកជន និងផ្អែកតាមអត្ថិភាពនៃវិបត្តិសេដ្ឋកិច្ច ក៏ដូចជា សមត្ថភាពរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងស្ថាប័នក្នុងការអនុវត្តកម្មវិធីគាំទ្រប្រកបដោយប្រសិទ្ធភាព។

[56] នេះជាបណ្តុំរងនៃក្រុមហ៊ុនខ្នាតមីក្រូនៅកម្ពុជា ដែលត្រូវបានកំណត់ជាក្រុមហ៊ុនដែលមាននិយោជិតតិចជាង 10 នាក់។

# ឯកសារយោង

Cunningham, W., and M. Shrestha (2020). "Non-farm Household Enterprises in Cambodia: Moving out of the policy shadow." World Bank, Washington, D.C.

World Bank (2018). Benefitting from the Digital Economy: Cambodia policy note. Washington, D.C.: World Bank Group.

World Bank (2020a). Cambodia Economic Update: Cambodia in the time of COVID-19. Washington, D.C.: World Bank Group.

World Bank (2020b). East Asia and Pacific Economic Update: From containment to recovery. Washington, D.C.: World Bank Group.

# ឧបសម្ព័ន្ធ

**តារាង A.S1៖ របាយសំណាក**

| | ក្រុមហ៊ុនខ្នាតមីក្រូ | ក្រុមហ៊ុនខ្នាតតូច | ក្រុមហ៊ុនខ្នាតមធ្យម | ក្រុមហ៊ុនខ្នាតធំ |
|---|---|---|---|---|
| បាត់ដំបង | 3.80% | 2.66% | 1.99% | 0.85% |
| កំពង់ចាម | 2.47% | 1.99% | 1.33% | 0.95% |
| កណ្ដាល | 1.71% | 1.14% | 0.85% | 1.23% |
| ទីក្រុងភ្នំពេញ | 23.06% | 12.43% | 12.24% | 11.39% |
| សៀមរាប | 7.87% | 4.36% | 4.27% | 3.42% |

**រូប A.S1៖ និន្នាការចល័តភាព Google ក្នុងខេត្តសៀមរាប មិនមានភាពប្រសើរឡើងវិញទេ ធៀបនឹងចល័តភាពទូទាំងប្រទេសកម្ពុជា**

*a. ប្រទេសកម្ពុជា*




*b. ខេត្តសៀមរាប*




*ប្រភព ៖ របាយការណ៍ស្តីពីចល័តភាពក្នុងសហគមន៍ក្នុងអំឡុងវិបត្តិជំងឺកូវីដ 19*

# ឧបសម្ព័ន្ធ ៖ សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា

| | 2017 | 2018 | 2019e | 2020p | 2021f | 2022f |
|---|---|---|---|---|---|---|
| **ទិន្នផល និងកំណើនសេដ្ឋកិច្ច** | | | | | | |
| កំណើន ផសស ពិត គិតត្រឹមតម្លៃទីផ្សារថេរ (% ប្រចាំឆ្នាំ) | 7.0 | 7.5 | 7.1 | -2.0 | 4.0 | 5.2 |
| ការប្រើប្រាស់ដោយឯកជន | 3.7 | 3.0 | 7.0 | -1.4 | 3.4 | 4.7 |
| ការប្រើប្រាស់ដោយរដ្ឋាភិបាល | 23.5 | 5.1 | 10.0 | 6.7 | 8.6 | 5.8 |
| ការវិនិយោគមូលធនថេរសរុប | 6.1 | 6.1 | 6.9 | 6.3 | 6.1 | 7.1 |
| ការនាំចេញ ៖ ទំនិញ និងសេវា | 5.3 | 5.3 | 7.8 | -12.6 | 5.4 | 5.4 |
| ការនាំចូល ៖ ទំនិញ និងសេវា | 4.1 | 4.1 | 6.0 | -8.9 | 5.5 | 5.4 |
| កំណើន ផសស ពិត គិតត្រឹមតម្លៃកត្តារួមចំណែកថេរ (% ប្រចាំឆ្នាំ) | 6.8 | 7.4 | 6.8 | -2.0 | 4.0 | 5.2 |
| កសិកម្ម | 1.7 | 1.1 | -0.5 | 1.5 | 0.9 | 1.0 |
| ឧស្សាហកម្ម | 9.7 | 11.6 | 11.3 | -1.2 | 6.9 | 7.1 |
| សេវាកម្ម | 7.0 | 6.8 | 6.2 | -4.3 | 2.6 | 5.1 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | |
| អតិផរណា តម្លៃអ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ មធ្យមភាគតាមអំឡុងពេល) | 3.3 | 3.1 | 3.2 | 3.0 | 2.5 | 2.5 |
| រូបិយវត្ថុទូលាយ (% ផសស) | 88.2 | 100.7 | 107.7 | 111.6 | 126.1 | 145.0 |
| ការផ្ដល់ឥណទានដោយធនាគារក្នុងស្រុកដល់វិស័យឯកជន (% ផសស) | 86.4 | 99.4 | 114.2 | 123.3 | 132.0 | 140.0 |
| អត្រាប្តូរប្រាក់ណ្ឋមីណល (រូបិយវត្ថុក្នុងស្រុក 1 ដុល្លារអាមេរិក) | 4,062 | 4,067 | 4,070 | 4,100 | 4,090 | 4,080 |
| អត្រាប្តូរប្រាក់ណ្ឋមីណលដែលមានប្រសិទ្ធភាព (% ប្រចាំឆ្នាំ, កំណើន = ឡើងថ្លៃ) | 0.0 | -0.8 | 1.1 | -0.1 | 0.3 | 0.3 |
| អត្រាប្តូរប្រាក់ពិតដែលមានប្រសិទ្ធភាព (% ប្រចាំឆ្នាំ, កំណើន = ឡើងថ្លៃ) | 1.3 | -3.4 | -0.1 | 0.5 | 0.5 | -0.1 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.7 | 9.7 | 9.5 | 9.3 | 9.0 | 9.0 |
| **សារពើពន្ធ** | | | | | | |
| ប្រាក់ចំណូល (% ផសស) | 21.9 | 23.8 | 26.3 | 18.8 | 18.6 | 20.8 |
| ចំណាយ (% ផសស) | 22.7 | 23.4 | 25.5 | 24.4 | 24.6 | 24.4 |
| សមតុល្យសារពើពន្ធរួម (% ផសស) | -0.8 | 0.4 | 0.8 | -5.6 | -6.1 | -3.5 |
| សមតុល្យសារពើពន្ធបឋម (% ផសស) | -0.4 | 0.8 | 1.2 | -5.1 | -5.6 | -3.0 |
| បំណុលទូទៅរបស់រដ្ឋាភិបាល (% ផសស) | 30.3 | 30.0 | 29.0 | 31.6 | 32.0 | 32.7 |
| **គណនីខាងក្រៅ** | | | | | | |
| ការនាំចេញ ៖ GNFS (ដុល្លារអាមេរិកណ្ឋមីណល, % ប្រចាំឆ្នាំ) | 9.4 | 12.3 | 9.5 | -18.5 | 8.0 | 9.0 |
| ការនាំចូល ៖ GNFS (ដុល្លារអាមេរិកណ្ឋមីណល, % ប្រចាំឆ្នាំ) | 7.8 | 9.3 | 9.0 | -17.8 | 7.1 | 8.1 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិកបច្ចុប្បន្ន) | -2,140.5 | -2,180.1 | -2,703.9 | -3,477.2 | -3,814.1 | -3,890.5 |
| សមតុល្យគណនីចរន្ត (% ផសស) | -9.7 | -8.9 | -10.0 | -12.8 | -13.1 | -12.4 |
| ការវិនិយោគផ្ទាល់ពីបរទេស លំហូរចូលសរុប (លានដុល្លារអាមេរិកបច្ចុប្បន្ន) | 2,673.1 | 3,088.8 | 3,561.0 | 2,092.1 | 3,040.8 | 2,981.3 |
| ទុនបម្រុងអន្តរជាតិសរុប (លានដុល្លារអាមេរិក) | 12,200.6 | 14,629.1 | 18,763.3 | 19,291.2 | 19,169.4 | 18,949.4 |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | 7.0 | 7.0 | 10.0 | 10.0 | 9.0 | 9.0 |
| ចំណាំ ៖ ផសស ណ្ឋមីណល (លានដុល្លារអាមេរិក) | 22,114.9 | 24,476.1 | 27,030.5 | 27,135.4 | 29,128.2 | 31,420.7 |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក ធម្មតា) | 1,376.1 | 1,500.5 | 1,633.2 | 1,616.7 | 1,712.1 | 1,822.9 |
| ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ វិធីសាស្ត្រ Atlas (ដុល្លារអាមេរិកបច្ចុប្បន្ន) | 1,230.0 | 1,380.0 | 1,480.0 | | | |

*ប្រភព ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក*

*ចំណាំ ៖ e = ប៉ាន់ស្មាន, f = ព្យាករណ៍, p = ព្យាករណ៍ (គណនា), GNFS = ទំនិញ និងសេវាដែលមិនមែនជាកត្តារួមចំណែក*

# គន្ថនិទ្ទេស

Congressional Research Service. 2020. "U.S.-Mexico Economic Relations: Trends, Issues, and Implications." Congressional Research Services, Washington, DC, June. https://fas.org/sgp/crs/row/RL32934.pdf.

Hilbers, Paul, Qin Lei, and Lisbeth Zacho. 2001. "Real Estate Market Developments and Financial Sector Soundness." IMF Working Paper WP/01/129, International Monetary Fund, Washington, DC.

Lederman, Daniel, William F. Maloney, and Luis Servén. 2003. "Lessons from NAFTA for Latin America and the Caribbean." A copublication of Stanford Economics and Finance and the World Bank, Stanford, California and Washington, DC.

Ministry of Agriculture, Fisheries and Forestry. 2020. *July 2020 Report on Agriculture, Fisheries and Forestry.* Ministry of Agriculture, Fisheries and Forestry, Phnom Penh.

———. *2020. Annual Report for Agriculture, Fisheries and Forestry for 2019–20 and Direction for 2020–21.* Ministry of Agriculture, Fisheries and Forestry, Phnom Penh.

Ministry of Economy and Finance. 2020. *Monthly Government Finance Statistics 2020.* Ministry of Economy and Finance, Phnom Penh.

———. *2020. Cambodia Public Debt Statistical Bulletin 10 (September 2020).* Ministry of Economy and Finance, Phnom Penh.

Ministry of Planning. 2020. *Cambodia National Accounts Statistics for 2019,* National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2020. Monthly Cambodia Consumer Price Index 2020. National Institute of Statistics, Ministry of Planning, Phnom Penh.

Ministry of Social Affairs, Veterans and Youth Rehabilitation 2020. *Presentation, Second Meeting on the Results of Cash Transfer Program for the Second Round, October 22, 2020.* Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation.

Ministry of Tourism. 2019. *Annual Tourism Statistics Report.* Phnom Penh: Ministry of Tourism.

———. 2020. "Monthly Tourist Statistics." Phnom Penh: Ministry of Tourism.

National Bank of Cambodia. 2020. 2020 *Semi-Annual Report.* Phnom Penh: National Bank of Cambodia.

———. 2020. *Balance of Payments Statistics* (2020Q2). National Bank of Cambodia, National Bank of Cambodia.

———. 2020. *Monetary Statistic Bulletin* (2020). National Bank of Cambodia, Phnom Penh.

Royal Government of Cambodia. 2020. Budget Law for 2020. Royal Government of Cambodia.

———. 2020. *Macro-fiscal framework for the 2021 budget.* Royal Government of Cambodia.

United States Department of Agriculture. 2020. "Food Price Outlook, 2020." Economic Research Service, United States Department of Agriculture, Washington, DC. https://www.ers.usda.gov/data-products/food-price-outlook/summary-findings/.

World Bank. 2015a. *Cambodian Agriculture in Transition: Opportunities and Risks.* Washington, DC: World Bank.

World Bank. 2017. "Selected Issue on Maximizing Tourism Potential." In the October 2017 *Cambodia Economic* Update. Washington, DC: World Bank.

———. 2020a. *East Asia and Pacific Economic Update, October 2020.* Washington, DC: World Bank.

———. 2020. *June Global Economic Prospects report.* Washington, DC: World Bank.

———. 2021. *January Global Economic Prospects report.* Washington, DC: World Bank.

**ក្រុមធនាគារពិភពលោក**

**ធនាគារពិភពលោក**
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
វេបសាយ: www.worldbank.org/cambodia